# ថ្ងៃទី០១ ខែ មេសា ឆ្នាំ២០២២

## គិតជាមធ្យមក្នុង ១ ថ្ងៃ មានពលករខ្មែរជាង ៧០០ នាក់វិលត្រឡប់ពីថៃចូលមកស្រុកវិញ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 31 March 2022 | 09:10 ICT

**បន្ទាយមានជ័យៈ** នាពេលបច្ចុប្បន្ន គិតជាមធ្យមក្នុង ១ ថ្ងៃ មានពលករខ្មែរជាង ៧០០ នាក់ បានវិលត្រឡប់ពីប្រទេសថៃចូលមកស្រុកកំណើតវិញ ខណៈដែលរាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរឡើងវិញ នៅពេលដែលអត្រាអ្នកឆ្លងជំងឺកូវីដ ១៩ បានបន្តថយចុះ។ ក្នុងចំណោមពលករជាង ៧០០ នាក់នោះ មានមកតាមច្រកអន្តរជាតិខេត្តចំនួន ៣ គឺខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តបាត់ដំបង។

អ្នកនាំពាក្យសាលាខេត្តបន្ទាយមានជ័យលោក សេក សុខុម ប្រាប់ ភ្នំពេញប៉ុស្តិ៍ថា សម្រាប់ឆ្នាំនេះសង្កេតឃើញមានពលករចាប់ផ្តើមសម្រុកមកបណ្តើរៗហើយ តាំងពីដើមខែមីនា ដោយក្នុង ១ ថ្ងៃជិត ៣០០ នាក់។ លោកថា៖ «ពលករចាប់ផ្តើមត្រឡប់មកផ្ទះសំបែងវិញហើយ ដើម្បីចូលរួមជួបជុំជាមួយបងប្អូន ក្រុមគ្រួសារគាត់ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិក្នុង ១ ថ្ងៃចន្លោះពី ២៧០ ទៅជាង ៣០០ នាក់ ព្រោះយើងបានខកខានប្រារព្ធអស់រយៈពេល ២ ឆ្នាំមកហើយ»។ បន្ថែមពីនេះលោកសង្ឃឹមថា ឈានចូលដល់ខែមេសា ពលករនឹងបន្តសម្រុកមកបន្ថែមទៀត ខណៈរដ្ឋាភិបាលបានបើកចំហទាំងផ្លូវគោក និងផ្លូវទឹក ដោយមិនបាច់ធ្វើតេស្តចំពោះអ្នកចាក់វ៉ាក់សាំងកូវីដរួចហើយ ។ លោកបញ្ជាក់ថា វិធានការចំពោះមុខនាពេលបច្ចុប្បន្នពលករណាដែលបានចាក់វ៉ាក់សាំងហើយ គឺអនុញ្ញាតឱ្យគាត់ទៅផ្ទះ តែពលករដែលមកអត់មានឯកសារគ្រប់គ្រាន់ ឬអត់មានកាតចាក់វ៉ាក់សាំងគឺតម្រូវឱ្យពិនិត្យសុខភាព និងដាក់នៅមណ្ឌលចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ។ លោកបន្តថា សម្រាប់វិធានការលើកនេះខុសពីលើកមុន ខណៈឆ្នាំកន្លងទៅអាជ្ញាធរបានត្រៀមឡានកងយោធពលខេមរភូមិន្ទ ដើម្បីដឹកពួកគាត់ចេញពីព្រំដែនហើយបែងចែកបន្តទៅតាមខេត្តនីមួយៗ។ ប៉ុន្តែឥឡូវនេះ ពលករអាចរកមធ្យោបាយត្រឡប់ទៅផ្ទះរៀងៗខ្លួន។

លោកថា៖ «ប៉ុន្តែបន្ទុកអាជ្ញាធរខេត្ត គឺផ្តល់បាយដល់ពលករ ៣ ពេលសម្រាប់ពលករដែលជាប់ធ្វើចត្តាឡីស័ក និងអ្នកវិជ្ជមានកូវីដ ១៩ អាចអនុញ្ញាតឱ្យទៅសម្រាកព្យាបាលនៅផ្ទះថែមទៀតផង ក្នុងករណីគាត់មានលទ្ធភាព»។ លោកឱ្យដឹងទៀតថា ក្នុងរយៈពេល ១០ ថ្ងៃចុងក្រោយនេះ មានពលករត្រឡប់មកវិញជាង ២ ០០០ នាក់ ខណៈដែលនៅក្នុងខែមេសា ពលករអាចនឹងវិលចូលស្រុក ១ ថ្ងៃ ៣០០ ទៅ ៤០០ នាក់ឯណោះ។ បើតាមលោក សុខុម ក្នុងចំណោមពលករដែលត្រឡប់ពីថៃទាំងនោះ មានអ្នកវិជ្ជមានកូវីដពី ២ ទៅ ៣ នាក់ ក្នុងចំណោម ២០០ ទៅ ៣០០ នាក់ ហើយភាគច្រើននោះបានចាក់វ៉ាក់សាំងរួចហើយ។

អ្នកនាំពាក្យសាលាខេត្តបាត់ដំបងលោក សួស សុភ័ក្រ្ត បានឱ្យដឹងថា ក្នុង ១ ថ្ងៃពលករត្រឡប់ចូលស្រុកតាមច្រកព្រំដែនក្នុងខេត្តបាត់ដំបងមានពី ៣០ ទៅ ៤០ នាក់ ហើយថ្ងៃខ្លះសម្រុកមកច្រើនរហូតជាង ១០០ នាក់។ សម្រាប់ខេត្តបាត់ដំបង ការអនុវត្តវិធានការសុខាភិបាល ក៏មិនខុសពីខេត្តផ្សេងទៀតដែរចំពោះអ្នកចាក់វ៉ាក់សាំងហើយ មិនតម្រូវឱ្យធ្វើតេស្តនោះទេ ខណៈពលករមិនទាន់ចាក់វ៉ាក់សាំងតម្រូវឱ្យធ្វើតេស្ត និងបញ្ជូនទៅធ្វើចត្តាឡីស័ក។

រីឯនៅខេត្តឧត្តរមានជ័យវិញពលករវិលមកស្រុកវិញក្នុងរយៈពេល ១០ ថ្ងៃចុងក្រោយនេះ មានជាង ៤ ពាន់នាក់ហើយគិតជាមធ្យមក្នុង ១ ថ្ងៃមាន ៤០០ នាក់។ នេះបើយោងតាមរបាយការណ៍ស្តីពីចំនួនពលករចូលមកតាមច្រកខេត្តនេះ។ អ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យលោក ផល លឹម បានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ បន្ថែមថា ក្នុងចំណោមពលករទាំងនោះ ភាគច្រើនបានវិលចូលស្រុកដើម្បីត្រៀមអបអរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរនាពេលខាងមុខ ហើយក្នុងចំណោមនោះក៏មានពលករខុសច្បាប់ត្រូវបានថៃចាប់បញ្ជូនត្រឡប់មកវិញផងដែរ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី ២៨ ខែមីនា ក៏បានជំរុញឱ្យមានពិនិត្យឱ្យបានហ្មត់ចត់ផង ដែរចំពោះពលករដែលធ្វើដំណើរមកពីប្រទេសថៃ ហើយអ្នកដែលមិនបានចាក់វ៉ាក់សាំងត្រូវធ្វើចត្តាឡីស័កចំនួន ១៤ ថ្ងៃ។ លោកបានឱ្យដឹងថា មកដល់ពេលនេះ មានពលករខ្មែរដែលកំពុងធ្វើចត្តាឡីស័កជាង ១ ៣ន់នាក់ នៅតាមព្រំដែនកម្ពុជា-ថៃ៕

## មានជនរងគ្រោះនៅមជ្ឈមណ្ឌលហៅទូរស័ព្ទដែលជាប់ ឃុំឃាំងបន្ថែមទៀត លើកនេះមកពីប្រទេសម៉ាឡេស៊ី កំពុងស្វែងរកការជួយពីខ្មែរថាមស៍

https://www.khmertimeskh.com/ Khmer Times March 31, 2022

យុវជនម៉ាឡេស៊ីរហូតដល់១០០នាក់កំពុងត្រូវបានចាប់បង្ខាំងខ្លួនក្នុងប្រទេសកម្ពុជាដោយក្រុមដែលបង្ខំពួកគេឱ្យបោកប្រាស់មនុស្សតាមអ៊ីនធឺណិត។ ដំណឹងនេះត្រូវបានលាតត្រដាងដោយសារព័ត៌មានម៉ាឡេស៊ី New Straits Times ខណៈខ្មែរថាមស៍ បាននិងកំពុងស៊ើបអង្កេតរឿងនេះតាំងពីដើមខែមីនាមកម្ល៉េះ។

ជនជាតិម៉ាឡេស៊ីម្នាក់ ដែលបានទាក់ទងមកខ្មែរថាមស៍បាននិយាយថា "ដោយសារយើងមិនមានទូរសព្ទដៃ ខ្ញុំអាចផ្ញើអ៊ីមែលទៅអ្នកដោយសម្ងាត់ក្នុងពេលម៉ោងធ្វើការ។ ខ្ញុំនឹងប្រមូលពួកវាឱ្យបានឆាប់តាមដែលអាចធ្វើបាន ហើយផ្ញើឱ្យអ្នកឱ្យបានឆាប់តាមដែលអាចផ្ញើទៅបាន។ យ៉ាងណាមិញមានមនុស្ស និងភ្នែក ត្រចៀកច្រើនណាស់។ បើចាប់បានលើសពីម្តងខ្ញុំនឹងត្រូវកប់នៅស្រុកខ្មែរ។ខ្ញុំបានសុំលុយពីខាងក្រៅច្រើនដងសម្រាប់ជំនួយលើសពីម្តង»។ "ទីកន្លែងនេះត្រូវបានបំពាក់សម្ភារៈយ៉ាងល្អ និងបង្កើតជាកន្លែងបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណេតតែមួយគត់ និងមជ្ឈមណ្ឌលភ្នាល់ និងលេងល្បែងស៊ីសងតាមអ៊ីនធឺណិត។ វាមានហាងម៉ាស្សាផ្ទាល់ខ្លួន កន្លែងដែលគេហៅថាមាន់កាស៊ីណូ ខារ៉ាអូខេ បារ អាហារដ្ឋាន និងភោជនីយដ្ឋាន។ ពួកគេបាននិយាយទៅកាន់ខ្មែរថាមស៍ តាមអ៊ីមែលសម្ងាត់មួយថា "មានបួនផ្នែក មួយផ្នែកសម្រាប់បោកបញ្ឆោតមនុស្សនៅក្នុងប្រទេសចិន មួយផ្នែកសម្រាប់បញ្ឆោតចិនតៃប៉ិ មួយផ្នែកសម្រាប់បោកបញ្ឆោតជនជាតិអឺរ៉ុប និងគោលដៅចុងក្រោយគឺសហរដ្ឋអាមេរិក។ យើងក៏ជាប់ពាក់ព័ន្ធក្នុងការបោកបញ្ឆោតអឺរ៉ុប និងសហរដ្ឋអាមេរិកដែរ ប៉ុន្តែ "ផ្នែករបស់យើង" មិនទាន់ទទួលបានការបញ្ជាណាមួយ ឬប្រាក់ដុល្លារក្នុងការភ្នាល់ ឬបោកប្រាស់នៅឡើយទេ" ។

កាសែត The New Straits Times កាលពីយប់មិញ បានរាយការណ៍ថា ប្រធាននាយកដ្ឋានសេវាសាធារណៈ និងទទួលពាក្យបណ្តឹងរបស់ MCA លោក Michael Chong បានអះអាងថា យុវជនលើសពី១០ នាក់នៅក្នុងប្រទេសកម្ពុជាបានទូរស័ព្ទមកគាត់តាំងពីដើមឆ្នាំមក ដើម្បីអង្វរគាត់ឱ្យមកជួយសង្គ្រោះពួកគេ។ គាត់បាននិយាយនៅក្នុងសន្និសីទសារព័ត៌មានកាលពីថ្ងៃពុធថា "ពួកគេបានអង្វរខ្ញុំកុំឱ្យប្រាប់ឪពុកម្តាយរបស់ពួក គេព្រោះពួកគេមិនចង់ឱ្យឪពុកម្តាយរបស់ពួកគេព្រួយបារម្ភ។ ឪពុកម្តាយរបស់ពួកគេជាច្រើនមិនដឹងថាកូនរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា"។ ក៏មានឪពុកម្តាយរបស់បុរសជនជាតិម៉ាឡេស៊ីពីរនាក់ដែលអះអាងថាកូនប្រុសរបស់ពួកគេដែលមានអាយុ ១៨ និង២៤ឆ្នាំ ត្រូវបានបោកបញ្ឆោតឱ្យចាប់យកការងារជា "អ្នកទីផ្សារទូរស័ព្ទ" នៅក្នុងប្រទេសគ្រាន់តែដឹងថាពួកគេត្រូវបានបោកបញ្ឆោតដោយក្រុមបោកប្រាស់។

ម្តាយរបស់ក្មេងប្រុសម្នាក់ដែលសុំអោយដឹងត្រឹមតែ Madam Wong បាននិយាយថា គាត់ខ្លាចនឹងមានអ្វីកើតឡើងចំពោះកូនប្រុសរបស់គាត់ ហើយបានអង្វរអាជ្ញាធរឱ្យជួយសង្គ្រោះកូនគាត់។ គាត់បាននិយាយថា កូនប្រុសរបស់គាត់បានទូរស័ព្ទមកគាត់កាលពីប៉ុន្មានខែមុនដោយមានការពិបាកចិត្ត ដោយអះអាងថាគាត់ត្រូវបានផ្តល់ការងាររកកម្រៃជាអ្នកទីផ្សារទូរស័ព្ទ ហើយត្រូវបានគេនាំមកប្រទេសកម្ពុជាពី Penang តាមរយៈច្រកខុសច្បាប់។ កូនប្រុសរបស់គាត់បានប្រាប់គាត់ថា អគារដែលគេដាក់គាត់នោះត្រូវបានចាក់សោពីខាងក្រៅ ហើយមានបុរសកាន់

កាំភ្លើងនៅមាត់ទ្វារ។ Wong បាននិយាយថា កូនប្រុសរបស់គាត់ ត្រូវបានបង្ខំឱ្យចូលក្នុងផ្នែកមួយនៃប្រតិបត្តិការរបស់ក្រុមដែលបោកប្រាស់ប្រជាជនម៉ាឡេស៊ីតាមអ៊ីនធឺណិត។ គាត់បាននិយាយថា គាត់ភ័យខ្លាចថាក្រុមនោះនឹងលក់កូនប្រុសរបស់គាត់ទៅឱ្យក្រុមផ្សេងទៀតប្រសិនបើគាត់បដិសេធក្នុងការបំពេញការងារ។

ឪពុកម្តាយម្នាក់ទៀត ដែលចង់បង្ហាញត្រឹមតែឈ្មោះ Ng បាននិយាយថា កូនប្រុសរបស់គាត់ត្រូវបានគេនាំមកប្រទេសកម្ពុជាកាលពីបីខែមុន តាមរយៈច្រកខុសច្បាប់។ លោកបានបន្ថែមថា៖ «គាត់បានទូរស័ព្ទមកដោយប្រាប់ថា ការងាររបស់គាត់គឺបោកមនុស្សតាមទូរស័ព្ទ បើគាត់មិនធ្វើតាម ពួកគេនឹងវាយធ្វើបាបគាត់»។ Ng បាននិយាយថា គាត់បានផ្ញើលិខិតមួយទៅកាន់រដ្ឋមន្ត្រីការបរទេស Saifuddin Abdullah ប្រហែលពីរសប្តាហ៍មុន ដើម្បីជូនដំណឹងដល់គាត់អំពីទុក្ខលំបាករបស់កូនប្រុសគាត់ ហើយមិនទាន់ទទួលបានការឆ្លើយតបណាមួយពីក្រសួងការបរទេសម៉ាឡេស៊ី នៅឡើយទេ។ គាត់បាននិយាយថា គាត់ក៏បានរាយការណ៍ទៅនគរបាលផងដែរ។

នៅក្នុងសេចក្តីថ្លែងការណ៍មួយ ក្រសួងការបរទេសម៉ាឡេស៊ី បានអោយដឹងថា ខ្លួនកំពុងធ្វើការជាមួយបេសកកម្មរបស់ម៉ាឡេស៊ីនៅក្នុងប្រទេសផ្សេងៗ ដែលពាក់ព័ន្ធ ដើម្បីតាមដានស្ថានការណ៍យ៉ាងជិតដល់។ "យើងកំពុងស្ថិតក្នុងដំណើរការប្រមូលព័ត៌មានលម្អិតបន្ថែមទៀត។ ប្រសិនបើមានការវិវឌ្ឍន៍ថ្មីៗ នឹងជូនដំណឹងដល់សាធារណជនឱ្យបានឆាប់តាមដែលយើងអាចធ្វើបាន"។

ខ្មែរថាមស៍ ដែលទម្លាយរឿង មជ្ឈមណ្ឌលទូរស័ព្ទ និងល្បែងស៊ីសង និងភ្នាល់អនឡាញ កំពុងស៊ើបអង្កេតរឿងនេះ ហើយក៏ជាអ្នកដំបូងដែរ ដែលទម្លាយរឿងអំពីការចោទប្រកាន់ក្លែងក្លាយរបស់ស្ត្រីថៃអាយុ ២៥ឆ្នាំ ដែលកុហកនគរបាលថៃថា គេប្លន់យកឈាមរបស់នាង និងកំពុងត្រូវបានគេរៀបចំកាត់សរីរាង្គរបស់ដើម្បីធ្វើការជួញដូរ។ នេះត្រូវបានគេបង្ហាញថាក្លែងក្លាយដោយការចូលខ្លួនរបស់ជនរងគ្រោះដែលត្រូវបានចោទប្រកាន់ ហើយចាប់តាំងពីពេលនោះមកត្រូវបានចាប់ខ្លួនដាក់ពន្ធនាគាររយៈពេល ៦ ខែ។ *NST.com/ខ្មែរថាមស៍*

## ពលរដ្ឋខ្មែរ៣នាក់ ត្រូវបានអាជ្ញាធរថៃ
## បញ្ជូនមកឲ្យអាជ្ញាធរកម្ពុជាវិញ ដោយលិខិតឆ្លងដែនហួសសុពលភាព

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ៣១ មីនា ២០២២ដោយ Kang Tola

ឧត្តរមានជ័យ ៖ នៅវេលាម៉ោង ១៤និង០៥នាទី ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ មានពលករខ្មែរចំនួន ០៣ នាក់ ស្រី ០១នាក់ បានវិលត្រឡប់មកពីប្រទេសថៃវិញ តាមច្រកអន្តរជាតិជាំដែលមានឈ្មោះដូចជា ១,ឈ្មោះ ផូ ស្រីរត្ន័ ភេទស្រី ៣៣ឆ្នាំ ២, ផែន ចាន់ថាច ភេទប្រុស អាយុ ៣៥ឆ្នាំអ្នកទាំងពីរ រស់នៅភូមិអូរអង្រែ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ និង ៣,ឈ្មោះ ហេង ជា ភេទប្រុស អាយុ ២៩ឆ្នាំរស់នៅភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ អ្នកទាំងបី ធ្វើការនៅខេត្តស៊ីសាកេតប្រទេសថៃ ( លិខិតឆ្លងដែនហួសសុពលភាព ) បន្ទាប់មកលោកគ្រូពេទ្យក៏បានយកសំណាកជំងឺ covid-19 ជាលទ្ធផល អវិជ្ជមាន ទាំង ០៣នាក់ ឲ្យវិលត្រឡប់ទៅផ្ទះវិញ៕

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ
## វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/04/01/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃសុក្រ ១៥កេីត ខែផល្គុន ឆ្នាំខ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តនតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់

ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន១៩៦នាក់, ស្រី៧៦នាក់ និងក្មេង៣៤នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺវិជ្ជមានកូវីដ-១៩ ចំនួន៤នាក់ ស្រី២នាក់ ក្មេងម្នាក់ (ស្រី)។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន១៨៦នាក់ (ស្រី៦៩នាក់, ក្មេង៣៣នាក់) ចំណែកពលករចំនួន១០នាក់ (ស្រី៧នាក់ ក្មេងម្នាក់) ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៨ឆ្នាំ ចំនួន១៤នាក់ (ស្រី៨នាក់) ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

# ថ្ងៃទី០៤ ខែ មេសា ឆ្នាំ២០២២

## ត្រឹម៧ថ្ងៃចុងខែមីនា ពលករបញ្ជូនពីថៃមកកម្ពុជាវិញជិត៣៧០០នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០១ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១៦:៥៣

ខេត្តបន្ទាយមានជ័យ ៖ ស្របពេលពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ឆ្នាំ២០២២ ខិតជិតចូលមកដល់ ពលករខ្មែរបញ្ជូនពីថៃតាមច្រករបៀង, តំបន់និងអន្តរជាតិ ក្នុងខេត្តបន្ទាយមានជ័យ ហាក់មានចំនួនកើនឡើង។ បើគិតត្រឹមរយៈពេល៧ថ្ងៃ គឺចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី៣១ ចុងខែមីនា ឆ្នាំ២០២២នេះ ។ ហើយពលករខ្មែរបញ្ជូនពីថៃតាមច្រកនានា ក្នុងខេត្តបន្ទាយមានជ័យ រួមមាន ៖ ច្រកកិច្ចព្រមព្រៀងរៀង ខេត្តបន្ទាយមានជ័យកម្ពុជា និងខេត្តស្រះកែវ ថៃ (MOU) គឺច្រករបៀងអូរបីជាន់ ក្នុងស្រុកអូរជ្រៅ, ច្រករបៀង ក្នុងស្រុកម៉ាឡៃ, ច្រកតំបន់បឹងត្រកួន និងច្រកទ្វារអន្តរជាតិប៉ោយប៉ែត មានជិត៣៧០០នាក់។ ក្នុងចំណោមពលករទាំងនេះ ក៏មានស្រ្តី១៥១៦នាក់ កុមារ៤៨៣នាក់ និងរកឃើញអ្នកវិជ្ជមានកូវីដជិត២០នាក់ផងដែរ (ក្នុងនោះស្រី១០នាក់) ។ នេះបើតាមប្រភពពីមន្ត្រីជំនាញផ្នែកទទួលពលករបញ្ជូនពីប្រទេសថៃ នៅខេត្តបន្ទាយមានជ័យ។ ហើយរាល់ទីតាំងទទួលពលករបញ្ជូនពីថៃ គេឃើញមានមន្ត្រីជំនាញផ្នែកចត្តាឡីស័ក បានធ្វើការត្រួតពិនិត្យសុខភាពពលករយ៉ាងតឹងរឹង ប៉ុន្តែទីតាំងទទួលពលករនៅច្រករបៀងអូរបីជាន់ ហាក់មានការជួររលុង ដោយមានក្រុមអ្នកលក់ស៊ីមទូរស័ព្ទបានពពាក់ពពូនគ្នាជាមួយពលករដែលវិលត្រឡប់ពីថៃ មុនក្រុមពលករចូលទៅដល់ទីតាំងត្រួតពិនិត្យរបស់មន្ត្រីជំនាញ។

គួរបញ្ជាក់ថា ចាប់តាំងពីជំងឺកូវីដ១៩ ចាប់ផ្តើមរាតត្បាតនៅទូទាំងពិភពលោក ប្រទេសថៃបានធ្វើការបិទច្រកទាំងអស់តាមបន្ទាត់ព្រំដែនជាប់កម្ពុជា លើកលែងតែច្រកទ្វារអន្តរជាតិមួយចំនួន ជាពិសេសច្រកទ្វារអន្តរជាតិប៉ោយប៉ែត គឺនៅបន្តឲ្យចរាចររថយន្តធំៗដឹកទំនិញចេញចូលមកកម្ពុជាជាធម្មតា និងមួយរយៈចុងក្រោយនេះ ច្រកតំបន់ទាំង២នៅខេត្តបន្ទាយមានជ័យ គឺច្រកតំបន់ម៉ាឡៃ និងបឹងត្រកួនភាគីទាំង២ បានបើកដំណើរការឲ្យរថយន្តថៃចូលមកដឹកកសិផលខ្មែរ ដូចដើមឡើងវិញ៕

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/04/03/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអាទិត្យ ៣កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០៣ ខែមេសា ឆ្នាំ ២០២២ ដោយអនុវត្តនតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញាមេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងឃោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន៣៧៦នាក់, ស្រី១៣៣នាក់ និងក្មេង៤៥នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺវិជ្ជមានកូវីដ-១៩ ចំនួន២នាក់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំងចំនួន៣៧៤នាក់ (ស្រី១៣៣នាក់, ក្មេង៤៥នាក់) ចំណែកពលករចំនួន២នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៨ឆ្នាំ ចំនួន១៨នាក់ (ស្រី៤នាក់) ហេ ីយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## អាជ្ញាធរស្រុកសំពៅលូន នៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពី ប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/04/03/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃអាទិត្យ ២កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនគីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងឃោជាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ-ប៊ុណា (មេបញ្ជាការរងកងអនុសេនាធំ), កម្លាំងឃោជាវរសេនាតូច៥៣៣ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ធុក-លឹមយី (មេបញ្ជាការរងកងអនុសេនាធំ) កម្លាំងនគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣ ចំនួន២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ហ៊ាន-ហាន (នាយរងផ្នែក) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុចភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០២លើក សរុប៥នាក់ ស្រី២នាក់ ក្មេងប្រុសម្នាក់។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើការសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុប្រចាំ

ថ្ងៃ និងអប់រំណែនាំ រួចបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## ការបើកដំណើរការសុំកូនឡើងវិញនៅកម្ពុជា នាំឱ្យមានក្ដីបារម្ភ និងការរិះគន់

https://khmer.voanews.com/ 31 មីនា 2022ហ៊ុល រស្មី

ភ្នំពេញ៖ រដ្ឋាភិបាលកម្ពុជា បានសម្រេចបើកឱ្យមានការសុំកូនអន្តរប្រទេសឡើងវិញ ក្រោយផ្អាកអស់រយៈពេលជាង១០ឆ្នាំ ដែលការណ៍នេះ នាំឱ្យមានក្ដីបារម្ភពីអង្គការសិទ្ធិមនុស្សក្នុងស្រុក ដោយសារប្រព័ន្ធគ្រប់គ្រងដំណើរការសុំកូននេះ នៅទន់ខ្សោយនៅឡើយ។ នេះ ជាការកត់សម្គាល់របស់អង្គការការពារសិទ្ធិមនុស្សលីកាដូ ដែលបង្ហាញក្ដីបារម្ភជាខ្លាំងចំពោះការវិវឌ្ឍចុងក្រោយនៃការសុំកូនជាអន្តរប្រទេសនេះ។ អង្គការលីកាដូបានថ្លែងក្នុងសេចក្ដីប្រកាសមួយចុះថ្ងៃទី២៩ ខែមីនាថា យោងតាមការបង្ហាញច្បាស់ៗពីរដ្ឋាភិបាលប្រទេសអ៊ីតាលី «ការសុំកូនពីប្រទេសកម្ពុជាយ៉ាងតិចចំនួនប្រាំបួននាក់ដែលអាចកើតមានឡើង គឺកំពុងត្រូវបានដំណើរការដោយទីភ្នាក់ងារសុំកូនរបស់ជនជាតិអ៊ីតាលី»។ សេចក្ដីប្រកាសបានសរសេរតាមន័យដើមថា៖ «យើងខ្ញុំព្រួយបារម្ភថា ការសម្រេចចិត្តទាំងនេះ នឹងនាំឱ្យគ្រួសារជាច្រើនទៀត ត្រូវបែកបាក់ មិនអាចជួបជុំគ្នាវិញបាន ដោយសារប្រព័ន្ធគ្រប់គ្រងនៅទន់ខ្សោយនេះ មិនទាន់បានការពារផលប្រយោជន៍ល្អបំផុតរបស់កុមារកន្លងមក»។ អង្គការលីកាដូបន្ថែមក្នុងសេចក្ដីប្រកាសនេះថា៖ «បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលនៅតែខ្វះប្រព័ន្ធការពារកុមារ ប្រព័ន្ធតុលាការ និងវិធានការប្រឆាំងអំពើពុករលួយឱ្យបានគ្រប់គ្រាន់ ដើម្បីធានាថា ការសុំកូន នឹងដំណើរការទៅស្របតាមផ្លូវច្បាប់ និងក្រមសីលធម៌»។

នាយករងទទួលបន្ទុកឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូលោក អំ សំអាត ប្រាប់វីអូអេនៅថ្ងៃព្រហស្បតិ៍ថា ឪពុកម្ដាយ ឬអាណាព្យាបាលកុមារនៅប្រទេសកម្ពុជា បានទទួលរងគ្រោះពីភាពមិនច្បាស់លាស់នៃនីតិវិធីសុំកូនដោយពេលខ្លះ ពួកគេយកកុមារទៅដាក់នៅមណ្ឌលកុមារកំព្រា ប៉ុន្តែកុមារទាំងនោះមួយចំនួនបែរជាត្រូវបានគេសុំយកចេញពីប្រទេសកម្ពុជា។ លោកនិយាយថា៖ «ករណីហ្នឹង គឺយើងទទួលបានច្រើន កាលកន្លងមក គឺ១៥ករណីដែលទាក់ទងនឹងកូនដែលមានឪពុកម្ដាយបង្កើត ហើយត្រូវយកទៅដាក់នៅមជ្ឈមណ្ឌលកុមារកំព្រា ក្រោយមកស្រាប់តែមានដំណើរការនៃការសុំកូនចេញទៅក្រៅប្រទេស ហើយធ្វើឱ្យពួកគាត់ហ្នឹងមានការតក់ស្លុត ដោយសារតែកូនរបស់គាត់ត្រូវបានបែកចេញ ហើយយកទៅប្រទេសខាងក្រៅធ្វើជាកូនហ្នឹង»។ លោកបន្ថែមថា៖ «ហើយនៅក្នុងហ្នឹង គឺមាន ឪពុកម្ដាយខ្លះ ស្វះស្វែង ហើយនឹងអង្គការលីកាដូក៏ស្វះស្វែងរកអាសយដ្ឋាន និងការទំនាក់ទំនងទៅដល់ឪពុកម្ដាយរបស់គេ ហើយគេអាចនឹងធ្វើទំនាក់ទំនងគ្នាវិញបាន។ ខ្លះទៀតមកទល់ឥឡូវ គឺមិនមានការទំនាក់ទំនងជាមួយកូនបានទេ»។

បើតាមលោក អំ សំអាត កន្លងមករដ្ឋាភិបាលបានផ្អាកការសុំកូននេះ ក្រោយពីរកឃើញភស្តុតាងបញ្ជាក់ពីការក្លែងបន្លំ អំពើពុករលួយ និងភាពមិនប្រក្រតីមួយចំនួនទៀតនៅក្នុងដំណើរការនៃការសុំកូនជាអន្តរប្រទេសនេះ ដែលបានបង្កផលប៉ះពាល់លើទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន ហើយក៏អាចមានការឆបោកផងដែរ។

អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាលោក តូច ចាន់នី ស្នើឱ្យអង្គការលីកាដូបង្ហាញរបាយការណ៍ពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៃការសុំកូនពីប្រទេសកម្ពុជា ដែលមិនទាន់បានផ្ដល់ភាពស្របច្បាប់ដល់ភ្នាក់ងារអន្តរជាតិណាមួយនៅឡើយ ក្នុងនោះ គឺប្រទេសអ៊ីតាលីដើម្បីអាចសុំកូនពីកម្ពុជា។ លោកថ្លែងថា៖ «បើតាមដែលខ្ញុំដឹង មកដល់ពេលនេះ ភ្នាក់ងារអ៊ីតាលីគេបានស្នើសុំដាក់ បង្កើតទីភ្នាក់ងារសុំកូនអន្តរប្រទេសហើយ។ ក៏ប៉ុន្តែក្រសួងដូចមិនទាន់បានអនុញ្ញាត។ មែនទែនទៅ គាត់បង្កើតភ្នាក់ងារមកសុំកូន… សុំការអនុញ្ញាតពីក្រសួងហើយ បានន័យថា សុំ license [អាជ្ញាបណ្ណ] ពីក្រសួង អាហ្នឹង បានគាត់ដំណើរការបាន។

តែមកដល់ពេលនេះ តាមតែខ្ញុំដឹង គឺគាត់បានដាក់ពាក្យស្នើ ប៉ុន្តែក្រសួងមិនទាន់បានសម្រេចថា ឱ្យគាត់ជា ភ្នាក់ងារស្របច្បាប់ សម្រាប់សុំកូនអន្តរប្រទេសនៅឡើយទេបាទ។ នេះ អ្វីដែលខ្ញុំបានដឹង។ អ្វីដែលខ្ញុំបានគ្រប់គ្រង»។ លោកប្រតិកម្មទៅនឹងអង្គការលីកាដូថា៖ «រឿងលីកាដូនេះ បើសិនជាគាត់មានព័ត៌មានសុំឱ្យគាត់បង្ហាញព័ត៌មានហ្នឹងមកក្រសួងផង ព្រោះក្រសួងអត់ដឹងទេ...មិនដឹងគាត់ចេញតាមច្រកណា។ ខ្ញុំមិនដឹងទេ។ គាត់មានភ្នាក់ងារគាត់តាមច្រកណា? ខ្ញុំមិនដឹងទេ។ ខាងក្រសួងគឺយើងប្រើយន្តការតាមច្រក ភ្នាក់ងារអន្តរប្រទេសនេះបាទ។ ហើយបើគាត់មានព័ត៌មាននេះសុំឱ្យគាត់ផ្ញើព័ត៌មានមកឱ្យក្រសួងផង ដើម្បីឱ្យក្រសួងស្រាវជ្រាវមើល ។ តើរឿងនេះវាមែនមិនមែន?ពិតមិនពិត? បាទ!»។ រដ្ឋាភិបាលបានបង្កើតឱ្យមានច្បាប់សម្រាប់ការសុំកូនជាអន្តរប្រទេសនេះកាលពីឆ្នាំ២០០៩ ប៉ុន្តែត្រូវមានការរៀបចំឯកសារគតិយុត្តិទាក់ទងផ្សេងៗទៀត ដើម្បីធានាថា ការសុំកូនធ្វើឡើងដោយគ្មានហានិភ័យលើកុមារកម្ពុជា។នេះបើតាមលោក តូច ចាន់នី។

យ៉ាងណាក៏ដោយ បើតាមអង្គការលីកាដូទីភ្នាក់ងាររាជរដ្ឋាភិបាលកម្ពុជា និងអ៊ីតាលីមិនបានអើពើទេចំពោះសំណើសុំព័ត៌មានពីអង្គការលីកាដូ ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ អំពីការបើកដំណើរការសុំកូនជាអន្តរប្រទេសឡើងវិញ ក្នុងនោះរួមមានសំណើសុំព័ត៌មានអំពីកិច្ចព្រមព្រៀងទ្វេភាគី នីតិវិធីពាក់ព័ន្ធ ក៏ដូចជាពេលវេលារំពឹងទុកដែលកុមារទាំងនេះនឹងចាកចេញពីប្រទេសកម្ពុជា។ អង្គការសិទ្ធិមនុស្សលីកាដូបានកត់ត្រាទុកថា ចាប់តាំងពីឆ្នាំ២០១៧មក ប្រជាពលរដ្ឋចំនួនប្រាំមួយគ្រួសារបានទាក់ទងមកអង្គការលីកាដូ ដើម្បីស្វែងរកព័ត៌មានអំពីកុមារចំនួន១៥នាក់ ដែលត្រូវបានគេសុំ ដោយបោកបញ្ឆោតចេញពីប្រទេសកម្ពុជាក្នុងទសវត្សរ៍២០០០។ កំណត់ត្រារបស់អង្គការលីកាដូបង្ហាញថា កុមារមួយចំនួនត្រូវបានកំណត់ទីតាំងថា កំពុងស្ថិតនៅក្រៅប្រទេស បន្ទាប់ពីការស៊ើបអង្កេតយ៉ាងទូលំទូលាយ ប៉ុន្តែសម្រាប់កុមារផ្សេងទៀត គឺមិនមានការបញ្ជាក់ពីទីកន្លែងដែលពួកគេកំពុងរស់នៅ អ្នកដែលមើលថែទាំពួកគេ ឬថាតើពួកគេនៅរស់ឬយ៉ាងណា ដោយទុកឱ្យគ្រួសាររបស់ពួកគេស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់និងបន្តរងការឈឺចាប់។

អ្នកស្រី នាង ផល វ័យ៤២ ឆ្នាំ ជាម្តាយកូនប្រាំនាក់ ហើយដែលក្នុងចំណោមកូនប្រាំនាក់នោះគឺមានបីនាក់ត្រូវបានគេសុំយកទៅចិញ្ចឹមនៅប្រទេសអ៊ីតាលី។ អ្នកស្រីប្រាប់វីអូអេនៅថ្ងៃព្រហស្បតិ៍ថា គាត់បានបាត់ការទាក់ទងជាមួយកូនអស់រយៈពេល១១ឆ្នាំមកហើយ ក្រោយយកកូនៗដែលមានស្រី២ នាក់និងប្រុសម្នាក់មកដាក់នៅមណ្ឌលកុមារកំព្រាមួយក្នុងទីក្រុងភ្នំពេញ ដោយសារបញ្ហាជីវភាព។ អ្នកស្រី នាង ផល ដែលសព្វថ្ងៃជាកម្មករសំណង់ក្នុងទីក្រុងភ្នំពេញ និងបច្ចុប្បន្នមានទីលំនៅនៅខេត្តកំពង់ធំ បន្តថា បន្ទាប់ពីអង្គការលីកាដូជួយស្វះស្វែងរកកូន អ្នកស្រីទើបតែបានឃើញរូបថតកូនៗកាលពីអំឡុងខែតុលា ឬខែវិច្ឆិកា ឆ្នាំមុន។ ប៉ុន្តែមកទល់ពេលនេះ អ្នកស្រីមិនទាន់បានទាក់ទងកូនតាមមធ្យោបាយទំនាក់ទំនងណាមួយ ឬមិនទាន់ជួបកូនផ្ទាល់នៅឡើយ។ «ទៅយករូបថតហ្នឹង អង្គការលីកាដូគេ បាញ់អាហ្វេសប៊ុក អាម៉ែធម៌ឪធម៌ឱ្យយើងចូលមក។ ហើយយើងហ្នឹងក៏មិនចេះអង់គ្លេសចុចទៅវិញ។ តើគេតបវិញឬអត់? អ៊ីចឹង»។

គិតចាប់តាំងពីឆ្នាំ ២០២០ មកអង្គការលីកាដូបានធ្វើការលើករណីចំនួន៤៣ក់ព័ន្ធនឹងកុមារចំនួន១០នាក់ដែលត្រូវបានដាក់ក្នុងមណ្ឌលកុមារកំព្រាដែលមានប្រព័ន្ធគ្រប់គ្រងមិនមានតម្លាភាព។ បើតាមអង្គការលីកាដូ នៅក្នុងករណីនីមួយៗ អាជ្ញាធរបានបដិសេធអស់រយៈពេលជាច្រើនខែមិនប្រាប់ឪពុកម្តាយ ឬអាណាព្យាបាលថា កូនៗរបស់ពួកគេនៅទីណាទេ។ ក្នុងករណីមួយ កុមារម្នាក់បានបាត់ខ្លួនពីមណ្ឌលដែលគ្រប់គ្រងដោយរដ្ឋ ហើយដំណើរការនៃការសុំកូនក្នុងប្រទេសបានចាប់ផ្តើមដោយពុំមានការដឹងឮ ឬការយល់ព្រមពីម្តាយរបស់កុមារនោះទេ ហើយទោះបីជាគាត់ចង់ជួបជុំជាមួយកូនរបស់គាត់វិញក៏ដោយ។ កុមារម្នាក់ៗ បានជួបគ្រួសាររបស់ពួកគេវិញ បន្ទាប់ពីមានកិច្ចអន្តរាគមន៍ជាច្រើនតែប៉ុណ្ណោះ។ នេះបើតាមអង្គការលីកាដូ។

អ្នកស្រីនាង ផល ដែលទន្ទឹមរង់ចាំផ្លូវកូននោះ ក៏បានប្រាប់វីអូអេនៅថ្ងៃព្រហស្បតិ៍ថា កូនៗរបស់អ្នកស្រីត្រូវគេសុំយកទៅចិញ្ចឹមនៅប្រទេសអ៊ីតាលី ដោយគ្មានការស្នើសុំពីអ្នកស្រីទេ។ អ្នកស្រីបន្ថែមថា អ្នកគ្រប់គ្រងមណ្ឌលកុមារកំព្រាដែលអ្នកស្រីយកកូនទៅផ្ញើ ដើម្បីទទួលបានការរៀនសូត្រនោះ បានត្រឹមតែប្រាប់អ្នកស្រីថា ថ្ងៃណាមួយអ្នកស្រីគង់តែនឹងបានជួបកូនៗរបស់អ្នកស្រីវិញទេ។ អ្នកស្រីនិយាយថា៖ «ខ្ញុំចេះតែថា ហឹមគេសើច គេយំខ្ញុំ។ គេថា ខ្ញុំលក់កូនអីអ៊ីចឹង ហើយទៅ គាត់ថា តែកូនយើងមកវិញគេលែងថាហើយ!»។

គិតត្រឹមឆ្នាំមុន កុមារកម្ពុជាយ៉ាងតិចណាស់ចំនួន ៥.៨៤០នាក់ បានរស់នៅក្នុងមណ្ឌលនានា ខណៈកុមារមួយចំនួនមានឪពុកម្តាយរស់នៅនៅឡើយ។ នេះបើតាមអង្គការលីកាដូ។ អង្គការសិទ្ធិមនុស្សដដែលនេះថា ការថែទាំកូនតាមគ្រួសារនៅក្នុងប្រទេស ដូចជាការបង្រួបបង្រួមឱ្យជួបជុំគ្រួសារការថែទាំដោយសាច់ញាតិ ការថែទាំដោយឪពុកម្តាយធម៌ និងការសុំកូនក្នុងប្រទេស ទាំងអស់នេះ គឺមានភាពល្អប្រសើរជាងការសុំកូនជាអន្តរប្រទេស។ ប៉ុន្តែប្រព័ន្ធទាំងនេះមិនទាន់ដំណើរការបានស្រួលបួលពេញលេញនោះទេ ហើយប្រព័ន្ធនីមួយៗក៏នៅខ្វះធនធានបុគ្គលិកសង្គមកិច្ច ហើយក៏មិនទាន់បណ្តុះបណ្តាលបុគ្គលិកឱ្យបានគ្រប់គ្រាន់ផងដែរ៕

## ឥណ្ឌូណេស៊ីនិងម៉ាឡេស៊ី ចុះកិច្ចព្រមព្រៀងស្តីពីការការពារ ពលករចំណាកស្រុក

http://freshnewsasia.com/ 2022-04-01 06:01pm

**(ហ្សាការតា)៖** ប្រធានាធិបតីឥណ្ឌូណេស៊ីលោក ចូកូ វីដូដូ (Joko Widodo) និងនាយករដ្ឋមន្ត្រីម៉ាឡេស៊ីលោក អ៊ីស្មាអែល សាប្រី ប៊ីន យ៉ាកុប (Ismail Sabri Yaakob) នៅថ្ងៃសុក្រនេះ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដើម្បីបង្កើនការការពារសម្រាប់ពលករចំណាកស្រុក បន្ទាប់ពីកិច្ចប្រជុំរវាងមេដឹកនាំប្រទេសទាំងពីរ នៅទីក្រុងហ្សាការតា (Jakarta)។ នេះបើយោងតាមការចេញផ្សាយដោយសារព័ត៌មាន AFP នៅថ្ងៃសុក្រ ទី០១ ខែមេសា ឆ្នាំ២០២២។ អនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងប្រទេសអាស៊ីអាគ្នេយ៍ទាំងពីរនេះ បានធ្វើឡើងបន្ទាប់ពីមានការព្រួយបារម្ភ អំពីសុវត្ថិភាពពលករចំណាកស្រុក បន្ទាប់ពីឧប្បត្តិហេតុមួយចំនួន ពាក់ព័ន្ធនឹងការរំលោភបំពានលើ ពលករឥណ្ឌូណេស៊ី ដែលបម្រើការងារតាមផ្ទះ នៅក្នុងប្រទេសម៉ាឡេស៊ី។

លោកមេដឹកនាំម៉ាឡេស៊ី បាននិយាយបន្ទាប់ពីកិច្ចព្រមព្រៀង ត្រូវបានចុះហត្ថលេខានៅវិមានរដ្ឋាភិបាលថា **«អនុស្សរណៈនៃការយោគយល់គ្នានេះ នឹងធានាថា រាល់នីតិវិធី និងយន្តការការពារនានា ដែលនឹងត្រូវធ្វើឡើងគ្រប់ជ្រុងជ្រោយ ដោយភាគីពាក់ព័ន្ធទាំងអស់ និងស្របទៅតាមច្បាប់នៃប្រទេសទាំងពីរ»**។

គួរបញ្ជាក់ថា អនុស្សរណៈនៃការយោគយល់គ្នានេះ មានគោលបំណងផ្គូរផ្គងពលករឥណ្ឌូណេស៊ីជាមួយនឹងនិយោជកសមស្រប ខណៈវាជាផ្នែកមួយនៃគំនិតផ្តួចផ្តើម ដែលរួមបញ្ចូលផងដែរនូវការពង្រឹងការការពារប្រាក់ឈ្នួល រួមទាំងយន្តការដាក់ពាក្យបណ្តឹងជាដើម៕

## ថ្ងៃទី០៥ ខែ មេសា ឆ្នាំ២០២២

### ជិតចូលឆ្នាំខ្មែរ ! ពលករខ្មែរ សម្រុកចេញថៃ ចូលដីខ្មែរវិញ

https://kbn.news/ April 4, 2022

ខេត្តបាត់ដំបង៖ ខណៈដែលបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិមកដល់ បងប្អូនប្រជាពលរដ្ឋខ្មែរដែលធ្វើជាពលករនៅប្រទេសថៃ បាននាំគ្នាសម្រុកចេញពីស្រុកថៃ ត្រឡប់មកទឹកដីខ្មែរវិញ ដើម្បីជួបជុំបងប្អូន ក្រុមគ្រួសារញាតិមិត្ត។

សមត្ថកិច្ច បានឲ្យដឹងថា កាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០៤នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង បានចំនួន០២លើក សរុបចំនួន ៤៤១នាក់ ស្រី១៨០នាក់ ក្មេង៥១នាក់ ក្មេងស្រី២៤នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) តែមិនមាន រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមាន ទបន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន៣៣៦នាក់ ស្រី១៧៨នាក់ ក្មេង៥១នាក់ ក្មេងស្រី២៤នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្លែនអត់ចេញ ចំនួន៥នាក់ ស្រី២នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្ហា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង៕

### នាព្រឹកថ្ងៃចន្ទ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/04/04/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៨និង០០នាទី នាថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធា

ផ្នែកសឹករងសំពៅលូន ចំនួន០៤នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងឃោជាវរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន៣៦០នាក់ ស្រី១៣១នាក់ ក្មេង៤៣នាក់ ក្មេងស្រី២០នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យ នៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមាន និងមានប័ណ្ណចាក់វ៉ាក់សាំងស្តែនចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០២២

### ពលករខ្មែរ ៨៨ នាក់ចូលមកប្រទេសតាមច្រករបៀងម៉ាឡៃដើម្បីចូលរួមបុណ្យចូលឆ្នាំថ្មី

https://www.kampucheathmey.com/ ថ្ងៃអង្គារ ៥ មេសា ២០២២ដោយ deth leng

វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៥ម៉ាឡៃ បានប្រាប់ឲ្យដឹងថា មានពលករខ្មែរ ដែលកំពុងបម្រើការងារនិងស្នាក់នៅប្រទេសថៃ ចំនួន ៨៨ នាក់ បាននាំគ្នាសម្រុកចេញពីប្រទេសថៃចូលតាមច្រកព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដើម្បីមកលេងស្រុក និងចូលរួមពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិផង។ ការសម្រុករបស់ពលករខ្មែរធ្វើដំណើរចេញពីប្រទេសថៃ ចូលមកស្រុកខ្មែរនេះ គឺដោយសារពួកគាត់នឹករលឹកស្រុកកំណើតដែលពួកគាត់ខកខានមកលេងរយៈពេល២ឆ្នាំមកហើយ និងមួយទៀតដើម្បីមកចូលរួមពិធីបុណ្យចូលឆ្នាំខ្មែរនាពេលខាងមុខផងដែរ ព្រោះរដ្ឋាភិបាលបានផ្អាកប្រារព្ធពិធីចូលឆ្នាំខ្មែរពីរឆ្នាំមកហើយ ដោយសារការរាតត្បាតជំងឺកូវីដ១៩។

វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ម៉ាឡៃបានប្រាប់អ្នកយកព័ត៌មានឲ្យដឹងបន្តទៀតថា នេះតាមការណែនាំរបស់ក្រសួងសុខាភិបាលពលករខ្មែរធ្វើដំណើរមកពីថៃ ដែលបានចាក់វ៉ាក់សាំងបានចំនួន២ដូស ហើយមិនត្រូវបានធ្វើតេស្តរកជំងឺកូវីដ១៩ទៀតទេ និងតម្រូវឱ្យពួកគាត់ធ្វើដំណើរទៅស្រុកកំណើតតែម្តង។ ប៉ុន្តែ ចំពោះពលករណា ដែលចាក់វ៉ាក់សាំងមិនបានគ្រប់ដូស ឬមិនទាន់បានចាក់វ៉ាក់សាំងត្រូវអនុវត្តតាមគោលការណ៍របស់ក្រសួងសុខាភិបាល គឺត្រូវធ្វើតេស្តរកជំងឺកូវីដ១៩។ វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ម៉ាឡៃបានប្រាប់អ្នកយកព័ត៌មានឲ្យដឹងបន្តទៀតថា ពលករខ្មែរ ៨៨នាក់នោះមាន ស្រី៣៨នាក់ កុមារ៧ នាក់វិលពីស្រុកថៃ ចូលមកស្រុកខ្មែរ ដើម្បីមកចូលឆ្នាំខ្មែរនៅពេលខាងមុខ តាមច្រករបៀងស្រុកម៉ាឡៃ តាមភូមិសាស្ត្រប៉ុស្តិ៍សង្កែ ចំណុចកំពង់បងសល់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ៕

### ខាងភាគីថៃ បានបញ្ជូនពលករខ្មែរចំនួន ២៨២នាក់ មកស្រុកកំណើតវិញ

https://cen.com.kh/ Posted ByPen Srey NeatApril 5, 2022

សំពៅលូន ៖ ទីបញ្ជាការវរសេនាតូចលេខ ៨១៩ ស្រុកកំរៀង-ស្រុកភ្នំព្រឹក បានឲ្យដឹងថា នៅថ្ងៃទី៥ ខែមេសាឆ្នាំ២០២២ ខាងភាគីថៃ បានបញ្ជូនពលករខ្មែរលើទី១ ចំនួនរួម ២៨២នាក់ ស្រី ១០៨នាក់ ក្មេងរួម ៥៨នាក់ ក្មេងស្រី ២៧ នាក់។ ប្រភពដដែលបន្តថា កម្លាំងយើងបានធ្វើការវាស់កំដៅនិងកត់ត្រារួច ក្រុមគ្រូពេទ្យបានយកសំណាករហ័សរួចរាល់ឃើញថាពលកទាំង ២៨២នាក់ , វិជ្ជមានចំនួន ១ នាក់ស្រី១នាក់។ ក្រុមគ្រូពេទ្យបានយកគាត់ ទៅព្យាបាល នៅមណ្ឌលត្រាវជ្រុំ ស្រុកសំពៅលូន។ ដោយឡែកពលករចំនួន ១៦ នាក់ស្រី ៧ នាក់ ក្មេងរួម១ នាក់ស្រី ១ នាក់ បញ្ជូនពួកគាត់ទៅធ្វើចត្តាឡីស័ក នៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូនមធ្យាបាយធ្វើដំណើរ ដោយ

រថយន្តយោធា។ ដោយឡែកពលករដែរបានចាក់វ៉ាក់សាំងដុសទី ២ រួមចំនួន ២៦៥នាក់ ស្រី ១០០នាក់ ក្មេងរួមចំនួន ៥៧នាក់ស្រី ២៦នាក់ ក្មេងចាក់វ៉ាក់សាំង ចាប់ពីអាយុ ៥ ឆ្នាំដល់ ១៨ ឆ្នាំបានចំនួនរួម ១២ នាក់ស្រី ៦នាក់។ ក្រុមគ្រូពេទ្យឲ្យពួកគាត់ ទៅស្រុកកំណើតវិញរៀងៗខ្លួន។ មធ្យោបាយធ្វើដំណើរ ដោយរថយន្តឯកជន៕ សុទ្ធ លី

## ពលករខ្មែរជិត ៣០០នាក់ បន្ថែមទៀត
## ត្រូវបានទាហានថៃ ចាត់បញ្ជូនមកកាន់ស្រុកកំណើតវិញ

https://gntimes.com/ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២

បាត់ដំបង៖ ទាហានថៃ បានចាត់បញ្ជូនពលករខ្មែរប្រុស-ស្រី ជិត ៣០០នាក់ទៀត ប្រគល់ត្រឡប់មកស្រុកកំណើតវិញ ក្រោយរកឃើញថា ពួកគេលួចឆ្លងដែនដោយគ្មានច្បាប់អនុញ្ញាត ។ ប្រភពពីសមត្ថកិច្ចការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ បានឲ្យដឹងថា នៅព្រឹកថ្ងៃទី ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០២២ នេះ កម្លាំងប៉ុស្ដិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទៅទទួលពលករវិលត្រឡប់មកស្រុកវិញដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ សមត្ថកិច្ចបន្តថា បន្ទាប់ពីសាកសួរកត់ឈ្មោះរួចឃើញថា ពលករខ្មែរដែលទទួលត្រឡប់មកស្រុកកំណើតនាថ្ងៃនេះសរុបមានចំនួន ២៨២នាក់ ក្នុងនោះ ស្រី ១០៨នាក់ និងក្មេង ៥៨នាក់ ត្រូវបានក្រុមគ្រូពេទ្យធ្វើតេស្តរហ័ស ជាលទ្ធផល វិជ្ជមានកូវីដ-១៩ ម្នាក់ (ស្រី) ត្រូវបានបញ្ជូនទៅព្យាបាលនៅមណ្ឌលគ្រាវជូរស្រុកសំពៅលូន ។ ដោយឡែកពលករចំនួន ១៦នាក់ ស្រី ០៧នាក់ ក្មេងម្នាក់ ត្រូវបានក្រុមគ្រូពេទ្យបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ។ ចំពោះពលករដែលទទួលបានកាតចាក់វ៉ាក់សាំងដូសទី២ ចំនួន ២៦៥នាក់ ស្រី ១០០នាក់ និងក្មេង ៥៧នាក់ ត្រូវបានក្រុមគ្រូពេទ្យធ្វើការអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវីដ-១៩ រួចអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕

## ជិតចូលឆ្នាំ ពលករមកពីថៃ
## តាមច្រកខេត្តបន្ទាយមានជ័យ ១ថ្ងៃជាង១ពាន់នាក់ តែអ្នកវិជ្ជមានកូវីដ-១៩ តិចតួច

https://www.btv.com.kh/ 04/05/2022 03:04 PM

បន្ទាយមានជ័យ៖ ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ កាន់តែគៀកជិតឈានមកដល់ ពលករខ្មែរដែលធ្វើការនៅប្រទេសថៃ បានត្រឡប់មកស្រុកកំណើតវិញ តាមច្រកខេត្តបន្ទាយមានជ័យ មានការកើនឡើង ដែលថ្ងៃខ្លះកើន ដល់ជាង១ពាន់នាក់ ប៉ុន្តែការរកឃើញអ្នកវិជ្ជមានកូវីដ-១៩ មានការថយចុះ ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី៥ ខែមេសានេះ បានឱ្យដឹងថា ពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃ តាមច្រកខេត្តបន្ទាយមានជ័យ តម្រូវឲ្យធ្វើតេស្តសម្រាប់អ្នកដែលមាន អាការៈមិនស្រួលខ្លួន ហើយអ្នកបានចាក់វ៉ាក់សាំងដូសទី២រួចរាល់ អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះ និងអ្នកមិនទាន់ចាក់ ត្រូវធ្វើចត្តាឡីស័យគ្រប់ចំនួនថ្ងៃ ដែលកំណត់ បន្ទាប់ពីបញ្ចប់ការធ្វើចត្តាឡីស័ក នឹងត្រូវចាក់វ៉ាក់ សាំងកូវីដ-១៩ ។ ឯកឧត្តម បានបន្តថា ការវិលត្រឡប់របស់ពលករខ្មែរ ចូលតាមច្រកខេត្តបន្ទាយមានជ័យ កាលពី ដើមឆ្នាំ២០២២ ក្នុងមួយថ្ងៃត្រឹមជាង ៤០០ ទៅ៥០០នាក់ ប៉ុន្តែកាន់តែជិតដល់បុណ្យចូលឆ្នាំ គឺកើនក្នុង មួយថ្ងៃប្រមាណ៧០០នាក់ ដែលថ្ងៃខ្លះកើនឡើងរហូតដល់ជាង១០០០នាក់ ក្នុងចំណោមនេះ រកឃើញ អ្នកវិជ្ជមានកូវីដ-១៩ តិចតួចប៉ុណ្ណោះ ហើយបើគិតមកដលពេលនេះ គឺមានពលករចំនួនជាង ១ម៉ឺននាក់ ហើយដែលបានវិលមកពីថៃ ។ ឯកឧត្តម អ៊ុំ រាត្រី បានបញ្ជាក់

ថា បច្ចុប្បន្ន នៅខេត្តបន្ទាយមានជ័យ កំពុងដំណើរការចាក់វ៉ាក់សាំង កូវីដ-១៩ ដូសទី៣ ជូនដល់ប្រជាពលរដ្ឋ ហើយសម្រាប់ដូសទី៤ បានចាក់ដល់មន្ត្រីជួរមុខ ខណៈប្រជា ពលរដ្ឋមួយចំនួន ក៏បានចាក់ដូសទី៤នេះដែរ ៕

## ត្រឹម៤ថ្ងៃដើមខែនេះ
## ពលរដ្ឋខ្មែរចូលតាមច្រកអូរបើជាន់ជាង១ពាន់នាក់ រកឃើញកូវីដ១០នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៥ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១៥:២៧

ខេត្តបន្ទាយមានជ័យ ៖ រយៈពេល៤ថ្ងៃដើមខែមេសា ឆ្នាំ២០២២នេះ ពលករដែលវិលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ មានចំនួន១.២៩១នាក់ ក្នុងនោះរកឃើញវិជ្ជមានកូវីដ-១៩ ចំនួន១០នាក់ គិតចាប់ពីថ្ងៃទី១ មេសា ដល់ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២ តាមច្រកអូរបើជាន់ក្នុងស្រុកអូរជ្រៅ ។

លោកវរសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាក្រុមការងារទទួលពលករខ្មែរត្រឡប់ពីថៃនៅតាមច្រកអូរបើជាន់បានប្រាប់ថា រយៈពេល៤ថ្ងៃដើមខែមេសា ឆ្នាំ២០២២នេះ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញតាមច្រកអូរបើជាន់ ស្រុកអូរជ្រៅដែលក្រុមការងារទទួលមាន ចំនួន១.២៩១នាក់ ស្រី ៦០៤នាក់ កុមារ១៥០នាក់ និងរកឃើញអ្នកវិជ្ជមានកូវីដ-១៩ ចំនួន១០នាក់ស្រី៤នាក់ ។ លោកបានបញ្ជាក់ថា នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ មានចំនួន២៤០នាក់ ស្រី១១៦នាក់កុមារ៣២នាក់ ស្រី១៣នាក់។ ថ្ងៃទី២ ខែមេសា ឆ្នាំ២០២២ មានចំនួន៣៧៩នាក់ ស្រី១៦៤នាក់ កុមារ៣៦នាក់ ស្រី១៣នាក់ អ្នកវិជ្ជមានកូវីដ-១៩ មានចំនួន ៦នាក់ ស្រី៤នាក់ ។ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ មានចំនួន៣៧៤នាក់ ស្រី១៨០នាក់ កុមារ៤៥នាក់ ស្រី២៥ នាក់ អ្នកវិជ្ជមានកូវី-១៩ មានចំនួន២នាក់ ស្រី២នាក់ ។ និងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២ មានចំនួន២៨៩នាក់ ស្រី ១៤៤នាក់ កុមារ៣៧នាក់ ស្រី២០នាក់ អ្នកវិជ្ជមានកូវីដ-១៩ ចំនួន២នាក់ ។

លោកវរសេនីយ៍ទោ ម៉ាន់ ធី បានបញ្ជាក់ថា នៅអំឡុងបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរឆ្នាំ២០២២នេះ ឃើញថា បងប្អូនប្រជាពលរដ្ឋជាពលករខ្មែរបានត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាដើម្បីជួបជុំគ្រួសារមានច្រើនខុសពីធម្មតា ហើយពលករដែលត្រឡប់ពីប្រទេសថៃ ដែលមានឯកសារចាក់វ៉ាក់សាំងលើកទី២ និងទី៣ ក្រោយពិនិត្យសុខភាព ហើយឱ្យត្រឡប់ទៅផ្ទះវិញ ។ ដោយឡែកពលករខ្មែរដែលមិនទាន់ចាក់វ៉ាក់សាំងការពារកូវីដ-១៩ទេ និងមានឯកសារចាក់លើកទី១ ត្រូវបានដឹកជញ្ជូនដាក់មណ្ឌលធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃនិងអ្នកដែលមានវិជ្ជមានកូវីដ-១៩ត្រូវបានបញ្ជូនទៅព្យាបាលនៅមណ្ឌលក្រុងសិរីសោភ័ណ ៕

# ថ្ងៃទី០៧ ខែ មេសា ឆ្នាំ២០២២

## អាជ្ញាធរខេត្តបន្ទាយមានជ័យកត់សម្គាល់ថាពលករ
## ដែលត្រឡប់ពីប្រទេសថៃមានសញ្ញាជំងឺកូវីដ-១៩តិចតួចបំផុត

http://nokorwatnews.com/ 06/04/2022

ខេត្តបន្ទាយមានជ័យ៖ នៅក្នុងឱកាសដែលពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ កាន់តែកៀកជិតឈានមកដល់ ពលករខ្មែរដែលធ្វើការនៅប្រទេសថៃបានវិលត្រឡប់មកស្រុកកំណើតវិញតាមច្រកព្រំដែននានាក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យមានការកើនឡើង ដែលថ្ងៃខ្លះកើនដល់ជាង១ពាន់នាក់ ប៉ុន្តែអ្វីដែលសំខាន់នោះគឺការរកឃើញអ្នកវិជ្ជមានកូវីដ-១៩ មានការថយចុះ ។

អភិបាលខេត្តបន្ទាយមានជ័យលោក អ៊ុំ រាត្រី នៅថ្ងៃទី៥ ខែមេសានេះ បានឱ្យដឹងថា ពលករខ្មែរធ្វើការនៅប្រទេសថៃ ដែលត្រឡប់មកវិញតាមច្រកព្រំដែននានានៅក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ តម្រូវឱ្យធ្វើតេស្តសម្រាប់អ្នកដែលមាន អាការៈមិនស្រួលខ្លួន ហើយអ្នកបានចាក់វ៉ាក់សាំងដូសទី២រួចរាល់អនុញ្ញាតឱ្យត្រឡប់ទៅផ្ទះ និងអ្នកមិនទាន់ចាក់ត្រូវធ្វើចត្តាឡីស័កគ្រប់ចំនួនថ្ងៃដែលបានកំណត់ ។ បន្ទាប់ពីបញ្ចប់ការធ្វើចត្តាឡីស័កនឹងត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ។ លោកអភិបាលខេត្តបានបន្តថា ការវិលត្រឡប់របស់ពលករខ្មែរចូលតាមច្រកខេត្តបន្ទាយមានជ័យកាលពីដើមឆ្នាំ២០២២ ក្នុងមួយថ្ងៃត្រឹមជាង៤០០ទៅ ៥០០នាក់ ប៉ុន្តែនៅពេលដែលកាន់តែជិតដល់បុណ្យចូលឆ្នាំ គឺកើនក្នុងមួយថ្ងៃប្រមាណ៧០០នាក់ ដែលថ្ងៃខ្លះកើនឡើងរហូតដល់ជាង១០០០នាក់ ហើយក្នុងចំណោមនេះ រកឃើញអ្នកវិជ្ជមានកូវីដ-១៩ តិចតួចប៉ុណ្ណោះ ហើយបើគិតមកដល់ពេលនេះ គឺមានពលករចំនួនជាង ១ម៉ឺននាក់ហើយដែលបានវិលមកពីប្រទេសថៃ ។ លោកអភិបាលខេត្តបន្ទាយមានជ័យបានបញ្ជាក់ថា បច្ចុប្បន្ននៅខេត្តបន្ទាយមានជ័យកំពុងដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ជូនដល់ប្រជាពលរដ្ឋ ហើយសម្រាប់ដូសទី៤បានចាក់ជូនមន្ត្រីជួរមុខ ខណៈប្រជាពលរដ្ឋមួយចំនួនក៏បានចាក់ដូសទី៤នេះដែរ ៕

## នាថ្ងៃអង្គារនេះ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/04/05/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៣លើក សរុបចំនួន២៥៤នាក់ ស្រី៩៩នាក់ ក្មេង៣៨នាក់ ក្មេងស្រី២១នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចប្រគល់បងប្អូនចំនួន៤នាក់ ស្រី២នាក់ ក្មេង២នាក់ ក្មេងស្រី១នាក់ ទៅឲ្យក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារអន្តរជាតិគីឡូ១៣ និងបងប្អូនចំនួន២៥០នាក់ ស្រី៩៧នាក់ ក្មេង៣៥នាក់ ក្មេងស្រី១៨នាក់ ទៅឲ្យក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមានទាំងអស់ ក្រុមគ្រូពេទ្យបានអនុញ្ញាតឱ្យត្រឡប់ទៅមូលដ្ឋានចំនួន២៤២ ស្រី៩៦នាក់ ក្មេង២៨នាក់ ក្មេងស្រី១៩នាក់ ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ។ ចំណែកអ្នកមានបានចាក់វ៉ាក់សាំងតែស្តេនអត់ចេញ ចំនួន៨នាក់ ស្រី១នាក់ ក្មេង៤នាក់ ក្មេងស្រី១នាក់ ក្រុមគ្រូពេទ្យបានបញ្ជូនបងប្អូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្ហា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## នាព្រឹកថ្ងៃពុធ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/04/06/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង០០នាទី នាថ្ងៃពុធ ៥កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្ដិ៍គីឡូ១៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្ដិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០៤នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន៤១០នាក់ ស្រី១៨៨នាក់ ក្មេង៥៤នាក់ ក្មេងស្រី២២នាក់ ។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្ដិ៍។ ជាលទ្ធផល គឺអវិជ្ជមាន និងមានប័ណ្ណចាក់វ៉ាក់សាំងស្ដែនចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី០៨ ខែ មេសា ឆ្នាំ២០២២

## សម្ដេច ស ខេង អញ្ជើញផ្សព្វផ្សាយ របាយការណ៍ ការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ឆ្នាំ២០២១ របស់ គ.ជ.ប.ជ

https://dap-news.com/national/ ByKD102Posted on April 7, 2022

**ភ្នំពេញ៖ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ បានអញ្ជើញផ្សព្វផ្សាយរបាយការណ៍ ស្ដីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់ គ.ជ.ប .ជ។**

យោងតាមរបាយការណ៍ ស្ដីពីការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០២១ និងទិសដៅអនុវត្តឆ្នាំ២០២២ របស់ គ.ជ.ប.ជ បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា នៅតែចាត់ទុកការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាអាទិភាពខ្ពស់ បើទោះបីជាការរាតត្បាតនៃជំងឺកូវីដ-១៩ បានកើនឡើងខ្លាំង ព្រមទាំងស្ថានភាពប្រែប្រួល នៃសេដ្ឋកិច្ចពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមពុំរ៉ៃនៅបណ្ដាប្រទេសមួយចំនួន ជួបគ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ជាដើម) ក្នុងឆ្នាំ២០២១ ក៏ដោយ។ ទាំងនៅតាមបណ្ដាក្រសួងស្ថាប័ន ទាំងនៅថ្នាក់ក្រោមជាតិ រហូតដល់នៅតាមខ្សែបណ្ដោយព្រំដែន មន្ត្រីគ្រប់លំដាប់ថ្នាក់បានបង្កើនការយកចិត្តទុកដាក់ ក្នុងការស្រាវជ្រាវ និងបង្ក្រាបអំពើជួញដូរមនុស្ស ដែលជ្រកក្រោមរូបភាពផ្សេងៗ

បង្កើតឡើងដោយឧក្រិដ្ឋជន និងបណ្តាញរបស់ខ្លួន ។ លើសពីនេះទៀត រាជរដ្ឋាភិបាល បានបង្កើនថវិកាសម្រាប់វិស័យសង្គមកិច្ច ដើម្បីទ្រទ្រង់ជីវភាពកម្មករ ដែលបាត់បង់ការងារ ប្រជាពលរដ្ឋក្រីក្រ ពលករ ដែលវិលត្រឡប់ក្នុងអំឡុងពេល នៃការបិទខ្ទប់ក្នុងប្រទេសគោលដៅ ដែលមានចំនួនច្រើន លើសលប់ រហូតដល់ ១៤០.៦៦៤នាក់ ក្នុងនោះមានស្ត្រី ៦២.២៩៤នាក់ និងភាគច្រើនជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាពពេលត្រឡប់មកវិញហើយងាយរងគ្រោះ ៕

## សម្តេច ស ខេង បញ្ជាសមត្ថកិច្ច
## បង្ក្រាប ជនល្មើសជួញដូរមនុស្ស ដោយគ្មានការលើកលែង និង មិនយោគយល់

https://dap-news.com/national/ ByPH104Posted on April 7, 2022

**ភ្នំពេញ ៖** ក្នុងនាមជាប្រធាន គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចេញបទបញ្ជាឲ្យសមត្ថកិច្ចគ្រប់ប្រភេទ ធ្វើការបង្ក្រាបជនល្មើស រកស៊ីជួញដូរមនុស្ស ដោយគ្មានការលើកលែង និងមិនយោគយល់។

ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់ គ.ជ.ប.ជ សម្តេច ស ខេង បានថ្លែងថា ការឃាត់ខ្លួនជនសង្ស័យរកស៊ីជួញដូរមនុស្ស គឺត្រូវខិតខំបន្តឲ្យបានកាន់តែច្រើន ទៅតាមបរិមាណបទល្មើសដែលមាន ។ ទន្ទឹមនឹងនោះ ក៏ត្រូវពន្លឿនការកាត់សេចក្តី នៅតាមស្ថាប័នតុលាការ ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ប្រកបដោយភាពត្រឹមត្រូវ។ សម្តេច មានប្រសាសន៍ថា «កិច្ចការងារបង្ក្រាប ជនល្មើសនេះ និងការកាត់សេចក្តីផ្តន្ទាទោស ខ្ញុំក៏សូមលើកទឹកចិត្តបន្ថែមទៀតដល់សមត្ថកិច្ចពាក់ព័ន្ធរបស់យើង ធ្វើយ៉ាងម៉េចធ្វើឲ្យបានត្រឹមត្រូវ បានន័យថា ប្រកបដោយតម្លាភាព និងយុត្តិធម៌ដោយមិនលើកលែង មិនយោគយល់ មិនអនុគ្រោះ ចំពោះអ្នកប្រព្រឹត្តបទល្មើស ដ៏ហាវព្រៃផ្សៃនេះ»។

នាឱកាសនោះ សម្តេច ស ខេង ក៏បានលើកទឹកចិត្តគ្រប់ក្រសួងស្ថាប័ន ក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូក្នុងស្រុក និងអន្តរជាតិ បន្តសហការគ្នា ដើម្បីរិះរកវិធានការគន្លឹះនានា និងរួមសហការគ្នាជាធ្លុងមួយ ធ្វើសកម្មភាពឲ្យកាន់តែខ្លាំងក្លាក្នុងការ «បង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស» និងរួមចំណែករក្សាស្ថិរភាព សន្តិសុខនិងសុវត្ថិភាពសង្គម និងកាត់បន្ថយឈានទៅលុបបំបាត់ភាពរងគ្រោះ បង្កដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់ លើមនុស្សគ្រប់ភេទ គ្រប់វ័យ ជាពិសេសស្ត្រី កុមារ និងយុវវ័យ ។

សូមបញ្ជាក់ថា ឆ្នាំ២០២១ សមត្ថកិច្ចបានបង្ក្រាបករណីជួញដូរមនុស្សចំនួន ២៣៩ករណី ក្នុងនោះ បានបញ្ជូនទៅតុលាការចំនួន ៤០០នាក់ សរុបជនរងគ្រោះដែលសង្គ្រោះបានចំនួន១,៣៩០នាក់។ ដោយឡែក ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ បង្ក្រាបបានចំនួន១២៤ករណី (៨៦ករណី ជាករណីរួមភេទជាមួយអនីតិជន) ក្នុងនោះបានបញ្ជូនទៅតុលាការ ចំនួន១៣៨នាក់ សរុបជនរងគ្រោះដែលសង្គ្រោះបាន ចំនួន១៨៧នាក់៕

## កម្ពុជា ផ្តើមសិក្សារៀបចំច្បាប់ពពោះជំនួសឡើងវិញ ក្រោយផ្អាកមួយរយៈ

http://freshnewsasia.com/ 2022-04-07 12:52pm

**(ភ្នំពេញ)៖** បន្ទាប់ពីផ្អាកមួយរយៈ នៅពេលនេះសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឯកភាពជាគោលការណ៍ឲ្យស្ថាប័នពាក់ព័ន្ធសិក្សារួមគ្នាឡើងវិញឲ្យហ្មត់ចត់ ដើម្បីរៀបចំធ្វើច្បាប់ពពោះជំនួសបន្តទៀត ខណៈសេចក្តីព្រាងក៏បានរៀបចំចប់សព្វគ្រប់ហើយដែរកាលពីពេលកន្លងទៅ។

ច្បាប់ស្តីពីការពពោះជំនួស ត្រូវបានក្រសួងកិច្ចការនារី សហការជាមួយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ពិនិត្យតាក់តែងសេចក្តីព្រាងច្បាប់នេះ តាមការណែនាំរបស់ប្រមុខរដ្ឋាភិបាលកម្ពុជា ដើម្បីបង្ក្រាបបទល្មើសកើតចេញពីការពពោះជំនួស ដែលមានជាតុផ្សំជាបទល្មើស ហើយត្រូវបានចាប់ផ្តើមតាក់តែង ដោយក្រុមអ្នកជំនាញផ្នែកច្បាប់ នៃក្រសួងទាំងបី កាលពីឆ្នាំ២០១៦។

ក្នុងឱកាសអញ្ជើញផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២១ និងទិសដៅការងារបន្តឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅព្រឹកថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង បានគូសបញ្ជាក់ថា ច្បាប់ពពោះជំនួសនេះ ជាច្បាប់ថ្មីសម្រាប់កម្ពុជាដូច្នេះទាមទារឲ្យសិក្សាពីបណ្តាប្រទេសជិតខាង។ សម្តេចក្រឡាហោម ស ខេង បានថ្លែងបែបនេះថា «**ទាក់ទងច្បាប់ពពោះជំនួស បញ្ហានេះយើងបានរៀបចំតាំងពីឆ្នាំ២០១៦មកម្ល៉េះ ដែលយើងបានព្រាងចប់សព្វគ្រប់ហើយ។ ប៉ុន្តែដោយសារច្បាប់នេះថ្មីសម្រាប់កម្ពុជា អញ្ចឹងទេយើងត្រូវការសិក្សាឲ្យបានហ្មត់ចត់ ដូច្នេះត្រូវការពេលវេលា។ មកដល់ពេលនេះយើងបានសិក្សាហ្មត់ចត់ជាងមុនហើយ ដូច្នេះអាចលើកយកបញ្ហានេះមកវិញ ព្រោះកន្លងខ្ញុំស្នើឲ្យផ្អាកមួយរយៈអញ្ចឹងឥលូវនេះអាចលើកយកបញ្ហានេះមកជជែកគ្នាឡើងវិញបាន ខ្ញុំសូមគាំទ្រ**»។ ដោយសារតែច្បាប់នេះថ្មីសម្រាប់កម្ពុជា សម្តេចក្រឡាហោម ស ខេង បានស្នើឲ្យអ្នកពាក់ព័ន្ធសិក្សាពីបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់ ក៏ដូចជាអន្តរជាតិដែលប្រទេសនោះធ្លាប់បានធ្វើរឿងនេះ។ ប៉ុន្តែក្រោយមកមានខ្លះបានលុបចោលវិញ ដូច្នេះត្រូវសិក្សាអំពីមូលហេតុនៃការលុបចោលច្បាប់នេះវិញផងដែរ។ ទោះជាយ៉ាងណា សម្តេចក្រឡាហោម ស ខេង មិនបានបញ្ជាក់ថា តើប្រទេសណាដែលបានលុបចោលច្បាប់នោះវិញទេ? ប៉ុន្តែសម្តេចថាបន្ទាប់ពីប្រទេសនោះបានលុបវិញ អ្នកដែលចង់បានកូនតែមិនមានលទ្ធភាពសម្រាប់ពពោះខ្លួនឯងនោះ បានរត់មកប្រទេសកម្ពុជា។

ចំណុចនេះ សម្តេចក្រឡាហោម បានណែនាំឲ្យសិក្សាពីប្រទេសនោះថា នៅពេលមានច្បាប់ពពោះជំនួសនេះ តើប្រទេសនោះមានបញ្ហាប្រឈមអ្វីខ្លះ? ហើយសម្តេចក៏បានទទួលស្គាល់ថា កម្ពុជាមានអ្នកដែលហ៊ានពពោះជំនួសបែបនេះ បើទោះបីមិនទាន់មានច្បាប់អនុញ្ញាតក្តី ដោយពួកគាត់បានលួចលាក់ព្រមព្រៀងគ្នា។ ប៉ុន្តែពេលខ្លះកូននោះសម្រាលមក ក៏មានការខ្វែងគំនិតគ្នា ដោយអ្នកពពោះនោះ មិនព្រមប្រគល់កូននោះគេវិញក៏មាន ខណៈច្បាប់នេះនឹងមានចែងត្រង់ចំណុចនេះដូចគ្នា។

គួរជម្រាបថា ច្បាប់ស្តីពីការពពោះជំនួសនេះ ត្រូវបានបង្កើតឡើងដើម្បីការពារផលប្រយោជន៍ស្ត្រីកម្ពុជា។ ច្បាប់នេះត្រូវបានរៀបចំសេចក្តីព្រាងរួចរាល់ហើយ ប៉ុន្តែមិនទាន់ត្រូវគេបង្ហាញជាសាធារណៈនៅឡើយទេ។ កន្លងទៅសមត្ថកិច្ចក៏បានឃាត់ខ្លួនស្ត្រីខ្មែរប៉ុន្មាននាក់ផងដែរ ពាក់ព័ន្ធការធ្វើសកម្មភាពពពោះជំនួសនេះ ដោយភាគីច្រើនជាកូនរបស់ជនជាតិបរទេស៕

## សម្តេចក្រឡាហោម
## ស្នើឲ្យសមត្ថកិច្ច និងអ្នកពាក់ព័ន្ធទាំងអស់ ចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://cen.com.kh/ Posted ByPen Srey NeatApril 7, 2022

ភ្នំពេញ៖ នាព្រឹកថ្ងៃពុធ ទី៧ ខែមេសា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ថាគ.ជ.ប.ជ ប្រារព្ធនៅសាលវិទ្យាស្ថានជាតិអប់រំ ។ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ពិធីនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោក

ជំទាវ រដ្ឋមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ, អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ក្រសួងស្ថាប័នពាក់ព័ន្ធ អគ្គស្នងការដ្ឋាននគរបាលជាតិ ស្ថានទូតនានា ប្រចាំកម្ពុជា អង្គការសង្គមស៊ីវិល អភិបាលរាជធានី-ខេត្ត ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ព្រមទាំងអ្នកពាក់ព័ន្ធជាច្រើនរូបទៀត ។

ជាកិច្ចចាប់ផ្តើមលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានធ្វើរបាយការណ៍ជូនសម្តេចក្រឡាហោម និងអង្គពិធីអំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបានគូសបញ្ជាក់ថាឆ្នាំ២០២១ កម្ពុជាបានឆ្លងកាត់ការបិទខ្ទប់ព្រំដែន និងការបិទខ្ទប់តំបន់មានហានិភ័យខ្ពស់ដោយជំងឺកូវីដ-១៩ ក្នុងពេលមានការវិលត្រឡប់របស់ប្រជាពលរដ្ឋ និងពលករទេសន្តប្រវេសន៍ ដោយគំហុក ។ លោកជំទាវ បានបន្តថា ឆ្នាំ២០២១ គ.ជ.ប.ជ បានបង្កើនការចំណាយទៅលើវិស័យសង្គមកិច្ច ដើម្បីសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋពីវិបត្តិ ដែលបង្កដោយគ្រោះមហន្តរាយផ្សេងៗ ជាពិសេស ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩ ដូចជាការអប់រំផ្សព្វផ្សាយ ការគាំទ្រជីវភាពប្រជាពលរដ្ឋខ្វះខាត កម្មករកម្មការិនីដែលបាត់បង់ការងារ ស្ត្រីមានផ្ទៃពោះ សម្រាលកូន និងកូនតូចក្រោមអាយុ ២ឆ្នាំ ការឧបត្ថម្ភ និងផ្គត់ផ្គង់គ្រួសារប្រជាពលរដ្ឋក្នុងតំបន់បិទខ្ទប់ គាំទ្រ និងឧបត្ថម្ភគ្រួសារ ដែលមានអ្នកឆ្លង ឬមានអ្នកស្លាប់ដោយជំងឺកូវីដ-១៩ ជាដើម ។

អញ្ជើញមានប្រសាសន៍នាឱកាសនោះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានថ្លែងអំណរគុណបណ្តាដៃគូពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសកម្ពុជា បានយ៉ាងសកម្មជាមួយសមត្ថកិច្ច និងអ្នកពាក់ព័ន្ធទាំងអស់នៅកម្ពុជា ខិតខំប្រឹងប្រែងធ្វើសកម្មភាពព្រមៗគ្នា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដោយទទួលបានលទ្ធផលល្អច្រើន បើប្រៀបធៀបទៅនឹងឆ្នាំកន្លងទៅនេះ។ សម្តេចក្រឡាហោម ក៏បានសម្តែងក្តីរីករាយចំពោះសមត្ថកិច្ច និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅប្រទេសកម្ពុជា ទោះបីជួបបញ្ហាប្រឈមមួយចំនួនក៏ដោយ ក្នុងនោះការឃាត់ខ្លួនជនសង្ស័យពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស ការអនុវត្តនិតីវិធីតាមផ្លូវតុលាការ ការកាត់សេចក្តីដើម្បីផ្តន្ទាទោស ជនល្មើសពាក់ព័ន្ធជួញដូរមនុស្ស ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ។ សម្តេចក៏បន្ថែមថាជារៀងរាល់ឆ្នាំ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តែងតែបានរៀបចំកម្មវិធីបូកសរុប និងផ្សព្វផ្សាយលទ្ធផលការងារ ដើម្បីជូនជ្រាប អំពីស្ថានភាព និងព្រឹត្តិការណ៍ទូទៅ ដែលប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ហើយជះឥទ្ធិពលដល់ការងារប្រឆាំងការជួញដូរមនុស្ស ល្បិចកលថ្មីៗនៃជនល្មើសជួញដូរមនុស្ស ព្រមទាំងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ដែលមានទាំងសកម្មភាពបង្ការទប់ស្កាត់ ការបង្ក្រាប ការសង្គ្រោះ និងកិច្ចការពារជនរងគ្រោះ ការផ្តន្ទាទោស និងកិច្ចសហការដ៏ទូលំទូលាយ ពីថ្នាក់ជាតិដល់មូលដ្ឋាន និងរហូតដល់អន្តរជាតិ ។

ពីវេទិកាអធិបតីនេះដែរ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍លើកទឹកចិត្តដល់គ្រប់ក្រសួងស្ថាប័ន ក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូក្នុងស្រុក និងអន្តរជាតិសូមបន្តសហការគ្នា ដើម្បីបន្តរិះរកនូវវិធានការគន្លឹះនានា និងរួមសហការគ្នាជាធ្លុងមួយ ធ្វើសកម្មភាពឱ្យកាន់តែខ្លាំងក្លាក្នុងការ បង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដើម្បីព្រះរាជាណាចក្រកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងរួមចំណែកក្នុងការ រក្សាស្ថិរភាព សន្តិសុខ និងសុវត្ថិភាពសង្គម និងកាត់បន្ថយឈានទៅលុបបំបាត់នូវភាពរងគ្រោះ ដែលបង្កដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់ លើមនុស្ស គ្រប់ភេទ គ្រប់វ័យ ជាពិសេសស្ត្រី កុមារ និងយុវវ័យ ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

# បច្ចេកវិទ្យាទំនើបជំរុញការជួញដូររូបភាពអាសអាភាសកុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា

https://www.khmertimeskh.com/ តាំង វីនិត្យ / April 7, 2022

លើកចុងក្រោយ ដែលរូបភាពអាសអាភាសកុមារបានធ្វើឱ្យមានភាពភ្ញាក់ផ្អើលនៅកម្ពុជា គឺនៅពេលដែលស្ថានទូតអាមេរិក នៅទីក្រុងភ្នំពេញ បានបណ្តេញបុគ្គលិកជាង១០នាក់នៅក្នុងឆ្នាំ២០១៨ បន្ទាប់ពីរកឃើញក្រុប Facebook របស់ពួកគេមានទាក់ទងនឹងការចែកចាយរូបភាព ដែលមានអត្តន័យកេងប្រវ័ញ្ចលើកុមារ។

សាធារណជន នឹងឃើញរបាយការណ៍ ស្តីពីការចាប់ខ្លួនជនសង្ស័យម្តងម្កាល គឺភាគច្រើនជាជនបរទេសដែលផលិតរឿងអាសអាភាសរបស់កុមារ។ យ៉ាងណាមិញ បញ្ហាជុំវិញប្រធានបទនេះ គឺជាការកេងចំណេញលើកុមារតាមរយៈរូបភាពអាសអាភាស ដែលប្រព្រឹត្តឡើងដោយ «ឈ្មួញទុច្ចរិត»ជាជនជាតិកម្ពុជា។ «វីដេអូក្មេងស្រីទំហំ៧២៩ ជីមេហ្គាបាយ ចំណាយត្រឹមតែ១០ ដុល្លារ! មិនចាំបាច់ប្រើទូរស័ព្ទដែលមានអង្គចងចាំធំនោះទេ។ អ្នកគ្រាន់តែត្រូវការអ៊ីនធឺណិតប៉ុណ្ណោះដើម្បីមើលវីដេអូនេះ»។ សារផ្សាយជាភាសាខ្មែរនេះ ត្រូវបានបង្ហោះក្នុងឆាណែលតេលេក្រាម (Telegram Channel) ដែលពាក់ព័ន្ធនឹង «មាតិកាមនុស្សពេញវ័យ»។ ការបង្ហោះនេះ មានឃ្លីបវីដេអូបង្ហាញពីទិដ្ឋភាពកេងប្រវ័ញ្ចផ្លូវភេទអនីតិជន។ កុមារភាគច្រើននៅក្នុងវីដេអូ ហាក់ដូចជាមកពីប្រទេសអាស៊ីអាគ្នេយ៍ ហើយយ៉ាងហោចណាស់មានម្នាក់ជាជនជាតិខ្មែរ។ ការបង្ហោះនេះមានតំណភ្ជាប់ដែលអាចឱ្យអ្នកប្រើប្រាស់ទាក់ទងទៅកាន់ «អ្នកគ្រប់គ្រង» (Admin) ដើម្បីទិញវីដេអូទាំងនេះ។ ការបង្ហោះនេះត្រូវបានលុបចោលក្រោយពី ៣០នាទី ប៉ុណ្ណោះ ហើយភស្តុតាងនៃការប្រព្រឹត្តអំពើអាក្រក់ត្រូវបានលុបចោលផងដែរ។

ឆាណែលនេះមានអ្នកតាមដាន (Subscriber) ជាង ២៧,០០០នាក់ ហើយការបង្ហោះនេះត្រូវមើលឃើញដោយអ្នកប្រើប្រាស់ជាង ៥,០០០ នាក់។ វីដេអូអាសអាភាសខ្លីរបស់កុមារនេះ ក៏ត្រូវបានគេឃើញនៅក្នុងក្រុម Telegram មួយផ្សេងទៀតដែលមានសមាជិកជាង ១ម៉ឺននាក់ផងដែរ។ សមាជិកត្រូវបានប្រាប់ឱ្យផ្ទេរប្រាក់ទៅអ្នកគ្រប់គ្រងក្រុម ប្រសិនបើពួកគេចង់មើលវីដេអូពេញលេញ។ សមាជិកមួយចំនួនបានស្នើសុំអ្នកគ្រប់គ្រងឱ្យបង្ហោះវីដេអូ "គំរូ" បន្ថែមទៀត។ ឆាណែលទាំងនេះហាក់ដូចជាត្រូវបានគ្រប់គ្រងដោយក្រុមមនុស្សដូចគ្នា ហើយមានវេទិកាបែបនេះរាប់ពាន់នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមកម្ពុជា ហើយសកម្មភាពបែបនេះអាចនាំឱ្យមានការកើនឡើងនៃការរំលោភបំពានលើកុមារនៅក្នុងប្រទេសផងដែរ។

លោក សំនៀង សិលា នាយកប្រចាំប្រទេសនៃអង្គការសកម្មភាពដើម្បីកុមារ Action Pour Les Enfants (APLE) មានប្រសាសន៍ថា៖«យើងបានឃើញករណីនេះជាច្រើននៅក្នុងប្រទេសកម្ពុជា។ ការធ្វើពាណិជ្ជកម្មរូបភាពអាសអាភាសរបស់កុមារ អាចបង្កើតតម្រូវការ ក្នុងចំណោមមនុស្សពេញវ័យ ហើយនៅពេលដែលតម្រូវការកាន់តែខ្ពស់នោះ ការផលិតក៏សំបូរដែរ មានន័យថា កុមារកាន់តែច្រើននឹងទទួលរងការរំលោភផ្លូវភេទ និង ការជួញដូរ»។ លោកជឿថា ការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារនឹងនាំឱ្យមនុស្សពេញវ័យ ព្រមទាំងកុមារផងដែរប្រព្រឹត្តបទឧក្រិដ្ឋកាន់តែច្រើនឡើង។ លោក សំនៀង សិលា បានបញ្ជាក់ថា អំពើអាក្រក់បែបនេះអាចជះឥទ្ធិពលអវិជ្ជមានដល់កុមារទាំងផ្លូវកាយ ទាំងផ្លូវចិត្ត។ អ្នកខ្លះអាចរងគ្រោះអស់មួយជីវិតផងដែរ។

ទិដ្ឋភាពបែបនេះ មិនល្អនោះឡើយសម្រាប់ប្រទេសកម្ពុជា ដែលជាប្រទេសមួយដែលត្រូវបានគេរកឃើញថាមានកុមារជាច្រើនត្រូវគេបំពានសិទ្ធិ។ យោងតាមអង្គការយូនីសេហ្វ កុមារកម្ពុជាចំនួន ៥០ភាគរយ បានជួបប្រទះការវាយដំយ៉ាងធ្ងន់ធ្ងរ ខណៈម្នាក់ក្នុងចំណោមបួននាក់ត្រូវបានរំលោភបំពានផ្លូវចិត្ត និងម្នាក់ក្នុងចំណោម២០នាក់ត្រូវបានរំលោភបំពានផ្លូវភេទ។

យោងតាមគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស (NCCT) គេមិនទាន់មានទិន្នន័យផ្លូវការ ស្តីពីទំហំនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជានោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ តួ

លេខដែលប្រមូលបានពីករណីដែល សាធារណជនរាយការណ៍ទៅកាន់អាជ្ញាធរ និងតាមរយៈបណ្តាញទូរស័ព្ទទាន់ហេតុការណ៍គឺ មានចំនួនជាង១៥០ករណីក្នុងមួយឆ្នាំ។ ចំនួននេះនៅមិនទាន់រាប់បញ្ចូលករណីដែលមិនបានរាយការណ៍នោះទេ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មបដ្ឋូរភេទបានដាក់ទោសទណ្ឌចំពោះរាល់សកម្មភាពដែលទាក់ទងនឹងរូបភាពអាសអាភាសរបស់កុមារ ដែលសំដៅលើ «មាតិកាដែលអាចមើលឃើញដូចជា រូបថត វីដេអូ រួមទាំងសម្ភារៈក្នុងទម្រង់អេឡិចត្រូនិក ដែលបង្ហាញពីរូបអាក្រាតរបស់អនីតិជន ដែលជំរុញចំណង់ផ្លូវភេទ»។ ច្បាប់ចែងថា៖ ជនណាដែលចែកចាយ លក់ ជួល តាំងបង្ហាញ ឬបង្ហាញនៅទីសាធារណៈនូវរូបភាពអាសអាភាសរបស់កុមារនឹងត្រូវប្រឈមមុខនឹងការជាប់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០ ទៅ ២,៥០០ ដុល្លារ។ ដោយឡែក បច្ចេកវិទ្យាបានធ្វើឱ្យការអនុវត្តច្បាប់កាន់តែលំបាក។ មុនពេលមានអ៊ីនធឺណិត និង ប្រព័ន្ធផ្សព្វផ្សាយសង្គមនៅកម្ពុជា រូបភាពអាសអាភាសរបស់កុមារមាននៅក្នុងទីផ្សារ និងហាងលក់ឌីសនៅកម្ពុជា ដាក់លក់ក្នុងតម្លៃត្រឹមតែ ២ពាន់រៀលក្នុងមួយឌីស។

លោក គឹម ភាព អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ មានប្រសាសន៍ថា៖«អ៊ីនធឺណិតបាននាំយកបទល្មើសអាសអាភាសរបស់កុមារទៅជាយុគសម័យថ្មី ហើយមន្ត្រីរបស់យើងនៅមិនទាន់មានជំនាញគ្រប់គ្រាន់ដើម្បីដោះស្រាយវានោះទេ»។ លោកបានបញ្ជាក់ថា សាធារណជនបានរាយការណ៍ករណីរឿងអាសអាភាសលើកុមារ ហើយនាយកដ្ឋានរបស់លោកបាននឹងកំពុងដោះស្រាយករណីនេះ ប៉ុន្តែការកម្រិតចំណេះដឹងរបស់ពួកគេក្នុងវិស័យនេះនៅតែជាបញ្ហាប្រឈមចម្បង។ លោកបានបន្តថា៖ «ខុសពីមន្ត្រីនៅក្នុងប្រទេសមួយចំនួន ដែលទទួលបានការបណ្តុះបណ្តាលដើម្បីដោះស្រាយបញ្ហាបែបនេះ យើងខ្វះជំនាញ និងឧបករណ៍ចាំបាច់ក្នុងការកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនល្មើស។ យើងត្រូវពឹងលើអង្គភាពប្រឆាំងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ដើម្បីដោះស្រាយបញ្ហានេះ»។

ទន្ទឹមនឹងនេះ មាតិកាកេងប្រវ័ញ្ចលើកុមារធ្លាប់តែត្រូវបានគេរកឃើញនៅលើ Dark Web ជាតំបន់មួយនៅលើអ៊ីនធឺណិតដែលគេមិនអាចប្រើ Search Engine ដើម្បីស្វែងរកបាន ហើយវាទាមទារកម្មវិធីពិសេស ឬការអនុញ្ញាតដើម្បីចូលមើលមាតិកាខុសច្បាប់ផ្សេងទៀត។ ការផលិតមាតិកាបែបនេះបានក្លាយជាបញ្ហាដ៏ធំមួយក្នុងប្រទេសមួយចំនួនដូចជាហ្វីលីពីន និងថៃ ជាដើម។ ជាមួយនឹងការលេចធ្លោរនូវការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមនេះ វាបានធ្វើឱ្យកាន់តែមានភាពងាយស្រួលជាងមុនក្នុងការស្វែងរកវីដេអូ និងរូបភាពបែបនេះ។

អ្នកស្រី តាន់ សូដានី ប្រធាននាយកដ្ឋានគោលនយោបាយព័ត៌មានវិទ្យា របស់រដ្ឋាភិបាលបាននិយាយថា វាគឺជាការងាយស្រួលជាងសម្រាប់អាជ្ញាធរក្នុងការហាមឃាត់គេហទំព័រសាធារណៈ ដូចដែលបានធ្វើកាលពីខែធ្នូ ក្រោយពីនាយកដ្ឋានបានបិទគេហទំព័រចំនួន៩ដែលបង្ហោះរូបភាព និងវីដេអូអាសអាភាសរបស់កុមារ។ អ្នកស្រីបានបន្តថា វេទិកាដូចជា Telegram និង WhatsApp ប្រើមុខងារ End-to-End Encryption ដើម្បីការពារសេរីភាពនៃការបញ្ចេញមតិ និងភាពឯកជនរបស់អ្នកប្រើប្រាស់ ប៉ុន្តែក្រុមជនទុច្ចរិតបានទាញយកប្រយោជន៍ពីវាដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មដ៏គួរឱ្យស្អប់ខ្ពើមរបស់ពួកគេ។ អ្នកស្រីនិយាយថា៖ «ដូចជា Dark Web ដែរ វាស្ទើរតែមិនអាចទៅរួចទេក្នុងការតាមដានកន្លែងមូលដ្ឋាននៃប្រតិបត្តិការ។ វាមិនអាចទៅរួចទេក្នុងការទទួលបានកិច្ចសហការពីក្រុមហ៊ុននានា ដើម្បីឃើញមាតិកាខ្លឹមសារបែបនេះពីការរីករាលដាល ដោយសារយើងជាប្រទេសកំពុងអភិវឌ្ឍន៍ មិនមានជំនាញ ឬធនធានគ្រប់គ្រាន់ដើម្បីដោះស្រាយវា»។

កម្មវិធីបណ្តាញសង្គមផ្ញើសារមួយចំនួនមានគោលការណ៍ការពារប្រឆាំងនឹងមាតិកាអាសអាភាស ប៉ុន្តែពិរុទ្ធជនបានរកឃើញវិធីប្រើប្រាស់ចន្លោះប្រហោងដើម្បីបន្តប្រតិបត្តិការរបស់ពួកគេ។ ឧទាហរណ៍ ប្រតិបត្តិករនឹងលុបក្រុមចោល បន្ទាប់ពីផ្តល់ឱ្យអតិថិជនរបស់ពួកគេនូវពេលវេលាគ្រប់គ្រាន់ដើម្បីទាញយកមាតិកាអាសអាភាស។ ពួក

គេក៏រកប្រាក់បានពីការលក់តំណទៅកាន់វេទិកាផ្ទុកទិន្នន័យ (Cloud) សម្រាប់មាតិកាដែលត្រូវទាញយកផងដែរ។ សម្រាប់ពេលនេះ មធ្យោបាយដ៏ល្អក្នុងការដោះស្រាយបញ្ហានេះគឺថា សាធារណជនត្រូវរាយការណ៍ទៅកាន់អាជ្ញាធរគ្រប់ពេលដែលពួកគេជួបប្រទះនូវខ្លឹមសារអាសអាភាសរបស់កុមារ តាមអុីនធឺណិត ឬកន្លែងណាក៏ដោយ។

លោក គឹម ភាព បានមានប្រសាសន៍បន្តថា៖«សូមទាក់ទងទូរសព្ទលេខ១១២៨៨ របស់យើង ដើម្បីរាយការណ៍ នៅពេលដែលអ្នកជួបប្រទះការកេងប្រវ័ញ្ចលើកុមារតាមអុីនធឺណិត ការចែកចាយរូបភាពអាសអាភាសលើកុមារ និងការបៀតបៀនផ្លូវភេទ»៕

## ក្រសួងការងារ អនុញ្ញាតឱ្យក្រុមហ៊ុន ចំនួន ៣៧ ជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរ ទៅធ្វើការនៅភាតា

https://kohsantepheapdaily.com.kh/ ភ្នំពេញ០៦ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ២៣:១៨

ភ្នំពេញ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសនូវបញ្ជីរាយឈ្មោះក្រុមហ៊ុនឯកជន ចំនួន ៣៧ក្រុមហ៊ុន ដែលមានសិទ្ធិជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរ ទៅធ្វើការនៅរដ្ឋកាតា។ ក្នុងនោះ ក្រសួងការងារ ក៏បានកំណត់ថា ដើម្បីជៀសវាងការផ្សព្វផ្សាយព័ត៌មានខុស ដែលអាចនាំឱ្យប្រជាពលរដ្ឋរងគ្រោះ ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងការជ្រើសរើស ឬផ្តល់សេវារកការងារឱ្យធ្វើដល់ពលករខ្មែរ នៅតាមបណ្តាសារព័ត៌មានណាមួយ ជាពិសេសតាមបណ្តាស្ថានីយវិទ្យុ ត្រូវមានលិខិតអនុញ្ញាត ចេញដោយអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមុន។ ក្រសួងការងារ ប្រកាសថា រាល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងឡាយណា ដែលពុំមានឈ្មោះ ក្នុងបញ្ជីខាងក្រោមនេះ គឺចាត់ទុកថា ជាទីភ្នាក់ងារជ្រើសរើសឯកជនខុសច្បាប់ ដូច្នេះសូមសាធារណជនរាយការណ៍ជាបន្ទាន់ មកទូរស័ព្ទលេខ 023 880 474 និងទំនាក់ទំនងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥ រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ ឬពិនិត្យមើលបញ្ជីឈ្មោះក្រុមហ៊ុនដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh។

របាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្ហាញថា ពលករខ្មែរ ទៅធ្វើការនៅក្រៅប្រទេស គិតត្រឹមឆ្នាំ២០១៩ មានចំនួនសរុប ១,២៨៨,០០០នាក់។ ភាគច្រើន នៅប្រទេសថៃ។ ចំណែកកាលពីឆ្នាំ ២០១៨ មាន ១,២៣០,០០០នាក់។ កាលពីឆ្នាំ២០២០ ពលករចំណាកស្រុកកម្ពុជា មានចំនួនជាង ១,២លាននាក់។ ពលករខ្មែរ ដែលធ្វើការនៅក្រៅប្រទេស បានផ្ញើប្រាក់មកក្នុងប្រទេស ជិត ២,៨០០លានដុល្លារ ក្នុងមួយឆ្នាំ។ របាយការណ៍ បង្ហាញថា បច្ចុប្បន្ន កម្មករចំណាកស្រុករបស់កម្ពុជា ភាគច្រើន គឺធ្វើការនៅប្រទេសថៃ កូរ៉េខាងត្បូង ម៉ាឡេស៊ី សិង្ហបុរី និងប្រទេសជប៉ុន៕

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ទីភ្នាក់ងារជ្រើសរើសឯកជនដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅរដ្ឋកាតា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ទីភ្នាក់ងារជ្រើសរើសឯកជនដែលមានសិទ្ធិឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅរដ្ឋកាតា មានចំនួន ៣៧ ក្រុមហ៊ុន ដូចខាងក្រោម៖

| ល.រ No. | លេខបញ្ជី Registration Number | ឈ្មោះក្រុមហ៊ុន Company Name | ឆ្នាំចុះបញ្ជី Year of Registration | អាសយដ្ឋាន Address | លេខទូរស័ព្ទ Telephone |
|---|---|---|---|---|---|
| 1 | 003 | **ហ្វីលីម៉រ ខេមបូឌា**<br>PHILIMORE CAMBODIA CO., LTD | 2006 | អគារលេខ១៨G ផ្លូវដូងញាប២ ភូមិតោក ចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ<br>Building 18G, St. Doung Ngeab 2, Sangkat Chom Chao, Khan Posenchey, Phnom Penh | 023 6600 123 /012 601 123/ 012 601 123 |
| 2 | 004 | **ហ្យូមេន រីសស ឌីវេឡុបមេន**<br>HUMAN RESOURCE DEVELOPMENT CO., LTD. | 2006 | ផ្ទះលេខ ១៥៨០ ផ្លូវជាតិលេខ៥ ភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ភ្នំពេញ<br>No. 1580, National Road 5, Sangkat Russey Keo, Khan Russey Keo, Phnom Penh | 023 638 8377 /088 999 9744 /012 783 886 |
| 3 | 007 | **ថប ម៉េនផៅវ័រ**<br>TOP MANPOWER CO., LTD. | 2006 | ផ្ទះលេខ ៣-៤ អេ ផ្លូវ៤៤ស៊ីមសេ ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ភ្នំពេញ<br>No. 3-4A, St. 44, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 097 932 2322/ 012 922 322/ 081 990 077 |
| 4 | 008 | **ស៊ី ឌី អិម ត្រេឌីង ម៉េនផៅវ័រ**<br>CDM TRADING MANPOWER CO., LTD. | 2006 | ផ្ទះលេខ ២១៩ ផ្លូវលេខ ១៥០ សង្កាត់ទឹកល្អក់ ២ ខណ្ឌទួលគោក<br>No. 219, St. 150, Sangkat Tek Laak II, Khan Toul Kork, Phnom Penh | 023 630 3747/ 012 793 999/ 076 950 9999 |
| 5 | 011 | **អ៊ឹង រិទ្ធី គ្រុប**<br>UNG RITHY GROUP CO., LTD. | 2006 | លេខ ១៧៤ ផ្លូវលេខ ២១ BTZ ភូមិសន្សំកុសល១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ភ្នំពេញ<br>No. 174, St. 21BTZ, Sangkat Beung Tompun, Khan Meanchey, Phnom Penh | 012 365777/ 097 727 3007 / 012 686 996 |
| 6 | 025 | **អិន.អេ.អេស ម៉េនផៅវ័រ ខូ អិលធីឌី**<br>N.A.S MANPOWER CO., LTD. | 2010 | ផ្ទះលេខ ៥២ សេ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ ភ្នំពេញ<br>No. 52C, St. Betong, Sangkat DoungKor, Khan DoungKor, Phnom Penh | 092 555 587/ /088 217 9392 |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

| | | | | | |
|---|---|---|---|---|---|
| 7 | 026 | **អាយ អាយ អេស ខមភេនី**<br>I I S COMPANY LTD | 2010 | ផ្ទះលេខ ១៥ ផ្លូវជាតិលេខ ៥ ភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ភ្នំពេញ<br>No. 15, National Road No 5, Sangkat Russey Keo, Khan Russey Keo, Phnom Penh | 016 891 912 /077 855 552 088 755 5525 |
| 8 | 047 | **វីន-វីន ម៉េនផៅវ័រ សឺវីស**<br>WIN-WIN MANPOWER SERVICE CO., LTD | 2014 | លេខ ២៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ<br>No. 23, Rusian Federation Blvd, Sangkat Tek Thla, Khan Sen Sok, Phnom Penh | 096 7070 674 |
| 9 | 052 | **ហ្វមីស ម៉េនផៅវ័រ ខូអិលធីឌី**<br>FORMIS MANPOWER CO., LTD | 2014 | ផ្ទះលេខ ១៥៨០ ផ្លូវជាតិលេខ ៥ ភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ភ្នំពេញ<br>No. 1580, National Road No 5, Sangkat Russey Keo, Khan Russey Keo, Phnom Penh | 023 666 5222/ 088 700 7007 |
| 10 | 053 | **ឌ្រីម ម៉េនផៅវ័រ (ខេមបូឌា)**<br>DREAM MANPOWER (Cambodia) CO., LTD | 2014 | ផ្ទះលេខ៣១D ផ្លូវបេតុង ភូមិដំណាក់ធំ២ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>No. 31D, St.Betong, Domnakthom2 Village, Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 070 577 211 / 077 947 484 /086 797 993 |
| 11 | 056 | **សុខ លាភ មេត្រី**<br>SOK LEAP METREY CO., LTD | 2015 | ផ្ទះលេខ ៤៧ D ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ភ្នំពេញ<br>No. 47 D, St. 360, Sangkat Beung Kengkang I, Khan Chomkarmon, Phnom Penh | 015 301 111 |
| 12 | 065 | **ណាត់ ថាកណាន ម៉េនផៅវ័រ ឯ.ក**<br>NATH THAKNAN MANPOWER CO., LTD | 2016 | ផ្ទះលេខ០៨ ផ្លូវលំ ភូមិពន្លា សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ ភ្នំពេញ<br>No. 8, St. Lum, Sangkat Prek Pra, Khan Chhbar Ampov, Phnom Penh | 097 336 9999 / 012 533 912 |
| 13 | 073 | **អអឌី ម៉េនផៅវ័រ ឯ.ក**<br>RRD MANPOWER CO., LTD | 2017 | ផ្ទះលេខ១៤E០ ផ្លូវ១៤ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ភ្នំពេញ<br>Building 14 E0, St. 14, Sangkat Toul Sangke, Khan Russey Keo, Phnom Penh | 012 655 111 |
| 14 | 075 | **មាស សុវណ្ណ មាល្លិកេ ម៉េនផៅវ័រ ឯ.ក**<br>MEAS SOVANN MEALEAKE MANPOWER CO., LTD | 2017 | អគារលេខ៤៦៨ ផ្លូវលេខ១០១១ ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ<br>Building No. 468, St. 1011, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh | 092 231 111 /097 888 3888 |
| 15 | 076 | **យ៉ាគូស៊ីកៃ (ខេមបូឌា)ឯ.ក**<br>YAKUSHIKAI (CAMBODIA) CO., LTD | 2017 | អគារលេខ៤០ ផ្លូវ៣៦៣ សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ភ្នំពេញ<br>Building No. 40, St. 363, Sangkat Chhbar Ampov, Khan Chhbar Ampov, Phnom Penh | 096 367 6198 /089 885 001/ 088 681 7989 |
| 16 | 077 | **ស៊ី.អិល. សឹបផ្លាយ(ខេមបូឌា)ឯ.ក**<br>C.L SUPPLY (CAMBODIA) CO., LTD | 2017 | អគារលេខ C០១ ផ្លូវបេតុង ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ភ្នំពេញ<br>Building C01, St. Concrete, Sangkat Doung Kor, Khan Doung Kor, Phnom Penh | 023 648 0123 /088 424 9999 |
| 17 | 078 | **អេចអិន វើលដ៍ ខបភើរេសិន ឯ.ក**<br>HN WORLD CORPORATION CO.,LTD | 2017 | អគារលេខ១១ផ្លូវបេតុង(៣៥៧) ក្រុម១០ ភូមិដើមស្លែង១ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ<br>Building No.11, St. Concrete (357), Sangkat Chbar Ampov Ti Pir, Khan Chbar Ampov, Phnom Penh | 010 571 117/ 017571 117/ 069 237 858 |
| 18 | 084 | **ប៊ី.អេហ្វ.ជី សឺវិស ឯ.ក**<br>B.F.G SERVICE CO.,LTD | 2017 | អគារលេខ ៣C ផ្លូវលេខ៥១៤ ភូមិ១៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ភ្នំពេញ<br>Building No. 3 C, St. 514, Sangkat Beung Kok I, Khan Toul Kok, Phnom Penh | 086 995 202 /097 888 7543 /087 666 7709 |
| 19 | 085 | **អេកស្ពើត ម៉េនផៅវ័រសឹបផ្លាយ ឯ.ក**<br>EXPERT MANPOWER SUPPLY CO., LTD | 2017 | ផ្លូវលំ ភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ ភ្នំពេញ<br>St. Lum, Proka Village, Sangkat Prey Sor, Khan Daung Kor, Phnom Penh | 023 5217 999 /010 227 597/ 097 670 7777 |
| 20 | 086 | **ប៊ី.ភី ម៉េនផៅវ័រ(ខេមបូឌា) ឯ.ក**<br>B.P MANPOWER (CAMBODIA) CO.,LTD. | 2017 | អគារលេខ៥២ ផ្លូវ០៧ ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ<br>Building No. 52, St.07, Roung Chak Village,Sangkat Kouk Khleang, Khan Sen sok, Phnom Penh | 096 828 8888 088 999 9024 |

| | | | | | |
|---|---|---|---|---|---|
| 21 | 087 | **គ្រេន អ៊ីហ្គល (ខេមបូឌា) លេប័រ ឯ.ក**<br>GRAND EAGLE (CAMBODIA) LABOR CO., LTD. | 2017 | អគារលេខ២១៨ ផ្លូវលេខ១៩ ភូមិប្រកា សង្កាត់ព្រៃស ខណ្ឌដង្កោ ភ្នំពេញ<br>Building 218, St. 19, Proka Village, Sangkat Prey Sor, Khan Daung Kor, Phnom Penh | 088 888 9920/<br>096 222 2013 |
| 22 | 088 | **4 ថាយហ្គើរ លេប័រ សីបផ្លាយ ឯ.ក**<br>4 TIGERS LABOUR SUPPLY CO.,LTD. | 2018 | អគារលេខ ៧៤ ផ្លូវលេខ១៥ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ<br>Building 74, St. 15, Sangkat Chom Chao, Khan Posen Chey, Phnom Penh | 017 900 400/<br>097 8888429 |
| 23 | 089 | **មេត្រី អេចអ ឯ.ក**<br>METREY HR CO.,LTD. | 2018 | អគារលេខ៩០ ផ្លូវលេខ១៩ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ<br>Building 90, St. 19, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh | 085 888 535<br>/098 400 745/<br>017 743 954 |
| 24 | 090 | **ជេ ខេប រ៉ិក្រូតមិន ឯ.ក**<br>J CAB RECRUITMENT CO., LTD. | 2018 | អគារ៣៤ ផ្លូវលេខ៣៣៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក ភ្នំពេញ<br>Building 34, St. 335, Sangkat Beung Kok II, Khan Toul Kok, Phnom Penh | 096 9555 556<br>/092 913 133 |
| 25 | 091 | **មហាចក្រ ឌីវេឡុបមិន ឯ.ក**<br>MAHACHAK DEVELOPMENT CO.,LTD. | 2018 | អគារលេខ ៦៣១ ផ្លូវបេតុង ភូមិត្រពាំងល្ពៅ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ<br>Building 631, St. Concrete, Sangkat Kakab, Khan Posen Chey, Phnom Penh | 012 508 988<br>/010 508 988/<br>088 888 8456 |
| 26 | 095 | **វី.អិល.អឹម យូមេន រីសសស៍ ឯ.ក**<br>V.LM. HUMAN RESOUCES CO.,LTD. | 2018 | អគារលេខ C០១ ផ្លូវបេតុង ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>Building C01, St. Concrete, Sangkat Doung Kor, Khan Doung Kor, Phnom Penh | 088 424 9999 |
| 27 | 097 | **ស៊ី.ខនេច វើលដ៍ ឯ.**<br>C.CONNECT WORLD CO.,LTD | 2018 | អគារលេខ២៦ ផ្លូវលេខ០១ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ<br>Buillding 26 St. 01 Sangkat, Sangkat Chom Chao, Khan Posen Chey, Phnom Penh | 070 464 911 |
| 28 | 099 | **ខ្មែរ លេប៊ើរ សីបផ្លាយ ឯក.**<br>KHMER LABOUR SUPPLY CO.,LTD | 2018 | អគារលេខ១៩៣ ផ្លូវទី១ ក្រុមទី៦ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ<br>Building193, St.01,Sangkat Steung Meanchey2, Khan Meanchey, Phnom Penh | 081 424 446/<br>097 228 4444 |
| 29 | 103 | **តាហុក សឺវីស ឯក.**<br>TAHOK SERVICES CO., LTD | 2018 | អគារលេខ A-១៣៥ ផ្លូវMaha A ភូមិវិមានទ្រង់ សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ<br>Building A-135 St.Maha A,Sangkat Kreang Thnong, Khan Sen Sok, Phnom Penh | 092 789 151/<br>096 7500 600 |
| 30 | 107 | **មង្គល អេចអរ ឯក.**<br>MONGKOL HR CO., LTD | 2018 | អគារលេខ៤៦៩AB ផ្លូវលំលេខ៧១ ភូមិព្រែកតាល់ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>Building 469AB St.71 ,Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 087 3333 25 |
| 31 | 108 | **អ៊ែតវ៉ានស៍ ម៉ែនផៅវ័រ សឺវីស ឯក.**<br>ADVANCE MANPOWER SERVICE CO.,LTD. | 2018 | អគារលេខ ៣០៦E០ (បុរីពិភពថ្មីចំការដូង) ផ្លូវលេខ៧ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ<br>Building306, St.7, Sangkat DoungKor, Khan DoungKor, Phnom Penh | 096 297 7777 |
| 32 | 109 | **5 លីឌើ ប៊េនណីហ្វិត សឺវីស ឯក.**<br>5 LEADERS BENEFITS SERVICE CO.,LTD | 2018 | អគារលេខ០៥M ផ្លូវបេតុង ភូមិបឹងសាឡាង សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ<br>Building 05M, St. Concrete, Boeung salang Village ,Sangkat Russey Keo, Khan Russey, Phnom Penh | 078 301 111/<br>096 950 4444 |
| 33 | 112 | **ព្រីមៀម ម៉ែនផៅវ័រ សឺវីស ឯក.**<br>PREMIUM MANPOWER SERVICES CO.,LTD | 2019 | អគារលេខ៧៥,៧៧E០E1 ផ្លូវលេខ០២ ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ<br>Building 75,77E0E1, St.02, Sangkat DoungKor, Khan DoungKor, Phnom Penh | 097 7272189<br>/096 5656 808 |

| | | | | | |
|---|---|---|---|---|---|
| 34 | 114 | **សុភ័ក្ត្រ មេត្រី ឯ.ក**<br>SOPHEAK METREY CO.,LTD | 2019 | អគារលេខ១០អ៊ី ភូមិព្រាព សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ<br>Building 10E ,Sangkat Steung Meanchey, Khan Meanchey, Phnom Penh | 096 828 8888/<br>097 555 5563/<br>069 666 653 |
| 35 | 116 | **សម្បសាទ ឯ.ក**<br>SAMPASAT CO.,LTD | 2019 | អគារលេខ៧៨A ផ្លូវលេខ១៣៥ ភូមិ៨ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>Building78A, St. 135, Sangkat toul Tompong I, Khan Chomkarmorn, Phnom Penh | 095 312 524/<br>015 570 670/<br>010 828 174 |
| 36 | 117 | **រ៉ូយ៉ាល់ មេនផៅវ័រ (ខេមបូឌា) ឯ.ក**<br>ROYAL MANPOWER (CAMBODIA) CO.,LTD | 2019 | អគារលេខ៩៨ អាអឺo ផ្លូវលេខ២៣ ភូមិប្រកា សង្កាត់ព្រៃសរ ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>Building 98AEo St. 23, Proka Village, Sangkat Prey Sor, Khan Daung Kor, Phnom Penh | 097 999 9849/<br>099 888 588/<br>010 797 178 |
| 37 | 120 | **ធី អេស មេនផៅវ័រ (ខេមបូឌា) ឯ.ក**<br>T S MANPOWER (CAMBODIA) CO.,LTD | 2019 | អគារគ្មានលេខ ផ្លូវលេខ៦០ ភូមិលិចវត្ត សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ<br>Building ......., St.60,Lech Wat Village, Sangkat Kamboul, Khan Kamboul, Phnom Penh | 096 666 4519<br>077 796 694 |

រាល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងឡាយណាដែលពុំមានឈ្មោះក្នុងបញ្ជីខាងលើនេះទេ គឺចាត់ទុកថាជាទីភ្នាក់ងារជ្រើសរើសឯកជនខុសច្បាប់ ដូច្នេះសូមសាធារណជនរាយការណ៍ជាបន្ទាន់ មកទូរស័ព្ទលេខ ០២៣ ៨៨០ ៤៧៤ និងទំនាក់ទំនងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥ រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ ឬពិនិត្យមើលបញ្ជីឈ្មោះក្រុមហ៊ុនដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh ។

ដើម្បីជៀសវាងការផ្សព្វផ្សាយព័ត៌មានខុស ដែលអាចនាំឱ្យប្រជាពលរដ្ឋរងគ្រោះ ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងការជ្រើសរើស ឬផ្តល់សេវាកការងារឱ្យធ្វើដល់ពលករខ្មែរនៅតាមបណ្តាសារព័ត៌មានណាមួយ ជាពិសេសតាមបណ្តាស្ថានីយ៍វិទ្យុត្រូវមានលិខិតអនុញ្ញាតចេញដោយអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមុន ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន អង្គភាពពាក់ព័ន្ធ បណ្តាសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន និងសហការអនុវត្ត ។

ថ្ងៃសុក្រ ៦កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០២២

## ថ្ងៃទី១១ ខែ មេសា ឆ្នាំ២០២២

## ពលករខ្មែរចំណាកស្រុកបន្តសម្រុកមកពីប្រទេសថៃដើម្បីមកចូលឆ្នាំថ្មីនៅស្រុកកំណើត

https://www.khmertimeskh.com/ Khmer Times April 7, 2022

ពលករចំណាកស្រុកខ្មែរជាង ៤០០នាក់ និងសមាជិកគ្រួសាររបស់ពួកគេបានឆ្លងកាត់ព្រំដែនខ្មែរ-ថៃ នៅស្រុកសំពៅលូន ដើម្បីចូលរួមពិធីបុណ្យចូលឆ្នាំខ្មែរដែលនឹងមកដល់នៅសប្តាហ៍ក្រោយជាមួយក្រុមគ្រួសារនៅស្រុកកំណើតរៀងៗខ្លួន។ កងកម្លាំងការពារតាមបណ្តោយព្រំដែនកម្ពុជា-ថៃ កាលពីម្សិលមិញបានទទួលអ្នកទាំងនេះត្រឡប់មកកម្ពុជាវិញតាមភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ក្នុងនោះមានកុមារចំនួន ៥៤នាក់ និងកុមារី ២២នាក់។ ការធ្វើតេស្តនៅមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ទទួលបានលទ្ធផលអវិជ្ជមាន ហើយកំណត់ត្រាចាក់ថ្នាំទាំងអស់ក៏ត្រូវបានស្កេនយ៉ាងម៉ត់ចត់ផងដែរ។

ជារៀងរាល់ឆ្នាំ ចាប់ពីខែមីនា និងដើមខែមេសា មានពលករចំណាកស្រុកខុសច្បាប់ និងស្របច្បាប់រាប់រយនាក់ បានឆ្លងកាត់ព្រំដែន។ ពួកគេចេញពីប្រទេសថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកផ្សេងទៀតដើម្បីធ្វើដំណើរទៅកាន់ស្រុកកំណើត។ ពលករចូលប្រទេសកម្ពុជា ត្រូវបានត្រួតពិនិត្យយ៉ាងតឹងរ៉ឹងដោយក្រុមការងារចម្រុះដែលមានវេជ្ជបណ្ឌិត មកពីក្រសួងសុខាភិបាល និងអាជ្ញាធរពាក់ព័ន្ធ។ សម្រាប់អ្នកដែលបានរកឃើញថាមានលទ្ធផលអវិជ្ជមានពីការធ្វើតេស្តរហ័ស ប៉ុន្តែមិនបានទាន់បានចាក់វ៉ាក់សាំង ពួកគេត្រូវចាក់វ៉ាក់សាំងមុនពេលត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## អាជ្ញាធរថៃ បញ្ជូនពលរដ្ឋខ្មែរ
## ចំនួន ៤៥៥នាក់ ត្រឡប់ចូលប្រទេសកម្ពុជាវិញ តាមច្រកស្រុកកំរៀង

https://cen.com.kh/ Posted ByPen Srey NeatApril 7, 2022

បាត់ដំបង ៖ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន ស្រាវជ្រាវរកមុខសញ្ញាមេខ្យល់ នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលប្រជាពលរដ្ឋត្រឡប់ចូលប្រទេសកម្ពុជាវិញតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ ប្រជាពលរដ្ឋចំនួន ៤៥៥នាក់ ស្រី ១៨៦នាក់ ក្មេង ៥៤នាក់ ក្មេងស្រី ៣២នាក់ ត្រូវបានសមត្ថកិច្ចសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួច ក្រុមគ្រូពេទ្យធ្វើតេស្តរហ័ស ជាលទ្ធផល ៖

-អវិជ្ជមានកូវីដ-១៩ ទាំងអស់

-ដោយឡែកពលករចំនួន ១២នាក់ ស្រី ៣នាក់ កុមារ ១នាក់ បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ខេត្តបាត់ដំបង។

-ពលករដែលមានកាតចាក់វ៉ាក់សាំងត្រឹមត្រូវ ចំនួន ៤៤៣នាក់ ស្រី ១៨៣នាក់ ក្មេង ៥៤នាក់ ក្មេងស្រី ៣១នាក់។

ក្នុងនោះបានចាក់វ៉ាក់សាំងឲ្យក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំ ចំនួន ២១នាក់ ស្រី ១៣នាក់ ក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## ពលរដ្ឋ និងពលករខ្មែរជាង ១៤ម៉ឺននាក់ វិលត្រឡប់មកកម្ពុជាវិញ អំឡុងពេលបិទខ្ទប់ព្រំដែន ឆ្នាំ២០២១

https://dap-news.com/ ByKD102Posted on April 7, 2022

**ភ្នំពេញ៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានឲ្យដឹងថា ប្រជាពលរដ្ឋ និងពលករទេសន្តរប្រវេសន៍ខ្មែរ ចំនួន ១៤០.៦៦៤នាក់ ក្នុងនោះស្ត្រី ៦២.២៩៤នាក់ បានវិលត្រឡប់មកកម្ពុជាវិញ ក្នុងអំឡុងពេលបិទខ្ទប់ព្រំដែន កាលពីឆ្នាំ២០២១។

ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់ គ.ជ.ប.ជ នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ លោកស្រី ជូ ប៊ុនអេង បានថ្លែងថា «ការវិលត្រឡប់របស់ប្រជាពលរដ្ឋ និងពលករទេសន្តរប្រវេសន៍ ដោយគំហុកជាង១៣ម៉ឺននាក់ ក្នុងឆ្នាំ២០២០ និង ១៤០,៦៦៤នាក់ ស្ត្រី៦២.១៨៤នាក់ ក្នុងឆ្នាំ២០២១ ក្នុងអំឡុងមានការបិទខ្ទប់ព្រំដែន ប្រទេសជិតខាង»។ លោកស្រីបន្តថា ឆ្នាំ២០២១ បានបង្កើនការចំណាយទៅលើវិស័យសង្គមកិច្ច ដើម្បីសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋពីវិបត្តិ ដែលបង្កដោយគ្រោះមហន្តរាយផ្សេងៗ ជាពិសេស ដើម្បីទប់ស្កាត់រាតត្បាត រួមមាន៖ ការអប់រំផ្សព្វផ្សាយ ការគាំទ្រជីវភាពប្រជាពលរដ្ឋក្រីក្រ កម្មករកម្មការិនីដែលបាត់បង់ការងារ ស្ត្រីមានផ្ទៃពោះ សម្រាលកូន និងកូនតូចក្រោមអាយុ ២ឆ្នាំ ការឧបត្ថម្ភ និងផ្គត់ផ្គង់គ្រួសារប្រជាពលរដ្ឋក្នុងតំបន់បិទខ្ទប់ គាំទ្រ និងឧបត្ថម្ភគ្រួសារ ដែលមានអ្នកឆ្លង ឬមានអ្នកស្លាប់ដោយកូវីដ-១៩ ជាដើម។ លើសពីនេះ រដ្ឋលេខាធិការ ក៏បានលើកឡើងទៀតថា ក្នុងឆ្នាំ២០២១ សមត្ថកិច្ចបានបង្ក្រាបករណីជួញ ដូរមនុស្សចំនួន ២៣៥ករណី ក្នុងនោះ បានបញ្ជូនទៅតុលាការចំនួន ៤០០នាក់ សរុបជនរងគ្រោះដែលសង្គ្រោះបានចំនួន១,៣៩០នាក់។ ដោយឡែក ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ បង្ក្រាបបានចំនួន១២៤ករណី (៨៦ករណី ជាករណីរួមភេទជាមួយអនីតិជន) ក្នុងនោះបានបញ្ជូនទៅតុលាការ ចំនួន១៣៨នាក់ សរុបជនរងគ្រោះដែលសង្គ្រោះបាន ចំនួន១៨៧នាក់៕

## ១ថ្ងៃខាងថៃបញ្ជូនពលករខ្មែរ៤៥០នាក់មកស្រុកកំណើតចូលឆ្នាំ

https://kohsantepheapdaily.com.kh/ បាត់ដំបង០៧ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១០:៣២

ខេត្តបាត់ដំបង៖ ពលករខ្មែរក្មេង ចាស់ ប្រុស ស្រី ប្រមាណ៤៥០នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនត្រឡប់មកស្រុកកំណើតវិញក្នុងរយៈពេលត្រឹមតែមួយថ្ងៃ ដោយគិតចាប់ពីវេលាម៉ោង៧ព្រឹក រហូតដល់ម៉ោង៤រសៀលថ្ងៃទី០៦ មេសា តាមច្រករបៀងប៉ុស្តិ៍អង់តែន ស្ថិតក្នុងភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ។ មន្ត្រីនគរបាលការពារព្រំដែនបានឲ្យដឹងថា ពលករខ្មែរទាំងនោះ មិនមានកាន់លិខិតឆ្លងដែនស្របច្បាប់ទេ។ ពួកគេភាពច្រើនជាកម្លាំងពលករឆ្លងដែនលួចលាក់តាមរយៈមេខ្យល់ ទៅស៊ីឈ្នួលកាប់អំពៅក្នុងទឹកដីនៃប្រទេសថៃ។ បើតាមការសាកសួរ ពួកគេភាគច្រើនបានឆ្លងដែនទៅធ្វើការនៅទឹកដីថៃ តាំងពីអំឡុងខែធ្នូ ឆ្នាំ២០២១ ហើយពេលនេះអស់ការងារធ្វើ ទើបពួកគេវិលត្រឡប់មកស្រុកកំណើតវិញ ស្របពេលឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ជិតចូលមកដល់។

ប៉ុន្តែយ៉ាងណាក្តី បើតាមសមត្ថកិច្ចបានប្រាប់ថា ពលករខ្មែរទាំងនេះ ភាគច្រើនសុទ្ធតែមានប័ណ្ណចាក់វ៉ាក់សាំង តែមានក្មេងតូចៗខ្លះមិនទាន់បានចាក់វ៉ាក់សាំងកូវីដ១៩ដែរ ។ ក្រុមគ្រូពេទ្យបានប្រឹងប្រែងយ៉ាងមមារញឹកក្នុងការត្រួតពិនិត្យ និងធ្វើតេស្តលើពលករខ្មែរក្មេង ចាស់ ប្រុសស្រី ទាំងនោះ ក្រែងពួកគេមានវិជ្ជមានមេរោគកូវីដ ១៩។ ប៉ុន្តែបើតាមយោងលើការធ្វើតេស្តរហ័សទៅលើក្រុមពលករទាំងនោះ គឺអវិជ្ជមានទាំងអស់។ មន្ត្រីព្រំដែនបានផ្តល់ព័ត៌មានបឋមថា ក្រោយពីក្រុមគ្រូពេទ្យពិនិត្យធ្វើតេស្តកូវីដរួច អាជ្ញាធរបានអនុញ្ញាតឲ្យពួកគេវិលត្រឡប់ទៅកាន់ស្រុកកំណើតរៀងៗខ្លួនហើយ៕

## ពលករវិលមកពីថៃ
## តាមច្រកខេត្តឧត្តរមានជ័យ កើនឡើងដល់ខ្ទង់ពាន់ក្នុងមួយថ្ងៃ រកឃើញកូវីដ-១៩តិចតួច

https://btv.com.kh/ 04/07/2022 05:04 PM

ឧត្តរមានជ័យ៖ ខណៈថ្ងៃចូលឆ្នាំថ្មីខិតជិតមកដល់កាន់តែមានកំណើនពលករខ្មែរវិលមកពីថៃ ដល់ខ្ទង់ពាន់នាក់ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ក្នុងមួយថ្ងៃៗ តែរកឃើញករណីវិជ្ជមានកូវីដ-១៩ តែពីរបីករណីប៉ុណ្ណោះ។ ប្រភពពីមន្ត្រីច្រកព្រំដែនអូរស្មាច់បានឱ្យដឹងថា ចាប់តាំងពីចុងខែមីនា រហូតមកដល់ពេលនេះ រំហូរពលករខ្មែរវិលមកពីប្រទេសថៃ មានចំនួនច្រើនជារៀងរាល់ថ្ងៃ ចាប់ពីចំនួន៥០០នាក់ រហូតដល់ប្រមាណ១ពាន់នាក់ បច្ចុប្បន្នេះ តែមានអ្នកវិជ្ជមានកូវីដ-១៩តិចតួចទេ ដោយសារតែពលករទាំងនោះ បានទទួលការចាក់វ៉ាក់សាំងគ្រប់ដូស។

មន្ត្រីច្រកព្រំដែន បានឱ្យដឹងទៀតថា បើទោះជាមិនមានករណីវិជ្ជមានកូវីដ-១៩ច្រើនក្តី តែវិធាន ការទប់ស្កាត់ការនាំចូលជំងឺកូវីដ-១៩ នៅតាមច្រកព្រំដែន នៅតែត្រូវបានរឹតបន្តឹង។ ចំណែកការឆ្លងក្នុងសហគមន៍ខេត្តឧត្តរមានជ័យវិញ បើតាមការឱ្យដឹងពីមន្ត្រីសុខាភិបាល គឺមានការធ្លាក់ចុះដែរ ដោយសាតែប្រជាពលរដ្ឋ បានទទួលការចាក់វ៉ាក់សាំង ស្ទើរតែ១០០ភាគរយ។ ប៉ុន្តែទោះបី ជាដូច្នេះក្តី មន្ត្រីសុខាភិបាល សហការជាមួយអាជ្ញាធរមូលដ្ឋាន បន្តផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ ឱ្យបន្តអនុវត្តវិធានសុខាភិបាល និងវិធានបីកុំ បីការពារ ពិសេសត្រូវទៅទទួលការចាក់វ៉ាក់សាំងឱ្យបានគ្រប់ដូស ដើម្បីបង្កើនភាពស៊ាំក្នុងសហគមន៍៕អត្ថបទ៖ ឃិន សារិទ្ធ

## ថៃគ្រោងនាំពលករខ្មែរចូលជិត ៤ម៉ឺននាក់ ដើម្បីសម្រាលការខ្វះខាតកំលាំងពលកម្ម

https://www.khmertimeskh.com/ Khmer Times April 8, 2022

ប្រទេសថៃបានត្រៀមខ្លួនរួចជាស្រេចក្នុងការអនុញ្ញាតឱ្យពលករចំណាកស្រុកកម្ពុជា ជិត៤០,០០០នាក់ពីប្រទេសកម្ពុជា និង១២ម៉ឺននាក់ទៀតពីប្រទេសជិតខាងពីរផ្សេងទៀត។

លោក Pairoj Chotikasathien អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ មានប្រសាសន៍ថា ក្រសួងការងារគ្រោងដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្ម បន្ទាប់ពីមនុស្សជាច្រើនព្រួយបារម្ភថា ជនអន្តោប្រវេសន៍ខុសច្បាប់នឹងធ្វើអោយមានការឆ្លងរីករាលដាលជំងឺកូវីដ-១៩។ ពួកគេក៏បានចោទសួរពីដំណើរការនាំចូលពលករបរទេស។ ក្រសួងគ្រោងដោះស្រាយបញ្ហានេះតាមវិធីចំនួនពីរ៖

១៖ បើកប្រទេសដល់ពលករបរទេសចំនួន ១៦៧,៩៦១ នាក់ មកពីប្រទេសចំនួន៣ ក្រោមអនុស្សារណៈយោគយល់គ្នា (MoU) ។ និយោជកកំពុងស្វែងរកពលករចំណាកស្រុកខ្មែរចំនួន ៣៨,៩៣៣ នាក់ ពលករមីយ៉ាន់ម៉ា ចំនួន១១៧,០២៩ នាក់ និងឡាវចំនួន ១១,៩៩៩ នាក់។ ចំនួនជាក់លាក់នៃពលករចំនួន ១៤៤,៧០៩ នាក់

ត្រូវបានផ្តល់ការអនុញ្ញាត ដោយមានពលករកម្ពុជា និងឡាវប្រមាណ ៦,០០០ នាក់ ត្រូវបានកំណត់ឱ្យធ្វើការក្រោម MoU ។

២៖ ប្រទេសថៃទំនងជាផ្តល់លិខិតអនុញ្ញាតការងារដល់ពលករមីយ៉ាន់ម៉ា ឡាវ និងកម្ពុជាចំនួន ២,១៣២,៤៦៩ នាក់ ដូច្នេះពួកគេអាចបន្តនៅក្នុងប្រទេសបាន។ ចំពោះការបង្កើតចំណុចសេវាច្រកចេញចូលតែមួយក្នុងប្រទេសរបស់ពួកគេ វាជាចំណាត់ការដែលមិនអាចធ្វើបាននៅពេលនេះ។ លោក Pairoj បានស្នើឱ្យនិយោជកដែលចង់ជួលពលករខុសច្បាប់ត្រូវគិតពីសុវត្ថិភាពសុខភាព និងហានិភ័យពីកូវីដ-១៩ ជាមុនសិន។ លោកស្នើពួកគេកុំឲ្យជួលពលករបែបនេះ ព្រោះមន្ទីរនឹងនាំចូលពួកស្របច្បាប់ក្រោម MoU៕

## សង្គមស៊ីវិលស្នើដល់រដ្ឋាភិបាលទប់ស្កាត់ករណីជួញដូរមនុស្សឱ្យមានប្រសិទ្ធភាព

https://www.rfa.org/khmer/ ដោយ ឡេង ម៉ាលី 2022-04-07

មន្ត្រីអង្គការសង្គមស៊ីវិលលើកឡើងថា ករណីជួញដូរមនុស្សនៅតែជាក្តីកង្វល់សម្រាប់ពលរដ្ឋ ជាពិសេសចំពោះស្ត្រី ដែលប្រឈមនឹងបោកបញ្ឆោតលោមលួង ពីក្រុមចាប់ជំរិតយកទៅកន្លែងធ្វើអាជីវកម្មជួញដូរផ្លូវភេទ។ តិកម្មនេះ ធ្វើឡើងក្រោយពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបង្ហាញថា ករណីការជួញដូរផ្លូវភេទលើអនីតិជនក្រោម ១៨ឆ្នាំនៅវងការគំរាមកំហែងច្រើននៅកម្ពុជា។ អង្គការសង្គមស៊ីវិលផ្នែកសិទ្ធិមនុស្សសង្កេតឃើញថា ករណីជួញដូរមនុស្សនៅកម្ពុជាមិនទាន់មានភាពធូរស្រាលនៅឡើយ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។

នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការសិទ្ធិមនុស្សលីកាដូ (LICADO) លោក អំ សំអាត ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី៧ មេសាថា ករណីជួញដូរមនុស្សនៅតែមានសន្ទុះខ្លាំង ជាពិសេស ការកេងប្រវ័ញ្ចលោភបំពានផ្លូវភេទ និងប្រើអំពើហិង្សាលើអនីតិជនជាស្ត្រីអាយុក្រោម ១៨ឆ្នាំ។ លោកមើលឃើញថា អាជ្ញាធរហាក់មិនបានយកចិត្តទុកដាក់ក្នុងការទប់ស្កាត់បទល្មើសជួញដូរមនុស្សឱ្យមានប្រសិទ្ធនៅឡើយ ទើបធ្វើឱ្យកម្ពុជានៅតែជាប់ចំណាត់ថ្នាក់ក្នុងការតាមដានពីករណីជួញដូរផ្លូវភេទលើអនីតិជនជាស្ត្រី៖ *«ជាពិសេស អំពើហិង្សាបៀតបៀន ជួញដូរផ្លូវភេទជាដើម។ យើងបារម្ភចំពោះអនីតិជនជាស្ត្រីត្រូវបានកើតឡើងខ្ពស់។ ដូច្នេះករណីនេះ ទាមទារឱ្យរដ្ឋាភិបាលបង្កើនការបង្ក្រាប ទប់ស្កាត់ ចំពោះករណីការជួញដូរមនុស្ស ការជួញដូរផ្លូវភេទ ជាពិសេស ទៅលើកុមារីអាយុក្រោម ១៨ឆ្នាំ»*។

ប្រតិកម្មរបស់មន្ត្រីសង្គមស៊ីវិលរូបនេះ ធ្វើឡើងក្រោយពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង ថ្លែងក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាលពីឆ្នាំ២០២១ នៅថ្ងៃទី៧មេសា ថាករណីជួញដូរមនុស្សនៅតែមានច្រើនគួរឱ្យកត់សម្គាល់។ លោក ស ខេង ព្រួយបារម្ភថាករណីជួញដូរមនុស្សនេះបន្តកើតមានឡើងក្នុងបរិបទការរីករាលដាលកូវីដ-១៩ និងអំពាវនាវឱ្យអាជ្ញាធរកុំឱ្យមានការធ្វេសប្រហែសនឹងក្រុមឧក្រិដ្ឋជនជួញដូរមនុស្ស៖ *«ពួកឧក្រិដ្ឋជន ដែលយកមុខរបរទុច្ចរិតគឺ ការជួញដូរមនុស្សនេះ គេមិនបានបោះបង់ចោល ឬបង្អង់ដៃក្នុងការជួញដូរមនុស្សនោះទេ។ ប្រហែលជាគេអាចងាយស្រួលឆកឱកាសថែមទៀតក្នុងពេលដែលយើងកំពុង ជាប់ដៃដោះស្រាយបញ្ហាវិបត្តិគ្រោះធម្មជាតិ វិបត្តិអសន្តិសុខ បញ្ហាជម្លោះផ្សេងៗ វិបត្តិសុខភាពសាធារណៈ។ គេចាត់ទុកថា ជាឱកាសដ៏ល្អសម្រាប់គេ ដើម្បីគេធ្វើសកម្មភាពជួញដូរមនុស្សនេះ»*។

របាយការណ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបង្ហាញថា កាលពីឆ្នាំ២០២១កន្លងទៅ សមត្ថកិច្ចបានបង្ក្រាបករណីជួញដូរមនុស្សចំនួន ២៣៥ករណី ហើយសមត្ថកិច្ចបានបញ្ជូនជនល្មើសចំនួន ៤០០នាក់ ទៅតុលាការ។ ចំណែកឯជនរងគ្រោះមានចំនួន ១.៣៩០នាក់ ក្នុងនោះមានស្ត្រី ៥៩៥នាក់ ដែល

បានសង្គ្រោះពីករណីជួញដូរមនុស្សនេះ។ ចំពោះករណីអាជីវកម្មពេស្យាចារវិញ អាជ្ញាធរបង្ក្រាបបានចំនួន ១២៤ករណី ក្នុងនោះ ៨៦ករណីជាអនីតិជនបានរងការរំលោភបំពានបៀតបៀនផ្លូវភេទ។

អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សអ្នកស្រី ជូ ប៊ុនអេង ថ្លែងក្នុងពិធីផ្សព្វផ្សាយរបាយការណ៍នេះថា មូលហេតុដែលនាំឱ្យករណីជួញដូរមនុស្សនៅតែបន្តកើតមានឡើង គឺដោយសារសង្គមវិលទៅរកភាពក្រីក្រដោយជំងឺកូវីដ-១៩ ទើបធ្វើឱ្យក្រុមជនល្មើស ដែលមានបណ្តាញនៅតាមបណ្តាប្រទេសផ្សេងៗ បានប្តូរទិសដៅកេងប្រវ័ញ្ច និងជួញដូរនៅកម្ពុជា។

ទោះជាយ៉ាងណា លោក អំ សំអាត មើលឃើញថា ករណីជួញដូរមនុស្សនៅតែជាបញ្ហាប្រឈមមិនមានការទប់ស្កាត់ឱ្យបានប្រសិទ្ធភាពនៅឡើយទេ។ លើសពីនេះ លោកមើលឃើញថា ករណីចាប់បង្ខាំងមនុស្ស ធ្វើទារុណកម្មជំរិតទារប្រាក់ របស់ក្រុមឧក្រិដ្ឋជនបរទេសដែលភាគច្រើនជាជនជាតិចិនក៏បានកើតឡើងច្រើនក្នុងរយៈពេលចុងក្រោយនេះដែរ។

កាលពីដើម ខែមីនា ក្រុមអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិបានចេញសេចក្តីថ្លែងការណ៍រួមគ្នាមួយ ដោយពួកគេព្រួយបារម្ភជាខ្លាំងចំពោះការកើនឡើងនៃការជួញដូរមនុស្សការចាប់បង្ខំឱ្យធ្វើពលកម្ម អំពើទាសភាព និងទារុណកម្ម នៅតាមបរិវេណអគារនានានៅកម្ពុជា។ ពួកគេក៏បានបញ្ជាក់ថា ការរំលោភបំពានពាក់ព័ន្ធនឹងជនបរទេស ដែលត្រូវបានចាប់ជំរិត លក់ ជួញដូរ ឬត្រូវបោកបញ្ឆោត ឱ្យទទួលការងារនៅក្នុងខេត្តមួយចំនួន រួមមានខេត្តព្រះសីហនុ ភ្នំពេញ ពោធិ៍សាត់ កោះកុងជាដើម។ ជនរងគ្រោះដែលបានរត់គេចខ្លួនរួច បានរាយការណ៍ថា ពួកគេត្រូវបានធ្វើបាបទាំងរាងកាយ ផ្លូវចិត្ត រងអំពើហិង្សាពីសំណាក់ក្រុមដែលបង្ខាំងពួកគេ។

ទាក់ទងនឹងបញ្ហាជួញដូរមនុស្សនេះ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលលោក ហ៊ុន សែន ឱ្យគោរពតាមនីតិវិធីស៊ើបអង្កេតដ៏ត្រឹមត្រូវមួយ និងដោយយកចិត្តទុកដាក់ ហើយត្រូវចាប់ជនល្មើស ដែលជួញដូរមនុស្សនិងជួញដូរផ្លូវភេទទៅផ្តន្ទាទោសឱ្យបានតឹងរ៉ឹងបំផុត។ លើសពីនេះកម្ពុជា ត្រូវពង្រឹងបេសកកម្មការទូតជាមួយប្រទេសពាក់ព័ន្ធនានា ដើម្បីជួយជនរងគ្រោះជនរងគ្រោះកម្ពុជានៅបរទេសរួមទាំងប្រទេសគ្មានតំណាងអង្គទូតកម្ពុជាជាដើម។ ក្រៅពីនេះ រដ្ឋាភិបាលកម្ពុជាត្រូវ ប្រឹងប្រែងត្រួតពិនិត្យភ្នាក់ងារជ្រើសរើសពលករឯកជន និងឈ្មួញកណ្តាល ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ឬគ្មានអាជ្ញាប័ណ្ណសម្រាប់ជ្រើសរើសយកទៅធ្វើការនៅក្រៅប្រទេស ដើម្បីជៀសវាងការក្លែងបន្លំនិងការជួញដូរផ្សេងៗ ទៀត៕

## នាល្ងាចថ្ងៃព្រហស្បតិ៍ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ គ្រប់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/04/08/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នាល្ងាចថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៤នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរ

សេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២លើក សរុបចំនួន២៨នាក់ ស្រី១១២នាក់ ក្មេង៩នាក់ ក្មេងស្រី៤នាក់ ។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺអវិជ្ជមាន និងមានប័ណ្ណចាក់វ៉ាក់សាំងស្តែនចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ពលករមកពីថៃ ចូលតាមខេត្តបន្ទាយមានជ័យកើនឡើង ខណៈបុណ្យចូលឆ្នាំខិតជិតមកដល់

https://btv.com.kh/ 04/08/2022 12:04 PM

បន្ទាយមានជ័យ៖ ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ កាន់តែគៀកជិតឈានមកដល់ ពលករខ្មែរដែលធ្វើការនៅប្រទេសថៃ បានត្រឡប់មកស្រុកកំណើតវិញ តាមច្រកខេត្តបន្ទាយមានជ័យ ក្រោមការអនុវត្តវិធានបន្តឹងត្រួតពិនិត្យវិធានការសុខាភិបាល។

ថ្លែងប្រាប់BTV នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានឲ្យដឹងថា ពលករខ្មែរដែលត្រឡប់មកពីប្រទេសថៃ តាមច្រកខេត្តបន្ទាយមានជ័យ បានកើនឡើងតាំងពីសប្តាហ៍ចុងក្រោយខែមីនា ហើយបន្តកើនឡើងក្នុងសប្តាហ៍ដំបូងខែមេសា ដោយក្នុងមួយថ្ងៃមានចំនួនយ៉ាងហោចណាស់ប្រមាណ១ពាន់។ ឯកឧត្តម បន្តថា ក្នុងចំណោមនោះ បានឆ្លងដែនតាមច្រកចំនួន៤ រួមមាន ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ច្រកបឹងត្រកួន ស្រុកថ្មពួក ច្រកបឹងបេង ស្រុកម៉ាឡៃ និងច្រកអូរបីជាន់ ស្រុកអូរជ្រៅ ខណៈច្រកដែលមានពលករឆ្លងដែនច្រើនជាងគេមានច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកអូរបីជាន់។

ឯកឧត្តម បញ្ជាក់ថា ទោះបីមានការកើនឡើងនៃចំនួនពលករមកពីថៃ ប៉ុន្តែក្រុមការងារជំនាញដែលឈរជើងតាមបណ្តាព្រំដែនបន្តអនុវត្តវិធានការសុខាភិបាលម៉ឺងម៉ាត់ ពោលគឺអ្នកមិនទាន់បានចាក់វ៉ាក់សាំងដូសមូលដ្ឋាន ឬយ៉ាងហោចណាស់ចំនួនដូសនោះនឹងត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ក។ ឯកឧត្តម បន្តថា រាល់ការឆ្លងដែនរបស់ពលករទាំងអស់តម្រូវឲ្យធ្វើតេស្តសម្រាប់អ្នកដែលមានអាការៈមិនស្រួលខ្លួន ហើយអ្នកបានចាក់វ៉ាក់សាំង ដូសទី២រួចរាល់ អនុញ្ញាត ឲ្យត្រឡប់ទៅផ្ទះ និងអ្នកមិនទាន់ចាក់ត្រូវធ្វើចត្តាឡីស័កគ្រប់ចំនួនថ្ងៃ ដែលកំណត់ បន្ទាប់ពីបញ្ចប់ការធ្វើចត្តាឡីស័ក បានរៀបចំចាក់វ៉ាក់សាំងជូនពួកគេ។ ឯកឧត្តម អ៊ុំ រាត្រី បន្ថែមថា ដើម្បីឆ្លើយតបចំពោះបញ្ហាកំណើនពលករ រដ្ឋបាលខេត្តបន្ទាយមានជ័យ បានបន្តឲ្យកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីជំនាញឈរជើងជាប់ជាប្រចាំរង់ចាំទទួលពលករមកពីថៃ និងបានរៀបចំទីតាំងធ្វើចត្តាឡីស័ក និងព្យាបាល សំដៅជានាឲ្យបានពីការរីករាលមេរោគកូវីដ១៩ក្នុងសហគមន៍ ខណៈប្រទេសថៃនៅថ្ងៃទី៨ ខែមេសានេះ បានរកឃើញករណីឆ្លងចំនួនជាង ២ ម៉ឺនករណី និងស្លាប់៨៩នាក់៕ អត្ថបទ សេក ឧត្តម

# ថ្ងៃទី១២ ខែ មេសា ឆ្នាំ២០២២

## សកម្មភាពបង្ក្រាបករណីជួញដូរមនុស្សនិងបញ្ជូនទៅតុលាការ។ រូបភាពផ្តល់ឲ្យ

https://www.khmertimeskh.com/ ទិត្យ គង់នៅ / Khmer Times April 8, 2022

កាលពីឆ្នាំមុន រដ្ឋាភិបាលបានបង្ក្រាបករណីជួញដូរមនុស្សជាង ២០០ករណី ដោយមានមនុស្ស ៤០០នាក់បញ្ជូនទៅតុលាការដើម្បីកាត់ទោស។ ជនរងគ្រោះជិត ១៤០០ នាក់ត្រូវបានជួយសង្គ្រោះ ដែលក្នុងនោះមានស្ត្រីប្រហែល ៦០០ នាក់។

ក្នុងកិច្ចប្រជុំប្រចាំឆ្នាំដែលរៀបចំដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (NCCT) កាលពីម្សិលមិញ បានរាយការណ៍ពីការងាររបស់ខ្លួនលើការទប់ស្កាត់ការជួញដូរមនុស្សកាលពីឆ្នាំមុន និងកំណត់គោលដៅប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនៅឆ្នាំនេះ អនុប្រធានអចិន្ត្រៃយ៍NCCT លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា នៅឆ្នាំ២០២១ មាន២៣៥ករណី ឧក្រិដ្ឋកម្មជួញដូរមនុស្សក្នុងនោះចាប់ខ្លួនមនុស្ស៤០០នាក់ត្រូវបញ្ជូនទៅតុលាការ។ យ៉ាងហោចណាស់ជនរងគ្រោះ ១៣៩០ ត្រូវបានជួយសង្គ្រោះ។ លោកស្រីថា៖ «ករណីកេងប្រវ័ញ្ចផ្លូវភេទខុសច្បាប់មានចំនួន ១២៤ ករណី ក្នុងនោះមាន ៨៦ ករណីនៃការរួមភេទជាមួយអនីតិជន។ ចំពោះឧក្រិដ្ឋកម្មបែបនេះ មនុស្ស១៣៨នាក់ត្រូវបានបញ្ជូនទៅតុលាការ ហើយជនរងគ្រោះ១៨៧នាក់ត្រូវបានសង្គ្រោះ» ។

បើតាមលោកស្រី នៅពេលដែលកម្ពុជាមានជំងឺរាតត្បាតកូវិត១៩ប្រទេសនេះបានក្លាយជាជម្រកសុវត្ថិភាពសម្រាប់ឧក្រិដ្ឋជនមកពីប្រទេសផ្សេងៗចូលមកប្រព្រឹត្តឧក្រិដ្ឋកម្មជួញដូរមនុស្សជាមួយជនរងគ្រោះមកពីប្រទេសផ្សេងៗ។ លោកស្រី បន្ថែមថា «វាជាទម្រង់ថ្មីនៃការជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជា កំពុងសហការជាមួយអាជ្ញាធរបរទេស ដើម្បីបង្ក្រាបជនល្មើស និងជួយសង្គ្រោះជនរងគ្រោះ ដោយបញ្ជូនពួកគេត្រឡប់ទៅប្រទេសកំណើតវិញដោយសុវត្ថិភាព»។ លោកស្រីបានកត់សម្គាល់ថា ដើម្បីជួយទប់ស្កាត់ឧក្រិដ្ឋកម្មនេះនៅពេលអនាគតគណៈកម្មាធិការបានរៀបចំសិក្ខាសាលា និងកិច្ចប្រជុំដើម្បីអប់រំមនុស្សជាង ៦,៥លាននាក់អំពីឧក្រិដ្ឋកម្មនេះ និងវិធីជៀសវាងការធ្លាក់ចូលទៅក្នុងអន្ទាក់ជួញដូរ។

គេប៉ាន់ប្រមាណថា មានជនជាតិថៃចន្លោះពី ៣០០០ ទៅ ៤០០០ នាក់ កំពុងធ្វើការដោយខុសច្បាប់នៅកម្ពុជា។ អ្នកដែលរៀបចំធ្វើមាតុភូមិនិវត្តន៍នឹងត្រូវចាត់ថាជាជនរងគ្រោះនៃការជួញដូរមនុស្ស។ ពួកគេក៏អាចប្រឈមមុខនឹងវិធានការផ្លូវច្បាប់ក្នុងប្រទេសរបស់ពួកគេចំពោះការបំពានច្បាប់អន្តោប្រវេសន៍ដោយការចាកចេញពីប្រទេសរបស់ពួកគេដោយខុសច្បាប់។ *ប្រែសម្រួលដោយ៖ សុ ជាតា*

## អភិបាលខេត្តៈ

## ពលករជាង ១ពាន់នាក់ មួយថ្ងៃ ត្រឡប់ពីថៃចូលកម្ពុជា តាមច្រកខេត្តឧត្តរមានជ័យ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៨ មេសា ២០២២ដោយ Sophal Tuon

រយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ មានពលករខ្មែរជាង ១ពាន់នាក់ ក្នុងមួយថ្ងៃ វិលត្រឡប់ពីថៃចូលស្រុកវិញ គោលបំណងចូលរួមពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ។ នេះបើតាមការបញ្ជាក់របស់លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ។ ថ្លែងប្រាប់កម្ពុជាថ្មី នៅរសៀលថ្ងៃទី ០៨ ខែ មេសា លោក ប៉ែន កុសល្យ បានឱ្យដឹងថា ពលករភាគច្រើនចូលតាមច្រកអូរស្មាច់ ដោយគិតត្រឹមព្រឹកថ្ងៃនេះ មានចំនួនខ្ទង់ ៦០០នាក់ហើយ។ លោកបញ្ជាក់ថា ភាគច្រើននៃពលករត្រឡប់ចូលកម្ពុជានេះ គឺដើម្បីចូលរួមអបអរពិធីបុណ្យចូលឆ្នាំខ្មែរ។ លោកអភិបាលខេត្ត គូសបញ្ជាក់ទៀតថា អាជ្ញាធរសម្របសម្រួលនីតិវិធីដល់ពលករ ដោយមិនឱ្យមានការលំបាកអ្វីឡើយ ហើយក៏មិនមានការយកប្រាក់ពីពលករនោះដែរ។ លើសពីនេះទៀត អាជ្ញាធរក៏ធ្វើតេស្តពលករមុនអនុញ្ញាតឱ្យចូលផងដែរ។

លោក ប៉ែន កុសល្យ ថ្លែងដូច្នេះថា «យើងពិនិត្យមើលពួកគាត់ បើគាត់មានកាតវ៉ាក់សាំងពីរឬបីដូស ហើយពុំមានអាការៈឈឺក្បាលវិលមុខអីទេ គឺឱ្យគាត់ទៅផ្ទះតែម្ដង...តែបើពួកគាត់មានអាការៈមិនស្រួលយើងធ្វើតេស្តរហ័សភ្លាម»។ បើតាមលោក ប៉ែន កុសល្យ ក្នុងមួយថ្ងៃ អាជ្ញាធររកឃើញពលករម្នាក់ ឬពីរនាក់ ដែលមានវិជ្ជមានកូវីដ-១៩។ អ្នកដែលរកឃើញវិជ្ជមាន គឺត្រូវចូលមណ្ឌលសម្រាកព្យាបាល ជាទើបអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះបាន៕

អត្ថបទ៖ ទូន សុផល

## ពលករជាង ៨០០ នាក់ បានវិលពីថៃតាមស្រុកចំនួន ២ ខណៈថ្ងៃចូលឆ្នាំជិតចូលមកដល់

https://www.postkhmer.com/ គឹម សារុំ | Publication date 08 April 2022 | 10:37 ICT

**បាត់ដំបង:** ពលករប្រុសស្រី និងកូនៗរបស់ពួកគេចំនួន ៨៦៥ នាក់បានវិលត្រឡប់មកពីថៃវិញ តាមស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបងពីថ្ងៃទី ៦ មេសា ខណៈថ្ងៃចូលឆ្នាំថ្មីជិតចូលមកដល់ ក្នុងនោះមានពលករ ១២ នាក់ត្រូវបានគ្រូពេទ្យបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។ នេះបើតាមសមត្ថកិច្ចទទួលពលករនៃស្រុកទាំង ២។

លោក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ ប្រចាំការនៅតាមបន្ទាត់ព្រំដែននៅចំណុចតំបន់អូរអន្លក់ ក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង បានឱ្យដឹងនៅថ្ងៃទី ៧ មេសាថា ពលករប្រុសស្រីចំនួន ៤៥៥ នាក់ (ស្រី ១៨៦ នាក់ និងក្មេង ៥៤ នាក់) កាលពីថ្ងៃទី ៦ មេសាបានឆ្លងដែនពីថៃចូលមកចំណុចប៉ុស្តិ៍អូរអន្លក់ក្នុងភូមិអូរអន្លក។ ដំណើរវិលមកវិញរបស់ពួកគាត់នេះ មិនមែនពួកគាត់ប្រព្រឹត្តបទល្មើសហើយត្រូវបានទាហានថៃចាប់បញ្ជូនមកទេ តែពួកគាត់មកស្របច្បាប់។ ក្នុងចំនួនពលករទាំង ៤៥៥ នាក់ ដែលចូលតាមស្រុកកំរៀងគឺមានតែ ១២ នាក់ប៉ុណ្ណោះដែលខាងជំនាញពេទ្យបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ដោយសារអាចមកពីចាក់វ៉ាក់សាំងមិនទាន់គ្រប់ដូស។ លោកបន្តថា៖ «ឃើញពលករខ្មែរយើងសម្រុកមកច្រើនមុនបុណ្យចូលឆ្នាំខ្មែរយើង។ ខ្ញុំសួរពួកគាត់ ហើយប្រាប់ថា ពួកគាត់មកលេងស្រុកពេលបុណ្យចូលឆ្នាំខ្មែរខាងមុខ។ ម្យ៉ាងនៅថៃមិនសូវសម្បូរការងារធ្វើផង ម្យ៉ាងគាត់នៅថៃយូរឆ្នាំផង»។ បើតាមលោក ម៉ង់ ស៊ី ចំនួនពលករទៅធ្វើការនៅប្រទេសថៃ ហើយវិលមកតាមប៉ុស្តិ៍អូរន្លក់ គឺពួកគាត់ឆ្លងដែនមកជាបន្តបន្ទាប់ ជារៀងរាល់ថ្ងៃ តែមានចំនួនមិនដល់ ៥០ នាក់ទេ ក្នុង ១ ថ្ងៃៗ។ ប៉ុន្តែនៅពេលជិតដល់ថ្ងៃចូលឆ្នាំខ្មែរ ទើបពលករនាំគ្នាសម្រុកឆ្លងដែនមកស្រុកកំណើតច្រើនដែលមានរហូតដល់រាប់រយនាក់ឯណោះ។ ពាក់ព័ន្ធនឹងវិធានការការពារ និងការយល់ដឹងពីជំងឺកូវីដវិញលោកថាតាមការសង្កេត បងប្អូនពលករខ្មែរមានការយល់ដឹងច្រើនហើយពួកគាត់ម្នាក់ៗក៏ហាក់ដូចជាមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការពារមេរោគកូវីដនេះដែរ។ លោកប្រាប់ថា៖ «ជាគោលការណ៍របស់លោកអភិបាលខេត្ត និងលោកឧត្តមសេនីយ៍ទោស្នងការខេត្តបាត់ដំបងគឺយើងបានជួយសម្រួលដល់បងប្អូនពលករយើងមិនមានបញ្ហាអីទេ»។

ដោយឡែកលោក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ បានឱ្យដឹងនៅថ្ងៃទី ៧ មេសាថា កម្លាំងរបស់លោកដែលមានគ្រូពេទ្យរួមជាមួយកម្លាំងនគរបាលប៉ុស្តិ៍គីឡូ ១៣ ក្នុងភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូនបានទទួលពលករប្រុសស្រីចំនួន ៤១០ នាក់ (ស្រី ១៤៨ នាក់ ក្មេង ៥៤ នាក់ ក្មេងស្រី ២២ នាក់) កាលពីថ្ងៃទី ៦ ខែមេសា ។ ទន្ទឹមនឹងនេះ ទាំងកម្លាំងសមត្ថកិច្ចរបស់លោកទាំងគ្រូពេទ្យក៏បានណែនាំពន្យល់អប់រំដល់ពលករទាំងនោះឱ្យយល់ពីបញ្ហាឆ្លងនៃជំងឺកូវីដ និងវិធីការពារខ្លួនផងដែរ។ លោកថ្លែងថា៖ «ពលករខ្មែរយើងប្រុស និងក្មេងៗជាកូនរបស់ពួកគាត់ទាំងនោះមិនមានជំងឺកូវីដទេ ហើយភាគច្រើនពួកគាត់បានចាក់វ៉ាក់សាំងកូវីដរួចអស់ហើយ»៕

## ប្រទេសថៃអះអាងថាមិនមានដំណើរឆ្ពោះ
## ទៅមុខក្នុងការបង្កើតមជ្ឈមណ្ឌលជ្រើសរើសពលករតាមសេវាកម្មតែមួយនៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times April 9, 2022

ពាក្យស្នើសុំការងារនៅក្នុងប្រទេសថៃ ត្រូវបានអនុម័តសម្រាប់ពលករចំណាកស្រុកជាង ១៤០,០០០ នាក់ តាមរយៈអនុស្សរណៈ នៃការយោគយល់គ្នា (MoU) ដែលបានចុះហត្ថលេខាជាមួយប្រទេសជិតខាងចំនួនបី នេះបើយោងតាមនាយកដ្ឋានការងារ ។

អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ លោក Pairoj Chotikasathien បាននិយាយកាលពីថ្ងៃព្រហស្បតិ៍ថា និយោជកបានដាក់ពាក្យសុំជាមួយនាយកដ្ឋានដើម្បីនាំយកពលករចំណាកស្រុកចំនួន ១៦៧,៩៦១ នាក់ មកពីប្រទេសមីយ៉ាន់ម៉ា ឡាវ និងកម្ពុជា ។ លោក Pairoj បាននិយាយថា មិនទាន់មានដំណើរឆ្ពោះទៅមុខក្នុងការបង្កើតមជ្ឈមណ្ឌលជ្រើសរើសពលករតាមសេវាតែមួយកន្លែងនៅក្នុងប្រទេសកម្ពុជា និងប្រទេសចំនួនពីរផ្សេងទៀតនោះទេ។ រហូតមកដល់ពេលនេះ ជនចំណាកស្រុកខ្មែរ និងឡាវជាង ១០,០០០នាក់ បានមកដល់តាមរយៈទិដ្ឋាការការងារផ្អែកលើ MoU។ ទោះយ៉ាងណាក៏ដោយ មានពលករតិចជាងមុនបានមកពីប្រទេសមីយ៉ាន់ម៉ា ដោយសារភាពចលាចលនយោបាយដែលកំពុងបន្តក្នុងប្រទេស។ ក្នុងចំណោមពួកគេ ពលករចំនួន ១១៧,០២៩ នាក់ កំពុងត្រូវបានស្វែងរកពីប្រទេសមីយ៉ាន់ម៉ាចំនួន៣៨,៩៣៣ ពីប្រទេសកម្ពុជា និងតុល្យភាពពីប្រទេសឡាវ។ ក្នុងចំណោមពាក្យសុំដែលបានដាក់រហូតមកដល់ពេលនេះ ចំនួន ១៤៤,៧០៩ ត្រូវបានយល់ព្រម។

លោក Pairoj បាននិយាយថា ការនាំចូលកម្លាំងពលកម្មតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការទ្វេភាគី ហើយឧបសគ្គមួយចំនួនគឺហួសពីអំណាចរបស់ប្រទេសថៃក្នុងការដោះស្រាយ។ លោកបាននិយាយថា នាយកដ្ឋានបានរៀបចំប្រព័ន្ធប្រសិទ្ធភាពនៃការនាំចូលកម្លាំងពលកម្ម ដើម្បីដោះស្រាយបញ្ហាកង្វះខាត ក៏ដូចជាកាត់បន្ថយឱកាសនៃការឆ្លងជំងឺកូវីដ-១៩ ក្នុងចំណោមពលករផងដែរ។ សម្រាប់ពលករចំណាកស្រុកចំនួន ២.១ លាននាក់បច្ចុប្បន្ននៅក្នុងព្រះរាជាណាចក្រ ពួកគេត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំបន្តការងាររបស់ពួកគេដោយមិនចាំបាច់ធ្វើដំណើរត្រឡប់ទៅប្រទេសរបស់ពួកគេវិញដើម្បីដាក់ពាក្យឡើងវិញទេ។ លោក Pairoj បាននិយាយថា ពលករចំណាកស្រុកដែលបច្ចុប្បន្ននៅក្នុងប្រទេស និងអ្នកដែលចង់ចូលមកតាមរយៈ MoU គួរតែធានាបាននូវការផ្គត់ផ្គង់ក្នុងស្រុកគ្រប់គ្រាន់នៃកម្លាំងពលកម្មចំណាកស្រុកយ៉ាងហោចណាស់រហូតដល់ដើមឆ្នាំក្រោយ នេះបើយោងតាមលោក Pairoj ។ តម្រូវការការងារកំពុងកើនឡើងជាលំដាប់ ខណៈដែលសកម្មភាពសេដ្ឋកិច្ចកំពុងត្រូវបានស្តារឡើងវិញបន្ទាប់ពីជាប់គាំងជាងពីរឆ្នាំដោយសារជំងឺរាតត្បាត។ ទោះយ៉ាងណាក៏ដោយ លោក Pairoj បាននិយាយថា មិនទាន់មានដំណើរឆ្ពោះទៅមុខក្នុងការបង្កើតមជ្ឈមណ្ឌលជ្រើសរើសពលករតាមសេវាកម្មតែមួយនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឡាវ និងកម្ពុជា។ លោកបានព្រមាននិយោជកកុំឲ្យជួលពលករខុសច្បាប់ ដើម្បីបញ្ចៀសហានិភ័យនៃការឆ្លងមេរោគកូវីដ-១៩ទ្រង់ទ្រាយធំ។

## កម្លាំងសមត្ថកិច្ចឃាត់ខ្លួនប្រជាពលរដ្ឋវិលពីប្រទេសថៃចូលមកកម្ពុជា ប្រុសស្រីចំនួន១៦នាក់

http://nokorwatnews.com/ 10/04/2022

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងចម្រុះឈរជើងតាមខ្សែបន្ទាត់ព្រំដែន បានឃាត់ខ្លួនពលករខ្មែរវិលពីប្រទេសថៃចូលកម្ពុជារយៈពេលពីរថ្ងៃបាន១៦នាក់ ដោយគិតចាប់ពីម៉ោង១៦និង៣០នាទី រសៀលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២នេះ មកដល់វេលាម៉ោង ០៦និង១៥នាទី ព្រឹកថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២២ នេះ។ សមត្ថកិច្ចប្រាប់ថា: ប្រជាពលរដ្ឋវិលត្រឡប់ប្រទេសថៃ (លើកទី២)កាលពីវេលាម៉ោង ១៨និង៣០នាទី ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ

២០២២នេះប្រជាពលរដ្ឋខ្មែរចំនួន ០៥នាក់ (ស្រី០២នាក់ កុមារ០១នាក់) វិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាតាមភូមិសាស្រ្តប៉ុស្តិ៍សង្កែ (ចំណុចក្រោយស្តង់) ពួកគាត់មានទីលំនៅក្នុងខេត្តចំនួន ០២គឺៈ
១. បាត់ដំបង ០៣នាក់
២.កំពង់ឆ្នាំង ០២នាក់

សមត្ថកិច្ចបញ្ជាក់ថា ពលរដ្ឋទាំងនោះក្រោយពីធ្វើការណែនាំស្តីពីការឆ្លងរាលដាលរបស់ Virus Covid-19 រួច កម្លាំងប៉ុស្តិ៍សង្កែចំនួន ០៣នាក់ ដឹកនាំដោយលោក ឡុក ធី នាយប៉ុស្តិ៍ សហការជាមួយកម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំបឹងបេង កម្លាំងកងពល៥១ បានប្រគល់ពួកគាត់ជូនក្រុមគ្រូពេទ្យពិនិត្យ ធ្វើតេស្តរកមេរោគកូវីដ-១៩ ។ សមត្ថកិច្ចបន្តថាៈមកដល់ម៉ោង ៦និង១៥នាទីថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០២២នេះមានប្រជាពលរដ្ឋចំនួន ១១នាក់ ក្នុងនោះស្រី០៣នាក់ កុមារ០៣នាក់ វិលត្រឡប់ពីប្រទេសថៃ តាមភូមិសាស្រ្តប៉ុស្តិ៍ស្ពានម៉ាឡៃ (ចំណុចគោលដៅអូរថ្មៃ) ពួកគាត់មានទីលំនៅក្នុងខេត្ត បន្ទាយមានជ័យ បន្ទាប់ពីធ្វើការណែនាំស្តីពីការឆ្លងរាលដាលរបស់ Virus Covid-19 រួចកម្លាំងប៉ុស្តិ៍ស្ពានម៉ាឡៃចំនួន ០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ថៃ ប៊ុនរ៉ុង នាយរងប៉ុស្តិ៍ សហការជាមួយកម្លាំងយោធា (វរៈ៥១៣) បានប្រគល់ពួកគាត់ជូនក្រុមគ្រូពេទ្យពិនិត្យ ធ្វើតេស្តរកមេរោគកូវីដ-១៩ ផងដែរ៕

## យោធាថៃឃាត់ខ្លួនពលករខ្មែរ៥គោលដៅផ្សេងគ្នាលួចឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 10/04/2022

ប្រទេសថៃ៖ សេចក្តីរាយការណ៍ពីសមត្ថកិច្ចតាមបន្ទាត់ព្រំដែនកាលពីថ្ងៃទី៨ មេសា ២០២២នេះថា កម្លាំងការពារព្រំដែនខេត្តស្រះកែវ កងកម្លាំងបូរផា បង្កើនការរឹតបន្តឹងបញ្ហាការលួចចូលប្រទេសដោយខុសច្បាប់ និងការនាំទំនិញខុសច្បាប់គ្រប់ប្រភេទចេញ-ចូលបរិវេណបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដោយកម្លាំងទាហានប្រាណទី១២០៣ សហការជាមួយកម្លាំងទាហានអង្គភាពទី១១១ បានល្បាតនិងឃ្លាំមើលក្នុងភូមិសាស្រ្តទទួលខុសត្រូវ ប្រទះឃើញមនុស្សគួរឲ្យសង្ស័យ ដើរតាមច្រករបៀងសំដៅមកប្រទេសថៃ បរិវេណភូមិមើនសំបូរណ៍ ឃុំស្រុកតាព្រះយ៉ា ខេត្តស្រះកែវចំនួន១២នាក់ ក្នុងនោះប្រុស២ ស្រី៥ ក្មេងប្រុស២នាក់ និងក្មេងស្រី៣នាក់ ទើបសមត្ថកិច្ចចូលទៅត្រួតពិនិត្យជំហ៊ានដំបូង មិនឃើញមានឯកសារធ្វើដំណើរ និងស្នាក់នៅក្នុងប្រទេសថៃ។

សេចក្តីរាយការណ៍ថាក្រោយពីសមត្ថកិច្ចថៃសួរនាំ ពួកគេបានសារភាពថា ធ្វើដំណើរមកពីខេត្តសៀមរាប ដើម្បីទៅធ្វើការនៅក្នុងស្រុកតាព្រះយ៉ា ខេត្តស្រះកែវ មិនមានមេខ្យល់នាំផ្លូវ ទើបសមត្ថកិច្ចថៃឃុំខ្លួនបណ្តេញឲ្យត្រឡប់ទៅប្រទេសវិញ។ ក្រោយមកទៀត កម្លាំងសមត្ថកិច្ចថៃខាងលើ នៅបានចាប់ឃុំពលករខ្មែរ៤នាក់ទៀតក្នុងនោះប្រុសម្នាក់និងស្រី៣នាក់ ដែលដើរចូលមកប្រទេសថៃតាមច្រករបៀងក្នុងភូមិទ័ពសៀម ឃុំស្រុកតាព្រះយ៉ា ខេត្តស្រះកែវ ដោយពួកគេខាងលើធ្វើដំណើរមកពីស្រុក វ៉ាត់ថៈណា ណៈខន ខេត្តស្រះកែវ ត្រូវការធ្វើដំណើរត្រឡប់ទៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ ខណៈដូចគ្នានេះដែរ កម្លាំងទាហានប្រាណកងរយទី១២០២ កងកម្លាំងបូរផាបានចុះល្បាតក្នុងភូមិសាស្រ្តទទួលខុសត្រូវ ក៏បានចាប់ឃុំជនជាតិខ្មែរ កំពុងធ្វើដំណើរតាមច្រករបៀងសំដៅចូលមកប្រទេសថៃ ត្រង់បរិវេណភូមិ មើនសំបូរណ៍ ឃុំស្រុកតាព្រះយ៉ា ខេត្តស្រះកែវចំនួន៩នាក់ ក្នុងនោះប្រុស៥ ស្រី៣ និងក្មេងស្រីម្នាក់ បន្ទាប់ពីសមត្ថកិច្ចថៃសួរនាំជំហ៊ានដំបូង បានឲ្យដឹងថា មានភូមិលំនៅស្រុកពួក ខេត្តសៀមរាប ចង់ធ្វើដំណើរទៅធ្វើការសំណង់នៅក្រុងបាងកក។

សេចក្តីរាយការណ៍ខាងលើបញ្ជាក់ថាបន្ទាប់មកទៀតសមត្ថកិច្ចថៃបានចាប់ឃុំពលករខ្មែរចំនួន៦នាក់បន្ថែមទៀត ក្នុងនោះប្រុស៤និងស្រី២នាក់ដើរចូលមកប្រទេសថៃតាមច្រករបៀង ក្នុងភូមិណង យ៉ាកែវ ឃុំស្រុកគោកឃ្យូង ខេត្តស្រះកែវ។យ៉ាងណាក៏ដោយ សមត្ថកិច្ចថៃបន្តចាប់ឃុំពលករខ្មែរបានបន្ថែម៧នាក់ទៀត ដែលដើរចូល

ប្រទេសថៃតាមច្រករបៀង បរិវេណព្រៃល្បាសព្រំប្រទល់រវាងភូមិកែវពេជ្រផ្លូយ-មើន សំបូរណ៍ ឃុំ/ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ នៅពេលសមត្ថកិច្ចថៃសួរនាំបានឲ្យដឹងថា ពលករខ្មែរ ចង់ធ្វើដំណើរទៅធ្វើការនៅខេត្តរះយ៉ង,ឈុនបូរី ក្រោយសួរចម្លើយក៏បានបញ្ជូនទៅឲ្យជំនាញស្រុកតាព្រះយ៉ា ដើម្បីចាត់ការតាមនីតិវិធីបន្ត៕

## អាជ្ញាធរថៃ បញ្ជូនពលករខ្មែរ ២៨ នាក់ដែលឆ្លងដែនខុសច្បាប់មកកម្ពុជាវិញ

https://www.postkhmer.com/ វី សុបាន់ | Publication date 09 April 2022 | 17:09 ICT

**បាត់ដំបង:** អាជ្ញាធរថៃ នៅថ្ងៃទី៧ ខែមេសា បានចាប់បញ្ជូនពលករចំណាកស្រុកខ្មែរ ចំនួន ២៨នាក់ ក្នុងនោះ កុមារ ៩នាក់ ដែលឆ្លងដែនខុសច្បាប់ចូលទឹកដីថៃមកកាន់កម្ពុជាវិញ នៅស្រុកសំពៅលូន។ នេះបើយោងតាមរបាយការណ៍នគរបាលជាតិ។

គេហទំព័រអគ្គស្នងការដ្ឋាននគរបាលជាតិបញ្ជាក់នាថ្ងៃទី៨ ខែមីនា ថា៖ «[កម្លាំងប៉ុស្តិ៍គីឡូ ១៣ ខេត្តបាត់ដំបង] បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន ២លើក សរុបចំនួន ២៨នាក់»។ បើតាមប្រភពដដែល ពលករកម្ពុជាចំនួនទាំង ២៨ នាក់ ត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់ទៅលំនៅឋានរៀងៗខ្លួន បន្ទាប់ពី ក្រុមគ្រូពេទ្យបានធ្វើតេស្តរកមេរោគកូវីដ១៩ ហើយឃើញថា លទ្ធផលអវិជ្ជមាន និងបានពិនិត្យប័ណ្ណចាក់វ៉ាក់សាំងកូវីដ១៩ បានត្រឹមត្រូវ៕

## ពលករបន្តចាកចេញពីថៃ កើនជាង ៨០០ នាក់ ខណៈមកចូលឆ្នាំខ្មែរ នៅស្រុកកំណើត

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ១០ មេសា ២០២២ដោយ Sorn Phanith

មន្ត្រីនគរបាលបានបញ្ជាក់ប្រាប់ឲ្យដឹងថា រយៈពេលបីថ្ងៃចាប់ពីថ្ងៃទី ០៦ ដល់ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០២២ នេះ អាជ្ញាធរមានសមត្ថកិច្ចព្រមទាំងមន្ត្រីជំនាញ បានសហការជាមួយភាគីទាហានថៃ ទទួលពលករខ្មែរប្រុសស្រីរួមទាំងក្មេងៗផងដែរ មានចំនួនកើនដល់ ៨៥៩ នាក់ ក្នុងនោះពលករបុរស ៤៣២ នាក់ស្រី ៣៤៣ នាក់ និងក្មេង១៨៤ នាក់ ដែលធ្វើដំណើរឆ្លងដែនទៅជាមួយឪពុកម្តាយ។ នគរបាលជំនាញបានឲ្យដឹងបន្តថា ដោយសារលំហូរពលករបន្តចាកចេញពីកន្លែងធ្វើការងារប្រទេសថៃ មានចំនួនកើនឡើងជាលំដាប់នេះ អាជ្ញាធរ និងសមត្ថកិច្ចកម្ពុជាថៃ បានឯកភាពគ្នាបើកច្រកទ្វារចំនួនពីរដើម្បីទទួលពលករ គឺទីមួយច្រកទ្វាអន្តរជាតិដូងក្នុងស្រុកកំរៀង និងទីពីរបើតនៅក្នុងភូមិសាស្ត្រច្រកតំបន់ក្នុងភូមិពោធិជ្រៃ ស្រុកសំពៅលូនខេត្តបាត់ដំបង ដើម្បីសម្រួល និងបង្កលក្ខណៈដល់ពលករខ្មែរទាំងអស់ងាយស្រួលចាកចេញក្នុងការវិលត្រឡប់មកស្រុកកំណើតវិញ។

ការបើកទទួលជាផ្លូវការ ឲ្យពលករត្រឡប់វិលមកចូលរួមក្នុងពិធីចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅតាមលំនៅឋានរៀងៗខ្លួននេះ ក្រុមគ្រូពេទ្យបានពិនិត្យធ្វើតេស្តរកជំងឺកូវីដ១៩ ជាលទ្ធផលអវិជ្ជមានទាំងអស់ ប៉ុន្តែយោងទៅលើការពិនិត្យកាតផ្តល់វ៉ាក់សាំងពលករភាគច្រើនសុទ្ធសឹងបានចាក់វ៉ាក់សាំងរួចរាល់ ត្រូវបានអប់រំណែនាំហើយឲ្យវិលត្រឡប់ទៅកាន់ផ្ទះរៀងៗខ្លួនដោយឡែកចំពោះពលករដែលភាគតិចមិនបានចាក់វ៉ាក់សាំង ឬបានចាក់ហើយតែមិនគ្រប់ដូសត្រូវគ្រូពេទ្យបញ្ជូនទៅធ្វើចត្តាឡីស័កអនុវត្តតាមវិធានការការពាររបស់ក្រសួងសុខាភិបាល៕**សៅ សារិទ្ធ**

## ពលករខ្មែរនៅថៃ
## សម្រុកនាំគ្នាឆ្លងដែនមកស្រុកកំណើតវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

https://news.btv.com.kh/ 04/10/2022 12:04 PM

កោះកុង៖ ពលករខ្មែរដែលបម្រើការងារនៅប្រទេសថៃ កំពុងសម្រុកនាំគ្នាឆ្លងដែនចូលមកប្រទេសកម្ពុជា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ដែលឈានមកដល់នាពេលខាងមុខ។ មន្ត្រីប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានឱ្យដឹងនៅនាទីថ្ងៃទី១០ ខែមេសានេះថា លំហូពលករខ្មែរឆ្លងដែនមកតាមច្រកទ្វារព្រំដែនចាំយាម ខេត្តកោះកុង ផ្តើមតាំងពីដើមខែមេសា ឆ្នាំ២០២២មកម្ល៉េះ។ ដោយទទួលពលករខ្មែរមិនទៀងទាត់ពេលក្នុង១ថ្ងៃបើច្រើន ២០ទៅ៣០នាក់ប៉ុណ្ណោះ។ មន្ត្រីនៅច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បន្ថែមថា ភាគច្រើនពលករខ្មែរដែលឆ្លងដែនមក ពួកគេធ្វើការនៅខេត្តត្រាត។ គោលបំណងឆ្លងដែនមកតាមច្រកទ្វារព្រំដែនចាំយាម របស់ក្រុមពលករ ដើម្បីចូលអបអរសាទរពិធីបុណ្យចូលឆ្នាំខ្មែរ ប្រពៃណីជាតិ ខាងមុខនេះ ហើយពលករខ្លះមានស្រុកកំណើត នៅខេត្តកំពត ព្រៃវែង តាកែវ កែប និងខេត្តស្វាយរៀង។

ចំណែកនគរបាលអន្តោប្រវេសន៍ និងមន្ត្រីសុខាភិបាលផ្នែកចត្តាឡីស័ក លើកឡើងថា មុននឹងអនុញ្ញាតឱ្យពលករខ្មែរយើងបន្តដំណើរទៅស្រុកកំណើត គឺតម្រូវឱ្យវាស់កម្តៅ ពិនិត្យកាតចាក់វ៉ាក់សាំង ឯកសារពាក់ព័ន្ធផ្សេងទៀត។ ករណីពលករខ្មែរណាពុំមានកាតចាក់វ៉ាក់សាំងនឹងបញ្ជូនទៅមណ្ឌលចត្តាឡីស័កខេត្តអនុវត្តវិធានការសុខាភិបាលរយៈពេល១៤ថ្ងៃ៕

## ថ្ងៃទី១៣ ខែ មេសា ឆ្នាំ២០២២

## ទូតម៉ាឡេស៊ីស្នើប៉ូលិសដោះលែង
## ជនជាតិម៉ាឡេស៊ី ៥០នាក់ ដែលត្រូវបានចាប់បង្ខាំងឲ្យធ្វើការនៅកម្ពុជា

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី2022-04-10

ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក អេលឌីន ហូសៃនី មូហាហ្ស៊ីម (Eldeen Husaini Mohd Hashim) បានសរសេរលិខិតមួយច្បាប់ ស្នើទៅអគ្គស្នងការនគរបាលជាតិ លោក នេត សាវឿន កាលពីដើមខែមេសា ឲ្យជួយអន្តរាគមន៍ដោះលែងជនជាតិម៉ាឡេស៊ី ៥០នាក់ ដែលត្រូវបានចោទប្រកាន់ថា ពួកគេរងការបង្ខិតបង្ខំឱ្យធ្វើសកម្មភាពខុសច្បាប់ នៅខេត្តព្រះសីហនុ។

កាសែតខ្មែរថាមស៍ ដែលបានដកស្រង់លិខិតរបស់ស្ថានទូត ចុះផ្សាយនៅថ្ងៃទី ៩ខែមេសា ឲ្យដឹងថា ជនជាតិម៉ាឡេស៊ីរងគ្រោះដោយសារការជួញដូរមនុស្ស ចំនួន២០នាក់ ក្នុងនោះ ប្រុស ១៦ នាក់ ស្រី៤ នាក់ ត្រូវបានគេឃុំឃាំង និងបង្ខំឱ្យធ្វើការ ១៤ម៉ោងក្នុងមួយថ្ងៃ ទទួលរងការគំរាមកំហែង និងវាយដំ ប្រសិនបើពួកគេមិនគោរពតាមបញ្ជា និងមានចេតនាចង់រត់ចេញ។

កាលពីដើមសប្តាហ៍នេះ សមត្ថកិច្ចបានជួយសង្គ្រោះ យុវជនម៉ាឡេស៊ីចំនួន ១៥នាក់។ ក្រោយពីបានសួរចម្លើយ ពួកគេមិនត្រូវបានចាញ់បោកគេដូចការលើកឡើងនោះ ប៉ុន្តែត្រូវបានគេជួលឲ្យធ្វើការស្របច្បាប់នៅកាស៊ីណូមួយក្នុងក្រុងព្រះសីហនុ។ ពួកគេខ្លះចង់នៅធ្វើការ និងខ្លះទៀតចង់វិលត្រឡប់ទៅប្រទេសម៉ាឡេស៊ីវិញ។

ជុំវិញរឿងនេះ ស្នងការនគរបាលខេត្តព្រះសីហនុ លោកឧត្តមសេនីយ៍ទោ ជួន ណារិទ្ធ បានប្រាប់ខ្មែរថាមស៍ថា យុវជនម៉ាឡេស៊ីចំនួន ១៥ នាក់ ពួកគេត្រូវបានបញ្ជូនទៅកាន់នគរបាលរាជធានីភ្នំពេញរួចហើយ ដើម្បីសួរចម្លើយ និងសម្រេចចិត្តចុងក្រោយ ថាតើនឹងត្រូវនិរទេសពួកគេឬអត់។ លោកបន្តថា ជនរងគ្រោះត្រូវបានបោក

បញ្ឆោតជាមួយនឹងការផ្ដល់ការងារជាអ្នកលក់តាមប្រព័ន្ធទូរគមនាគមន៍ ដោយបានប្រាក់ខែពី៣ពាន់ដុល្លារ ដល់ ៤ ពាន់ដុល្លារ ក្នុងមួយខែ៕

## ប្រទេសថៃនឹងទទួលពលករប្រមាណ១៦ម៉ឺននាក់ មកពីប្រទេសកម្ពុជា ឡាវ និងភូមា

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី2022-04-09

ប្រទេសថៃនឹងនាំចូលពលករប្រមាណ ១៦ម៉ឺននាក់ មកពីប្រទេសកម្ពុជា ឡាវ (Lao) និងមីយ៉ាន់ម៉ា ឬភូមា (Myanmar) សំរាប់តម្រូវការកង្វះខាតកម្លាំងពលកម្ម ខណៈដែលអាជ្ញាធរថៃ កំពុងពិនិត្យពីលទ្ធភាពផ្ដល់ទិដ្ឋាការបន្តដល់ពលករបរទេស ប្រមាណជាង ២លាន២សែននាក់ ដែលស្ថិតនៅក្នុងប្រទេសថៃ។ ការអះអាងនេះធ្វើឡើងបន្ទាប់ពីក្រសួងការងារថៃ បានចុះអនុស្សរណៈយោគយល់គ្នា (MoU) រួចហើយ ជាមួយប្រទេសកម្ពុជា ឡាវ (Lao) និងមីយ៉ាន់ម៉ា ឬភូមា (Myanmar)។

មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសក៍នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា មានប្រសាសន៍ប្រាប់វិទ្យុអាស៊ីសេរី កាលពីយប់ថ្ងៃសុក្រ ទី៨ ខែមេសា ថា ការនាំពលករខ្មែរទៅធ្វើការនៅប្រទេសថៃ តាមរយៈអនុស្សារណៈយោគយល់គ្នា (MoU) នេះ មានភាពស្មុគ្រស្មាញច្រើន និងប្រើពេលយូរ។ បញ្ហានេះហើយ ដែលជាហេតុនាំឲ្យពលរដ្ឋខ្មែរ ចូលចិត្តធ្វើដំណើរឆ្លងកាត់ព្រំដែនទៅរកការងារធ្វើ តាមរយៈមេខ្យល់វិញ៖ «តាមដែលខ្ញុំធ្វើការផ្ទាល់ក្នុងរឿងហ្នឹង ខ្ញុំសង្កេតឃើញថា ការទៅធ្វើការតាម MoU មកដល់ពេលនេះ មិនសូវដំណើរការបានល្អនៅឡើយទេ។ ព្រោះពលរដ្ឋខ្មែរ យើងគាត់ជ្រើសរើសតាមរយៈមេខ្យល់ តាមផ្លូវកាត់ ដោយសារចំណាយតិច គាត់ទៅធ្វើការបានលឿន ទៅពីព្រឹកល្ងាចទៅដល់។ ម្យ៉ាងវិញទៀត ពលរដ្ឋខ្មែរយើង មិនចង់ទេ ព្រោះវាមានស្មុគស្មាញសំរាប់គាត់ផង និងចំណាយលុយច្រើន ហើយពួកគាត់មិនដឹងពីរបៀបរបបដាក់ពាក្យទាំងនោះ»។

ប្រធានអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារថៃ លោក ប៉ារ៉យ ចូទិកាសាទីន (Pairoj Chotikasathien) ត្រូវបានសារព័ត៌មានអនឡាញដកស្រង់សំដីថា ក្រសួងការងារ បានចុះអនុស្សរណៈយោគយល់គ្នា (MoU) រួចហើយជាមួយប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ លោកបន្តថា ប្រទេសថៃត្រូវការពលករខ្មែរ ជិត៤ម៉ឺននាក់ (៣៨.៩៣៣) ពលករឡាវ ជិត ១ម៉ឺន២ពាន់នាក់ (១១.៩៩៩) និងពលករមីយ៉ាន់មា ឬភូមា ជាង១១ម៉ឺន ៧ពាន់នាក់ (១១៧.០២៩)។ មន្ត្រីនាយកដ្ឋានការងារថៃរូបនេះ ឲ្យដឹងថា អាជ្ញាធរថៃ នឹងផ្ដល់ទិដ្ឋាការឲ្យពលករបរទេសទាំងនោះសរុប ចំនួនជាង២លាននាក់ ដើម្បីឲ្យពួកគេ អាចបន្តការងារនៅក្នុងប្រទេសថៃបន្តទៀតបាន។ លោក ប៉ារ៉យ ជំរុញឲ្យនិយោជក ឬថៅកែថៃ កុំឲ្យជួលពលករខុសច្បាប់ ដោយត្រូវគិតពីសុវត្ថិភាពសុខភាពសាធារណៈជាមុនសិន ជាពិសេស ការរាលដាលនៃជំងឺកូវីដ១៩ ហើយត្រូវអនុវត្តតាមកិច្ចព្រមព្រៀងអនុស្សរណៈយោគយល់គ្នា (MoU) ដើម្បីនាំពលករស្របច្បាប់មកធ្វើការនៅក្នុងប្រទេសថៃ។

ចាប់តាំងពីការរាតត្បាតសកលនៃជំងឺកូវីដ១៩មក ពលករបរទេសយ៉ាងច្រើន បាននាំគ្នាសម្រុកត្រឡប់ទៅប្រទេសកំណើតវិញ ស្របពេលដែលអាជ្ញាធរថៃបានបិទព្រំដែន និងរឹតបន្តឹងការធ្វើដំណើរជាដើម ដែលជាហេតុធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចក្នុងស្រុក និងអាជីវកម្មជាច្រើន ត្រូវក្ស័យធន។ ទោះជាយ៉ាងនេះក្ដី ក៏មានពលករខ្មែរ ឡាវ និងភូមា រាប់ពាន់នាក់ ត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ពីបទលួចឆ្លងដែនចូលទឹកដីថៃខុសច្បាប់ ទៅរកការងារធ្វើក្នុងប្រទេសថៃ កាលពីអំឡុងឆ្នាំ២០២១៕

# ពលករខ្មែរ ៣៦៤ នាក់ ត្រូវអាជ្ញាធរថៃចាប់បញ្ជូនវិលត្រឡប់មកកម្ពុជាវិញ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១១ មេសា ២០២២ដោយ Sorn Phanith

ពលករខ្មែរ ៣៦៤ នាក់ ត្រូវអាជ្ញាធរថៃចាប់បញ្ជូនវិលត្រឡប់មកកម្ពុជាវិញ នៅត្រង់ចំណុចភូមិសាស្រ្តឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ពលករខ្មែរ ៣៦៤ នាក់ ត្រូវបានកម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ បានចេញទៅទទួល កាលពីថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០២២។

លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានឱ្យដឹងថាកាលពីថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តម សេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង ៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្រ្តប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្រ្តឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន ០៨ លើក សរុបចំនួន ៣៦៤ នាក់ ស្រី ១៤៧ នាក់ ក្មេង ៥៨ នាក់ ក្មេងស្រី ២៨ នាក់។

លោកវរសេនីយ៍ឯក ប្រាក់ សាយ បានបន្តថា ក្រោយពីទទួលបានកម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចប្រគល់បងប្អូន ចំនួន ២៦ នាក់ ស្រី ១២ នាក់ ក្មេង ៨ នាក់ ក្មេងស្រី ១ នាក់ ទៅឲ្យក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារអន្តរជាតិគីឡូ ១៣ និងបងប្អូនចំនួន ៣៣៨ នាក់ ស្រី ១៣៥ នាក់ ក្មេង ៥០ នាក់ ក្មេងស្រី ២៧ នាក់ ទៅឲ្យក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើការត្រួតពិនិត្យសុខភាព និងស្កេនប័ណ្ណចាក់វ៉ាក់សាំងនៅនឹងប៉ុស្តិ៍ជាលទ្ធផលអវិជ្ជមានទាំងអស់ បន្ទាប់មកក្រុមពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ ៕

# ពលករខ្មែរកំពុងរងគ្រោះចាញ់បោក
# មេខ្យល់នាំឆ្លងដែនទៅថៃនាំត្រឡប់មកស្រុកខ្មែរវិញ

https://kohsantepheapdaily.com.kh/ បាត់ដំបង១១ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១១:៥៥

ខេត្តបាត់ដំបង ៖ ខណៈដែលពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ សល់តែប៉ុន្មានថ្ងៃប៉ុណ្ណោះនឹងចូលមកដល់ និងស្របពេលពលករខ្មែររាប់រយនាក់ក្នុងមួយថ្ងៃៗ បាន និងកំពុងសម្រុកវិលត្រឡប់ពីប្រទេសថៃ មកកាន់ស្រុកកំណើត ដើម្បីជួបជុំក្រុមគ្រួសារ ស្រាប់តែនៅស្រុកកំរៀង មានលេចចេញនូវក្រុមជនទុច្ចរិត(មេខ្យល់) ដែលជនខ្លះជាមន្ត្រីការពារព្រំដែនផង បានប្រើមធ្យោបាយបោកបញ្ឆោតល្បួងឲ្យក្រុមពលករខ្មែរដែលត្រឡប់មកស្រុកវិញ លួចឆ្លងដែនតាមច្រករបៀង ជាថ្នូរនឹងការបង្ខំទារប្រាក់ម្នាក់ៗចន្លោះពី៧០០បាត ទៅជាង១០០០បាត តាមលទ្ធភាពដែលពួកគេអាចជំរិតទារបាន ដោយភូតកុហក់ថា «គេមិនបើកឲ្យពលករចូលតាមច្រកទ្វារអន្តរជាតិទេ»។ កាលពីល្ងាចថ្ងៃទី៩ មេសា មានពលករខ្មែរប្រុស ស្រី ប្រហែល១០នាក់ ដែលបានវិលត្រឡប់ពីប្រទេសថៃ មកកាន់ស្រុកកំណើតវិញ ។ ពេលមកទឹកដីច្រកអន្តរជាតិ «បានឡែម» ស្រុកប៉ូណាំរ៉ន ខេត្តច័ន្ទបុរី ឈមនឹងច្រកអន្តរជាតិ «ដូង» ស្រុកកំរៀង ត្រូវបានពួកជនទុច្ចរិតនិយាយបញ្ចុះបញ្ចូលលួងលោមបោកបញ្ឆោតពួកគេឲ្យដើរឆ្លងព្រំដែនតាមខ្លួន

តាម«ច្រករបៀង»មួយកន្លែងដែលគេហៅថា «ច្រកចាន់គិរី» ដោយភូតកុហកក្រុមពលករទាំងនោះថា គេមិនបើកច្រកទ្វារអន្តរជាតិ«ដូង»ឲ្យឆ្លងកាត់ឡើយ ជាថ្នូរនឹងការបង់ទារប្រាក់ក្នុងម្នាក់ចំនួន៧០០បាត ។

បើតាមការបំភ្លឺពីក្រុមពលករខ្មែរ ដែលសួរនាំដោយអាជ្ញាធរស្រុកកំរៀង ពួកគេបាននិយាយថា ពេលពួកគេត្រឡប់មកដល់ព្រំដែនខាងទឹកដីថៃ ស្រាប់តែមានមេខ្យល់មកបញ្ចុះបញ្ចូលពួកគាត់ ដោយអះអាងថា ពួកគេអាចនាំឆ្លងដែនតាមច្រករបៀងចូលដីខ្មែរបានទាំងយប់ ហើយលឿនទៀតផង ព្រោះនៅច្រកទ្វារអន្តរជាតិ«ដូង» គេមិនបើកឲ្យចេញចូលទេ។ ប៉ុន្តែមេខ្យល់នោះបានទាមទារប្រាក់ពីពួកខ្លួន(ពលករ) ក្នុងម្នាក់ចំនួន៧០០បាត ជាថ្នូរនឹងការនាំឆ្លងដែនតាមច្រករបៀង ដែលគេស្គាល់ថា «ច្រកចាន់គិរី»។ ក្រុមពលករបានបញ្ជាក់ថា ក្រោយពីពួកខ្លួនបានបង់ប្រាក់គ្រប់ចំនួន នៅវេលាម៉ោងជិត៣រំលងអធ្រាត្រឈានចូលថ្ងៃទី ១០ មេសា មេខ្យល់នោះបាន ត្រឹមតែចង្អុលបង្ហាញផ្លូវឆ្លងអូរព្រំដែន រួចហើយជននោះបានគេចខ្លួនបាត់ស្រមោល។

ពលករបាននិយាយថា នៅពេលពួកខ្លួននាំគ្នាឆ្លងអូរផុតចូលដល់ដីខ្មែរបានបន្តិច ស្រាប់តែលេចមុខក្រុមមនុស្សស្លៀកពាក់ឯកសណ្ឋានយោធា និងនគរបាលការពារព្រំដែនផង បានស្ទុះមកកាក់ពួកគាត់សួរនាំ។ ក្រោយមកពួកជនឯកសណ្ឋាននោះ បានទាមទារប្រាក់ពីពួកគាត់ក្នុងម្នាក់ៗចនួន១២០០បាតទៀត ដោយអះអាងថា នឹងជូនពួកគាត់ឡើងរថយន្តតាក់ស៊ីចេញទៅស្រុកកំណើតទាំងយប់ ដោយមិនចាំបាច់ឲ្យគេពិនិត្យ ឬ ធ្វើតេស្តកូវីដ១៩ឡើយ ។ ដោយសារតែខ្លាចអាជ្ញាធរសួរនាំរកលិខិតឆ្លងដែនផង និងខ្លាចចាប់ធ្វើសេត្តរោគសញ្ញាកូវីដ១៩ផង ទើបពួកគាត់សម្រេចសូកប៉ាន់ក្រុមឆ្មាំប្រចាំច្រករបៀងនេះ (ច្រកចាន់គីរី) គ្រប់ចំនួនតាមការទាមទារ ។ ប៉ុន្តែក្រោយពីទទួលប្រាក់ដល់ដៃគ្រប់ចំនួន មិនបានមួយប៉ព្រិចភ្នែកផង ស្រាប់តែបាត់មុខក្រុមស្លៀកពាក់ឯកសណ្ឋានទាំងនោះអស់ពីមាត់ច្រកភ្លាមៗផងដែរ ។

គ្រាហ៍នោះ ពួកគាត់ក៏ធ្វើដំណើរទៅថ្នល់ជាតិ រកម៉ូតូឌុបជិះទៅរករថយន្តកាត់ស៊ី ដើម្បីបន្តដំណើរបន្តទៅស្រុក។ ប៉ុន្តែពេលកំពុងធ្វើដំណើរតាមផ្លូវ ក៏ត្រូវកម្លាំងសមត្ថកិច្ចកាក់ជាប់ទៀត រួចនាំពួកគេទៅសួរនាំអំពីដំណើររឿងរ៉ាវឆ្លងដែនខុសច្បាប់នេះ។ នៅកន្លែងសាកសួរ មន្ត្រីស្រុកបានស្ដីបន្ទោសដល់ក្រុមពលករខ្មែរទាំងនោះ ដែលជឿស្លុងនឹងការបោកបញ្ឆោតរបស់ពួកមេខ្យល់ទុច្ចរិត ។ មន្ត្រីរដ្ឋបាលស្រុកកំរៀង បានប្រាប់ទៅកាន់ក្រុមពលករទាំងនោះថា សម្រាប់ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីខ្មែរខាងមុខនេះ អាជ្ញាធរខ្មែរ និង អាជ្ញាធរថៃ បានព្រមព្រៀងគ្នាបើកច្រកទ្វារអន្តរជាតិ «ដូង» មួយរយៈពេលខ្លី ដើម្បីឲ្យបងប្អូនប្រជាពលរដ្ឋខ្មែរដែលធ្វើការងារនៅប្រទេសថៃ វិលត្រឡប់មកធ្វើបុណ្យ ជួបជុំគ្រួសារនៅស្រុកកំណើត ។ ចុះហេតុអ្វី បានជាបងប្អូនមិនចូលតាមច្រកដូង បែរជាទៅជឿតាមមេខ្យល់បោកប្រាស់ទៅវិញ ?

សូមបញ្ជាក់ថា បើយោងលើសេចក្ដីជូនដំណឹងរវាងអាជ្ញាធរខេត្តបាត់ដំបង និងអាជ្ញាធរខេត្តចាន់បុរី ច្រកទ្វារអន្តរជាតិ «ដូង» ស្រុកកំរៀង ដែលភាគីថៃហៅ ច្រកទ្វារអន្តរជាតិ «បានឡែម» ត្រូវបានបន្ធូរបន្ថយ បើកឲ្យដំណើរការចេញចូលក្នុងរយៈពេលខ្លី ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរខាងមុខនេះ ។ ប៉ុន្តែខ្លឹមសារនៃសេចក្ដីជូនដំណឹងនេះ ការឯកភាពគ្នាបើកបន្ធូរបន្ថយច្រកចេញចូលនេះ គឺសម្រាប់តែ «ពលករខ្មែរ ដែលធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃមានបំណងទៅចូលឆ្នាំថ្មី នៅស្រុកកំណើតរបស់ខ្លួនតែប៉ុណ្ណោះ» ។ បើតាមមន្ត្រីព្រំដែនបានបញ្ជាក់ថា ច្រកទ្វារអន្តរជាតិ«ដូង» បានបើកឲ្យពលករខ្មែរវិលត្រឡប់ពីថៃ ចូលស្រុកខ្មែរវិញ ចាប់តាំងពីថ្ងៃទី៨ មេសា រហូតថ្ងៃបិទបញ្ចប់ចូលឆ្នាំខ្មែរ ទើបច្រកទ្វារអន្តរជាតិ«ដូង» នេះបិទទ្វារបញ្ចប់ដំណើរការចេញចូលរបស់ពលករដែរ ។

ប៉ុន្តែអាជ្ញាធរមានសមត្ថកិច្ចប្រចាំច្រកទ្វារចេញចូលនេះ ក៏ត្រូវពិនិត្យរាល់លិខិតឯកសារនានា លើជនបរទេសទាំងឡាយណា ដែលឆ្លងដែនដោយខុសច្បាប់យ៉ាងល្អិតល្អន់ផងដែរ។ ជុំវិញករណីដែលពលករខ្មែរ ត្រូវជនខិលខូចបោកប្រាស់យកប្រាក់អស់រាប់ពាន់បាតខាងលើនេះ ជាថ្នូរនឹងការនាំឆ្លងដែនតាមច្រករបៀងខុសច្បាប់វិញ

បើតាមមន្ត្រីស្រុកកំរៀង បានលើកឡើងថា បើពិនិត្យ និង ស្រាវជ្រាវ លើសកម្មភាពក្រុមសង្គមងងឹតដែលជំរិតទារប្រាក់ពីពលករខ្មែរប៉ុន្មាននាក់ខាងលើនេះ គឺពួកគេជាក្រុមឆក់ឱកាស ដើម្បីទាញយកផលប្រយោជន៍ពីពលករខ្មែរដែលធ្វើចំណាកស្រុកទៅរកការងារធ្វើនៅទឹកដីថៃ។ តាមការស្រាវជ្រាវកន្លងមក គេអាចសន្និដ្ឋានបានថា សមាសភាពក្រុមសង្គមងងឹតទាំងនោះ មានជនស៊ីវិលផង និងមានសមត្ថកិច្ចនៅតាមតំបន់ព្រំដែនមួយចំនួនផង ដែលពួកគេឃុបឃិតគ្នាធ្វើជាមេខ្យល់នាំមនុស្សឆ្លងដែន បណ្ដាក់គ្នាមានលក្ខណៈជាប្រព័ន្ធតែម្ដង។ ហើយអ្នកដែលរងគ្រោះពិតមិនឈប់ឈរម្ដងហើយ ម្ដងទៀត គឺជាប្រជាពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកស្វែងរកការងារធ្វើ តាមតំបន់ព្រំដែន ឬ មានគោលបំណងឆ្លងដែនទៅរកការងារនៅទឹកដីថៃ។ ដូច្នេះ អាជ្ញាធរស្រុក និងខេត្ត គួតែធ្វើការស៊ើបអង្កេតលើករណីនេះ ឲ្យបានជាក់លាក់ដើម្បីវែកមុខក្រុមជនសង្គមងងឹតទាំងនោះយកមកផ្ដន្ទាទោសតាមច្បាប់ ចៀសវាងការបង្កផលលំបាកដល់ជនចំណាកស្រុកនានាដល់សង្គម និងបង្កឲ្យប៉ះពាល់ដល់សន្តិសុខតាមតំបន់ព្រំដែនទៀតផង៕

## នាព្រឹកថ្ងៃចន្ទ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/04/11/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃចន្ទ ១០កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៤លើក សរុបចំនួន១៩៧នាក់ ស្រី៨៣នាក់ ក្មេង៣២នាក់ ក្មេងស្រី១៣នាក់។ ក្រោយពីទទួលបាន កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចប្រគល់បងប្អូន ចំនួន៧នាក់ ស្រី២នាក់ ទៅឲ្យក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារអន្តរជាតិគីឡូ១៣ និងបងប្អូនចំនួន១៩០នាក់ ស្រី៨១នាក់ ក្មេង៣២នាក់ ក្មេងស្រី១៣នាក់ ទៅឲ្យក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើការត្រួតពិនិត្យសុខភាព និងស្វែនប័ណ្ណចាក់វ៉ាក់សាំងនៅនឹងប៉ុស្តិ៍។ ជាលទ្ធផលគឺអវិជ្ជមានទាំងអស់ បន្ទាប់មកក្រុមពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ។

## ពលករខ្មែរខ្ទង់ពាន់នាក់ធ្វើការនៅថៃ វិលចូលស្រុកវិញក្នុង ១ ថ្ងៃៗ នាខែមេសានេះ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 12 April 2022 | 09:14 ICT

**បន្ទាយមានជ័យ/ឧត្តរមានជ័យ៖** នាដើមខែមេសានេះ ពលករខ្មែរដែលធ្វើការនៅប្រទេសថៃបានវិលត្រឡប់ចូលស្រុកវិញក្នុង ១ថ្ងៃៗ ខ្ទង់ពាន់នាក់ ខណៈពលករមួយចំនួនទៀត ដែលមិនទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ ១៩ ឬបន្លំឯកសារវ៉ាក់សាំងត្រូវបានដាក់ឱ្យនៅមណ្ឌលចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ ដើម្បីតាមដានសុខភាព។

អ្នកនាំពាក្យសាលាខេត្តបន្ទាយមានជ័យលោក សេក សុខុម ប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ១១ មេសា ថា ពលករ ដែលវិលចូលតាមច្រកចំនួន ៣ ក្នុងខេត្តនេះមានការកើនឡើងចាប់ពីដើមខែមេសាជាបន្តបន្ទាប់ ពោលគឺកើនឡើងប្រមាណពី ២៥០ ទៅជិត ១ ០០០ នាក់ ក្នុង ១ ថ្ងៃ។ ក្នុងចំណោមនោះពលករភាគច្រើនបានចាក់វ៉ាក់សាំងដូ

សទី ២ រួចហើយ រីឯអ្នកមិនទាន់ចាក់វ៉ាក់សាំងមានចំនួនតិចតួច។ លោកថ្លែងថា៖ «បើគាត់អត់មានឯកសារចាក់វ៉ាក់សាំងទេ យើងឃុំគាត់ ១៤ ថ្ងៃ នៅមណ្ឌលចត្តាឡីស័ក ហើយក្នុងនោះពិនិត្យឃើញមានពលករខ្លះបន្លំឯកសារចម្លងកាតវ៉ាក់សាំងកូវីដដែរ តែមិនច្រើនទេ ហើយក៏មិនពិន័យអីដែរ ប៉ុន្តែ ដាក់ឃុំគាត់ ១៤ ថ្ងៃដូចផ្សេងអ៊ីចឹង»។ លោកបន្តថា ចំពោះពលករដែលវិលចូលស្រុកវិញនោះក្នុងចំណោម ១០០ នាក់ មានពលករតែ ២ នាក់ប៉ុណ្ណោះមិនទាន់បានចាក់វ៉ាក់សាំងកូវីដ ហើយភាគច្រើនធ្វើតេស្តរហ័សរកឃើញវិជ្ជមានកូវីដ-១៩។ ទាក់ទងនឹងគម្រោងបើកច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតខេត្តស្រះកែវក្នុងកម្រិតតំបន់រវាងភាគីកម្ពុជា និង ថៃ គឺមិនទាន់ឯកភាពឱ្យបើកក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនោះទេ ដោយសារការឆ្លងជំងឺកូវីដ ១៩ នៅថៃ មិនទាន់ធូរស្រាលនៅឡើយ។

ដោយឡែកអ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យ លោក ផល លឹម ថ្លែងថា ពលករដែលចូលតាមខេត្តនេះមានចន្លោះពី ៥០០ ទៅ ជិត ១ ០០០ នាក់នៅដើមខែមេសានេះ។ លោកថា តាមការសាកសួរ ពលករដែលវិលចូលស្រុកយ៉ាងគំហុកនេះ ពួកគេប្រាប់ថា ដើម្បីចូលរួមបុណ្យចូលឆ្នាំថ្មី ហើយពលករខ្លះគ្មានការងារធ្វើនៅថៃ។ ពលករខ្លះឆ្លងដែនខុសច្បាប់ ហើយមិនទាន់បានចាក់វ៉ាក់សាំងកូវីដ ១៩ គឺ តម្រួតថៃចាប់បញ្ជូនមកវិញដែរ។ លោកបញ្ជាក់ថា៖ «កាលពីថ្ងៃទី ១ ខែមេសា ពលករចូលមកជិត ៨០០ នាក់ ហើយនៅថ្ងៃទី ២ ជាង ៩០០ នាក់។ នៅថ្ងៃទី ៣ មានពលករជាង ៧០០ នាក់ ហើយភាគច្រើនពលករគាត់ថា មកចូលឆ្នាំ ហើយអ្នកខ្លះនោះគាត់ថាអត់ការងារនៅថៃ»។ លោក ផល លឹម ឱ្យដឹងដែរថា ក្នុងចំណោមពលករចូលតាមច្រកខេត្តនេះ មិនមែនសុទ្ធតែអ្នករស់នៅខេត្តឧត្តរមានជ័យនោះទេ ពោលគឺពលកររស់នៅ ២៥ រាជធានី-ខេត្ត។ លោកបន្តថា ក្នុងរយៈពេល ១០ ថ្ងៃនាដើមខែមេសានេះ មានពលករវិលចូលតាមច្រកខេត្តឧត្តរមានជ័យមានចំនួន ៧ ២៨៨ នាក់ ហើយក្នុងនោះវិជ្ជមានកូវីដតែ ៦ នាក់ប៉ុណ្ណោះ។

ទន្ទឹមនឹងមានពលករខ្មែរសម្រុកវិលចូលស្រុក ក៏មានពលករខ្លះសម្រេចចិត្តមិនវិលត្រឡប់មកខ្មែរដែរនាឆ្នាំនេះ។ លោក យាង ថា អាយុ ៣៨ ឆ្នាំរស់នៅខេត្តតាកែវ ដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃអស់រយៈពេល ៨ ឆ្នាំមកហើយប្រាប់ថា មុនមានបញ្ហាកូវីដ ១៩ គាត់តែងតែមកលេងស្រុកកំណើតស្ទើរតែរៀងរាល់ឆ្នាំ។ ប៉ុន្តែលោកថាជាង ២ ឆ្នាំចុងក្រោយនេះ លោកមិនបានមកខ្មែរនោះទេ ដោយលោកបារម្ភពីផលវិបាកក្នុងការវិលត្រឡប់ទៅធ្វើការនៅថៃវិញ។ លោកថា៖ «ខ្ញុំនៅថៃធ្វើការនៅរោងចក្រសាច់មាន់ក្នុង ១ ខែរកបានប្រាក់ ១៨ ០០០ បាត (៥៣៥ ដុល្លារអាមេរិក)។ តាមពិតខ្ញុំ ចង់ទៅខ្មែរដែរនៅឆ្នាំនេះ ប៉ុន្តែខ្ញុំខ្លាចវិលមកថៃវិញពិបាក ព្រោះយើងដឹងហើយនៅខ្មែរគេបើកឱ្យចូល តែគេអត់ទាន់បើកឱ្យចេញទេ ហើយណាមួយការងារខ្ញុំនៅទីនេះធ្វើការធម្មតាអត់ប៉ះពាល់ទេ»៕

## ពលករចំណាកស្រុកជាច្រើននាក់កាន់ឯកសារចាក់វ៉ាក់សាំងដែលមិនអាចផ្ទៀងផ្ទាត់បាន

https://www.khmertimeskh.com/ យឹម ស្រីលីន / តាំង រីនិត្យ / Khmer Times April 12, 2022

ខណៈពេលដែលពលករចំណាកស្រុករាប់ពាន់នាក់ត្រឡប់មកកម្ពុជាពីថៃ ដើម្បីអបអរបុណ្យចូលឆ្នាំខ្មែរ ពលករជាច្រើនបានបង្ហាញឯកសារចាក់វ៉ាក់សាំង ឬ កាតដែលមានលេខ QR កូដមិនអាចស្កេនបញ្ជាក់បានឡើយ។ ប្រការនេះនាំឱ្យមានការសង្ស័យថាពួកគេប្រហែលជាទទួលបានឯកសារក្លែងក្លាយដោយមិនដឹងខ្លួននៅប្រទេសថៃ។ ពលករចំណាកស្រុកទាំងនេះ ដែលអះអាងថា បានចាក់វ៉ាក់សាំងពេញលេញ មុនពេលត្រឡប់មកកម្ពុជាវិញ ត្រូវបានដាក់ក្នុងមណ្ឌលចត្តាឡីស័ក គឺជារឿងដែលពួកគេមិននឹកស្មានដល់។

កាសែតខ្មែរថាមស៍ ក្នុងសប្តាហ៍នេះបានចុះទៅមណ្ឌលចត្តាឡីស័ក និងច្រកព្រំដែននៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ហើយបានរកឃើញថា ពលករខ្មែរជិត ៣០០នាក់ ដែលត្រឡប់មកកម្ពុជាពីថៃ គឺបានជាប់គាំងនៅក្នុងមណ្ឌលចត្តាឡីស័ករយៈពេល ១៤ថ្ងៃនៅ មណ្ឌលចត្តាឡីស័កសំពៅលូន ខេត្តបាត់ដំបង និងមណ្ឌល

កូបធំ ខេត្តបន្ទាយមានជ័យ។ ពលករចំណាកស្រុកទាំងនោះ បានកាន់ឯកសារចាក់វ៉ាក់សាំងថតចម្លង និងច្បាប់ដើម ជាច្រើនប្រភេទពីប្រទេសថៃ។ អ្នកខ្លះបានអះអាងថា ពួកគេបានចាក់វ៉ាក់សាំងដល់ទៅបីដូស ប៉ុន្តែមន្ត្រីសុខាភិបាលមិនអាចស្កេនQRកូដបញ្ជាក់បានឡើយ។ ឯកសារពិតប្រាកដដែលត្រូវបានស្កេនរួច នឹងបង្ហាញព័ត៌មានលម្អិតអំពីការចាក់វ៉ាក់សាំង ប៉ុន្តែ នៅពេលដែលស្កេនឯកសារក្លែងក្លាយ វានឹងបង្ហាញ Line App ឬលេខសេរី។

លោក ពេជ្រ ថាន អាយុ ៣៥ឆ្នាំ ដែលបានត្រឡប់មកពីខេត្តចាន់បុរី កំពុងធ្វើចត្តាឡីស័កនៅមណ្ឌលសំពៅលូន បាននិយាយថា គាត់បានចាក់វ៉ាក់សាំងស៊ីណូហ្វាម Sinopharm ចំនួនពីរដូសរួចហើយនៅឯប្រទេសថៃ ហើយគាត់បានទទួលឯកសារចាក់វ៉ាក់សាំងរបស់គាត់ពីនិយោជករបស់គាត់ផ្ទាល់។ លោក ពេជ្រ ថាន មានប្រសាសន៍ថា៖«ពេលខ្ញុំត្រឡប់ មកកម្ពុជាវិញតាមច្រកទ្វារព្រំដែនអន្តរជាតិដូង លោកគ្រូពេទ្យបានប្រាប់ខ្ញុំថា ខ្ញុំត្រូវធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ពីព្រោះ QR កូដ នៅលើឯកសារមិនបានភ្ជាប់ទៅនឹងទិន្នន័យស្ថានភាពចាក់វ៉ាក់សាំងរបស់ប្រទេសថៃនោះឡើយ»។ លោកបន្តថា៖«ខ្ញុំប្រញាប់ប្រញាល់ត្រឡប់មកផ្ទះដើម្បីចូលឆ្នាំថ្មី ហើយឥឡូវនេះ ខ្ញុំត្រូវជាប់នៅក្នុងមណ្ឌលចត្តាឡីស័ករយៈពេល១៤ ថ្ងៃ។ ខ្ញុំខកចិត្តយ៉ាងខ្លាំង ព្រោះខ្ញុំមិនដឹងថា ហេតុអ្វីបានជា QRកូដនៅលើវិញ្ញាបនបត្រចាក់វ៉ាក់សាំងមិនអាចភ្ជាប់ទៅនឹងទិន្នន័យនោះទេ»។

អ្នកស្រី ជឿ ណេ អាយុ ៣០ ឆ្នាំ បាននិយាយថា គាត់បានចាក់វ៉ាក់សាំងស៊ីណូហ្វាក់ Sinovac រួចហើយ ប៉ុន្តែគាត់ក៏ជួបប្រទះបញ្ហាដូចគ្នាផងដែរ។ អ្នកស្រីបន្តថា៖«លេខ QRកូដ នៅលើវិញ្ញាបនបត្រចាក់វ៉ាក់សាំងរបស់ខ្ញុំមិនអាចភ្ជាប់នឹងទិន្នន័យបានទេ។ ខ្ញុំបានទូរស័ព្ទទៅវេជ្ជបណ្ឌិតដែលចាក់វ៉ាក់សាំងឲ្យខ្ញុំនៅប្រទេសថៃដើម្បីពិភាក្សាជាមួយគ្រូពេទ្យនៅទីនេះ ប៉ុន្តែគាត់មិនព្រមនិយាយសោះ។ ខ្ញុំអស់សង្ឃឹម ដែលមិនបានចំណាយពេលចូលឆ្នាំថ្មីជាមួយគ្រួសាររបស់ខ្ញុំ ហើយឥឡូវនេះ ខ្ញុំកំពុងជាប់នៅមណ្ឌលចត្តាឡីស័កទៀត»។

កញ្ញា អ៊ាង សូឡា អាយុ ២៥ឆ្នាំ ដែលកំពុងធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក កូបធំ បាននិយាយថា នាងពិតជាមិនសប្បាយចិត្តនោះទេ នៅពេលដែលនាងជាប់ក្នុងមណ្ឌលចត្តាឡីស័ក បើទោះជានាងបានចាក់វ៉ាក់សាំង ចំនួនពីរដូសរួចហើយក៏ដោយ។ កញ្ញាបានបញ្ជាក់ថា៖«គ្រូពេទ្យនៅច្រកព្រំដែនម៉ាឡៃប្រាប់ខ្ញុំថា វិញ្ញាបនបត្រចាក់វ៉ាក់សាំងរបស់ខ្ញុំក្លែងក្លាយ ហើយវាមិនបានបញ្ជាក់អំពីកាលបរិច្ឆេទ និងប្រភេទវ៉ាក់សាំងនោះទេ។ ខ្ញុំមិនមានវិញ្ញាបនបត្រដូចអ្នកដទៃទេ មានតែកាតលឿងដែលបង្ហាញអំពី ឈ្មោះ អាយុ ប៉ុណ្ណោះ»។ កញ្ញាបន្តថា៖«ខ្ញុំមានការខកចិត្តជាខ្លាំងដែលជាប់នៅក្នុងមណ្ឌលចត្តាឡីស័ក។ ប្រសិនបើខ្ញុំបានដឹងជាមុននៅក្នុងប្រទេសថៃថា ប័ណ្ណចាក់វ៉ាក់សាំងមិនផ្តល់ព័ត៌មានច្បាស់លាស់ ហើយខ្ញុំត្រូវធ្វើចត្តាឡីស័កនោះ ខ្ញុំប្រាកដជាត្រូវដោះស្រាយបញ្ហានេះជាមុនសិនហើយ»។

លោក សុខ ជាតិ អាយុ ២៧ ឆ្នាំ ដែលបម្រើការងារជាកម្មករសំណង់នៅខេត្តចាន់បូរី បានចំណាយប្រាក់ជាង ៧៧ ដុល្លារដើម្បីមកកម្ពុជា បាននិយាយថា ឥឡូវនេះគាត់កំពុងជាប់នៅក្នុងមណ្ឌលចត្តាឡីស័ក។ លោក សុខ ជាតិ បាននិយាយថា៖«វេជ្ជបណ្ឌិតប្រាប់ខ្ញុំថា លេខQR កូដរបស់ខ្ញុំ មិនអាចភ្ជាប់ទៅទិន្នន័យមន្ទីរពេទ្យថៃដែលខ្ញុំបានចាក់វ៉ាក់សាំងនោះទេ»។

លោក មុំ ចាន់ថន មន្ត្រីសុខាភិបាលនៅមណ្ឌលសំពៅលូន ស្រុកកំរៀង មានប្រសាសន៍ថា ពលករចំណាកស្រុកទាំងអស់ដែលត្រូវបាននាំយកទៅទីនោះ នឹងត្រូវគេស្កេនឯកសារចាក់វ៉ាក់សាងរបស់ពួកគេឡើងវិញ ប្រសិនបើពួកគេមានឯកសារ។ លោកបន្តថា៖«ប្រសិនបើព័ត៌មានពាក់ព័ន្ធលេចឡើងនៅពេលស្កេន QRកូដ ពួកគេនឹងត្រូវអនុញ្ញាតឱ្យត្រឡប់ទៅភូមិកំណើតរបស់ពួកគេវិញ។ ប្រសិនបើវាមិនបង្ហាញព័ត៌មានលម្អិតទេ ពួកគេត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ ថ្ងៃសិន សម្រាប់អ្នកមិនបានចាក់វ៉ាក់សាំង ក្រោយធ្វើតេស្តរហ័សអវិជ្ជមានរួច»។ លោកបន្ថែមថា

៖«អ្នកដែលធ្វើតេស្តវិជ្ជមានត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ហើយបច្ចុប្បន្នមានពលករចំណាកស្រុករហូតដល់ ១០០ នាក់ដែលកំពុងធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ»។

លោក ថន សៃ អនុប្រធានមន្ទីរសុខាភិបាលស្រុកកំរៀង បានមានប្រសាសន៍ថា ពលករចំណាកស្រុកជិត ២.០០០នាក់ បានវិលត្រឡប់មកវិញកាលពីម្សិលមិញ ហើយពួកគេខ្លះត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័កក្រោយពីមានបញ្ហាជាមួយឯកសារចាក់វ៉ាក់សាំងរបស់ពួកគេ។ លោកបន្តថា៖«ព័ត៌មានស្ដីពីវិញ្ញាបនបត្រចាក់វ៉ាក់សាំងរបស់ពួកគេមិនអាចចូលប្រើបានទេ ដោយសារកន្លែងធ្វើការរបស់ពួកគេមិនបានបញ្ជូនព័ត៌មានចាក់វ៉ាក់សាំងរបស់ពួកគេទៅកាន់ក្រសួងសុខាភិបាលក្នុងប្រទេសថៃ។ ពួកគេខ្លះជាពលករចំណាកស្រុកខុសច្បាប់ ដូច្នេះកន្លែងធ្វើការមិនអាចផ្ញើឈ្មោះទៅក្រសួងបានឡើយ»។

អភិបាលរងខេត្តបាត់ដំបង លោក សឿម ប៊ុនរិទ្ធ មានប្រសាសន៍កាលពីម្សិលមិញថា ក្រុមមន្ត្រីកំពុងយកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់ក្នុងការទប់ស្កាត់ការហូរចូលរបស់អ្នកដែលមានលិខិតបញ្ជាក់វ៉ាក់សាំងក្លែងក្លាយ។ លោកបានបន្តថឱ្យដឹងថា៖«យើងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជាក់អំពីស្ថានភាពនៃការចាក់វ៉ាក់សាំង។ យើងនឹងពិភាក្សាបន្ថែមទៀត ដើម្បីស្វែងរកដំណោះស្រាយសម្រាប់ពលករចំណាកស្រុកដែលប្រឈមនឹងបញ្ហានេះ»៕

## ថ្ងៃទី១៨ ខែ មេសា ឆ្នាំ២០២២

### "រដ្ឋាភិបាលខកខានមិនបានការពារស្ត្រី និងក្មេងស្រីពីការបៀតបៀនពេលបុណ្យចូលឆ្នាំថ្មី"

https://www.rfa.org/khmer/ ដោយ ឡេង ម៉ាលី 2022.04.15

សង្គមស៊ីវិល និងពលរដ្ឋមើលឃើញថា រដ្ឋាភិបាលលោក ហ៊ុន សែន ខកខានមិនបានការពារស្ត្រី និងក្មេងស្រីពីការបៀតបៀន ដូចជា ការចាប់ថើប និងបន្លំប៉ះពាល់រាងកាយជាដើម ខណៈនិន្នាការបែបនេះតែងតែកើតឡើងអំឡុងពេលពិធីបុណ្យចូលឆ្នាំខ្មែរ។ ពួកគេស្នើដល់រដ្ឋាភិបាលឱ្យគិតគូបញ្ហានេះឡើងវិញ ដើម្បីលើកកម្ពស់សិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ពលរដ្ឋដែលជានាដោយរដ្ឋធម្មនុញ្ញ។ អង្គការសង្គមស៊ីវិល និងពលរដ្ឋចាត់ទុកអំពីបៀតបៀនលើស្ត្រីដែលកំពុងផ្ទុះឡើងក្នុងពិធីបុណ្យចូលឆ្នាំខ្មែរថា បានប៉ះពាល់ដល់តម្លៃស្ត្រី និងទំនៀមទំលាប់ប្រពៃណីខ្មែរ ជាពិសេសជាទង្វើផ្ទុយពីច្បាប់។

ប្រធានសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) លោក នី សុខា ថ្លែងថា ពិធីបុណ្យចូលឆ្នាំខ្មែរឆ្នាំនេះ បុគ្គលខិលខូចមួយចំនួនឆ្លៀតឱកាសប្រព្រឹត្តអំពើអសីលធម៌លើស្ត្រី និងក្មេងស្រី ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ពួកគាត់ ជាពិសេសករណីជាការរំលោភបំពានសិទ្ធិ និងច្បាប់។ លោកបន្តបញ្ហាទាំងនេះកើតឡើងដោយសាររដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធហាក់ខ្វះការយកចិត្តទុកដាក់ក្នុងការទប់ស្កាត់ និងចាត់វិធានការម៉ឺងម៉ាត់ទាក់ទងអំពើខុសឆ្គងទាំងនោះ ៖ «អ្នកខ្លះគាត់មានចេតនាមិនល្អធ្វើអំពើអ្វីដែលហួសទៅនឹងទំនៀមទំលាប់ប្រពៃណីយើង អាហ្នឹងមិនមែនជាការប្រើប្រាស់សិទ្ធិក្នុងការគោរពប្រពៃណីទំនៀមទំលាប់ទេ មានន័យអាហ្នឹងជាការឆ្លៀតយកឱកាសក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីនេះ ជារឿងមួយបង្កឱ្យមានបញ្ហា និងរំលោភលើគោលការណ៍សិទ្ធិមនុស្សទៅវិញបាទ»។

ស្រដៀងគ្នានេះ អគ្គលេខាធិការសហព័ន្ធនិស្សិតបញ្ញវន្តកម្ពុជា លោក គៀន ពន្លក លើកឡើងថា ល្បែងប៉ាតម្សៅ និងការជះទឹក អំឡុងបុណ្យចូលឆ្នាំខ្មែរ បាននាំឱ្យស្ត្រីមួយចំនួនងាយរងគ្រោះពីការបៀតបៀនលើរាងកាយពីសំណាក់ជនខិលខូច។ លោកបន្តថា និន្នាការបែបនេះ ភាគច្រើនកើតលើយុវតី ខណៈអាជ្ញាធរហាក់មិន

អើពើ និងណែនាំ អប់រំផ្សព្វផ្សាយឱ្យបានទូលំទូលាយនោះទេ។ លោកអំពាវនាវដល់រដ្ឋាភិបាលត្រូវចាត់វិធានទប់ស្កាត់ការអំពើបៀតបៀនលើស្ត្រីគ្រប់ទម្រង់ទាំងអស់ ដើម្បីថែរក្សាទំនៀមទំលាប់ និងសេចក្ដីថ្លៃថ្នូររបស់ពួកគេ៖ « អំពើអសីលធម៌នឹងប្រែក្លាយជាអំពើមួយដែលយុវជនទូទៅនិយមប្រើ នេះមិនមែនជាផលល្អសម្រាប់សង្គមកម្ពុជានោះទេ ពោលគឺធ្វើឱ្យប៉ះពាល់ខ្លាំងទៅដល់ការរីកចម្រើនវប្បធម៌ខ្មែរទាំងនៅលើឆាកជាតិ និងអន្តរជាតិ»។

ពលរដ្ឋមួយរូបរស់នៅស្រុកស្ទោង ខេត្តកំពង់ធំ កញ្ញា សុម៉ាលី ប្រាប់វិទ្យុអាស៊ីសេរីថា ការបាញ់ទឹក ប៉ាតម្សៅតែងតែកើតឡើងលើអ្នកដំណើរតាមដងផ្លូវក្នុងពេលបុណ្យចូលឆ្នាំខ្មែរ តែគ្មានអាជ្ញាធរណាទប់ស្កាត់ឡើយ។ កញ្ញាឱ្យដឹងថា ឆ្នាំនេះក្រុមក្មេងស្ទាវមួយក្រុមបានឃាត់កញ្ញាដោយបាញ់ទឹក និងប្រើប្រាស់ពាក្យសម្ដីមិនសមរម្យ ខណៈយុវតីមួយចំនួនត្រូវក្រុមបុរសចោមរោម និងលូកលាន់ ។ កញ្ញាចាត់ទុកទង្វើបៀតបៀនលើស្ត្រីបែបនេះ គឺជាអំពើរំលោភបំពានសិទ្ធិស្ត្រី ដែលមិនអាចទទួលយកបានឡើយ៖ «តាមពិតការបាញ់ទឹក និងការប៉ាតម្សៅមានយូរហើយក៏ប៉ុន្តែមិនទាក់ទងនឹងល្បែងប្រជាប្រិយខ្មែរទេ តែឥឡូវខ្ញុំជួបផ្ទាល់ខ្លួនឯង ហើយពួកគាត់បង្ហាញអាកប្បកិរិយាអត់គប្បី ចំពោះខ្ញុំទទួលយកអត់បានទេ ព្រោះវាឈ្លើយហើយម្យ៉ាងទៀតវាក៏អត់ល្អដែរ»។

វិទ្យុអាស៊ីសេរី មិនអាចទាក់ទងអ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល លោក កត្តា អ៊នប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល ផៃ ស៊ីផាន និងអ្នកនាំពាក្យក្រសួងកិច្ចការនារី អ្នកស្រី ម៉ាន ចិន្ដា ដើម្បីបកស្រាយរឿងនេះបាននៅឡើយទេ នៅថ្ងៃ១៥ ខែមេសា ដោយទូរស័ព្ទហៅចូលច្រើនដង តែគ្មានអ្នកទទួល។

ករណីបៀតបៀនលើស្ត្រី និងក្មេងស្រីពីសំណាក់ជនខិលខូចនេះ តែងកើតមានជាហូរហែនៅក្នុងកាសបុណ្យចូលឆ្នាំខ្មែរ ប៉ុន្តែរដ្ឋាភិបាល លោក ហ៊ុន សែន ហាក់មិនបានអើពើដោះស្រាយបញ្ហានេះឡើយ។ រដ្ឋាភិបាលមិនបានចេញវិធានការជាក់លាក់ណាមួយ ដើម្បីការពារ ឬទប់ស្កាត់អំពើបៀតបៀនលើស្ត្រីទាំងនោះទេ។ ផ្ទុយទៅវិញ រដ្ឋាភិបាលហាក់បើកដៃទូលំទូលាយក្នុងការលេងល្បែងទាំងនោះដោយសេរី ដែលបង្កលក្ខណៈងាយស្រួលដល់ជនខិលខូច។ ម្យ៉ាងវិញទៀត ជនរងគ្រោះដោយការបៀតបៀនទាំងនេះក៏ទំនងជាពិបាកប្ដឹង ឬស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ពីស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាលផងដែរ ហើយពេលខ្លះពួកគាត់អាចនឹងរងការស្ដីបន្ទោសថែមទៀត។

ពលរដ្ឋរស់នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប លោកស្រី ឈុន ថុន ថ្លែងថា ដើមឡើយរាល់ពិធីបុណ្យចូលឆ្នាំពលរដ្ឋខ្មែរម្ដងៗ ពលរដ្ឋខ្មែរនាំគ្នាលេងល្បែងប្រជាប្រិយ ដូចជាចោលឈូង បោះអង្គុញ ទាញព្រ័ត្រជាដើម ហើយពួកគាត់តែងតែគោរព និងឱ្យតម្លៃ និងសេចក្ដីថ្លៃថ្នូររបស់ស្ត្រី។ ប៉ុន្តែលោកស្រីសោកស្ដាយរដូវកាលបុណ្យឆ្នាំថ្មីបច្ចុប្បន្ន យុវជនបែរជានាំគ្នាលេងប៉ាតម្សៅ និងគប់ទឹក ដែលធ្វើឱ្យអ្នកដំណើររងគ្រោះថ្នាក់ ហើយស្ត្រីមួយចំនួនត្រូវរងគ្រោះដោយសារបុរសកេងចំណេញក្នុងឱកាសនេះទៀតផង៖ «អត់ចង់ឱ្យលេងជ្រុលជ្រួសលើស្ត្រី ឬក្មេងៗ ដែលគ្នាកំពុងដើរលេងដោយមិនសមរម្យ វាខាតបង់ ព្រោះស្ត្រីត្រូវការពារកិត្តិយសរបស់គ្នា ប៉ុន្តែបុរសខ្លះមិនគិតការពារស្ត្រីទេ គិតឃើញចាប់យកតែម្ដង វាធ្វើឱ្យខុសប្រពៃណីខ្មែរហើយហ្នឹងឯង»។

ជុំវិញរឿងនេះ នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ (Licadho) លោក អំ សំអាត មានប្រសាសន៍ថា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិលេងល្បែងកំសាន្តទាំងនោះក៏ពិតមែន ប៉ុន្តែពួកគេត្រូវគោរពសិទ្ធ និងសេចក្ដីថ្លៃថ្នូររបស់ស្ត្រីដែរ។ លោកមើលឃើញថា ស្ត្រីងាយរងការរំលោភបំពានចេញពីទម្រង់ល្បែងកំសាន្តក្នុងពិធីបុណ្យចូលឆ្នាំថ្មីនេះ ដោយសារការធ្លាក់ចុះក្រមសីលធម៌សង្គម និងខ្វះការយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរពាក់ព័ន្ធ។ លោកបន្ថែមថា ប្រសិនបើអាជ្ញាធរមិនទប់ស្កាត់បញ្ហាឱ្យទាន់ពេលវេលានោះទេ ស្ត្រីនឹងទទួលនឹងទទួលរងគ្រោះបន្ថែមទៀត៖ «ទៅជារឿងបៀតបៀន ទៅជារឿងអីទៅអាហ្នឹងវាប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់ស្ត្រីវិញ ចំណុចទាំងអស់ហ្នឹងហើយដែលអាជ្ញាធរគួរតែមានការអប់រំធ្វើយ៉ាងមិចកុំការលេងហ្នឹងក្លាយជាការប៉ះពាល់ដល់ប្រពៃណីជាតិ ប៉ះពាល់ទៅដល់ការបៀតបៀនធ្វើឱ្យមានគ្រោះថ្នាក់ទៅដល់ប្រជាពលរដ្ឋ»។

# ថៃសហការជាមួយកម្ពុជា
# ពិនិត្យមើលករណីជនរងគ្រោះរាយការណ៍អំពីការបង្ខាំងជនជាតិថៃនៅកម្ពុជា

https://khmer.voanews.com/ 13 មេសា 2022

ភ្នំពេញ៖ មន្ត្រីនគរបាលជាន់ខ្ពស់កម្ពុជាឲ្យដឹងថា អាជ្ញាធរកម្ពុជាបានសហការជាមួយនគរបាលថៃ កាលពីពេលថ្មីៗនេះ ចុះពិនិត្យមើលកន្លែងមួយចំនួន ដែលត្រូវបានរាយការណ៍ថា ឃុំឃាំងជនជាតិថៃនៅក្នុងអគារ ដែលរកស៊ីតាមអនឡាញ។ មន្ត្រីកម្ពុជាអះអាងថា ជនជាតិថៃជាង៦០នាក់ ត្រូវបានឃាត់ខ្លួនសាកសួរ ហើយរកឃើញថាពួកគេមកធ្វើការខុសច្បាប់នៅខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។ នេះបើតាមអ្នកនាំពាក្យនគរបាលជាតិកម្ពុជា លោក ឆាយ គឹមខឿន។ លោកប្រាប់វីអូអេនៅថ្ងៃពុធនេះថា ជនជាតិថៃប្រមាណជាង ៦០នាក់នោះចូលមកធ្វើការនៅកម្ពុជាដោយខុសច្បាប់ ហើយចាញ់បោកមេខ្យល់ រហូតប្រកាសស្វែងរកជំនួយពីអាជ្ញាធរថៃ។ លោកបន្ថែមថា ការចុះត្រួតពិនិត្យអគារកាលពីពេលថ្មីៗនេះ ដោយសារមានការស្នើសុំពីអាជ្ញាធរថៃ ដែលទទួលព័ត៌មានទាក់ទងនឹងជនជាតិខ្លួនធ្វើការនៅកម្ពុជា។ លោកថ្លែងថា៖ «យើងបានរកឃើញពួកគាត់ និងបានរៀបចំបែបបទសហការព្រោះថៃគាត់មានបញ្ជីឈ្មោះរបស់គាត់។គាត់សុំសហការ។ យើងក៏ស្រាវជ្រាវទៅឃើញថាពួកគាត់សុទ្ធតែឆ្លៀតចូលមកធ្វើការដោយខុសច្បាប់។យើងចាប់ឃាត់ពួកគាត់ អនុវត្តទៅតាមច្បាប់អន្តោប្រវេសន៍ ហើយយើងបញ្ជូនចេញទៅថៃវិញ»។

បើតាមលោក ឆាយ គឹមខឿន គិតត្រឹមថ្ងៃពុធនេះ អាជ្ញាធរចាប់ឃាត់ខ្លួនជនជាតិថៃចំនួន ៦៦នាក់ដែលត្រូវបានចាត់ទុកថា មកកម្ពុជាដោយខុសច្បាប់ហើយក្នុងនោះបានបញ្ជូនត្រឡប់ទៅប្រទេសថៃវិញចំនួន៣១នាក់។ មន្ត្រីនគរបាលជាន់ខ្ពស់រូបនេះបន្ថែមថាភាគច្រើននៃជនជាតិថៃនោះមកធ្វើការនៅកាស៊ីណូ និងក្រុមហ៊ុនដែលមានប្រតិបត្តិការតាមប្រព័ន្ធអនឡាញ និងបានស្នើសុំអន្តរាគមន៍ នៅពេលដឹងថាខ្លួនចាញ់បោកមេខ្យល់ បើទោះបីជាពួកគេបានមកកម្ពុជាដោយខុសច្បាប់កាលពីដំបូងឡើយក៏ដោយ។ លោកបន្ថែមថា៖ «គាត់មកខុសច្បាប់ហើយ គាត់ថាគេចាប់ជំរិតគាត់។វាជារឿងកំហុសរបស់គាត់ទេ។ហើយតាមការផ្តល់ព័ត៌មានពីភាគីថៃថាពិត។ អ្នកខ្លះចាញ់បោកគេ ដោយសារការលួងលោម ប្រាក់ខែ ប្រាក់អីអ៊ីចឹង។ តែមួយចំនួនទៀតគាត់ដឹងថាគាត់មកខុសច្បាប់តែគាត់នៅតែប្រព្រឹត្តដើម្បីចង់បានប្រាក់ខែខ្ពស់អីអ៊ីចឹង។តែបែរជាខុសបំណង ហើយរកអ្នកណាជួយមិនបានគាត់បានប្តឹងទៅទូតហើយផ្តល់ព័ត៌មានដល់សមត្ថកិច្ចថៃថា គេចាប់គាត់មកស្រុកខ្មែរ។រឿងវាអញ្ចេះ»។

ស្នងការនគរបាលខេត្តព្រះសីហនុ លោក ជួន ណារិន្ទ ថ្លែងនៅថ្ងៃពុធថាកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរកម្ពុជា និងថៃ ចុះពិនិត្យអគារក្នុងខេត្តព្រះសីហនុ មិនផ្តោតលើការបង្ក្រាបបទឧក្រិដ្ឋឆបោកណាមួយដែលកើតឡើងលើទឹកដីកម្ពុជាឡើយ ប៉ុន្តែមានគោលបំណងសម្របសម្រួល ដើម្បីឲ្យជនជាតិថៃ ដែលត្រូវបានរកឃើញថា មកធ្វើការនៅកម្ពុជាដោយខុសច្បាប់នោះអាចត្រឡប់ទៅប្រទេសខ្លួនវិញបាន។ លោកថ្លែងថា៖ «មិនមានពាក់ព័ន្ធនឹងករណីបង្ក្រាបជនឆបោកណា ទេ។ ហើយករណីដែលយើងធ្វើកិច្ចសហប្រតិបត្តិការ ជនជាតិថៃ ដែលគាត់ចូលមកធ្វើការដោយខុសច្បាប់ ហើយគាត់ថា មានការស្ម័គ្រចិត្តចង់ទៅ វិលទៅប្រទេសវិញ គឺយើងបានសហការជាមួយនគរបាលថៃដើម្បីបញ្ជូនទៅភ្នំពេញ ឬយកទៅថៃ»។

វីអូអេមិនទាន់ទទួលបានការឆ្លើយតបពីស្ថានទូតថៃប្រចាំកម្ពុជានៅឡើយទេនៅថ្ងៃពុធនេះ។ ចំណែកព័ត៌មាននៅលើគេហទំព័ររបស់នគរបាលថៃ ដែលផ្សព្វផ្សាយកាលពីថ្ងៃចន្ទបានឲ្យដឹងថា មានការសហការគ្នារវាងនគរបាលថៃនិងកម្ពុជា ដើម្បីជួយជនជាតិថៃមួយចំនួន ដែលត្រូវបានមេខ្យល់បោកបញ្ឆោត និងបង្ខំឲ្យធ្វើការឲ្យក្រុមឆបោកតាមប្រព័ន្ធទូរសព្ទនៅខេត្តព្រះសីហនុ និងក្រុងភ្នំពេញ។ ព័ត៌មានខាងលើអះអាងថាក្នុង ប្រតិបត្តិការប៉ូលិសកាលពីថ្ងៃអាទិត្យ ទី១០ ខែមេសាប៉ូលិសថៃបានចុះពិនិត្យអគារកម្ពស់១០ជាន់មួយ ក្នុងសង្កាត់៤ ខេត្តព្រះសីហនុ។

ហើយរបាយការណ៍ប៉ូលិសថៃបានលើកឡើងថា ជនជាតិថៃចំនួន២៤នាក់ ត្រូវបានជួយសង្គ្រោះនៅក្នុងប្រតិបត្តិការនោះ។បើតាមគេហទំព័រនោះមានករណីចុះត្រួតពិនិត្យអគារចំនួនពីរនៅតំបន់កណ្តាលក្រុងភ្នំពេញផងដែរ ប៉ុន្តែប៉ូលិសបានអះអាងថា ក្រុមប្រតិបត្តិការឆបោកតាមប្រព័ន្ធទូរសព្ទបានរត់គេចខ្លួនអស់ មុនពេលអាជ្ញាធរបានទៅដល់ ដោយបន្សល់ទុកតុ កៅអី និងឯកសារមួយចំនួនប៉ុណ្ណោះ។

បើតាមគេហទំព័រ នោះ នគរបាលថៃបានប៉ាន់ប្រមាណថាមានជនជាតិថៃប្រមាណ១.៥០០នាក់ កំពុងជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការឆបោកនានានៅកម្ពុជា ដែលមានប្រភពនៅតាមសណ្ឋាគារ អគារស្នាក់នៅ ឬអគារបោះបង់ចោលផ្សេងៗ។ គួរបញ្ជាក់ថា កាលពីកន្លងទៅមានសេចក្តីរាយការណ៍ថា កម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធឺណិត ឬគេហៅថា Scam ដោយប្រើប្រាស់កម្លាំងបរទេស ក្នុងនោះមានជនជាតិថៃ និងចិនធ្វើការនៅតាមអគារក្នុងប្រទេសកម្ពុជា រហូតមានសេចក្តីរាយការណ៍អំពីការបង្ខាំងទុកពួកគេ មិនឲ្យមានសេរីភាពការធ្វើទារុណកម្មការជំរិតទារប្រាក់ជាដើម។ អង្គការសង្គមស៊ីវិលធ្លាប់បានបង្ហាញការព្រួយបារម្ភពាក់ព័ន្ធនឹងការបង្ខាំងមនុស្សប្រើប្រាស់ក្នុងការងារដែលជាញឹកញាប់ទាក់ទងនឹងប្រតិបត្តិការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិតដែលដាក់គោលដៅលើជនបរទេសរស់នៅខាងក្រៅប្រទេសកម្ពុជា។ នេះបើតាមសេចក្តីថ្លែងការណ៍របស់អង្គការសង្គមស៊ីវិលចេញផ្សាយកាលពីខែមីនា ឆ្នាំ២០២២។ ពួកគេស្នើឱ្យអាជ្ញាធរកម្ពុជាស៊ើបអង្កេតឱ្យបានពេញលេញទៅលើករណីនេះ។

នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូលោក អំ សំអាត បាននិយាយថាប្រសិនបើមានករណីនាំខ្លួនដោយមេខ្យល់ចូលមកធ្វើការនៅកម្ពុជាដោយខុសច្បាប់ពិតមែននោះ នោះការឃាត់ខ្លួនជនជាតិថៃក្នុងករណីខាងលើ នេះគឺជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋជួញដូរមនុស្សឆ្លងដែន។ហើយលោកបានស្នើឲ្យអាជ្ញាធរចាត់វិធានការផ្លូវច្បាប់លើជនពាក់ព័ន្ធទាំងអស់។ លោកថ្លែងថា៖ «ករណីនេះវាអាចពាក់ព័ន្ធជាមួយជនជាតិថៃដូចជាអ្នកពាក់ព័ន្ធខ្លះដែលជាកម្ពុជាយើង... ជនរបស់កម្ពុជា។ អ៊ីចឹងកិច្ចសហការនេះធ្វើយ៉ាងម៉េចត្រូវតែបង្ក្រាប ឬក៏តាមចាប់ទៅដល់អ្នកដែលចរាចរមនុស្ស ឬក៏ធ្វើការជួញដូរមនុស្សហ្នឹងណា»។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង និយាយថា បទឧក្រិដ្ឋជួញដូរមនុស្សក្រោមសណ្ឋានជាការនាំជនបរទេសមកជួញដូរនៅកម្ពុជា គឺជាបញ្ហាចោទថ្មីមួយ គួបផ្សំលើការជួញដូរមនុស្សក្រោមរូបភាពជទៃផ្សេងទៀត។ អ្នកស្រីបន្ថែមថា ករណីចាប់បង្ខាំង ឬបង្ខំឲ្យធ្វើការពាក់ព័ន្ធនឹងជនបរទេសនៅកម្ពុជាជារឿងស្មុគស្មាញមួយ ពាក់ព័ន្ធនឹងមេខ្យល់ និងជនរងគ្រោះ។ អ្នកស្រីថ្លែងថា៖ «នៅក្នុងករណីចាប់បង្ខាំងហ្នឹងវាពិបាកយល់ដែរព្រោះនៅពេលខ្លះ យើងរកឃើញថាមិនមានជាការចាប់បង្ខាំងដោយគាត់គ្មានសេរីភាពចេញទៅណាសោះទេ។ ប៉ុន្តែរឿងសំខាន់គឺ គាត់មិនបានទទួលលទ្ធផលតាមអ្វីដែលគាត់រំពឹងទុក។ វាមិនខុសអ្វីពីជនជាតិកម្ពុជាដែលទៅក្រៅទេ គឺដូចគ្នា។ មានន័យថា នៅពេលមានបញ្ហា គឺពួកគាត់នេះ ច្រើនតែជាអ្នកមិនទទួលបានផលប្រយោជន៍ តាមការសន្យារបស់មេខ្យល់»។ បើតាមអ្នកស្រី ជូ ប៊ុនអេង អាជ្ញាធរកម្ពុជាបានបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្សបាន ៣៥៩ ករណី នៅឆ្នាំ២០២១ ដែលជាកំណើនជាងពីរដងពីចំនួន ១៥៥ ករណីនៅ ឆ្នាំ២០២០។

# ថ្ងៃទី១៩ ខែ មេសា ឆ្នាំ២០២២
## ភាពមន្ទិលសង្ស័យជុំវិញ
## ផែនការការងាររបស់ថៃក្នុងការនាំពលករ ក្នុងនោះមានចំនួន ៣៩៣៣៣ នាក់ពីកម្ពុជា

https://www.khmertimeskh.com/ Khmer Times 19/04/2022

ខណៈពេលដែលប្រជាជនថៃប្រហែល ៦០០,០០០នាក់ នៅតែគ្មានការងារធ្វើ រដ្ឋាភិបាលបានអនុម័តផែនការ ដើម្បីនាំយកពលករចំណាកស្រុកបន្ថែមប្រហែល ១៧០,០០០ នាក់ តាមការស្នើសុំដោយអាជីវកម្មដែលចង់បានកម្លាំងនៅពេលពួកគេចាប់ផ្តើមប្រតិបត្តិការឡើងវិញ។ កម្ពុជា និងឡាវ មានសមត្ថភាពបញ្ជូនពលករប្រមាណ ៦០០០នាក់ ទៅប្រទេសថៃ ក្រោមអនុស្សរណៈយោគយល់គ្នា ស្តីពីប្រតិបត្តិការការងារ ខណៈមីយ៉ាន់ម៉ានៅតែមិនអាចធ្វើដូច្នេះបាន ដោយសារបញ្ហាផ្ទៃក្នុងរបស់ខ្លួន។

លោក Pairoj Chotikasathien អគ្គនាយក នៃនាយកដ្ឋានការងារបាននិយាយថា ថ្មីៗនេះប្រទេសថៃបានចុះហត្ថលេខាលើអនុស្សរណៈ ដើម្បីនាំយកពលករចំណាកស្រុកចំនួន ១១៧,០២៩ នាក់បន្ថែមទៀតពីប្រទេសមីយ៉ាន់ម៉ា ៣៨,៩៣៣ នាក់ ពីប្រទេសកម្ពុជា និង ១១,៩៩៩ នាក់ មកពីប្រទេសឡាវ។ អ្នកខ្លះបានសួរថាហេតុអ្វីបានជាមិនអោយជនជាតិថៃដែលអត់ការងារធ្វើ ចូលធ្វើការងារទាំងនេះមុននឹងនាំចូលពលករចំណាកស្រុកបន្ថែម ខណៈដែលអ្នកផ្សេងទៀតមើលឃើញថាការលើកឡើងបែបនេះមិនសមហេតុផលទេ ដោយអះអាងថាជនជាតិថៃមិនធ្វើការងារដោយប្រើកំលាំងនោះទេ។

លោក Yongyuth Chalamwong នាយកផ្នែកស្រាវជ្រាវការងារនៅមូលនិធិវិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍ប្រទេសថៃ (TDRI) បាននិយាយថា លោកជឿជាក់ថាអ្នកស្វែងរកការងារធ្វើជនជាតិថៃប្រហែល ៦០០,០០០ នាក់នឹងអាចបំពេញកន្លែងការងារទាំងនេះបាន។ សាស្ត្រាចារ្យ Yongyuth បាននិយាយថា ពាក់កណ្តាលនៃអ្នកទាំងនេះ គឺជាកម្មករគ្មានជំនាញ ចំណែកពាក់កណ្តាលទៀតជានិស្សិតបញ្ចប់បរិញ្ញាបត្រ ដែលអ្នកខ្លះត្រូវបានអោយធ្វើសម្រាប់អ្នកដែលមានការអប់រំតិចតួច។ លោកបាននិយាយថា ស្ថានភាពអត់ការងារធ្វើនៅក្នុងប្រទេសថៃកំពុងមានការព្រួយបារម្ភ ជាពិសេសសម្រាប់និស្សិតទើបបញ្ចប់ការសិក្សាដែលមានអាយុពី ១៥-២៤ ឆ្នាំ ដែលពិបាកក្នុងការស្វែងរកការងារធ្វើនៅក្នុងទីផ្សារការងារដែលកំពុងធ្លាក់ចុះ។ លោកបានបន្តថា បើប្រៀបធៀបទៅនឹងអ្នកដែលមានបទពិសោធន៍ ជាធម្មតាវាពិតជាពិបាកសម្រាប់និស្សិតទើបបញ្ចប់ការសិក្សាក្នុងការស្វែងរកការងារធ្វើសូម្បីតែក្នុងស្ថានភាពការងារធម្មតាក៏ដោយ។ លោកបានបន្តថា អ្វីដែលជាងនេះទៅទៀត ផែនការនាំពលករចំណាកស្រុកកាន់តែច្រើន ជាពិសេសមកពីប្រទេសមីយ៉ាន់ម៉ា មិនអាចអនុវត្តបានភ្លាមៗទេ ដោយសារភាពចលាចលនយោបាយក្នុងប្រទេស។

លោកថា ប្រតិបត្តិករអាជីវកម្ម ដូចជាអ្នកនៅក្នុងឧស្សាហកម្មផ្លែឈើ គួរតែពិចារណាជួលកម្មករថៃបន្ថែមទៀត ជាជាងពឹងផ្អែកលើជនចំណាកស្រុកដែលពួកគេធ្លាប់ជួលមុនការរាតត្បាតជំងឺកូវីដ។ ពួកគេក៏អាចនឹងឃើញកម្មករដែលមានឆន្ទៈក្នុងការទទួលការងារច្រើនជាងការរំពឹងទុករបស់ពួកគេ។ លោកបាននិយាយថា ទោះជាយ៉ាងណាក៏ដោយ និយោជកទាំងនេះប្រហែលជាត្រូវកែលម្អស្តង់ដារសុវត្ថិភាពការងារដោយការទទួលយកបច្ចេកវិទ្យាកសិកម្មថ្មី ដើម្បីទាក់ទាញកម្មករថៃឱ្យមកធ្វើការឱ្យពួកគេ។ លោកបានបន្តថា កម្មកររោងចក្រក្រោមកិច្ចសន្យាជាច្រើនដែលត្រូវបានបញ្ឈប់កាលពីពេលថ្មីៗនេះ នៅខេត្តរ៉ាក់យ៉ុងប្រហែលជាចង់ធ្វើការងាររើសផ្លែឈើក្នុងខេត្តប្រសិនបើពួកគេត្រូវបានជួល។ លោកបាននិយាយថា ការកែលម្អស្ថានភាពគ្មានការងារធ្វើមិនមែនជាទំនួលខុសត្រូវតែមួយគត់របស់ក្រសួងការងារនោះទេ ប៉ុន្តែក៏ជាបន្ទុករបស់ភាគីជាច្រើនទៀត រួមទាំងប្រតិបត្តិករអាជីវកម្មផងដែរ។

លោកបន្តថា ទន្ទឹមនឹងនេះ ពលករថៃគួរតែលើកកម្ពស់ក្រមសីលធម៌ការងាររបស់ខ្លួន និងព្យាយាមស្មោះត្រង់ជាមួយនិយោជកកាន់តែខ្លាំង។ លោកជឿជាក់ថា មនុស្សគ្រប់រូបមានការងារសមរម្យសម្រាប់ពួកគេ ប៉ុន្តែបញ្ហាគឺកម្មករជាច្រើននៅតែមិនអាចទទួលបានព័ត៌មានស្តីពីឱកាសការងារដែលអាចសាកសមនឹងពួកគេ។

ទន្ទឹមនឹងនោះ លោក Poj Aramwattananont អនុប្រធានសភាពាណិជ្ជកម្មថៃបាននិយាយថា អាជីវកម្មនៅទូទាំងវិស័យជាច្រើនឥឡូវនេះមានបុគ្គលិកតិច។ លោកបន្តថា សម្រាប់សំណង់មួយត្រូវការកម្មករជិត ១០ ម៉ឺននាក់បន្ថែមទៀត ជាពិសេសសម្រាប់គម្រោងដែលមានសម្បទានពីរដ្ឋាភិបាល។ លោកបានបន្តថា អាជីវកម្មទាំងអស់នេះកំពុងស្នើសុំឱ្យរដ្ឋាភិបាលនាំយកពលករចំណាកស្រុកកាន់តែច្រើន ជាពិសេសជនជាតិមីយ៉ាន់ម៉ាដែលមានតម្រូវការរហូតដល់ ៨០% នៃតម្រូវការនៅក្នុងទីផ្សារការងារនៅទីនេះ។ ចំពោះគំនិតជំនួសពលករចំណាកស្រុកជាមួយជនជាតិថៃដែលគ្មានការងារធ្វើនោះ លោក Poj បាននិយាយថាវាទំនងជាមិនជោគជ័យទេព្រោះមានមនុស្សមិនច្រើននាក់ដែលមានឆន្ទៈធ្វើការងារប្រើកំលាំងខ្ពស់ ដែលកម្មករចំណាកស្រុកកំពុងធ្វើនោះទេ។ លោកបាននិយាយថា ជាច្រើនឆ្នាំកន្លងមក ពលករថៃភាគច្រើនដែលធ្វើការងារប្រភេទនេះ ដូចជាការងារសំណង់ គឺជាមនុស្សដែលមកពីភាគឦសាននៃទីក្រុងបាងកក និងខេត្តជុំវិញ។ លោកបានបន្តថា ឥឡូវនេះ មានមនុស្សតិចណាស់មកពីតំបន់នេះដែលធ្វើការងារទាំងនេះ។ លោកបានបន្តថា៖ «ប្រជាជនថៃភាគច្រើនមាននិន្នាការស្វែងរកការងារដែលមិនសូវប្រើកំលាំង។ "មនុស្សជំនាន់ថ្មីដែលមានអាយុពី ១៨-៣០ ឆ្នាំ មានទំនោរទៅខាងអាជីវកម្មអនឡាញ ដែលរកប្រាក់បានកាន់តែច្រើន។"

លោក Chalee Loysoong ប្រធានគណៈកម្មាធិការសាមគ្គីភាពការងារថៃ បាននិយាយថា និយោជកដែលជួលកម្មករថៃ និងពលករចំណាកស្រុកមុនជំងឺរាតត្បាត គួរពិចារណាជួលជនជាតិថៃបន្ថែមទៀត ដើម្បីជំនួសពលករចំណាកស្រុកដែលចាកចេញពីប្រទេសថៃ ហើយមិនអាចវិលត្រឡប់មកវិញបាន។ លោកបាននិយាយថា មានពលករចំណាកស្រុកជាង ២.១ លាននាក់ត្រូវបានអនុញ្ញាតឱ្យធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសថៃក្នុងអំឡុងពេលនៃជំងឺរាតត្បាតកូវីដ។ លោកបានបន្តថា ដោយសារខិតខំរក្សាកម្មករទាំងនេះ រដ្ឋាភិបាលបានសម្រេចអនុញ្ញាតបន្ថែមទៀតឱ្យពួកគេមានប័ណ្ណការងារ និងបន្តទិដ្ឋាការដោយមិនចាំបាច់វិលត្រឡប់ទៅប្រទេសកំណើតវិញជាមុនឡើយ ព្រោះពួកគេត្រូវធ្វើក្នុងស្ថានភាពធម្មតា៕ ប្រភព: Bangkokpost

## ថ្ងៃទី២០ ខែ មេសា ឆ្នាំ២០២២

### អាជ្ញាធរខេត្តបន្តរឹតបន្តឹង
### ការពារតាមព្រំដែនកម្ពុជា-ថៃ បារម្ភក្រែងពលករលួចឆ្លងដែនខុសច្បាប់

https://www.postkhmer.com/ ឡាយ សាមាន | Publication date 19 April 2022 | 10:55 ICT

**ឧត្តរមានជ័យ/បន្ទាយមានជ័យ/ពោធិ៍សាត់:** អាជ្ញាធរនៅជាប់ព្រំដែនកម្ពុជា-ថៃ បន្តរឹតបន្តឹង និងដាក់កម្លាំងការពារនៅតាមព្រំដែន ដោយបារម្ភពីពលករលួចឆ្លងដែនខុសច្បាប់ ខណៈចំនួនពលករត្រឡប់ពីប្រទេសថៃចូលស្រុកវិញ មានការថយចុះផងដែរ ក្រោយពីបញ្ចប់បុណ្យចូលឆ្នាំប្រពៃណីខ្មែរ។

អ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យ លោក ផល លឹម ប្រាប់ភ្នំពេញប៉ុស្តិ៍នាថ្ងៃទី ១៨ មេសាថា មុនចូលឆ្នាំខ្មែរ ពលករជាច្រើនបានសម្រុកវិលចូលស្រុក ដើម្បីជួបជុំគ្រួសារ និងដើរកម្សាន្ត ហើយពលករខ្លះមិនទាន់ត្រឡប់ទៅធ្វើការនៅថៃនោះទេ។ លោកបញ្ជាក់ថា៖ «ព្រោះពលករខ្លះគាត់នៅដើរលេងសប្បាយ វត្តខ្លះគេនៅលេង ១ អាទិត្យទៀតឯណោះ»។ ទោះយ៉ាងណា លោកបានឱ្យដឹងថា ទោះបីនៅខេត្តឧត្តរមានជ័យ មិនសូវមានពលករលួចឆ្លងដែនទៅថៃក្តី ប៉ុន្តែអាជ្ញាធរខេត្តបន្តដាក់កម្លាំងនៅតាមគោលដៅ ដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់ក្រោយ

ចូលឆ្នាំខ្មែរ។ លោកថ្លែងថា៖ «ខេត្តឧត្តរមានជ័យមិនសូវមានពលករឆ្លងដែនខុសច្បាប់ទៅថៃទេ ព្រោះដីវាខ្ពស់ ប៉ុន្តែបើមកពីថៃវិញវាទាប។ អ៊ីចឹងភាគច្រើនគាត់ឆ្លងដែនខុសច្បាប់តាមច្រកខេត្តបន្ទាយមានជ័យ បើគាត់ចុះពីថៃបាន។ តែបើឡើងទៅថៃវិញ អត់បានទេ ព្រោះវាខ្ពស់ ហើយអាជ្ញាធរខេត្តនៅបន្តដាក់កម្លាំងនៅតាមព្រំដែន និងតាមគោលដៅ មិនមានដកកម្លាំងនោះទេ»។

លោក ផល លឹម ឱ្យដឹងដែរថា ក្រោយចូលឆ្នាំខ្មែរ ពលករត្រឡប់ពីថៃវិញមានការថយចុះខ្លាំង។ ប៉ុន្មានថ្ងៃចុងក្រោយនេះ ពលករវិលចូលស្រុកក្នុង ១ ថ្ងៃនៅសល់ តែខ្ទង់ ៦០ ទៅ ៨០ នាក់ទេ។ មុនចូលឆ្នាំខ្មែរ ដោយគិតពីដើមខែមេសាមក ពលករវិលចូលស្រុកក្នុង ១ ថ្ងៃ ៥០០ ទៅ ១ ពាន់នាក់។ បើតាមរបាយការណ៍ខេត្តឧត្តរមានជ័យ ចំនួនពលករចំណាកស្រុកមកពីប្រទេសថៃ តាមច្រកអន្តរជាតិខេត្តឧត្តរមានជ័យ ក្នុងអំឡុងពេលចូលឆ្នាំខ្មែរគិតពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៧ ខែមេសានេះ មាន ៣៦៤ នាក់។

លោក លាង ទិត្យដ្ឋាន អ្នកនាំពាក្យសាលាខេត្តពោធិ៍សាត់បានថ្លែងនាថ្ងៃទី ១៨ មេសាថា បច្ចុប្បន្ន ពលករឆ្លងតាមព្រំដែនអន្តរជាតិថ្មដាមានចំនួនតិច ដោយសារបញ្ហាកូវីដ ១៩ ខណៈច្រកព្រំដែនមួយនេះ បើកសម្រាប់តែការដឹកទំនិញប៉ុណ្ណោះ។ ប៉ុន្តែលោកថា ក្រោយចូលឆ្នាំខ្មែរ អាជ្ញាធរខេត្តក៏បានរឹតបន្តឹងនៅតាមច្រកព្រំដែនផងដែរ។ លោកថ្លែងថា៖ «នៅពោធិ៍សាត់ អត់មាន ច្រករបៀងទេ ហើយសម្រាប់កម្លាំងនៅតាមព្រំដែន យើងនៅបន្តដាក់ជាប្រចាំ ដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់»។

អភិបាលរងខេត្តបន្ទាយមានជ័យ លោក ង៉ោ ម៉េងជ្រួន ថ្លែងថា អាជ្ញាធរខេត្តមិនបានបន្ធូរបន្ថយកម្លាំងនៅតាមព្រំដែននោះទេ ទោះបីមុនចូលឆ្នាំ និងក្រោយចូលឆ្នាំក៏ដោយ មានតែបង្កើនការប្រុងប្រយ័ត្ន ក្នុងការទប់ស្កាត់ការឆ្លងដែនខុសច្បាប់។ លោកថា៖ «ចំពោះបញ្ហាទុច្ចរិត ដែលរកស៊ីជួញដូរមនុស្ស ឬហៅថាមេខ្យល់នោះ ក្នុងនាមអាជ្ញាធរខេត្ត បានចេញបញ្ជាទប់ស្កាត់យ៉ាងតឹងរ៉ឹងបំផុតចំពោះបុគ្គលដែលបានប្រព្រឹត្តនាំមនុស្សឆ្លងដែនខុសច្បាប់ យើងបានអនុវត្តដែរ»។

ពាក់ព័ន្ធការឆ្លងដែនខុសច្បាប់នេះ នគរបាលស្រុកសំពៅលូន ខេត្តបាត់ដំបង បានឃាត់ខ្លួន និងបញ្ជូនសំណុំរឿងមេខ្យល់ម្នាក់ទៅកាន់ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ករណីនាំពលករលួចឆ្លងដែនទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់។ ហ្វេសប៊ុកស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងឱ្យដឹងថា ជនសង្ស័យដែលជាមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី ១៤ មេសា នៅក្រុមទី ៧ ភូមិគីឡូ ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន នៅវេលាម៉ោង ៥ និង ៣០ នាទីព្រឹក។ ប្រភពបន្តថា ការឃាត់ខ្លួននេះ បន្ទាប់ពីកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ កម្លាំងកងយោធពលខេមរភូមិន្ទវរៈលេខ ១ និងកម្លាំងវរសេនាតូចលេខ ៥៣៣ ប្រចាំការតាមមាត់អូរព្រំដែនកម្ពុជា-ថៃ បានចុះបង្ក្រាបករណីការនាំចេញដោយមិនស្របច្បាប់សម្រាប់ការនាំឆ្លងដែន។ ក្នុងប្រតិបត្តិការនេះ សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ ឈ្មោះ សោម បូរិទ្ធ ភេទប្រុស អាយុ ៣៣ ឆ្នាំ មានទីលំនៅ ភូមិគីឡូ ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។

ចំណែកពលករ ២ នាក់ទៀតត្រូវជាប្ដី-ប្រពន្ធ ឈ្មោះ ប៊ុន សុភាព ភេទប្រុស អាយុ ៤៣ ឆ្នាំ និងឈ្មោះ លូត ឡឹង ភេទស្រី អាយុ ៤២ ឆ្នាំមានទីលំនៅភូមិផ្លែខាំប្រើស ឃុំព្រៃកដឹក ស្រុកមោងឫស្សី ខេត្តបាត់ដំបង បម្រុងចូលទៅក្នុងប្រទេសថៃ ដោយយកប្រាក់ថ្លៃនាំផ្លូវក្នុងម្នាក់ៗចំនួន ៥ ៥០០ បាត (ប្រាក់ថៃ)។ បច្ចុប្បន្ន ពលករទាំង ២ នាក់ត្រូវបានកម្លាំងសមត្ថកិច្ចធ្វើការអប់រំ និងធ្វើកិច្ចសន្យាឱ្យបញ្ឈប់សកម្មភាព និងឱ្យវិលត្រឡប់ទៅមូលដ្ឋានវិញ។ រីឯជនសង្ស័យជាមេខ្យល់ សមត្ថកិច្ចកំពុងកសាងសំណុំរឿងបញ្ជូនទៅការិយាល័យជំនាញនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងចាត់ការបន្តតាមនីតិវិធីច្បាប់៕

# អាជ្ញាធរកំពុងឃ្លាំមើលយ៉ាងតឹងរ៉ឹងក្នុងការទប់ស្កាត់ការឆ្លងព្រំដែនខុសច្បាប់

https://www.khmertimeskh.com/ ឃឹម ស្រីលីន / April 20, 2022

អាជ្ញាធរបានហាមប្រាមពលករមិនឲ្យចេញទៅប្រទេសថៃ ដោយខុសច្បាប់ ហើយចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីតាមចាប់មេខ្យល់ និងអ្នករត់ការ។ ពលរដ្ឋខ្មែររាប់ម៉ឺននាក់ ត្រូវបានគេរំពឹងថា នឹងត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ ហើយអាជ្ញាធរបានបង្កើនការឃោមកាម ដើម្បីបញ្ឈប់អ្នកឆ្លងដែនខុសច្បាប់ និងតាមចាប់មេខ្យល់ និងអ្នករត់ការដែលដឹកនាំពលករឆ្លងព្រំដែនដោយខុសច្បាប់។

អភិបាលរងខេត្តបន្ទាយមានជ័យ លោក ង៉ោ ម៉េងជ្រួន មានប្រសាសន៍ថា អាជ្ញាធរកម្ពុជានឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយសមភាគីថៃ ដើម្បីទប់ស្កាត់ការការឆ្លងដែនដោយខុសច្បាប់។ លោកថា៖ « ប្រហែល ៧០% នៃពលករដែលត្រឡប់មកពីប្រទេសថៃកាលពីសប្តាហ៍មុន គឺជាពលករខុសច្បាប់ដែលបានទទួលការងារតាមរយៈមេខ្យល់ដែលជាឈ្មួញកណ្តាលដែលមានចរិតបោកប្រាស់ប្រជាពលរដ្ឋ»។ លោកបន្តថា៖ « យើងចង់ចាប់មេខ្យល់។ យើងក៏ចង់ចាប់អ្នករត់ការដែលដឹកនាំពលករខុសច្បាប់ឆ្លងព្រំដែនផងដែរ»។ លោកថា៖«យើងរំពឹងថាការឆ្លងកាត់ទាំងនេះនឹងចាប់ផ្តើម ប្រសិនបើមនុស្សរាប់ពាន់នាក់បានត្រឡប់មក ដើម្បីប្រារព្ធបុណ្យចូលឆ្នាំខ្មែរ ហើយឥឡូវពួកគេចង់ត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ»។ លោកបានបន្ថែមថា៖ «បន្ទាយមានជ័យមានច្រកព្រំដែនជាច្រើន ហើយវាងាយស្រួលណាស់ក្នុងការរត់ពន្ធពលករខុសច្បាប់ឆ្លងកាត់។ មេខ្យល់នឹងច្បាស់ជាបបួលកម្មករដោយខុសច្បាប់ ហើយដឹកនាំពួកគេឆ្លងព្រំដែន។ ពួកគេរកលុយបានច្រើនតាមវិធីនេះ»។ លោកបានបន្តថា៖«យើងដាក់ប៉ូលិស និងទាហានបន្ថែមទៀតនៅច្រកឆ្លងកាត់ និងពង្រឹងការល្បាតតាមព្រំដែន។ អាជ្ញាធរនឹងត្រូវចុះល្បាត២៤ម៉ោង ហើយយើងនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីព្រំដែនថៃ»។

លោក ម៉េង ជ្រួន បានមានប្រសាសន៍ថា៖ « មេខ្យល់ដែលធ្វើការខុសច្បាប់នឹងប្រឈមមុខនឹងច្បាប់នៅពេលចាប់ខ្លួន។ យើងនឹងយកឱកាសនេះ ដើម្បីចាប់ពួកគេ។ ថៃក៏នឹងតាមរកពួកគេ ហើយនឹងចាប់ខ្លួនពួកគេផងដែរ»។ លោកបានបន្ថែមថា ការឆ្លងដែនខុសច្បាប់អាចកាត់បន្ថយបានច្រើន ប្រសិនបើចាប់បានមេខ្យល់។ លោកថា អាជ្ញាធរចង់ឲ្យពលករដែលចង់ទៅធ្វើការនៅប្រទេសថៃ មកចុះឈ្មោះជាមួយក្រុមហ៊ុនថៃ ឬភ្នាក់ងារស្របច្បាប់នៅកម្ពុជា។ លោកបន្តថា នៅពេលដែលពួកគេបានឯកសារ និងការងារត្រឹមត្រូវ ថៅកែថៃរបស់ពួកគេនឹងមកចាំនៅច្រកព្រំដែន ដើម្បីមកទទួលយកពួកគេ និងជួយការឆ្លងកាត់របស់ពួកគេ។ លោកបានបន្ថែមថា និយោជកថៃខ្លះអាចជួលកម្មករបានចន្លោះពី ៥០០ ទៅ ១០០០នាក់។

វិធានការ និងយុទ្ធសាស្ត្រសន្តិសុខស្រដៀងគ្នានេះ ក៏កំពុងត្រូវបានអនុវត្តនៅក្នុងខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យផងដែរ។ មនុស្សរាប់ពាន់នាក់ក៏បានត្រឡប់មកពីប្រទេសថៃវិញតាមព្រំដែនខេត្ត។ លោក សុខ លូ អភិបាលខេត្តបាត់ដំបង បានប៉ាន់ប្រមាណថា ពលករចំណាកស្រុកប្រហែល ២០០០ នាក់បានវិលត្រឡប់មកវិញកាលពីសប្តាហ៍មុន។ លោកថា៖ « យើងកំពុងតាមដានព្រំដែនយ៉ាងជិតស្និទ្ធជាមួយមន្ត្រីថៃ ព្រោះយើងបានប្តេជ្ញាក្នុងការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ក្នុងខេត្តរបស់យើង»។ លោកថា អាជ្ញាធរនឹងមិនអនុញ្ញាតឱ្យមានការឆ្លងដែនខុសច្បាប់ ហើយមន្ត្រីប៉ូលិស និងទាហាននឹងសហការជាមួយសមភាគីថៃក្នុងការចាត់វិធានការនេះ។

អភិបាលរងខេត្តឧត្តរមានជ័យ លោក ឌី រ៉ាដូ មានប្រសាសន៍ថា មានការបោកប្រាស់របស់មេខ្យល់ក្នុងការល្បួងពលករទៅធ្វើការនៅប្រទេសថៃ ហើយឆ្លងដែនដោយខុសច្បាប់ គឺពួកគេកំពុងឈរជើងនៅតាមព្រំដែន ក៏ដូចជាជ្រើសរើសមនុស្សតាមភូមិដែរ។ លោកបានថ្លែងប្រាប់ឱ្យដឹងថា៖ «ប្រជាជនរបស់យើងកំពុងប្រថុយប្រថានយ៉ាងខ្លាំងក្នុងការឆ្លងដែនខុសច្បាប់សម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។ ពួកគេភាគច្រើននឹងក្លាយជាជនរងគ្រោះនៃមេខ្យល់ដែលគ្មានសីលធម៌។ យើងត្រូវតែជួយប្រជាជនយើង ហើយយើងអាចជួយពួកគេបានដោយការលើកទឹកចិត្ត

និងជួយពួកគេឱ្យទៅស្របច្បាប់»។ លោកបានបន្ថែមថា៖ «សំខាន់បំផុត យើងត្រូវតែចាប់ក្រុមហ៊ុនមេខ្យល់ និងភ្នាក់ងារការងារខុសច្បាប់របស់ពួកគេ»៕

## ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២

## តុលាការកំពូល ជម្រះបណ្តឹងសាទុក្ខ បុរសម្នាក់ ពាក់ព័ន្ធបទល្មើស សព្វកម្មមានស្ថានទម្ងន់ទោស បើកកន្លែងម៉ាស្សាបង្កប់កន្លែងរំលោភសិច

https://cen.com.kh/ Posted ByPen Srey NeatApril 20, 2022

ភ្នំពេញ : តុលាការកំពូលកាលពីថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២២ នេះ បានបើកសវនាការជំនុំជម្រះ លើបណ្តឹងសាទុក្ខ បុរសជាប់ចោទម្នាក់ ដែលតុលាការថ្នាក់ក្រោម កាត់ទោស ដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ ជាប់ពាក់ព័ន្ធករណីបើកកន្លែងម៉ាស្សា តែបង្កប់កន្លែងរំលោភសិច ប្រព្រឹត្ត ភូមិវិហារសួគ៌ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ ២០២០ ។

លោកជំទាវ គិម សត្ថាវី ជាប្រធានចៅក្រមជំនុំជម្រះនៃ តុលាការកំពូល បានឲ្យដឹងថា ជនជាប់ចោទរូបនេះមាន ឈ្មោះ ថៃ ម៉េងគង់ ភេទប្រុស អាយុ ២៩ ឆ្នាំ មុខរបរ ថៅកែហាងម៉ាស្សា ។ នៅក្នុងសំណុំរឿងក្តីនេះ សាលាដំបូងខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ ២០២១ បានកាត់ទោស ជនជាប់ចោទ ដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ និង បង្គាប់ឱ្យសងជំងឺចិត្តដល់ជនរងគ្រោះចំនួនពីរនាក់ ក្នុងម្នាក់ៗ ចំនួន ៥០០ ដុល្លារ ពីបទ " សព្វកម្មមានស្ថានទម្ងន់ទោស " តាមមាត្រា ២៧ នៃច្បាប់ស្តីពីការជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ ។ ជនជាប់ចោទបានប្តឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍រាជធានី បានតម្កល់ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដដែល ។ ជនជាប់ចោទ ក៏បានបន្តប្តឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត។ ជនជាប់ចោទរូបនេះ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២០ នៅភូមិវិហារសួគ៌ ឃុំវិហារសួគ៌ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ នៅក្នុងសំណុំរឿងនេះ តុលាការកំពូលនឹងប្រកាសដីកា នៅព្រឹកថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០២២ នេះ ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## ពលរដ្ឋខ្មែរជាច្រើននាក់បន្តសំរុកឆ្លងដែនរកការងារធ្វើ តែត្រូវបានអាជ្ញាធរថៃចាប់ខ្លួន

https://www.rfa.org/khmer/ 2022.04.20

ពលរដ្ឋខ្មែរជាច្រើននាក់ បាននាំគ្នាឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ ក្រោយពេលចប់បុណ្យចូលឆ្នាំប្រពៃណីខ្មែរ ក្នុងនោះពលករខ្លះត្រូវបានអាជ្ញាធរថៃចាប់ខ្លួននៅតំបន់ព្រំដែន។ ទូរស្សប៉ុស្តិ៍លេខ៧ របស់ថៃ ចុះផ្សាយ នៅថ្ងៃ១៩ ខែមេសា ថាមានពលរដ្ឋខ្មែរចំនួន៧នាក់ ត្រូវបានអាជ្ញាធរចាប់ខ្លួនក្នុងពេលឆ្លងដែននៅភូមិ Ban Dong Ngu ឃុំ Pa Rai ស្រុក Aranyaprathet ខេត្ត Sa Kaeo។ ប្រភពដដែលឱ្យដឹងថា ពលករទាំង៧ នាក់នោះមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ បានចាញ់បោកមេខ្យល់ជនជាតិខ្មែរនាំសារភាពថា បានធ្វើដំណើរមកពីខេត្តបន្ទាយមានជ័យដោយឆ្លងដែនខុសច្បាប់ ដើម្បីទៅរកការងារធ្វើនៅប្រទេសថៃ។

ទាក់ទងនឹងបញ្ហានេះស្នងការរងទទួលបន្ទុកការពារព្រំដែនខេត្តបន្ទាយមានជ័យ លោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីថា លោកពុំទទួលព័ត៌មានអំពីអាជ្ញាធរថៃចាប់ពលករខ្មែរទាំងនោះនៅឡើយទេ។ ប៉ុន្តែលោកបញ្ជាក់ថា អាជ្ញាធរខ្មែរតែងតែបន្តដាក់ពង្រាយកម្លាំងការពារ តាមព្រំដែន ទប់ស្កាត់ពលរដ្ឋមិនឱ្យឆ្លងព្រំដែនខុសច្បាប់ឡើយ៖ «នៅទប់ស្កាត់បាននៅឡើយ ព្រោះអាហ្នឹងវាជួនអីចេញបាត់ដំបង ជួនអីចេញឧត្តរមានជ័យ គ្រប់កន្លែងលួចចេញ តែតាមបណ្តាខេត្តនីមួយៗគឺទប់ស្កាត់ទាំងអស់គ្នាហ្នឹងមិនអោយទៅទេ»។

ទោះជាយ៉ាងណាអតីតអ្នកទោសនយោបាយអ្នកស្រី សាត ផា ដែលកំពុងភៀសខ្លួននៅប្រទេសថៃ អះអាងថា ក្នុងពេលលោកស្រីឆ្លងដែន ឃើញមានពលករខ្មែរជិត១០០នាក់ ត្រូវបានមេខ្យល់ក្នុងព្រៃតំបន់ព្រំដែនក្នុងប្រទេសថៃ កាលពីថ្ងៃទី១៨ ខែមេសា លោកស្រីបន្តថា ពលករភាគច្រើនត្រូវបានមេខ្យល់នាំឆ្លងដែនតាមច្រករបៀងនានាក្នុងខេត្តបាត់ដំបង៖ «ខ្ញុំឆ្លងដែនមកហ្នឹង គឺខ្ញុំដើរដីប្រហែល ៧គីឡូមកដល់ព្រៃជ្រៅមួយ គេយកខ្ញុំដាក់ព្រំដែនក្បែរទឹកដីថៃហ្នឹង រួចបានគេយកខ្ញុំចេញមកប្រទេសថៃហ្នឹង សុទ្ធតែប្រជាពលរដ្ឋ ប្រជាពលករ សុទ្ធតែធ្វើការនៅប្រទេសថៃ គាត់វេទនាហើយក៏មេឃភ្លៀងខ្លាំងមែនទែន ចាំ ខ្ញុំមកឆ្លងដែនតាំងពីអោយគេអោយអីគីម្នាក់ ៧០០០ បាត ខ្ញុំនៅជាមួយពលករ ៦០នាក់»។ លោកស្រីបន្តថា ពលករភាគច្រើនទៅរកការងារធ្វើនៅតំបន់ទីក្រុងបាងកក និងខេត្តក្បែរនោះ ប៉ុន្តែរហូតមកដល់ពេលនេះមានពលករខ្លះជាប់គាំងនៅតំបន់ព្រំដែនកម្ពុជា និងថៃមិនទាន់ធ្វើដំណើរទៅដល់គោលដៅនៅឡើយ៕

## ពលករសម្រុកមកច្រើនធ្វើឱ្យអាជ្ញាធរព្រំដែនពិបាកតាមដានប័ណ្ណចាក់វ៉ាក់សាំង

https://www.khmertimeskh.com/ យឹម ស្រីលីន / April 21, 2022

មន្ត្រីសុខាភិបាលនៅច្រកព្រំដែនកំពុងមានបញ្ហាក្នុងការផ្ទៀងផ្ទាត់ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩របស់ពលរដ្ឋខ្មែរដែលត្រឡប់មកពីប្រទេសថៃ ហើយដោយសារបញ្ហានេះមនុស្សជាច្រើនដែលចាំបាច់ត្រូវដាក់ឱ្យធ្វើចត្តាឡីស័កបានរួចផុតពីវិធានការបង្ការដ៏សំខាន់នេះក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ ការលំបាកភាគច្រើនគឺកំណត់ភាពស្របច្បាប់នៃស្ថានភាពចាក់ថ្នាំបង្ការរបស់ពលករ។ អ្នកយកព័ត៌មាន ខ្មែរថាមស៍ ដែលរាយការណ៍អំពីលំហូរនៃពលករចំណាកស្រុកត្រឡប់ពីប្រទេសថៃនៅបន្ទាយមានជ័យ និងឧត្តរមានជ័យ បានដឹងរឿងនេះ ខណៈសង្កេតឃើញមនុស្សយ៉ាងច្រើនលើសលប់នៅប៉ុស្តិ៍ត្រួតពិនិត្យ។

លោក ឡុង យុន ប្រធានបុគ្គលិកថែទាំសុខភាពនៅច្រកទ្វារអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ បាននិយាយកាលពីថ្ងៃច័ន្ទថា ពលករភាគច្រើនមានប័ណ្ណវ៉ាក់សាំង ឬវិញ្ញាបនបត្រ ប៉ុន្តែអាជ្ញាធរមិនអាចផ្ទៀងផ្ទាត់វាជាមួយនឹងមូលដ្ឋានទិន្នន័យវ៉ាក់សាំងរបស់ប្រទេសជិតខាងបានទេ ។ លោកនិយាយថា៖ កម្មករចំណាកស្រុកភាគច្រើនមានវិញ្ញាបនបត្រចាក់វ៉ាក់សាំងហើយយើងអាចផ្ទៀងផ្ទាត់បានតែ២០%នៃពួកគេជាមួយនឹងមូលដ្ឋានទិន្នន័យ។ លោកថា៖ « សម្រាប់អ្វីដែលនៅសល់ យើងពិនិត្យមើលយ៉ាងលំបាកលើប័ណ្ណចាក់ថ្នាំរបស់ពួកគេ ហើយពិនិត្យមើលភាពជាក់លាក់ នឹងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ហើយភាគច្រើនយើងអនុញ្ញាតឱ្យពួកគេទៅ ប្រសិនបើពួកគេមានទិន្នន័យគ្រប់គ្រាន់»។ លោកបន្តថា៖ « យើង មានជម្រើសតិចតួចប្រសិនបើយើងមើលឃើញថាវាមិនមានចម្ងល់ ទោះបីជាយើងមិនអាចផ្ទៀងផ្ទាត់វាតាមរយៈមូលដ្ឋានទិន្នន័យក៏ដោយ»។ លោកក៏បានបង្ហាញការទទួលស្គាល់ពីភាព«ចន្លោះប្រហោង» បានធ្វើឱ្យពលករមួយចំនួនអាចគេចពីការដាក់ឱ្យនៅដាច់ពីគេរយៈពេល ១៤ ថ្ងៃ ដោយបន្ថែមថា បុគ្គលិកសុខាភិបាលបានធ្វើការច្រើនជាមួយនឹងការត្រូវដោះស្រាយនឹងចំនួនពលករត្រឡប់មកវិញយ៉ាងច្រើនគំហុក។

មន្ត្រីនៃក្រុមផ្ទៀងផ្ទាត់ឯកសារនៅច្រកអូរបីជាន់ ខេត្តបន្ទាយមានជ័យ បាននិយាយថា ចាប់តាំងពីសប្តាហ៍មុនមានពលករចំណាកស្រុករហូតដល់ ៥០០ នាក់បានឆ្លងដែនជារៀងរាល់ថ្ងៃ ហើយក្រុមលោកពិបាកក្នុងការគ្រប់គ្រងការចូលរបស់ពួកគេ។ លោកបាននិយាយថា៖ យើងកំពុងតស៊ូដើម្បីបញ្ជាក់ពីស្ថានភាពនៃការចាក់វ៉ាក់សាំងរបស់ពួកគេដោយសារភាគច្រើនយើងមិនអាចចូលប្រើមូលដ្ឋានទិន្នន័យស្ថានភាពវ៉ាក់សាំងរបស់ពួកគេបាន ។ លោកបានបន្ថែមថា៖ « ផ្ទុយទៅវិញ យើងគ្រាន់តែពិនិត្យមើលវិញ្ញាបនបត្ររបស់ពួកគេ ដោយមិនដឹងថា ឯកសារនោះពិត ឬក្លែងក្លាយ ដោយសារពួកគេមានទម្រង់ចាក់ថ្នាំបង្ការជាច្រើនប្រភេទ»។ លោកថា៖ « នៅពេលដែល

យើងមិនអាចចូលប្រើមូលដ្ឋានទិន្នន័យដើម្បីផ្ទៀងផ្ទាត់ស្ថានភាពនៃការចាក់វ៉ាក់សាំងរបស់ពួកគេ យើងពិនិត្យឈ្មោះ លេខសម្គាល់ លេខដូស ហើយប្រសិនបើអ្វីៗទាំងអស់ដំណើរការ នោះយើងនឹងអនុញ្ញាតឱ្យពួកគេទៅ»។ លោកបន្តថា៖ « នេះបានធ្វើឱ្យអ្នកដែលមានក្រដាសក្លែងក្លាយអាចគេចផុតពីការដាក់ឱ្យនៅដាច់ដោយឡែក។ មនុស្សជាច្រើនបានបោកបញ្ឆោតយើង»។

នាយនគរបាលប៉ុស្តិ៍អូរបែកក្អម លោក ម៉ាត់ ធី បាននិយាយថា ប៉ូលីសកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយបុគ្គលិកសុខាភិបាល ដើម្បីចាប់អ្នកដែលមានលិខិតបញ្ជាក់វ៉ាក់សាំងក្លែងក្លាយ។ លោកបាននិយាយថា៖ « យើងក៏កំពុងធ្វើការជាមួយមន្ត្រីថៃដើម្បីបង្កើនការចូលប្រើម៉ាស៊ីនមេ នៃមូលដ្ឋានទិន្នន័យ ដូច្នេះស្ថានភាពនៃការចាក់វ៉ាក់សាំងអាចត្រូវបានកំណត់»។

អភិបាលរងខេត្តបន្ទាយមានជ័យ លោក ង៉ោ ម៉េងជ្រួន មានប្រសាសន៍ថា ពលករចំណាកស្រុកជាង ៦០០ នាក់ ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីគេកាលពីខែមុន ដោយសារ «យើងមិនអាចចូលប្រើមូលដ្ឋានទិន្នន័យវ៉ាក់សាំងបានទេ»។ លោកបាននិយាយថា៖ « ដោយសារតែនោះយើងបានផ្ទេរពួកគេទៅមជ្ឈមណ្ឌលដាច់ដោយឡែកដោយស្វ័យប្រវត្តិទោះបីជាវិញ្ញាបនប័ត្រវ៉ាក់សាំងរបស់ពួកគេពិតប្រាកដក៏ដោយ» ។ ប៉ុន្តែថ្មីៗនេះ ពលករចំណាកស្រុកតិចជាងមុនកំពុងត្រូវបានដាក់ឱ្យនៅដាច់ពីគេ ដោយសារតែចន្លោះប្រហោងនៃការគ្រាន់តែពិនិត្យមើលវិញ្ញាបនបត្រ។ អាជ្ញាធរនឹងពិភាក្សាបញ្ហានេះជាមួយមន្ត្រីព្រំដែនថៃដើម្បីកែលម្អ។

លោក ហ៊ុយ ហាក់ អាយុ ២៥ឆ្នាំ បាននិយាយថា គាត់ត្រូវបានគេចាក់ថ្នាំបង្ការនៅកន្លែងធ្វើការរបស់គាត់ ហើយត្រូវបានផ្តល់កាតវ៉ាក់សាំង។ លោកថា៖ « មិត្តភ័ក្តិរបស់ខ្ញុំម្នាក់នៅប្រទេសថៃបានប្រាប់ខ្ញុំថា ព័ត៌មានវ៉ាក់សាំងរបស់ខ្ញុំមិនអាចបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យបានទេ ព្រោះខ្ញុំជាពលករខុសច្បាប់នៅក្នុងប្រទេសថៃ»។ លោកបន្តថា៖ « នោះហើយជាមូលហេតុដែលកាតរបស់ខ្ញុំមិនអាចស្កេនបានទេ។ ខ្ញុំត្រឡប់មកសប្បាយក្នុងពិធីបុណ្យចូលឆ្នាំខ្មែរវិញ ហើយខ្ញុំមិនបានដឹងពីការដាក់ឱ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ»។

លោកបានបន្តថា៖ « សំណាងល្អសម្រាប់ខ្ញុំ គ្រូពេទ្យបានពិនិត្យឈ្មោះខ្ញុំ លេខអត្តសញ្ញាណប័ណ្ណ និងលេខថ្នាំរបស់ខ្ញុំ ហើយបានអនុញ្ញាតឲ្យចាកចេញ»។

លោក សុខ ជាតិ អាយុ ២៧ ឆ្នាំ បាននិយាយថា គាត់បានបង់ប្រាក់ចំនួន ២៧០០ បាតសម្រាប់ការចាក់វ៉ាក់សាំងរបស់គាត់ ហើយវិញ្ញាបនបត្ររបស់គាត់ ត្រូវបានរៀបចំដោយនិយោជករបស់គាត់។ លោកបានបន្តថា៖ « ខ្ញុំមិនដឹងថា វិញ្ញាបនបត្រក្លែងក្លាយឬពិតទេ ប៉ុន្តែវាជារបស់ខ្ញុំហើយវាបង្ហាញថា ខ្ញុំមានវ៉ាក់សាំងបីដងហើយ»៕

# ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២

## ចប់ចូលឆ្នាំ! ពលករខ្មែរនៅតែបន្តចូលកម្ពុជា តែក៏មានពលរដ្ឋលួចឆ្លងដែន ត្រូវចាប់ខ្លួន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ២១ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ០៩:២៧

ខេត្តបន្ទាយមានជ័យ ៖ បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរត្រូវបានបញ្ចប់ហើយ តែឃើញមានពលករខ្មែរនៅតែបន្តចូលមកកម្ពុជាដដែល ហើយក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនពលករខ្មែរដែលបម្រុងលួចឆ្លងទៅប្រទេសថៃ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យផងដែរ។

ដោយយោងតាមរបាយការណ៍ក្រុមការងារទទួលពលករខ្មែរច្រកអូរបីជាន់ ស្រុកអូរជ្រៅ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២នេះ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជា តាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ ដែលក្រុមការងារទទួលមានចំនួន៥៥នាក់ ក្នុងនោះស្រី៣០នាក់ និងកុមារ១២នាក់ (ស្រី៦នាក់) ។ ហើយក្នុងចំណោមពលរដ្ឋខ្មែរ ក្នុងនោះមានឯកសារ និងប័ណ្ណចាក់វ៉ាក់សាំងការពារកូវីដ១៩ មានចំនួន៥០នាក់ (ស្រី៣០នាក់) ត្រូវ

បានអោយបន្តដំណើរទៅផ្ទះ និងប្រកតំបន់ព្រំដែនបឹងត្រកួន ស្រុកថ្មពួកវិញ ក៏ទទួលពលករខ្មែរចំនួន០២នាក់ ស្រី ១នាក់ និងមានឯកសារប័ណ្ណចាក់វ៉ាក់សាំង។ ប្រភពដដែលបន្តថា នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២នេះ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧ ក៏បានឃាត់ពលករខ្មែរចំនួន២៥នាក់ ក្នុងនោះស្រី១៣នាក់ ដែលកុមារ១ នាក់ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ តាមរយៈមេខ្យល់ ដែលត្រូវឃាត់ខ្លួនបាន នៅចំណុចភូមិសាស្ត្រប៉ុស្តិ៍ភ្នំប្រាក់ ស្ថិតក្នុងភូមិក្តិបថ្ម ឃុំគោករមៀត ស្រុកថ្មពួក។ ប្រភពដដែលបន្តថា ពលករខ្មែរលួចឆ្លងដែនទាំង២៥នាក់ ត្រូវបាននាំមកទីបញ្ជាការវរៈសេនេនាតូច នគរបាលការពារព្រំដែនគោកលេខ៨០៧ ដើម្បីធ្វើការណែនាំ និងធ្វើកិច្ចសន្យា ដោយពលករខ្មែរបានប្រាប់ថា ៖ ពួកគាត់បម្រុងទៅប្រទេសថៃ ដើម្បីរកការងារធ្វើតាមរយៈមេខ្យល់ ហើយក៏ត្រូវបង់លុយមុនចេញទៅ ដោយក្នុងម្នាក់ៗតម្លៃ៥.០០០បាតទៅ៦.០០០បាត (ប្រមាណជាង៨០ម៉ឺនរៀល) ហើយត្រូវបានកម្លាំងសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

គួររំលឹកថា រយៈពេលកន្លងមក អភិបាលខេត្តបន្ទាយមានជ័យ ឯកឧត្តម អ៊ុំ រាត្រី ក៏បានលើកឡើងក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ដោយបានដាក់វិធានការចំពោះកងកម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវទប់ស្កាត់ខានតែបានចំពោះពលករខ្មែរដែលលួចឆ្លងដែនចូលមកកម្ពុជា និងពលករខ្មែរដែលលួចឆ្លងដែនទៅប្រទេសថៃ តាមរយៈមេខ្យល់ ត្រូវទប់ស្កាត់ និងការពារសុវត្ថិភាពបងប្អូនប្រជាពលរដ្ឋ៕

## ជនជាតិម៉ាឡេស៊ី ៤នាក់ចុងក្រោយ ដែលរងគ្រោះពីការបោកប្រាស់អោយធ្វើការងារខុសច្បាប់នៅកម្ពុជា បានត្រឡប់មកផ្ទះវិញ ក្រោយពីបានធ្វើតេស្តរកជំងឺកូវីដ-១៩

https://www.khmertimeskh.com/ Khmer Times April 21, 2022

ជនជាតិម៉ាឡេស៊ី ៤នាក់ ក្នុងចំណោម ១៦នាក់ ដែលអះអាងថា ជាជនរងគ្រោះដែលត្រូវគេបោកប្រាស់អោយធ្វើការងារខុសច្បាប់នៅកម្ពុជា បានត្រឡប់មកប្រទេសម៉ាឡេស៊ីវិញហើយ កាលពីម្សិលមិញ ដោយបានជាសះស្បើយពីជំងឺកូវីដ១៩ ដែលបានពន្យារពេលត្រឡប់ទៅប្រទេសម៉ាឡេស៊ីវិញ ជាមួយនឹងជនរងគ្រោះ១២នាក់ផ្សេងទៀត។ ក្រសួងការបរទេសម៉ាឡេស៊ីបាននិយាយថា អ្នកទាំងបួនមិនអាចធ្វើដំណើរជាមួយ ១២ នាក់ផ្សេងទៀតនៅលើជើងហោះហើរត្រឡប់មកវិញនៅថ្ងៃទី១១ ខែមេសា ដោយសារតែពួកគេមានតេស្តវិជ្ជមានកូវីដ-១៩ មុនពេលចេញដំណើរ។

លោក Wisma Putra បាននិយាយនៅក្នុងសារបង្ហោះនៅលើទំព័រ Facebook ផ្លូវការរបស់ខ្លួនកាលពីថ្ងៃពុធថា "ពួកគេត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅប្រទេសម៉ាឡេស៊ីវិញ បន្ទាប់ពីឆ្លងកាត់ការដាក់ឱ្យនៅដាច់ដោយឡែករយៈពេលប្រាំពីរថ្ងៃនៅក្នុងប្រទេសកម្ពុជា ក្រោមការត្រួតពិនិត្យរបស់ស្ថានទូតម៉ាឡេស៊ីនៅទីនោះ" ។ ក្រសួងការបរទេសក៏បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលកម្ពុជា និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធដែលផ្តល់ដោយស្ថានទូតម៉ាឡេស៊ី ក្នុងការសម្របសម្រួលកិច្ចការពាក់ព័ន្ធនានា ដើម្បីឱ្យពួកគេត្រឡប់ទៅប្រទេសកំណើតវិញដោយសុវត្ថិភាព។ លើសពីនេះ លោក Wisma Putra ក៏បានណែនាំដល់ប្រជាជនម៉ាឡេស៊ី ឱ្យប្រុងប្រយ័ត្នជានិច្ចចំពោះការផ្តល់ការងារនៅបរទេស ដើម្បីធានាថា ពួកគេមិនត្រូវបានចាញ់បោកដោយក្រុមបោកប្រាស់។ ទោះយ៉ាងណាក៏ដោយ ពុំមានការលើកឡើងអំពីស្ថានភាពនៃជនជាតិម៉ាឡេស៊ីរហូតដល់ ១០០ នាក់ ដែលនៅតែជាប់គាំងជាមួយក្រុមឆបោកផ្សេងៗក្នុងប្រទេសកម្ពុជា។

ជនរងគ្រោះទាំង ១៦ នាក់បានអះអាងថា ពួកគេត្រូវបានផ្តល់ការងារដ៏គួរឱ្យទាក់ទាញ នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនៅពេលមកដល់ប្រទេសកម្ពុជាពួកគេត្រូវបានគេឃុំឃាំងដូចនៅក្នុងពន្ធនាគារ ហើយបង្ខំឱ្យធ្វើការហៅទូរស័ព្ទទៅកាន់មនុស្សដោយប្រើមធ្យោបាយបោកប្រាស់មួយចំនួនដូចជាការក្លែងបន្លំខ្លួនជាប៉ូលីស។ ក្រសួងបាន

និយាយថា បេសកកម្មម៉ាឡេស៊ីនៅក្រៅប្រទេសតែងតែត្រៀមខ្លួនជាស្រេចក្នុងការផ្តល់ជំនួយដើម្បីដោះស្រាយបញ្ហានេះ ក៏ដូចជាជួយដល់ពលរដ្ឋម៉ាឡេស៊ីដែលជួបការលំបាក។ *Wisma Putra*

## ពលករខ្មែរ ១៧នាក់ និងមេខ្យល់ជនជាតិថៃម្នាក់ ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួន នៅខេត្តស្រះកែវ ក្រោយឆ្លងដែនចូលទឹកដីថៃ

https://gntimes.com/news/ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២

បន្ទាយមានជ័យ៖ កាលពីវេលាម៉ោង ២១ យប់ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២២ សារព័ត៌មានថៃរាយការណ៍ថា៖ កម្លាំងនគបាលខេត្តស្រះកែវ ចូលទៅត្រួតពិនិត្យរថយន្តម៉ាកតូយ៉ូតា ព៌ណខ្មៅ ពាក់ស្លាកលេខ បក-8711 ស្រះកែវ ១គ្រឿង នៅបរិវេណភូមិហួយ ក្រែតាយ ថ្នល់ទ័ពព្រិច-វ៉ាំងណាំយេន ស្រុកខ្លងហាត ខេត្តស្រះកែវ ដោយបានចាប់ខ្លួនបុរសឈ្មោះ ឡាំដួន អះនុស៊ី អាយុ ៥៣ឆ្នាំ ជាមេខ្យល់ជនជាតិថៃ នឹងដកហូតរថយន្តខាងលើទុកត្រួតពិនិត្យ ។ ក្រោយការត្រួតពិនិត្យក្នុងរថយន្ត ប្រទះឃើញពលករខ្មែរ ១៧នាក់ (ស្រី ៩នាក់ ,ក្មេងប្រុស ៣នាក់) ។ បន្ទាប់ពីសមត្ថកិច្ចថៃសួរនាំ ពួកគេបានសារភាពថា ចង់ទៅធ្វើការនៅប្រទេសថៃ ដោយចំណាយលុយឲ្យមេខ្យល់នាំឆ្លងដែនក្នុងម្នាក់ ៥០០ បាត ដោយមេខ្យល់នាំឯស្រុកវ៉ាំង ណាំយេន បន្ទាប់មកមានអ្នកមកទទួលហើយបញ្ជូនទៅឲ្យជនជាតិខ្មែរ ដោយចំណាយលុយក្នុងម្នាក់ ៥.០០០ បាត ដើម្បីទៅធ្វើការនៅផ្សារថៃ ។ ក្រោយពីសួរនាំសមត្ថកិច្ចថៃបានបញ្ជូនពលករខ្មែរទាំងអស់ ព្រមទាំងមេខ្យល់ និងរថយន្តទៅប្រគល់ឲ្យជំនាញ ដើម្បីចាត់ការតាមនីតិវិធីបន្ត ៕ ដោយ៖ ចន្ទ្រា

## គ្រូបង្រៀនអង់គ្លេសប្រាប់តុលាការគាត់មិនបានប៉ះពាល់ក្មេងស្រីរងគ្រោះទេ

https://www.khmertimeskh.com/ ប៊ិត ស្មើគង្គា / ខ្មែរថាមស៍ April 21, 2022

អតីតគ្រូបង្រៀនជនជាតិអង់គ្លេសម្នាក់ ដែលជាប់ពន្ធនាគារពីបទរំលោភផ្លូវភេទលើកុមារីអាយុ ១៣ឆ្នាំ បានបដិសេធចំពោះការរំលោភលើក្មេងស្រីនេះ នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់គាត់ទៅកាន់តុលាការកំពូល ដើម្បីឲ្យការផ្ដន្ទាទោសរបស់គាត់ត្រូវបានលុបចោល។

លោក Matthew William Watkin អាយុ៣៩ឆ្នាំ បានប្រាប់សវនាការកាលពីម្សិលមិញថា គាត់មិនបានប៉ះសុដន់ឬប្រដាប់ភេទរបស់ជនរងគ្រោះដូចការចោទប្រកាន់នោះទេ។ គាត់បន្តថា គាត់ក៏មិនបានរួមភេទជាមួយក្មេងស្រីនោះដែរ ប៉ុន្តែបានសារភាពថា ក្មេងស្រីនោះបានមករស់នៅជាមួយគាត់ និងប្រពន្ធរបស់គាត់នៅខេត្តសៀមរាប។

ប្រធានចៅក្រមជំនុំជម្រះនៃតុលាការកំពូល លោក គឹម សត្ថាវី បានថ្លែងថា ជនរងគ្រោះបានទៅស្នាក់នៅជាមួយលោក Matthew William Watkin និង ប្រពន្ធ នៅសង្កាត់សាលាកំរើក ក្រុងសៀមរាប ក្នុងឆ្នាំ ២០១៩។ លោកបន្តថា នៅពេលសមត្ថកិច្ចនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តសាកសួរនារីរងគ្រោះ នាងបានឆ្លើយថា គាត់បានរំលោភនាងជាច្រើនលើកច្រើនសារ ពីខែមករា ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ពេលដែលប្រពន្ធរបស់គាត់ អាយុ ៣៩ឆ្នាំ ជាជនជាតិខ្មែរ មិននៅផ្ទះ។ នារីរងគ្រោះបានចាកចេញពីគ្រួសាររបស់លោក Matthew William Watkin ក្នុងខែមីនា ឆ្នាំ ២០២០។

លោក គឹម សត្ថាវី មានប្រសាសន៍ថា៖«នៅពេលដែលប្រពន្ធគាត់ជាជនជាតិខ្មែរមិននៅផ្ទះ គាត់នៅម្នាក់ឯងជាមួយនារីរងគ្រោះ គាត់តែងតែស្លៀកខោខ្លី នៅមុខនាង។ គាត់តែងតែឱបនារីរងគ្រោះ ស្ទាបសុដន់ និង ប្រដាប់ភេទរបស់នាង។ គាត់ក៏ឲ្យនារីរងគ្រោះស្ទាប ឬលេងប្រដាប់ភេទរបស់គាត់ផងដែរ»។ លោកបានថ្លែងថា៖«ទង្វើ

របស់គាត់ គឺជាការបៀតបៀនផ្លូវភេទលើនារីរងគ្រោះ និងជាការរំលោភច្បាប់កម្ពុជា»។ លោកបន្តថា នៅវេលាម៉ោងប្រហែល១២ថ្ងៃត្រង់ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ប្រពន្ធជាជនជាតិខ្មែរ ត្រឡប់មកផ្ទះវិញ បានឃើញប្តីរបស់ខ្លួនរំលោភសេពសន្ថវៈលើនារីរងគ្រោះនៅលើសាឡុងក្នុងផ្ទះ ហើយបានឈ្លោះប្រកែកគ្នាជាមួយប្តី ក្រោយមកក៏ដេញក្មេងស្រីរងគ្រោះនោះចេញពីផ្ទះ។ លោកបន្តថា នារីរងគ្រោះបានត្រឡប់ទៅផ្ទះវិញនៅភូមិកំពង់ត្រែង ក្រុងសៀមរាប ហើយបានប្រាប់ម្តាយរបស់នាង ដែលត្រូវជាបងស្រីបង្កើតរបស់ប្រពន្ធជនល្មើស។

លោក Matthew William Watkin ត្រូវបានចាប់ខ្លួននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ តាមពាក្យបណ្តឹងរបស់ម្តាយនារីរងគ្រោះ។ លោក Matthew William Watkin ត្រូវបានសាលាដំបូងខេត្តសៀមរាប សម្រេចផ្តន្ទាទោសកាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ ឲ្យជាប់ពន្ធនាគារ ២ឆ្នាំ ៦ខែ និងពិន័យជាប្រាក់ ៤លានរៀល។ តុលាការ ក៏បានបង្គាប់ឱ្យគាត់សងជំងឺចិត្ត១០លានរៀលដល់នារីរងគ្រោះផងដែរ។ លោក Matthew William Watkin ត្រូវបានចោទប្រកាន់ពីបទ «រំលោភបំពានដោយមានស្ថានទម្ងន់ទោស» តាមមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា។

ដោយឡែក ជនល្មើស បានប្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍ខេត្តបាត់ដំបង ប៉ុន្តែតុលាការតម្កល់ទោសរបស់តុលាការថ្នាក់ក្រោម។ បន្ទាប់មក លោកបានប្តឹងឧទ្ធរណ៍ទៅតុលាការកំពូល។ លោក Matthew William Watkin បានប្រាប់តុលាការកំពូលកាលពីម្សិលមិញថា វាមិនពិតទេ។ គ្មានអ្វីកើតឡើងដូច្នេះនោះទេ។ ខ្ញុំគ្មានកំហុស។ ខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ខ្ញុំសូមតុលាការកំពូលរកការពិត និងយុត្តិធម៌ឲ្យខ្ញុំ ហើយដោះលែងខ្ញុំពីពន្ធនាគារ។ ទោះបីជាយ៉ាងណាក៏ដោយ យោងតាមរបាយការណ៍របស់នគរបាល លោក Matthew William Watkin បានសារភាពក្នុងអំឡុងសាកសួរថា គាត់ធ្លាប់ថើបថ្ពាសរបស់នារីរងគ្រោះ។ ដោយឡែក សេចក្តីសំរេច ត្រូវបានរំពឹងថា នឹងមាន នៅថ្ងៃទី៤ ខែឧសភាខាងមុខនេះ៕

## ប្រភពទម្លាយតម្លៃមេខ្យល់ ទារពីពលករឆ្លងដែនខុសច្បាប់ទៅថៃ

www.kampucheathmey.co ថ្ងៃព្រហស្បតិ៍ ២១ មេសា ២០២២ដោយ Dy Bunnara

បន្ទាយមានជ័យ៖ មហាជនចេះតែមានការងឿងឆ្ងល់ថា សម័យកូវីដមិនថាសមត្ថកិច្ចខ្មែរឬសមត្ថកិច្ចថៃសុទ្ធតែរិតបន្តឹងលើការឆ្លងដែនខុសច្បាប់ ដោយដាក់ពង្រាយកងកម្លាំងតាមព្រំដែននិងមិនមានការបើកច្រកតំបន់ឬអន្តរជាតិឲ្យឆ្លងកាត់ឡើយតែពលករខ្មែរតាមរយៈមេខ្យល់នៅតែអាចឆ្លងដែនដោយខុសច្បាប់ចូលទៅទឹកដីថៃបាន។

ជាក់ស្តែងនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង១០:០០នាទី សមត្ថកិច្ចកម្ពុជានៃស្រុកម៉ាឡៃបានទទួលពត៌មានពីទាហានព្រាន (ឈុតខ្មៅថៃ) កងអនុសេនាធំលេខ១៣០៥ ឈរជើងទល់មុខភូមិសាស្រ្តប៉ុស្តិ៍ក្បាលទំនប់ទទួលខុសត្រូវនៅវេលាម៉ោង ០៤និង០០នាទី ថ្ងៃទី ២១ មេសា ឆ្នាំ២០២២ បានទប់ស្កាត់ឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន ៣១ នាក់ ស្រី ១៤ នាក់ លួចឆ្លងដែនខុសច្បាប់នៅចំណុចភូមិគុតហ៊ុន ឃុំខ្លងណាំសែ ស្រុកអារញ្ញ ខេត្តស្រះកែវ ទល់មុខកងអនុសេនាធំទាហានសឹករងម៉ាឡៃ ស្ថិតភូមិបន្ទាយទី២ ឃុំអូរសំព័រស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

ទាក់ទងនឹងការឆ្លងដែននេះ មានប្រភពខ្លះនិយាយថា ចំពោះការឆ្លងដែនចេញទៅថៃ លុះត្រាតែមានមេខ្យល់នាំដោយបច្ចុប្បន្នតាមការឲ្យដឹងពីពលករខ្មែរដែលថៃចាប់បញ្ជូនមកវិញកន្លងមកបានអោយដឹងថា **ចាប់តាំងពីមានការរិតបន្តឹងតាមព្រំដែនក្នុងសម័យកូវីដការចេញទៅថៃដោយខុសច្បាប់តាមរយៈមេខ្យល់ ត្រូវចំណាយលុយអោយមេខ្យល់ពី ៥ ពាន់បាតទៅ ៨ ពាន់បាត។ ខុសពីមុនសម័យកូវីដមួយនាក់មេខ្យល់យកតែ ៣ពាន់បាតទៅ ៥ ពាន់**

បាតតៃប៉ុណ្ណោះ។ បើតាមប្រភពបានទម្លាយបន្តថា ការនាំពលករខ្មែរចេញពីសំណាក់មេខ្យល់ បើពុំមានការបើកភ្លើងខៀវពីសមត្ថកិច្ចនៅតាមព្រំដែនទេ គឺមិនងាយគេចផុតពីការបង្ក្រាបរបស់សមត្ថកិច្ចទាំងសងខាងបានឡើយ។

ជុំវិញបញ្ហានេះ លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរនគរបាលការពារព្រំដែន៨១៥ ក៏ដូចជាយោធាដែលទទួលខុសត្រូវជួរមុខនៃស្រុកម៉ាឡៃបានអោយដឹងថា សមត្ថកិច្ចបានខិតខំប្រឹងប្រែងទាំងយប់ទាំងថ្ងៃហាលភ្លៀងខ្យល់ ដើម្បីការពារទប់ស្កាត់បទល្មើសព្រំដែន ជាពិសេសការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ពីសំណាក់ពលករខ្មែរតាមបញ្ជាថ្នាក់ដឹកនាំ។ ដោយសារព្រំដែនមិនមានរបង កម្លាំងឈរជើងការពារពីកន្លែងមួយទៅមួយទៀតឆ្ងាយពីគ្នា។ ពលករក៏ដូចជាមេខ្យល់ឥឡូវទាក់ទងគ្នាតាមទូរស័ព្ទមុននឹងឆ្លងដែន ហើយក៏មានការឃ្លាំមើលសមត្ថកិច្ចនិងទីតាំងទាល់តែស្ងាត់ឬចន្លោះប្រហោងពីការត្រួតពិនិត្យនឹងនាំចេញភ្លាម។ យ៉ាងណាសមត្ថកិច្ចក៏បានស្រាវជ្រាវទប់ស្កាត់ជានិច្ចនិងចាប់បានជាបន្តបន្ទាប់ស្ទើររាល់ថ្ងៃ៕ អត្ថបទ៖ ពៅ

## សមត្ថកិច្ចព្រំដែនកម្ពុជា-ថៃ
## ជួបពិភាក្សាពង្រឹងកិច្ចសហប្រតិបត្តិការនិងសហការទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់

www.kampucheathmey.co ថ្ងៃព្រហស្បតិ៍ ២១ មេសា ២០២២ដោយ Kang Tola

បន្ទាយមានជ័យ ៖ ខណៈដែលធម្មតាពេលចូលឆ្នាំរួចពលរដ្ឋខ្មែរមួយចំនួនដែលធ្វើការនៅប្រទេសថៃតែងត្រឡប់ឆ្លងដែលទៅធ្វើការវិញ។ សមត្ថកិច្ចតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ នៃប៉ុស្តិ៍ភ្នំប្រាក់ក្នុងភូមិសាស្ត្រស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ បានជួបពិភាក្សាគ្នាពង្រឹងកិច្ចសហប្រតិបត្តិការ និងសហការទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់។

យោងតាមរបាយការណ៍របស់វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨០៧បានឲ្យដឹងថា ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០២២ វេលាម៉ោង០៩:១០នាទី កម្លាំងនគរបាល ប៉ុស្តិ៍ភ្នំប្រាក់ ចំនួន ០៥ នាក់ ដឹកនាំដោយលោកព្រិន្ទបាលឯក បូ សុខា នាយរងប៉ុស្តិ៍ សហការជាមួយ អង្គភាពពាក់ព័ន្ធ ជួបពិភាក្សាការងារជាមួយភាគីថៃ នៅចំណុច គោលដៅបឹងព្រីង នៃប៉ុស្តិ៍ភ្នំប្រាក់ដោយភាគីកម្ពុជាសរុបចំនួន ១០នាក់។ ដោយឡែកភាគីថៃ*សរុបចំនួន ០៧ នាក់រួមមានកម្លាំងទាហានឈុតខ្មៅចំនួន០៧នាក់ដឹកនាំដោយ លោក អ/ត្រី អាឌីឡិក ចិកស៊ុន មេបញ្ជាការរង ក.អ.ធ១២០២។ ភាគីទាំងពីរបានជួបពិភាក្សាការងារពាក់ព័ន្ធខ្លឹមលើកិច្ចពង្រឹងកិច្ចសហប្រតិបត្តិការរវាងភាគីកម្ពុជានិងភាគីថៃនិងកិច្ចសហការទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩៕ *ដោយ ៖ អែបពៅ*

# ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២

## ប្រទះឃើញប្រុសស្រី២០នាក់នៅមាត់អូរព្រំដែន លុះឃាត់ខ្លួនសួរនាំទើបដឹង

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២២ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ០៩:៥២

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលវរការពារព្រំដែនគោកលេខ៨១៥ បានឃាត់ពលករខ្មែរចំនួន២០នាក់បម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ដែលឃាត់នៅវេលាម៉ោង១០ថ្ងៃ ទី២១ ខែមេសា ឆ្នាំ២០២២ នៅចំណុចអូរព្រំដែន ស្ថិតក្នុងភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានប្រាប់ថា ជាការណែនាំពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ កម្លាំងនគរបាល

ការពារព្រំដែនគោកលេខ៨១៥ បានចេញល្បាតតាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ បានប្រទះឃើញពលករខ្មែរចំនួន២០នាក់ ក្នុងនោះស្រី៦នាក់ និងកុមារ១០នាក់ នៅចំណុចមាត់អូរព្រំដែន ដែលបម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់។ លោកបានបញ្ជាក់ថា ក្រោយឃាត់ពលករខ្មែរខុសច្បាប់ហើយ ត្រូវបាននាំយកមកពីទីបញ្ជាការការពារព្រំដែនគោកលេខ៨១៥ ដើម្បីសាកសួរ និងបានប្រាប់ថា ពួកគាត់មានបំណងឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ តាមរយៈមេខ្យល់ ដោយក្នុងម្នាក់ៗតម្លៃ៦.០០០បាត ហើយជូនទៅដល់កន្លែងធ្វើការ និងទៅរកការងារបានធ្វើ ។ ប៉ុន្តែនៅពេលមេខ្យល់យកលុយហើយ ក៏នាំទៅទុកនៅចំណុចអូរព្រំដែន ដើម្បីរង់ចាំរថយន្តមេខ្យល់ថៃមកទទួលយកដល់ព្រំដែន តែនៅពេលដែលកំពុងតែរង់ចាំនោះ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

លោកវរសេនីយ៍ឯក សួង សៅ បានបញ្ជាក់ថា ក្រោយពេលឃាត់ពលករខ្មែរចំនួន២០នាក់ដែលបម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃតាមរយៈមេខ្យល់ ក្រោយសាកសួរ ហើយត្រូវបានធ្វើការណែនាំ និងធ្វើកិច្ចសន្យារួចហើយ ក៏បានអោយត្រឡប់ទៅស្រុកកំណើតវិញ ហើយពេលនេះ កម្លាំងនគរបាលជំនាញកំពុងធ្វើការស្រាវជ្រាវរកចាប់ខ្លួនមេខ្យល់ ដើម្បីចាត់ការតាមច្បាប់ផងដែរ។

## ពលករខ្មែរជិត ២០នាក់ត្រូវបានចាប់ខ្លួនបញ្ជូនមកកម្ពុជាវិញ

https://www.rfa.org/khmer/ ដោយ ខែ សុណង2022.04.21

ពលករខ្មែរចំនួន ១៧នាក់ ដែលត្រូវបានអាជ្ញាធរថៃចាប់ខ្លួនដោយសារប៉ុនប៉ងឆ្លងដែនចូលប្រទេសថៃនោះ នឹងត្រូវបញ្ជូនត្រឡប់មកកម្ពុជាវិញ។

ស្នងការរងទទួលបន្ទុកការពារព្រំដែនខេត្តបន្ទាយមានជ័យ លោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីថា ពលករទាំងនោះ នឹងបញ្ជូនមកដល់កម្ពុជាវិញនៅល្ងាចថ្ងៃទី២១ ខែមេសា។ លោកបញ្ជាក់ថា អាជ្ញាធរថៃតែងចាប់បញ្ជូនពលករខ្មែរ មកឲ្យអាជ្ញាធរកម្ពុជាវិញជារៀងរាល់ថ្ងៃ គ្រាន់តែថ្ងៃខ្លះមានចំនួនច្រើនថ្ងៃខ្លះមានចំនួនតិចប៉ុណ្ណោះ។ លោកអះអាងថា ក្រោយពិធីបុណ្យចូលឆ្នាំខ្មែរនេះ មិនទាន់មានសន្ទុះពលករខ្មែរ សម្រុកឆ្លងដែនទៅប្រទេសថៃច្រើននោះទេ ដោយសារមានអាជ្ញាធរកម្ពុជា និងថៃ បន្តពង្រឹងទប់ស្កាត់។

កាលពីយប់ថ្ងៃទី២០ ខែមេសា អាជ្ញាធរថៃបានចាប់ខ្លួនពលករខ្មែរចំនួន ១៧នាក់ ក្នុងនោះមានស្ត្រី ៩នាក់ និងក្មេងប្រុសតូចៗចំនួន ៣នាក់។ ការចាប់ខ្លួននេះ ធ្វើឡើងក្នុងពេលដែលពួកគាត់ធ្វើដំណើរតាមរថយន្តរបស់មេខ្យល់ជាជនជាតិថៃ ស្ថិតនៅតាមផ្លូវក្នុងស្រុកក្លងហាត់ (Klong Hat ) ខេត្តសាកែវ (Sakeao) ប្រទេសថៃ។ សារព័ត៌មានក្នុងស្រុកចុះផ្សាយថា ពេលសមត្ថកិច្ចថៃសួរនាំនោះ គឺជនជាតិខ្មែរទាំង ១៧នាក់បានប្រាប់ថា ពួកគេធ្វើដំណើរទៅប្រទេសថៃ ដើម្បីរកការងារធ្វើ ហើយពលករម្នាក់ត្រូវបង់ប្រាក់ឱ្យមេខ្យល់ ៥.០០០បាត ឬស្មើនឹងប្រមាណ ១៤៧ដុល្លារ ដើម្បីដឹកទៅប្រទេសថៃ។ ក្រោយពីសួរចម្លើយពលករខ្មែរទាំង ១៧នាក់ និងមេខ្យល់ថៃ ត្រូវបានអាជ្ញាធរថៃបញ្ជូនទៅកាន់កម្លាំងជំនាញ ដើម្បីចាត់ការតាមច្បាប់ ។

កាលពីថ្ងៃទី១៩ ខែមេសា ក៏មានពលរដ្ឋខ្មែរចំនួន ៧នាក់ផ្សេងទៀតត្រូវបានអាជ្ញាធរថៃ ចាប់ខ្លួននៅស្រុកអារញ្ញប្រាថេត (Aranyaprathet) ខេត្តសាកែវ។ ក្រុមពលករដែលអាជ្ញាធរថៃចាប់ខ្លួនទាំងនេះ ស្ថិតក្នុងចំណោមពលរដ្ឋខ្មែរជាច្រើននាក់ទៀត ដែលបាននាំគ្នាឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ ក្រោយពេលចប់បុណ្យចូលឆ្នាំប្រពៃណីខ្មែរ។

ប្រធានផ្នែកប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍នៃអង្គការសង់ត្រាល់ (Central) លោក ឌី ថេ ហូយ៉ា ថ្លែងថា បញ្ហាអាជ្ញាធរថៃចាប់បញ្ជូនពលករខ្មែរនេះ គឺជារឿងដដែលៗ ដូច្នេះមិនគួរមានការដាក់ទោសទណ្ឌលើពួកគាត់ជាជនរងគ្រោះ ដោយសារការស្វែងរកការងារចិញ្ចឹមជីវិតនោះទេ។ ទោះជាយ៉ាងណាលោក ជំរុញឲ្យរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ឲ្យបានខ្ពស់លើសុវត្ថិភាព និងពង្រីកការងារសម្រាប់ពួកគាត់ ជាពិសេសលើវិស័យកសិកម្ម និងទីផ្សារការងារ ព្រមទាំងបង្កើតឱកាសងាយស្រួលសម្រាប់ការវិនិយោគផ្សេងៗ ជាដើម។ លោក ឌីថេ ហូយ៉ា ព្រួយបារម្ភថា ប្រសិនបើបញ្ហាទាំងនេះ មិនត្រូវបានយកចិត្តទុកដាក់ដោះស្រាយទេ នឹងបង្កឲ្យមានបញ្ហាសង្គមធ្ងន់ធ្ងរនៅពេលខាងមុខ៕

## រយៈពេល២ថ្ងៃសមត្ថកិច្ចថៃឃាត់បានពលករខ្មែរលួចឆ្លងដែនខុសច្បាប់ចំនួន៤៨នាក់

https://www.khmertimeskh.com/ កែវ រចនា / Khmer Times April 22, 2022

រយៈពេល២ថ្ងៃ ពីថ្ងៃទី២០ ដល់២១ ខែមេសា សមត្ថកិច្ចថៃឃាត់បានពលករខ្មែរ ដែលលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងក្នុងភូមិសាស្ត្រព្រំដែនប្រទេសថៃ។ មន្ត្រីទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ បានលើកឡើងថា រយៈពេល២ថ្ងៃនេះ សមត្ថកិច្ចថៃបានឃាត់ពលករខ្មែរដែលលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ តាមរយៈមេខ្យល់មានចំនួន៤៨នាក់ ក្នុងនោះមានស្រី២៣នាក់។ កាលពីវេលាម៉ោង៩យប់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ នៅចំណុចបរិវេណភូមិហួយក្រែតាយ ឃុំវ៉ាំងណាំយេន ស្រុកខ្លងហាត ខេត្តស្រះកែវ ប្រទេសថៃ កម្លាំងនគរបាលខេត្តស្រះកែវ បានឃាត់រថយន្ត១គ្រឿងម៉ាក់តូយូតា ពាក់លេខ៨៧១១ ស្រះកែវ បានដឹកពលករខ្មែរចំនួន១៧នាក់ ស្រី៩នាក់ និងឃាត់អ្នកបើកបរម្នាក់ឈ្មោះ ឡាំជួន អៈនុស៊ី ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិថៃ។ រីឯវេលាម៉ោង ៤ទាបភ្លឺថ្ងៃទី២១ ខែមេសានៅចំណុចភូមិគុតហ៊ីន ឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ កម្លាំងយោធាឈុតខ្មៅថៃបានឃាត់ពលករខ្មែរចំនួន ៣១នាក់ (ស្រី១៤នាក់) ដែលលួចឆ្លងដែនដោយខុសច្បាប់។ តាមការសួរនាំពលករខ្មែរ ដែលត្រូវសមត្ថកិច្ចថៃចាប់បាន និងក្រោយធ្វើការត្រួតពិនិត្យសុខាភាព ដោយកម្លាំងជំនាញហើយបានប្រគល់ជូនទៅនគរបាលស្រុកអារញ្ញ ខេត្តស្រះកែវ ដើម្បីសាកសួរ តាមចម្លើយពលករខ្មែរ ពួកគាត់ទៅរកការងារធ្វើតាមរយៈមេខ្យល់ខ្មែរទទួលជូនដល់កន្លែងការងារប្រទេសថៃ ក្នុងម្នាក់តំលៃ ៥០០០ទៅ ៦០០០បាត៕

## មេបញ្ជាការរងកងទ័ពជើងគោក ណែនាំដល់កងកម្លាំង ត្រូវទប់ស្កាត់បទល្មើសតាមបន្ទាត់ព្រំដែន និងពលករចំណាក់ស្រុកខុសច្បាប់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២២ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ២៣:១០

បន្ទាយមានជ័យៈ មេបញ្ជាការរងកងទ័ពជើងគោក បានណែនាំដល់កងកម្លាំងត្រូវទប់ស្កាត់បទល្មើសតាមបន្ទាត់ព្រំដែន និងពលករចំណាកស្រុកខុសច្បាប់ រួមទាំងការពារសុវត្ថិភាពជូនបងប្អូនប្រជាពលរដ្ឋ។ ការលើកឡើងនេះ បានធ្វើឡើង ក្នុងពិធីប្រកាសសមាសភាពនាយទាហាន នៅរសៀលថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ នៅទីបញ្ជាការទិសទី១ ខេត្តបន្ទាយមានជ័យ។

ក្នុងពិធីប្រកាសសមាភាពនាយទាហាន ប្រចាំទិសទី១ បន្ទាយមានជ័យ គឺបានប្រគល់ភារកិច្ចជូនលោក ឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មុខតំណែង ជាមេបញ្ជាការរង យោធភូមិភាគទី៥ កងឯកភាព យោធភូមិភាគទី៥ បន្ថែមលើមុខងារ ដែលមានស្រាប់ ជាមេបញ្ជាការប្រចាំទិសទី១ខេត្តបន្ទាយមានជ័យ យោធភូមិភាគទី៥។ លោក ឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការរងយោធភូមិភាគទី៥ និងជាមេបញ្ជាការទិសទី១ បន្ទាយមានជ័យ បាន

មានប្រសាសន៍វាយការណ៍ថាកងកម្លាំងយោធាទិសទី១បន្ទាយមានជ័យ បានខិតខំយកចិត្តទុកដាក់ជួយអន្តរាគមន៍ដល់ប្រជាពលរដ្ឋ ដែលរងគ្រោះដោយធម្មជាតិមានគ្រោះទឹកជំនន់ និងខ្យល់កន្ត្រាក់ និងជួយប្រមូលផលស្រូវជូនប្រជាពលរដ្ឋ ដែលរងគ្រោះដោយទឹកជំនន់ និងការពារបូរណភាពទឹកដី និងសន្តិសុខសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានមានប្រសាសន៍កោតសសើរ ចំពោះកងកម្លាំងបញ្ជាការប្រចាំទិសទី១ ខេត្តបន្ទាយមានជ័យ ដែលបានខិតខំយកចិត្តទុកដាក់បង្ក្រាប និងទប់ស្កាត់ការរុករានទន្ទ្រានដីព្រៃលិចទឹកតំបន់៣ ខេត្តបន្ទាយមានជ័យ តាមការណែនាំពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានដកហូត ហើយដាំកូនឈើស្តារឡើងវិញ និងជួយអន្តរាគមន៍ដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយធម្មជាតិ មានគ្រោះទឹកជំនន់ និងខ្យល់កន្ត្រាក់ និងទប់ស្កាត់ពលករ ដែលលួចឆ្លងដែនចូលមកកម្ពុជាការពារមិនអោយរីករាលដាលក្នុងសហគមន៍។

លោកឧត្តមសេនីយ៍ឯក ឯក សំអូន មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី៥ បានមានប្រសាសន៍ណែនាំដល់កងកម្លាំងទិស១ ខេត្តបន្ទាយមានជ័យ ដែលឈរជើងតាមតាមបន្ទាត់ព្រំដែន ត្រូវតែបង្កើនការយកចិត្តទុកការពារបូរណភាពទឹកដី និងទប់ស្កាត់បទល្មើសតាមបន្ទាត់ព្រំដែន ទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ ការពារសុវត្ថិភាពបងប្អូនប្រជាពលរដ្ឋ ហើយកោតសសើរចំពោះកងកម្លាំង ដែលបានជួយអន្តរាគមន៍ដល់ប្រជាពលរដ្ឋ ដែលរងគ្រោះដោយធម្មជាតិ មានគ្រោះទឹកជំនន់ និងខ្យល់កន្ត្រាក់កន្លងមក បានចុះជួយអន្តរាគមន៍ បានទាន់ពេលវេលា៕ ប៊ុន ធឿន

## ក្រោយបុណ្យឆ្នាំថ្មីរួច ពលករខ្មែរ
## ត្រឡប់ទៅរកការងារធ្វើ នៅប្រទេសថៃ ២ថ្ងៃ ថៃចាប់បាន ៤៨នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២២ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ២៣:២៤

បន្ទាយមានជ័យ៖ ក្រោយបុណ្យឆ្នាំថ្មីរួច ពលករខ្មែរ បានត្រឡប់ទៅរកការងារធ្វើនៅប្រទេសថៃវិញ។ តែរយៈពេល ២ថ្ងៃ នៅថ្ងៃទី២០-២១ ខែមេសា សមត្ថកិច្ចថៃ ចាប់បានចំនួន ៤៨នាក់ នៅតាមបន្ទាត់ព្រំដែន ក្នុងទឹកដីថៃ ជាប់ភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ។

មន្ត្រីទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ បានប្រាប់ថា រយៈពេល ២ថ្ងៃនេះ សមត្ថកិច្ចថៃ បានឃាត់ពលករខ្មែរ ដែលលួចឆ្លងដែន ទៅរកការងារធ្វើនៅប្រទេសថៃ តាមរយៈមេខ្យល់ ចំនួន ៤៨នាក់ ( ស្ត្រី ២៣នាក់ )។ កាលពីវេលាម៉ោង ៩យប់ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ នៅចំណុចបរិវេណភូមិហួយក្រែតាយ ឃុំរ៉ាំងណាំយេន ស្រុកខ្លងហាត ខេត្តស្រះកែវ ប្រទេសថៃ កម្លាំងនគរបាលខេត្តស្រះកែវ បានឃាត់រថយន្ត ១គ្រឿង ម៉ាក់តូយូតា ពាក់លេខ ៨៧១១ ស្រះកែវ បានដឹកពលករខ្មែរ ចំនួន ១៧នាក់ ( ស្រី ៩នាក់) និងឃាត់អ្នកបើកបរម្នាក់ ឈ្មោះ ឡាំដួន អ:នុស៊ី ភេទប្រុស អាយុ ៥៣ឆ្នាំ(ជនជាតិថៃ)។ កាលពីវេលាម៉ោង ៤ ទៀបភ្លឺ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ នៅចំណុចភូមិគុតហ៊ីន ក្នុងឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ កម្លាំងយោធា ឈុតខ្មៅថៃ បានឃាត់ពលករខ្មែរ ចំនួន ៣១នាក់ ( ស្រី ១៤នាក់ ) ដែលលួចឆ្លងដែនដោយខុសច្បាប់។

មន្ត្រីទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ បានបញ្ជាក់ថា ពលករខ្មែរ ដែលត្រូវបានសមត្ថកិច្ចថៃ ចាប់រយៈពេល ២ថ្ងៃនេះ មានចំនួន ៤៨នាក់ ក្រោយធ្វើការត្រួតពិនិត្យសុខភាព ដោយកម្លាំងជំនាញហើយ បានប្រគល់ជូនទៅប៉ូលិសស្រុកអារញ្ញ ខេត្តស្រះកែវ ដើម្បីសាកសួរ ហើយតាមចម្លើយ ពលករខ្មែរ ទៅរកការងារធ្វើតាមរយៈមេខ្យល់ខ្មែរ ទទួលជូនដល់កន្លែងការងារ ក្នុងប្រទេសថៃ ដោយម្នាក់តម្លៃ ៥.០០០ ទៅ ៦.០០០បាត។ ប៉ុន្តែក្រោយជូនឆ្លងដែន និងដឹកតាមរថយន្ត ដែលមានមេខ្យល់ថៃ នាំផ្លូវ ក៏ត្រូវសមត្ថកិច្ច ចាប់បាន។ ចំពោះពលករខ្មែរ ដែលភាគីថៃ

ចាប់នេះ ដោយសារតែលួចឆ្លងដែនខុសច្បាប់ ហើយថៃអនុវត្តន៍តាមនីតិវិធី ដោយត្រូវបញ្ជូនមកកម្ពុជាវិញ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត៕ ប៊ុន ធឿន

## សមត្ថកិច្ចស្រុកសំពៅលូនបានទទួលពលករខ្មែរ ២៦ នាក់ វិលត្រឡប់មកពីថៃ

https://www.postkhmer.com/ ភ្នំពេញ ប៉ុស្តិ៍ | Publication date 22 April 2022 | 17:07 ICT

**បាត់ដំបង:** សមត្ថកិច្ចចម្រុះ នៅថ្ងៃទី ២២ មេសានេះ បានទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រភូមិពោធិ៍ ជ្រៃឃុំសិរី មានជ័យស្រុក សំពៅលូន ចំនួន២៦ នាក់ ស្រី៩ នាក់ ក្មេង៧ នាក់ ក្មេងស្រី ២ នាក់ ។ នេះបើតាមអគ្គស្នងការដ្ឋាននគរបាលជាតិ។ ក្រោយ ពីទទួលបានកម្លាំងសមត្ថកិច្ចបានធ្វើការកត់ឈ្មោះចុះកំណត់ហេតុ ប្រចាំថ្ងៃ រួចធ្វើការអប់រំណែនាំ ហើយបានប្រគល់ពលរដ្ឋទាំងអស់ ឱ្យទៅ ក្រុម គ្រូពេទ្យ នៃ មន្ទីរពេទ្យ បង្អែក ស្រុក សំពៅ លូន ធ្វើតេស្ត ពិនិត្យសុខភាព រកមេរោគកូវីដ១៩ នៅ នឹង ប៉ុស្តិ៍ ។ ជា លទ្ធផល អវិជ្ជមាន និង មាន បណ្ណ ចាក់ វ៉ាក់សាំង ស្ដែ ន ចេញ ត្រឹមត្រូវ ទាំងអស់ បន្ទាប់ មក ក្រុម គ្រូពេទ្យ បាន អនុញ្ញាត ឱ្យ ពលរដ្ឋទាំងនោះ ត្រឡប់ ទៅ មូលដ្ឋាន រៀងៗ ខ្លួន ៕

## ១ថ្ងៃចាប់បាន៤១នាក់ ថៃបញ្ជូនត្រឡប់វិញជាង១ពាន់នាក់រយៈពេល៧ថ្ងៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ២៣ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១០:២៦

ខេត្តបន្ទាយមានជ័យ ៖ យោធា និងតម្រួតជាយដែនថៃ បានធ្វើការចាប់ពលករខ្មែរចំនួន៤១នាក់ ក្នុងស្រុកអារញ្ញ និងស្រុកតាប្រាយ៉ា ខេត្តស្រះកែវ កាលពីថ្ងៃទី២២ មេសា ២០២២ ខណៈពលករជាង១៣០០នាក់ ត្រូវបានភាគីថៃបញ្ជូនត្រឡប់ឲ្យអាជ្ញាធរ និងសមត្ថកិច្ចកម្ពុជា នៅខេត្តបន្ទាយមានជ័យ រយៈពេល៧ថ្ងៃចុងក្រោយនៃខែមេសា២០២២ ។

ករណីសមត្ថកិច្ចថៃចាប់ពលករនៅខេត្តស្រះកែវ កាលពីថ្ងៃទី២២ មេសា កើតមាន២លើក ដោយលើកទី១ កើតមាននៅឃុំនិងស្រុកតាប្រាយ៉ាគឺ២៦នាក់ស្រី១២នាក់កុមា២នាក់ និងលើកទី២កើតមាននៅភូមិ និងឃុំផានស៊ីកស្រុកអារញ្ញ គឺពលករ១៥នាក់ (ស្រី៥នាក់និងកុមា២នាក់) ។ យ៉ាងណាក៏ដោយ ពលករទាំង៤១នាក់ក្រោយសមត្ថកិច្ចថៃចាប់បានធ្វើការត្រួតពិនិត្យសុខភាពតាមវិធានការរបស់ក្រសួងសុខាភិបាលរបស់គេនិងបន្ទាប់មកក៏បានបញ្ជូនទៅឲ្យជំនាញចាត់ការបន្តមុនបញ្ជូនត្រឡប់មកកម្ពុជាវិញ។

ដោយឡែក ពលករបញ្ជូនត្រឡប់ពីថៃតាមច្រកកិច្ចព្រមព្រៀងMOU(ច្រករបៀងអូរបីជាន់ក្នុងស្រុកអូរជ្រៅ) ,ច្រកតំបន់ម៉ាឡៃ ,ច្រកតំបន់បឹងត្រកួន និងច្រកទ្វារអន្តរជាតិប៉ោយប៉ែតរយៈពេល៧ថ្ងៃចុងក្រោយ នៃខែមេសា ២០២២នេះមានចំនួន១៣០៦នាក់ នេះបើតាមប្រភពពីមន្ត្រីជំនាញផ្នែកទទួលពលករបញ្ជូនពីថៃនៅខេត្តបន្ទាយមានជ័យ។ ពលករបញ្ជូនត្រឡប់ពីថៃទាំងនេះមានស្ត្រី៥២៣នាក់កុមា១៤៩នាក់និងរកឃើញអ្នកវិជ្ជមានកូវីដ១នាក់៕

## ពលករខ្មែរសម្រុកទៅរកការងារធ្វើនៅថៃ កំពុងជាប់គាំងតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៤ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១៤:៣៨

ខេត្តបន្ទាយមានជ័យ ៖ ក្រោយបុណ្យចូលឆ្នាំប្រពៃណីរួច ពលករខ្មែរបានសម្រុកទៅរកការងារធ្វើនៅប្រទេសថៃ កំពុងជាប់គាំងតាមបន្ទាត់ព្រំដែន ក្នុងទឹកដីថៃ ដើម្បីរង់ចាំរថយន្តមេខ្យល់ថៃ ក្នុងភូមសាស្ត្រស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ដែលឈមភូមិសាស្ត្រស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ តាមព័ត៌មានពីពលករខ្មែរ បាន

អោយដឹងថា នៅពេលពួកគាត់ទៅរកការងារធ្វើនៅប្រទេសថៃ ទៅតាមរយៈមេខ្យល់ខ្មែរ ហើយជិះរថយន្តឈ្នួលដោយខ្លួនឯងចេញពីស្រុកមកដល់ចំណុចមេខ្យល់ណាត់ជួប ហើយត្រូវបង់លុយអោយមេខ្យល់ ដោយក្នុង១ម្នាក់ៗតម្លៃ៦.០០០បាត ហើយមេខ្យល់ក៏បានយកឡានមកដឹកបន្តមកដល់ចំណុចព្រំដែនខ្លាងាប់ នឹងមានមេខ្យល់ថៃចាំទទួលនាំឆ្លងដែនទៅដាក់នៅចំការ ក្នុងទឹកដីថៃ ដោយរង់ចាំរថយន្តថៃដឹកបន្តទៅរកការងារធ្វើ ឬជូនទៅដល់កន្លែងការងារធ្វើតែម្តង។

ពលករខ្មែររូបនោះ បានបញ្ជាក់ថា ក្នុងចំណោមពលរដ្ឋដែលឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ តាមប្រកភូមិសាស្ត្រខ្លាងា.ប់ ក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ មានប្រមាណជិត៥០នាក់ ហើយត្រូវបានរថយន្តមេខ្យល់ថៃដឹកចេញជាបន្តបន្ទាប់ ដោយក្រុមចេញមុន១ឡានចំនួន១៨នាក់ តែក៏ត្រូវជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ដោយរថយន្តដឹកពលករខ្មែរបុកជាមួយរថយន្តធំ បណ្តាលស្លា.ប់២នាក់ ក្នុងនោះថៃម្នាក់ និងរបួសធ្ងន់-ស្រាល១២នាក់ជាពលករខ្មែរ ហើយកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តស្រះកែវ ប្រទេសថៃ។ ពលករខ្មែររូបនោះបានបញ្ជាក់ថា ក្រោយពេលពលករខ្មែរជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ តម្រួតថៃក៏រឹតបន្តឹតាមផ្លូវ ដោយត្រួតពិនិត្យតឹងរឹង បណ្តាលជាប់គាំងតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃ ដោយដេកចាំរថយន្តមេខ្យល់ថៃមកដឹកចេញនៅពេលយប់ ឬពាក់កណ្តាលអធ្រាត្រ ទើបដឹកចេញជាបណ្តើរៗ ដោយរថយន្ត១គ្រឿងដឹកពលករខ្មែរជិត២០នាក់ ហើយគេចពីតម្រួតថៃតាមដងផ្លូវ ដែលអាចប្រឈមនឹងគ្រោះថ្នាក់គ្រប់ពេលវេលា ប៉ុន្តែព្រោះតែជីវភាព គឺត្រូវតែតស៊ូទៅរកការងារធ្វើនៅប្រទេសថៃ ជាកម្មករអន្តោប្រវេសន៍ខុសច្បាប់។

ពាក់ព័ន្ធនឹងពលករខ្មែរដែលឆ្លងដែនដោយខុសច្បាប់ក្នុងភូមិសាស្ត្រស្រុកម៉ាឡៃខាងលើ អ្នកសារព័ត៌មានបានទំនាក់ទំនងទៅលោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ បានប្រាប់ថា កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ បានសហការជាមួយកម្លាំងយោធា ចេញល្បាតតាមបន្ទាត់ព្រំដែន និងឃាត់ពលករខ្មែរដែលបម្រុងលួចឆ្លងទៅរកការងារធ្វើនៅប្រទេសថៃជាបន្តបន្ទាប់ ហើយត្រូវបាននាំមកធ្វើការអប់រំ និងធ្វើកិច្ចសន្យា ហើយកម្លាំងជំនាញក៏កំពុងតែស្រាវជ្រាវតាមចាប់មេខ្យល់ផងដែរ ដើម្បីចាត់ការតាមច្បាប់៕

## ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

### ឡានដឹកពលករខ្មែរគ្រោះថ្នាក់ចរាចរណ៍ នៅខេត្តស្រះកែវ ស្លាប់ ២ នាក់ និងរបួសធ្ងន់ ១១ នាក់

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ២៤ មេសា ២០២២ដោយ KC Virak

យ៉ាងហោចណាស់មានមនុស្សចំនួន ២ នាក់បានបាត់បង់ជីវិត និង ១១ នាក់បានរងរបួសធ្ងន់ ខណៈពលករខ្មែរទាំងនេះ បានធ្វើដំណើរមិនស្របច្បាប់តាមរថយន្តមួយគ្រឿង បានជួបនឹងឧប្បទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍រវាងរថយន្ត និងរថយន្ត។ ករណីនេះបានកើតឡើងកាលពីវេលាម៉ោង ២ និង ៥៥ នាទី រំលងអធ្រាត្រថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២ តាមបណ្តោយផ្លូវលេខ ៣៥៨ ក្នុងភូមិ៧ ឃុំស្រះខ្វាន់ ស្រុកមឿង ខេត្តស្រះកែវ ប្រទេសថៃ រវាងរថយន្តនីសាន់ និងរថយន្តសណ្តោងធុនធ្ងន់។ នៅកន្លែងកើតហេតុ គេសង្កេតឃើញរថយន្តនីសាន់បានបុកពីក្រោយទៅលើរថយន្តសណ្តោងធុនធ្ងន់ បណ្តាលឱ្យអ្នកបើកបរឈ្មោះ ថាំ ប្រាក់ឌិន ភេទប្រុស អាយុ ៣០ ឆ្នាំ ជាជនជាតិថៃ រងរបួសធ្ងន់ ដោយឡែកប្រពន្ធអ្នកបើកបរឈ្មោះ រិមុជា អាយុ ៣៥ ឆ្នាំ ដែលអង្គុយក្បែរ (ស្លាប់) និងកុមារាអាយុ ១ ឆ្នាំ ជាជនជាតិខ្មែរ (ស្លាប់) រីឯពលករខ្មែរដែលអង្គុយខាងក្រោយចំនួន ១១ នាក់ទៀត រងរបួសទាំងអស់ ដោយភ្លាមៗនោះ សមត្ថកិច្ចថៃបានបញ្ជូនទៅសង្គ្រោះនៅឯមន្ទីរពេទ្យ សម្តេចព្រះយុផារ៉ាត ក្នុងខេត្តស្រះកែវ។

បើតាមសេចក្ដីរាយការណ៍បានបញ្ជាក់ថា រថយន្តនីសាន់នេះ បានទៅដឹកពលករខ្មែរទាំង ១២ នាក់ មកពីចំណុចព្រំប្រទល់ស្រុកអារញ្ញប្រាថេត និងស្រុកខ្លងហាត ក្បែរព្រំដែនកម្ពុជា ដោយយកទៅដាក់នៅស្រុក ភ្នំសារ៉ាខាម ខេត្តឆៈឈើងសៅ ដោយសារតែការបើកលឿនទើបមានបញ្ហាបែបនេះ។ ដោយឡែកលោក ឈុន តាន អ្នកបើកបររថយន្តសណ្ដោងបាននិយាយថា លោកបានទៅដឹកម្សៅជំឡូងមីមកពីខេត្តស៊ីសាកេត ឆ្ពោះទៅកាន់រោងចក្រនៅខេត្តឈុនបុរី ដោយបើកយឺតៗធម្មតា ស្រាប់តែឮសំឡេងមានអ្វីបុកពីក្រោយ ទើបលោកបានឈប់ហើយចុះទៅមើល ស្រាប់តែឃើញមានរថយន្តមកបុកពីក្រោយ ព្រមទាំងមានមនុស្សស្លាប់ និងរបួសច្រើន ទើបលោករាយការណ៍ទៅសមត្ថកិច្ចតែម្ដង៕ អត្ថបទ៖ សោ និយមវត្ថ

## ត្រឹម៣ថ្ងៃ! ឃាត់ពលករបម្រុងលួចឆ្លងដែនចូលទឹកដីថៃជាង១០០នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៤ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១៦:៤១

ខេត្តបន្ទាយមានជ័យ ៖ រយៈពេល៣ថ្ងៃ កម្លាំងនគរបាលការពារព្រំដែនគោលលេខ៨១៥ បានឃាត់ពលករបម្រុងលួចឆ្លងដែនចូលទឹកដីថៃចំនួន១៣៩នាក់ ក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ។

លោកវរៈសេនីយ៍ឯក សួង សៅ មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានប្រាប់ថា ជាការណែនាំពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ហើយកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ បានសហការជាមួយកម្លាំងពាក់ព័ន្ធបានចេញល្បាតតាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ បានឃាត់ពលករដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃតាមរយៈមេខ្យល់ ក្នុងរយៈពេល៣ថ្ងៃចាប់ពីថ្ងៃទី២១ដល់២៣ ខែមេសា ឆ្នាំ២០២២ មានចំនួន១៣៩នាក់ (ស្រី៥៦នាក់កុមារ២៧នាក់)។ លោកបានបញ្ជាក់ថា កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ នៅចំណុចអូរព្រំដែន ភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ កម្លាំងចម្រុះឃាត់ពលករខ្មែរបម្រុងលួចឆ្លងដែនទៅប្រទេសថៃចំនួន៣៣នាក់ (ស្រី១១នាក់កុមារ១៦នាក់) ។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ នៅចំណុចអូរព្រំដែន ភូមិបន្ទាយទី១ ឃុំអូរសំព័រ ស្រុកម៉ាឡៃ កម្លាំងចម្រុះបានឃាត់ពលករបម្រុងលួចឆ្លងដែនទៅប្រទេសថៃចំនួន១១នាក់ (ស្រី៦នាក់) ។ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២ នៅចំណុចអូរព្រំដែន ស្ថិតក្នុងភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ កម្លាំងចម្រុះឃាត់ពលករខ្មែរចំនួន៩៥នាក់ (ស្រី៣៩នាក់ កុមារ១១នាក់)។ លោកវរសេនីយ៍ឯក សួង សៅ បានបញ្ជាក់ថា ចំពោះពលករខ្មែរដែលកម្លាំងឃាត់តាមបន្ទាត់ព្រំដែនរយៈពេល៣ថ្ងៃសរុប ចំនួន១៣៩នាក់ ត្រូវបាននាំយកមកសាកសួរនៅទីបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ។

តាមប្រភពពីពលករបានឱ្យដឹងថា ពួកគាត់មានបំណងឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃតាមរយៈមេខ្យល់ក្នុង១នាក់តំលៃ៥.០០០បាត ដោយសន្យាជូនពួកគាត់ទៅរកការងារធ្វើ និងជូនដល់កន្លែងការងារ នៅពេលចាំមេខ្យល់ថៃមកទទួលព្រំដែន ក៏ត្រូវសមត្ថកិច្ចឃាត់ការណែនាំ ហើយធ្វើកិច្ចសន្យា ហើយកម្លាំងកំពុងធ្វើការស្រាវជ្រាវរកចាប់ខ្លួនមេខ្យល់ដើម្បីមានវិធានការតាមច្បាប់ ៕

## ឃាត់ខ្លួន ពលរដ្ឋខ្មែរ ជិត១០០នាក់ បម្រុងឆ្លងដែនខុសច្បាប់ ទៅប្រទេសថៃ

https://dap-news.com/national/ BySS107 Posted on April 25, 2022

ភ្នំពេញ ៖ អនុវត្តតាមបទបញ្ជា របស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ដែលតែងដាក់ចេញនូវបទបញ្ជាទប់ស្កាត់រាល់បទល្មើសឆ្លងដែនខុសច្បាប់ ដូចជាបទល្មើសសេដ្ឋកិច្ច បទល្មើសគ្រឿងញៀន និងប្រជាពលរដ្ឋលួចឆ្លងដែនទៅប្រទេសជិតខាងដោយខុសច្បាប់ ។

យោងតាម អគ្គស្នងការនគរបាលជាតិ បានឱ្យដឹងថា ជាក់ស្តែង នៅវេលាម៉ោង១៦និង០០នាទី ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២ លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ អម ដំណើរដោយលោកវរសេនីយ៍ទោ មាស ម៉េងហួង មេបញ្ជាការរង វរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បាន ដឹកនាំកម្លាំងប៉ុស្តិ៍ការពារព្រំដែនចំបក់ សហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំបឹងបេង នៃអធិការដ្ឋាន នគរបាលស្រុកម៉ាឡៃ និងកម្លាំងកងរាជអាវុធហត្ថស្រុកម៉ាឡៃ បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរ បម្រុងលួចឆ្លង ដែនទៅប្រទេសថៃដោយខុសច្បាប់ ចំនួន៩៥នាក់ ត្រង់ចំណុចមាត់អូរព្រំដែន ស្ថិតក្នុងភូមិល្វា ឃុំ បឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក សួង សៅ បានប្រាប់ឲ្យដឹងនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២នេះថា៖ប្រជាពលរដ្ឋ ដែលបម្រុងលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ហើយត្រូវទប់ស្កាត់ សរុបចំនួន៩៥នាក់ (ស្រី៣៩នាក់ កុមារ១១នាក់ )មកពី១០ខេត្តមាន៖១/-បន្ទាយមានជ័យចំនួន២១នាក់,២/-សៀមរាបចំនួន២៩នាក់,៣/-បាត់ដំបង ចំនួន១៣នាក់,៤/-ឧត្តមានជ័យចំនួន០៥នាក់,៥/-កំពង់ធំចំនួន០២នាក់,៦/-កំពតចំនួន០៨នាក់,៧/-ព្រៃវែងចំនួន ១០នាក់,៨/-តាកែវចំនួន០៣នាក់,៩/-ស្វាយរៀងចំនួន០៣នាក់និង១០/-ត្បូងឃ្មុំ ០១នាក់។ លោកមេបញ្ជាការបាន បញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរទាំងអស់បន្ទាប់ពីធ្វើការសួរនាំនិងធ្វើកិច្ចសន្យារួច បានប្រគល់ពួកគាត់ជូនផ្នែកជំនាញ របស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីចាត់វិធានការបន្តតាមនីតិវិធី ។

ទាក់ទងនឹងប្រជាពលរដ្ឋដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃទាំង៩៥នាក់នេះដែរ លោកវរសេនីយ៍ឯក បេន សំអាត អធិការនគរបាលស្រុកម៉ាឡៃ បានបញ្ជាក់ថា តាមបទបញ្ជារបស់ ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្ត បន្ទាយមានជ័យ តាមរយៈ លោក ស្វាយ ជា អភិបាលស្រុកម៉ាឡៃ បានឲ្យកម្លាំងជំនាញអធិការដ្ឋាននគរបាលស្រុក ម៉ាឡៃធ្វើការអប់រំ និងធ្វើកិច្ចសន្យារួច ឲ្យពួកគាត់វិលត្រឡប់ទៅរកការងារធ្វើស្រុកកំណើតវិញ ព្រោះការលួចឆ្លងដែន ដោយខុសច្បាប់នេះ វាប្រឈមនឹងគ្រោះថ្នាក់ផ្សេងៗ ។

ទាក់ទងនឹងបញ្ហាពលរដ្ឋឆ្លងដែននេះដែរ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយ មានជ័យ ក៏បានជំរុញដល់កម្លាំងនគរបាលស្រុកម៉ាឡៃ ស្រាវជ្រាវមុខសញ្ញាមេខ្យល់ដែលពាក់ព័ន្ធនាំមនុស្សឆ្លងដែន ខុសច្បាប់ ដើម្បីចាប់ខ្លួនយកទៅផ្តន្ទាទោសផងដែរ ៕

## ឃាត់ពលករឆ្លងដែនខុសច្បាប់ទៅថៃរាល់ថ្ងៃ ខណៈមេខ្យល់មិនដឹងនៅទីណា

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២៥ មេសា ២០២២ដោយ KC Virak

ខេត្តបន្ទាយមានជ័យ៖ សមត្ថកិច្ច ជាពិសេសនគរបាលការពារព្រំដែនគោក តែងបង្ក្រាបបានពលករបម្រុង ឆ្លងដែនទៅធ្វើការនៅប្រទេសថៃជាបន្តបន្ទាប់ស្ទើររាល់ថ្ងៃ ខណៈមេខ្យល់ដែលនាំពលករឆ្លងដែននោះ មិនដឹងនៅទី ណា។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការ វរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨១៥ បានឱ្យ ដឹងថា នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ៥ ទាបភ្លឺ ដោយមានការចង្អុលបង្ហាញពី លោកឧត្តមសេនីយ៍ ទោ សិទ្ធិ ឡោះ ស្នងការនគរបាល ខេត្តបន្ទាយមានជ័យ ធ្វើការទប់ស្កាត់ពលករបម្រុងលួចឆ្លងដែនខុសច្បាប់ ទៅ ប្រទេសថៃ មានចំនួន ១៣នាក់ (ស្រី៥នាក់) ត្រង់ចំនុចភូមិក្បាលស្ពាន និងភូមិក្បាល់ទំនុបស្រុកម៉ាឡៃ ខេត្ត បន្ទាយមានជ័យ បន្ទាប់ពីបង្ក្រាបបានពលករជិត១០០នាក់ នៅថ្ងៃទី២៤ ខែមេសា ដោយពុំមានមេខ្យល់ក្នុងនោះ ឡើយ។ នគរបាលបានឱ្យដឹងថា ពលករដែលលួចឆ្លងដែនខុសច្បាប់ខាងលើមានទីលំនៅក្នុងខេត្តព្រៃវែង បន្ទាប់ពី

ធ្វើការសួរនាំ និងធ្វើកិច្ចសន្យារួច បានឱ្យពួកគាត់រង់ចាំនៅទីបញ្ជាការប៉ុស្តិ៍ ដើម្បីប្រគល់ជូនផ្នែកជំនាញនៅអធិការនគរបាលស្រុកម៉ាឡៃ ចាត់ការបន្តតាមនីតិវិធីច្បាប់។

សូមបញ្ជាក់ថា យោងតាមការរៀបរាប់របស់ពលករដែលសមត្ថកិច្ចចាប់កន្លងមក ការចេញទៅថៃគឺតាមរយៈមេខ្យល់ដោយត្រូវចំណាយលុយឱ្យមេខ្យល់ក្នុងមួយនាក់ពី ៥ ០០០ បាត ដោយការទាក់ទងមេខ្យល់តាមទូរស័ព្ទ។ ទាក់ទងទៅនឹងបញ្ហាមេខ្យល់នេះ បើតាមមន្ត្រីនគរបាលការពារព្រំដែនបាននិយាយថា ពលករដែលបង្ក្រាបបានគឺមិនដែលស្គាល់មេខ្យល់ទេ គឺគ្រាន់តែដឹងថាធ្វើដំណើរតាមរថយន្តហើយគេទម្លាក់ឱ្យចុះដើរឆ្លងដែនតែម្តង ដែលធ្វើឱ្យសមត្ថកិច្ចមិនអាចរកមេខ្យល់ឃើញ៕ អត្ថបទ៖ ពៅ

## ក្រសួងការងារ-អង្គការ IOM
## បន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងផ្តល់កិច្ចគាំពារនៅលើពលករទេសន្តរប្រវេសន៍

https://cen.com.kh/ Posted ByPen Srey NeatApril 25, 2022

ភ្នំពេញ ៖ គម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការកសាងជំនាញ និងលើកកម្ពស់ការរកការងារអោយធ្វើនៅក្នុងប្រទេសកម្ពុជា ឡាវ ភូមា និងថៃ (PROMISE) ក្នុងជំហានទី១ ដែលបានអនុវត្តនាពេលកន្លងមក(ចាប់ពីខែកញ្ញា ឆ្នាំ២០១៧ ដល់ ខែសីហា ឆ្នាំ២០២១) ត្រូវបានបញ្ចប់។

លោកស្រី Nenette Motus នាយកអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក និងលោកស្រី KRISTIN PARCO ប្រធានបេសកកម្មអង្គការ IOM ប្រចាំនៅកម្ពុជា នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ បានចូលជួប ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្តីការក្រសួងការងារ ដើម្បីសុំការឯកភាពគាំទ្រពី ឯកឧត្តមរដ្ឋមន្ត្រី លើការអនុវត្ត គម្រោង PROMISE ក្នុងជំហានទី២ បន្តទៀត (ចាប់ពីខែកញ្ញា ឆ្នាំ២០២១ ដល់ ខែសីហា ឆ្នាំ២០២៥)។

ក្នុងនាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានស្វាគមន៍ចំពោះលោកស្រី Nenette Motus ដែលបានអញ្ជើញមកទស្សនកិច្ចនៅកម្ពុជា និងវាយតម្លៃខ្ពស់ ចំពោះអង្គការ IOM ដែលបានដើរតួនាទីយ៉ាងសំខាន់ លើការផ្សព្វផ្សាយបញ្ហាទេសន្តរប្រវេសន៍ ប្រកបដោយស្ថិរភាព ជាដៃគូមិនអាចខ្វះបាននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងកម្ពុជា។ ជាពិសេស ស្ថិតក្នុងដំណាក់កាលកូវីដ-១៩ ដែលពលករមិនអាចធ្វើការឆ្លងកាត់បាន ត្រូវជាប់គាំងនៅតាមបណ្តាប្រទេសនីមួយៗ ត្រូវបាន អង្គការ IOM បានធ្វើការដោះស្រាយបញ្ហានេះ ប្រកបដោយប្រសិទ្ធភាព។

ក្នុងឱកាសនោះ លោកស្រី Nenette Motus បានគូសបញ្ជាក់ពី គម្រោង PROMISE ដែលជាកម្មវិធីថ្នាក់តំបន់ អនុវត្តក្រោមការដឹកនាំរបស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដោយទទួលបានការគាំទ្រពីទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC)។ គម្រោងនេះមានរយៈពេល ៨ឆ្នាំ ចែកជាពីរដំណាក់កាលដំណាក់កាលទី១ ៖ ចាប់ពីខែកញ្ញា ឆ្នាំ២០១៧ ដល់ ខែសីហា ឆ្នាំ២០២១, ដំណាក់កាលទី២ ៖ ចាប់ពីខែកញ្ញា ឆ្នាំ២០២១ ដល់ ខែសីហា ឆ្នាំ២០២៥ នៅចន្លោះឆ្នាំ ១៩៩៨-២០០២ លោកស្រីធ្លាប់ជាប្រធានអង្គការ IOM ប្រចាំប្រទេសកម្ពុជា ហើយលោកស្រីពិតជាមានក្តីរីករាយជាខ្លាំងដែលបានបំពេញទស្សនកិច្ចនៅកម្ពុជាសារជាថ្មី ដោយលោកស្រីមើលឃើញថា កម្ពុជាមានការរីកចម្រើនប្លែកពីមុនច្រើន ជាពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ឃើញថាមានវឌ្ឍនភាពច្រើនផងដែរ។ ខណៈកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះ ក្នុងកិច្ចប្រជុំអាស៊ានសម្រាប់ឆ្នាំនេះ អង្គការ IOM ចង់ផ្តល់ការគាំទ្រលើបញ្ហា បច្ចេកទេស និងឯកសារមួយចំនួន ក្នុងករណីមានរបៀបវារៈ ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ ស្តីពីពលករទេសន្តរប្រវេសន៍នេះ និងផ្តល់ជំនួយបច្ចេកទេសលើគោលនយោបាយទេសន្តរប្រវេសន៍នៅកម្ពុជាផងដែរ។

ឆ្លើយតបនឹងការជួយរបស់ IOM ឯកឧត្តមរដ្ឋមន្ត្រី បញ្ជាក់ថា ចំពោះកិច្ចប្រជុំអាស៊ានដែលកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះនៅក្នុងឆ្នាំនេះ ពិតជាមិនអាចរំលងពីប្រធានបទ ព័ន្ធពាក់ទៅនឹងពលករទេសន្តរប្រវេសន៍នេះឡើយ ដូច្នេះបានខាងអង្គការIOM ផ្តល់ការគាំទ្រជួយលើបញ្ហាបច្ចេកទេស និងឯកសារផងដែរនោះ វាផ្តល់នូវធាតុចូលកាន់តែច្រើនបន្ថែមទៀត សម្រាប់ធ្វើការដោះស្រាយនូវចំណុចប្រឈមមួយចំនួនដែលត្រូវធ្វើការរួមគ្នាដោះស្រាយ ។ សម្រាប់គោលនយោបាយទេសន្តរប្រវេសន៍ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការជាមួយ អង្គការ ILO ឯកឧត្តមរដ្ឋមន្ត្រី ចង់ឃើញគោលនយោបាយមួយនេះ ក្លាយជាគោលនយោបាយជាតិ ដោយមានការអនុម័តគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ហើយកម្ពុជាក៏ត្រូវការជួយជ្រោមជ្រែងបន្ថែមពីខាង IOM និងដៃគូពាក់ព័ន្ធមួយចំនួនទៀត ដើម្បីឲ្យគោលនយោបាយនេះ កាន់តែរឹងមាំ និងធានាបាននូវសុវត្ថិភាពសម្រាប់ពលករទេសន្តរប្រវេសន៍។

ឯកឧត្តមបណ្ឌិត អ៊ិត សំហេង ឯកភាពគាំទ្រ និងបន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការ IOM ក្នុងការអនុវត្តគម្រោង PROMISE សម្រាប់ជំហានទី២ បន្តទៀត។ ជាមួយគ្នានោះ ឯកឧត្តមរដ្ឋមន្ត្រី បានស្នើដល់អង្គការ IOM បង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួង លើគម្រោងសម្រាប់ផ្តល់ជំនួយទាក់ទងនឹងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ សម្រាប់ពលករទេសន្តរប្រវេសន៍ និងជួយគាំទ្រក្នុងការអនុវត្តន៍ លើលទ្ធផលសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ CLMVT កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ នៅខេត្តសៀមរាប ទាក់ទងទៅនឹង ផែនទីបង្ហាញផ្លូវទីក្រុងសៀមរាប ដើម្បីឆ្ពោះទៅកាន់ការចេញសេចក្តីថ្លែងការណ៍របស់ រដ្ឋមន្ត្រីការងារស្តីពី ចល័តភាពរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍នៃប្រទេស CLMVT ។ ព្រមជាមួយការកសាងសមត្ថភាព ការលើកកម្ពស់ការយល់ដឹងដល់សមាគមទីភ្នាក់ងារជ្រើសរើសពលករ និងទីភ្នាក់ងារជ្រើសរើសឯកជន ស្តីពីប្រព័ន្ធអន្តរជាតិនៃការជ្រើសរើសពលករដោយសុចរិត(IRIS) ។ ចំណុចមួយទៀត ដែលភាគីទាំងពីរយកមកពិភាក្សាផងដែរ ទៅលើកិច្ចប្រជុំ នៃតំបន់មេគង្គ ស្តីពីពលករទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ដែលកម្ពុជាជាសហប្រធាននៃកិច្ចប្រជុំនេះ ដែលនឹងត្រូវរៀបចំធ្វើឡើងនាខែ ឧសភា ឆ្នាំ២០២២ ខាងមុខនេះ ក្រោមការជួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី៕ រក្សាសិទ្ធិដោយៈ ចេស្តារ

## នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ ដឹកនាំក្រុមការងារ ចូលរួមកម្មវិធីដាក់ដំណើរការជាផ្លូវការនូវរបាយការណ៍ ស្តីពីការអនុវត្តគោលការណ៍ មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងក្របខណ្ឌអាស៊ាន

https://gntimes.com/ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២

ភ្នំពេញ៖ នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ អគ្គលេខាធិការ និងជាប្រធានក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជា (SOMTC) នៅព្រឹកថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២២ នេះបានអញ្ជើញដឹកនាំក្រុមការងារ SOMTC-កម្ពុជា ចូលរួមកម្មវិធីដាក់ដំណើរការជាផ្លូវការនូវរបាយការណ៍ ស្តីពីការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងក្របខណ្ឌអាស៊ាន ។ កម្មវិធីនេះ ធ្វើឡើងតាមរយៈប្រព័ន្ធវីដេអូសន្និសីទ ដោយមានការអញ្ជើញចូលរួមពី លោក លោកស្រី ជាសមាជិក សមាជិកានៃក្រុមការងារ SOMTC-កម្ពុជា ព្រមទាំងមន្ត្រីពាក់ព័ន្ធផងដែរ ។ សូមជម្រាបជូនផងដែរថា កម្មវិធីនេះត្រូវបានសហការរៀបចំដោយ SOMTC-កម្ពុជា SOMTC-ហ្វីលីពីន AICHR-ឥណ្ឌូណេស៊ី និង ASEAN-Australia Counter Trafficking (ASEAN-ACT) ៕

## ក្រសួងការងារថៃ
## រំពឹងថាឆ្នាំនេះនឹងបញ្ជូនពលករថៃទៅធ្វើការក្រៅប្រទេស ចំនួន ៥០,០០០ នាក់

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២

(បាងកក)៖ ឥឡូវនេះ ស្ថានការណ៍ Covid-19 នៅទូទាំងពិភពលោកបានស្ងប់ស្ងាត់បន្តិចហើយ ក្រសួងការងារថៃរំពឹងថា នឹងបញ្ជូនពលករថៃទៅបរទេសប្រមាណ ៥០,០០០ នាក់នៅឆ្នាំនេះ។ នាយកដ្ឋានការងារបាននិយាយថាឥឡូវនេះការរឹតបន្តឹងបានបន្ធូរបន្ថយយ៉ាងច្រើន ការនាំចេញកម្លាំងពលកម្មរបស់ប្រទេសថៃត្រូវបានកំណត់ឡើងវិញក្នុងចំនួនដ៏ច្រើន។ នេះបើយោងតាមការចុះផ្សាយរបស់សារព័ត៌មាន Bangkok Post នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២។ រហូតមកដល់ពេលនេះ កិច្ចព្រមព្រៀងនាំចេញកម្លាំងពលកម្មត្រូវបានចុះហត្ថលេខាជាមួយប្រទេសចំនួនពីរ គឺអារ៉ាប៊ីសាអូឌីត និងជប៉ុន។ កាលពីខែមុន រដ្ឋមន្ត្រីការងាររបស់ប្រទេសថៃបាននិយាយថា មនុស្សជាង ១០០០ នាក់ បានចុះឈ្មោះតាមអ៊ីនធឺណិតជាមួយនាយកដ្ឋានការងារដើម្បីដាក់ពាក្យរកការងារនៅអារ៉ាប៊ីសាអូឌីត។ ប៉ុន្តែមន្ត្រីក៏បានដឹងដែរថា ជនជាតិថៃជាច្រើននាក់ត្រូវបានបោកបញ្ឆោតឱ្យទៅធ្វើការនៅប្រទេសផ្សេងដោយក្រុមមេខ្យល់ខុសច្បាប់។ កាលពីខែមុន ប៉ូលីសនៅក្នុងខេត្ត Chachoengsao បានចាប់ខ្លួនស្ត្រីម្នាក់ដែលសង្ស័យថាបានបោកបញ្ឆោតស្ត្រីថៃផ្សេងទៀតឱ្យធ្វើការជាស្រីពេស្យានៅ អារ៉ាប៊ីសាអូឌីត៕

## ពលករខ្មែរ ១នាក់ស្លាប់ និងរងរបួសធ្ងន់ស្រាល ១២នាក់ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍

https://www.khmertimeskh.com/ កែវ រចនា / Khmer Times April 25, 2022

ពលករខ្មែរ ១នាក់ និងថៃ ១នាក់បានស្លាប់ ព្រមទាំងរងរបួសធ្ងន់ស្រាល ១២នាក់ទៀត ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ រវាងរថយន្តដឹកពលករខ្មែរបុកជាមួយរថយន្តធំនៅទឹកដីថៃ។ បច្ចុប្បន្នពលករខ្មែរកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ខេត្តស្រះកែវ ប្រទេសថៃ។

យោងតាមពលករខ្មែរម្នាក់បានឲ្យដឹង នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២ ក្នុងចំណោមពួកគេដែលឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ តាមច្រកភូមិសាស្ត្រខ្លាងាប់ ឃុំទួលពង្រ ស្រុកម៉ាឡៃ មានប្រមាណជាង៤០នាក់ ហើយត្រូវបានរថយន្តមេខ្យល់ថៃដឹកចេញជាបន្តបន្ទាប់ដោយក្រុមចេញមុន១ឡាន មានចំនួន១៨នាក់ ដោយជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ ដោយរថយន្តដឹកពលករខ្មែរបុកជាមួយរថយន្តធំបណ្តាលស្លាប់២នាក់ ថៃ១នាក់ និងរបួសធ្ងន់ស្រាល១២នាក់។ ពលករខាងលើដែលសុំមិនបញ្ចេញឈ្មោះ បន្ថែមថា ក្រោយពលករខ្មែរជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ តម្រួតថៃរឹតបណ្តឹងតាមផ្លូវ ដោយត្រួតពិនិត្យតឹងរឹងបណ្តាលពួកគាត់ជាប់គាំងនៅតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃ ដោយដេកចាំរថយន្តមេខ្យល់ថៃមកដឹកចេញនៅពេលពាក់កណ្តាលអាធ្រាធទើបដឹកចេញជាបណ្តើរៗ ដោយរថយន្ត១គ្រឿងដឹកជិត២០នាក់ ហើយគេចពីតម្រួតថៃតាមដងផ្លូវ ដែលប្រឈមគ្រោះថ្នាក់គ្រប់ពេល។

ពាក់ព័ន្ធពលករខ្មែរដែលឆ្លងដែនដោយខុសច្បាប់ក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ លោកវរសេនីយ៍ឯក សួង សៅមេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ភូមិសាស្ត្រស្រុកម៉ាឡៃ បានប្រាប់ថា កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ បានសហការជាមួយកម្លាំងយោធាបានចេញល្បាតតាមបន្ទាត់ព្រំដែន និងឃាត់ពលករខ្មែរដែលបម្រុងលួចឆ្លងទៅរកការងារធ្វើនៅប្រទេសថៃ ជាបន្តបន្ទាប់ហើយបានអប់រំ និងធ្វើកិច្ចសន្យា ចំណែកមេខ្យល់កំពុងស្រាវជ្រាវតាមចាប់ខ្លួនផងដែរ៕

# ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២

## សម្តេចក្រឡាហោម សង្ឃឹមថា អង្គការ IOM

## នឹងបន្តជួយកម្ពុជា លើការងារទេសន្តប្រវេសន៍ និងការងារបម្រែបម្រួលអាកាសធាតុ

https://cen.com.kh/ Posted ByPen Srey NeatApril 27, 2022

ភ្នំពេញ ៖ នៅរសៀលថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតជូនលោកស្រី Nenette Motus នាយិកាប្រចាំថ្នាក់តំបន់ របស់អង្គ IOM ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានរដ្ឋសភា។

សម្តេចក្រឡាហោម ស ខេង បានសម្តែងការស្វាគមន៍ចំពោះលោកស្រី Nenette Motus ហើយក្នុងឱកាសនៃជំនួបនេះ សម្តេចក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងគណៈកម្មការអន្តរក្រសួង បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អ ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកដែលអង្គការ IOM បានផ្តល់មករាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនៅកម្ពុជា។ សម្តេចក៏បានថ្លែងអំណរគុណចំពោះការដឹកនាំរបស់លោកស្រី និងបានសម្តែងក្តីសង្ឃឹមថា លោកស្រីនឹងបន្តផ្តល់កិច្ចសហការគាំទ្រ ដល់ការងារទេសន្តប្រវេសន៍ ដែលជាកិច្ចការងារដ៏មានសារៈសំខាន់នេះ។ សម្តេចក៏បានជម្រាបជូនដែរថា នៅក្នុងអំឡុងពេល នៃការរីករាលដាលជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានធ្វើកិច្ចការងារជាច្រើន ពាក់ព័ន្ធនឹងការងារទេសន្តប្រវេសន៍នេះ ពិសេសនៅពេលមានពលរដ្ឋវិលត្រឡប់មកតាមព្រំដែនកម្ពុជាថៃ ហើយដែលការនេះមានការចូលរួមចំណែក យ៉ាងសំខាន់ពីអង្គការIOM។ សម្តេចក៏បានមានប្រសាសន៍អំពីការផ្តល់ជំនួយសាងសង់មជ្ឈមណ្ឌលសំចតទេសន្តប្រវេសន៍ពីសំណាក់អង្គការ IOM ដើម្បីទទួលពលរដ្ឋឆ្លងដែនក្នុងស្ថានភាពកូវីដ-១៩។ សម្តេចក៏បានថ្លែងអំណរគុណចំពោះការគាំទ្រយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋាននៅទូទាំងប្រទេស ទាំងក្រសួងស្ថាប័ន និងដៃគូ រួមទាំងប្រជាពលរដ្ឋ ដែលបានរួមចំណែកធ្វើការងារពាក់ព័ន្ធនឹងទេសន្តប្រវេសន៍នៅកម្ពុជា។

ជាការឆ្លើយតបលោកស្រី Nenette Motus បានថ្លែងអំណរគុណរាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែយកចិត្តទុកដាក់លើការងារ ដ៏មានសារៈសំខាន់នេះ និងទទួលយកការជួយគាំទ្រពីអង្គការ IOM លើការងារទេសន្តប្រវេសន៍ ដោយលោកស្រីបានវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការនេះចាប់ពីឆ្នាំ១៩៩៣មក ដែលក្រសួងមហាផ្ទៃកម្ពុជា បានផ្តល់កិច្ចសហការលើការងារនេះ យ៉ាងល្អប្រសើរ។ លោកស្រីក៏បានសម្តែងការអបអរសាទរ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងជំងឺរាតត្បាតកូវីដ-១៩ និងយុទ្ធនាការចាក់វ៉ាក់សាំងដែល ទទួលបានលទ្ធផលប្រសើរល្អជាគេ ក្នុងតំបន់លើការងារប្រយុទ្ធប្រឆាំងកូវីដ-១៩។ លោកស្រីក៏បានអបអរសាទរកម្ពុជាដែលជាប្រទេសទទួលបានជ័យលាភីល្អក្នុងការងារ គ្រប់គ្រងអន្តោប្រវេសន៍ និងបានទទួលធ្វើជា ប្រធានអាស៊ាននៅឆ្នាំ២០២២។ លោកស្រីបានជម្រាបជូនសម្តេចដែរថាអង្គការ IOMមិនត្រឹមតែធ្វើការងារទេសន្តប្រវេសន៍ ការងារទទួល និងជួយធ្វើសមាហរណកម្មពលរដ្ឋ ក្នុងសង្គមប៉ុណ្ណោះទេ តែអង្គការនេះក៏យកចិត្តទុកដាក់ លើបញ្ហាប្រឈមសាកលផងដែរ គឺបញ្ហាបម្រែបម្រួលអាកាសធាតុ ដែលបានប៉ះពាល់ ដល់ជីវភាពរស់នៅរបស់ប្រជាជន ធ្វើឱ្យមានចលនាបម្លាស់ទី នាំទៅដល់ការធ្វើទេសន្តប្រវេសន៍ របស់ប្រជាជន។

សម្តេចក្រឡាហោមបានថ្លែងអំណរគុណចំពោះ ការវាយតម្លៃអំពីការគ្រប់គ្រងជំងឺកូវីដ-១៩នៅកម្ពុជា ហើយសម្តេចក៏ចាត់ទុកដែរថា ជោគជ័យមួយផ្នែកនៃការគ្រប់គ្រងជំងឺនេះ ក៏មិនអាចកាត់ផ្តាច់ពីការចូលរួមចំណែកពីអង្គការIOMដែរ ពិសេសការជួយរៀបចំឱ្យមានមណ្ឌលសំចតពលរដ្ឋ វិលចូលប្រទេសតាមច្រកព្រំដែន ដែលកត្តានេះជាការរួមចំណែក ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ផងដែរ។ សម្តេចក៏បានសម្តែងការគាំទ្រចំពោះការវាយតម្លៃ និងការគិតគូរបស់អង្គការ IOM អំពីបញ្ហាបម្រែលបម្រួលអាកាសធាតុ ដែលអាចធ្វើឱ្យមាន ផលប៉ះពាល់ដល់ជីវភាព

រស់នៅរបស់ប្រជាជន។ សម្តេចជាថ្មីម្តងទៀត ក៏សង្ឃឹមជឿជាក់ថា លោកស្រី និងអង្គការIOM នឹងបន្តជួយកម្ពុជា លើការងារទេសន្តប្រវេសន៍ និងការងារបម្រែបម្រួលអាកាសធាតុនេះ ហើយសម្តេចសូមជូនពរលោកស្រី និងសហការីទទួលបានជោគជ័យ ក្នុងបេសកកម្មការងារនៅកម្ពុជា ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## រដ្ឋតិចសាស់ ផ្តល់សំណងដល់ស្ត្រីខ្មែរ ចំនួន ១.៧៨ លានដុល្លារ បន្ទាប់ពីនាងត្រូវបានអោយធ្វើពលកម្មដោយបង្ខំ

https://www.khmertimeskh.com/ Khmer Times April 26, 2022

ចៅក្រមក្នុងរដ្ឋតិចសាស់ បានផ្តល់សំណងដល់ស្ត្រីខ្មែរម្នាក់ចំនួន ១,៧៨ លានដុល្លារកាលពីដើមខែនេះ បន្ទាប់ពីបានរកឃើញក្រុមគ្រួសារ Rockport ជួញដូរនាងដោយខុសច្បាប់ទៅសហរដ្ឋអាមេរិក ហើយបានបង្ខំនាងឱ្យធ្វើការនៅក្នុងហាងនំដូណាត់របស់ពួកគេ។ Sophy Treadway (ហៅ Sophy Koem) អាយុ ៣២ឆ្នាំដំបូងបានដាក់ពាក្យប្តឹងរដ្ឋប្បវេណីនៅតុលាការស្រុកភាគខាងត្បូងតិចសាស់ ក្នុងខែសីហា ឆ្នាំ២០១៩។ នៅថ្ងៃទី១១ ខែមេសា ចៅក្រមបានរកឃើញថា Matthew អាយុ៣៦ ឆ្នាំ និង Sopheak អាយុ៤៧ ឆ្នាំ ក៏ដូចជាអាជីវកម្មរបស់ពួកគេ Rockport Donuts (ដែលប្រតិបត្តិការក្រោមឈ្មោះស្របច្បាប់ Exxizz Foods Inc.) បានប្រព្រឹត្តិខុសច្បាប់ដោយប្រើពលកម្មដោយបង្ខំ និងជួញដូរ Treadway ដែលកើតក្នុងប្រទេសកម្ពុជា។ អាជីវកម្មរបស់ពួកគេត្រូវបានបញ្ជាដោយចៅក្រមឱ្យបង់ប្រាក់សំណងចំនួន ២៨២,២៨២ ដុល្លារសម្រាប់ Treadway សម្រាប់សំណងកម្លាំងពលកម្មកន្លងមករបស់នាង និង ១,៥០០,០០០ ដុល្លារចំពោះការប្រព្រឹត្តិខុសរបស់ម្ចាស់អាជីវកម្ម។

មេធាវីដែលមានមូលដ្ឋាននៅទីក្រុង Houston របស់ Treadway លោក Xenos Yuen បានហៅករណីនេះថាជាឧទាហរណ៍នៃ "ទាសភាពសម័យទំនើប" ។ លោក Yuen បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍តាមអ៊ីមែលទៅកាន់ Caller-Times ថា "គួរឱ្យសោកស្តាយ វាពិបាកនឹងជឿដែលថា ទាសភាពសម័យទំនើបនៅតែមានសព្វថ្ងៃនេះនៅក្នុងសហរដ្ឋអាមេរិក" ។ "វាពិបាកដូចគ្នាក្នុងការស្រមៃថាមនុស្សម្នាក់អាចមានអំណាចត្រួតត្រាលើមនុស្សម្នាក់ទៀតនៅក្នុងសហគមន៍របស់យើងក្នុងសម័យទំនើបនេះ"។ សម្រាប់ហេតុផលនេះ លោក Yeun បាននិយាយថា វាសំខាន់សម្រាប់ជនរងគ្រោះ "ដើម្បីឈានទៅមុខដើម្បីទាមទារសិទ្ធិ និងសំណងរបស់ពួកគេ"។ Treadway មិនឆ្លើយតបទៅនឹងសំណើសុំការអត្ថាធិប្បាយរបស់ Caller-Times ទេ។

មេធាវីរបស់ម្ចាស់អាជីវកម្ម លោក Andrea Johnson បាននិយាយថា កូនក្តីរបស់នាងកំពុងពិចារណាលើបណ្តឹងឧទ្ធរណ៍នៃសេចក្តីសម្រេចរបស់ចៅក្រម។ Matthew Otero ក៏បានបញ្ជាក់ប្រាប់ Caller-Times កាលពីថ្ងៃច័ន្ទថា គាត់ និងប្រពន្ធរបស់គាត់គ្រោងនឹងប្តឹងឧទ្ធរណ៍លើករណីនេះ។ លោក Johnson បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍តាមអ៊ីមែលទៅកាន់ Caller-Times ថា "កូនក្តីរបស់ខ្ញុំ និងដើមបណ្តឹងគឺជាសមាជិកគ្រួសារ។ លោកស្រី Otero គឺជាជនភៀសខ្លួនពីប្រទេសកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហម" ។ "នាង និងប្តីរបស់នាងបានជួយដើមបណ្តឹង ដែលជាបងប្អូនជីដូនមួយរបស់លោកស្រី Otero ឱ្យរួចផុតពីភាពទុគ៌ត ដោយមកសហរដ្ឋអាមេរិក"។ យោងតាមលោក Johnsom Treadway បច្ចុប្បន្នក៏ស្ថិតនៅក្រោមការចោទប្រកាន់ពីបទចោរកម្ម។ Johnson បាននិយាយថា "នាង (Treadway) បានធ្វើការជាបន្តបន្ទាប់នៅហាងនំដូណាត់តូចមួយនៅ Rockport ទោះបីជាអស់រយៈពេល 2 ឆ្នាំ 3 ខែបន្ទាប់ពីទទួលបានកាតបៃតងរបស់នាង" ។ "នាងបានឈប់ធ្វើការនៅទីនោះនៅថ្ងៃទី20 ខែសីហាឆ្នាំ២០១៨ នៅពេលដែលនាងបានរកឃើញថានាងត្រូវបានឃ្លាំមើលដោយកាមេរ៉ា។ លោក Johnson បាននិយាយថា "បន្ទាប់ពីត្រូវបានចាប់ខ្លួនដោយប៉ូលីស ដើមចោទបានប្តឹង Oteros ដោយលើកឡើងពីបញ្ហានៃការជួញ

ដូរមនុស្ស និងពលកម្មដោយបង្ខំដែលមិនធ្លាប់លើកឡើងពីមុនមក" ។ "Oteros មានរូបភាពជាច្រើនដែលបង្ហាញពីគ្រួសារដែលមានសុភមង្គល និងស្រលាញ់គ្នា"។

កំណត់ត្រារបស់តុលាការស្រុក Aransas បង្ហាញថា Treadway ត្រូវបានចោទប្រកាន់ដោយចៅក្រមធំនៅក្នុងខែមេសា ឆ្នាំ២០២១ ពីបទ "គ្រប់គ្រងលើអចលនទ្រព្យ ពោលគឺប្រាក់នៃតម្លៃសរុបចំនួន$៣០,០០០ ឬច្រើនជាងនេះ ប៉ុន្តែតិចជាង $១៥០,០០០ ពី Matthew Otero" និងអាជីវកម្មរបស់ Otero, Rockport ដូណាត់ "ដោយគ្មានការយល់ព្រមពីម្ចាស់និងដោយមានចេតនាដកហូតកម្មសិទ្ធិករ" – បទចោទប្រកាន់កម្រិតទីបីត្រូវបានដាក់។ បច្ចុប្បន្នសំណុំរឿងរបស់ Treadway ត្រូវបានកំណត់សម្រាប់ការជំនុំជម្រះនៅថ្ងៃទី២ ខែឧសភា នៅក្នុងតុលាការស្រុកទី ៣៦ នេះបើយោងតាមការិយាល័យក្រឡាបញ្ជីស្រុក Aransas County ។

## អាជ្ញាធរសូមឱ្យពលករស្របច្បាប់វិលទៅធ្វើការនៅថៃ ត្រូវទៅតាមច្រកព្រំដែនអន្តរជាតិ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 26 April 2022 | 09:22 ICT

**បន្ទាយមានជ័យ:** នគរបាលខេត្តបន្ទាយមានជ័យបានឃាត់ខ្លួនពលរដ្ឋខ្មែរជិត ១០០ នាក់ ដែលបម្រុងឆ្លងដែនដោយខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ ខណៈអាជ្ញាធរសូមឱ្យពលករស្របច្បាប់ ដែលវិលទៅធ្វើការនៅប្រទេសថៃវិញ ត្រូវចូលទៅតាមច្រកព្រំដែនអន្តរជាតិ ដោយមានការបំពេញបែបបទត្រឹមត្រូវ។ អគ្គស្នងការដ្ឋាននគរបាលជាតិបានឱ្យដឹងថា ពាក់ព័ន្ធកិច្ចការព្រំដែននេះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យលោក សិទ្ធិ ឡោះ បានដាក់ចេញនូវបទបញ្ជាទប់ស្កាត់រាល់បទល្មើសឆ្លងដែនខុសច្បាប់ ដូចជាបទល្មើសសេដ្ឋកិច្ច បទល្មើសគ្រឿងញៀន និងប្រជាពលរដ្ឋលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់។

ជាក់ស្តែង នៅវេលាម៉ោង ១៦ និង ០០ នាទី ថ្ងៃទី ២៣ ខែមេសា លោក សួង សៅ មេបញ្ជាការ វរសេនាតូចការពារព្រំដែនគោកលេខ ៨១៥ អមដំណើរដោយលោក មាស ម៉េងហួង មេបញ្ជាការរង វរសេនាតូចការពារព្រំដែនគោកលេខ ៨១៥ បានដឹកនាំកម្លាំងប៉ុស្តិ៍ការពារព្រំដែនចំបក់ សហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំបឹងបេង នៃអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ និងកម្លាំងកងរាជអាវុធហត្ថស្រុកម៉ាឡៃបានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរ ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់បានចំនួន ៩៥ នាក់ ត្រង់ចំណុចមាត់អូរព្រំដែនស្ថិតក្នុងភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ។ លោក សួង សៅ បន្តថា ពលករដែលបម្រុងលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ចំនួន ៩៥ នាក់នោះ មាន ស្រី ៣៩ នាក់ និងកុមារ ១១ នាក់ មកពីខេត្តចំនួន ១០។ ក្នុងនោះខេត្តបន្ទាយមានជ័យ ២១ នាក់ សៀមរាប ២៩ នាក់ បាត់ដំបង ១៣ នាក់ ឧត្តរមានជ័យ ៥ នាក់ កំពង់ធំ ២ នាក់ កំពត ៨ នាក់ ព្រៃវែង ១០ នាក់ តាកែវ ៣ នាក់ ស្វាយរៀង ៣ នាក់ និងខេត្តត្បូងឃ្មុំ ១ នាក់។ លោកបន្តថា ក្រោយការឃាត់ខ្លួនសួរនាំ និងធ្វើកិច្ចសន្យារួច សមត្ថកិច្ចបានប្រគល់ពួកគាត់ជូនផ្នែកជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីចាត់វិធានការបន្តតាមនីតិវិធី ។

លោក បេន សំអាត អធិការនគរបាលស្រុកម៉ាឡៃបញ្ជាក់ថា ពលរដ្ឋទាំងនោះត្រូវបានសមត្ថកិច្ចធ្វើការអប់រំ និងឱ្យធ្វើកិច្ចសន្យាហើយអនុញ្ញាតឱ្យពួកគាត់ វិលត្រឡប់ទៅរកការងារធ្វើនៅឯស្រុកកំណើតវិញ។ ទាក់ទងនឹងបញ្ហាពលរដ្ឋឆ្លងដែននេះ កម្លាំងស្នងការនគរបាលខេត្តបន្ទាយមានជ័យ កំពុងស្រាវជ្រាវរកមុខសញ្ញាមេខ្យល់ ដែលពាក់ព័ន្ធនាំមនុស្សឆ្លងដែនខុសច្បាប់ ដើម្បីចាប់ខ្លួនយកទៅផ្តន្ទាទោស ។

អភិបាលរងខេត្តបន្ទាយមានជ័យ លោក ង៉ោ ម៉េងជ្រួន បានថ្លែងថា ក្នុងនាមរាជរដ្ឋាភិបាលយើងបានខិតខំធ្វើការសម្របសម្រួលជាមួយក្រសួងការងារថៃ ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរចូលតាមច្រកអន្តរជាតិ ដើម្បីបញ្ជាក់លិខិតឆ្លងដែនដែលទទួលស្គាល់ដោយកម្ពុជា-ថៃជាផ្លូវការ។ លោកថា៖ «ព្រោះយើងមិនអនុញ្ញាតឱ្យគាត់ចេញចូលតាមច្រករបៀង (ខុសច្បាប់) ដែលមិនមែនជាច្រកផ្លូវការទេ ព្រោះតាមច្រកអន្តរជាតិ មានការបំពេញបែបបទត្រឹមត្រូវ

តាមផ្លូវច្បាប់ គាត់អាចចេញចូលបានសម្រាប់បងប្អូនពលករ ប៉ុន្តែមិនមែនសម្រាប់ទេសចរទេ»។ លោកថា តាមគោលការណ៍ខេត្តមិនអនុញ្ញាតឱ្យចេញចូលតាមច្រករបៀងនោះទេ ខណៈកម្លាំងសមត្ថកិច្ចនៅបន្តរឹតបន្តឹងតាមខ្សែបន្ទាត់ព្រំដែនដដែល និងស្រាវជ្រាវរកមេខ្យល់ផងដែរ។

ពលករមួយរូបរស់នៅខេត្តបន្ទាយមានជ័យ ដែលទើបត្រឡប់ពីប្រទេសថៃមុនពេលចូលឆ្នាំខ្មែរ បានប្រាប់ភ្នំពេញប៉ុស្តិ៍ ក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះថា លោកមិនមានឯកសារគ្រប់គ្រាន់សម្រាប់ឆ្លងកាត់ព្រំដែនតាមច្រកដែលស្របច្បាប់ទៅថៃវិញនោះទេ ដូច្នេះមានតែរង់ចាំរដ្ឋាភិបាលទាំង ២ បើកច្រកព្រំដែនទាំងស្រុងឡើងវិញសិន។ លោកនិយាយថា៖ «ឥឡូវខ្ញុំធ្វើការឱ្យគេដកជំឡូង និងធ្វើស្រែសិន ព្រោះបើទៅវិញគេត្រូវការលិខិតឆ្លងដែន និងឯកសារផ្សេងៗ ហើយបើខ្ញុំត្រឡប់ទៅវិញមានតែតាមច្រករបៀងហើយឱ្យអ្នកនាំផ្លូវ ៨ ០០០ បាត អ៊ីចឹងខ្ញុំសម្រេចចិត្តនៅខ្មែរសិន»។

ចំណែក ស្នងការនគរបាលខេត្តបាត់ដំបងលោក សាត គឹមសាន បានចេញបញ្ជាដាក់កម្លាំងជាប្រចាំការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃដើម្បីត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែន។ ជាក់ស្តែងនៅថ្ងៃទី ២៤ ខែមេសា កម្លាំងខេត្តបាត់ដំបងបានត្រៀមកម្លាំងចេញល្បាត រួមមាន កម្លាំងប៉ុស្តិ៍អូរអន្លក់ ចំនួន ៨ នាក់ កម្លាំងប៉ុស្តិ៍បឹងអាជាង ចំនួន ២ នាក់ និងបានសហការជាមួយកងកម្លាំងវរៈចំណុះឱ្យកម្លាំងកងពលតូចថ្មើរជើងលេខ ៥២ កម្លាំងកងពលលេខ ៥៣ និងកម្លាំងផ្នែកសឹករងស្រុក បានចុះល្បាតត្រួតពិនិត្យនៅតាមព្រំដែន ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទ និងក្តាប់សភាពការណ៍តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដែលជាលទ្ធផលពិនិត្យឃើញថា ពុំមានសកម្មភាពអ្វីគួរឱ្យកត់សម្គាល់ឡើយ។ យ៉ាងណាមិញលោក សាត គឹមសាន ប្រាប់ភ្នំពេញប៉ុស្តិ៍ថា លោកមិនទាន់ទទួលបានរបាយការណ៍សរុបពីភាគីពាក់ព័ន្ធនៅឡើយទេ។

ពាក់ព័ន្ធនឹងបញ្ហាពលករនេះដែរ យ៉ាងហោចណាស់មានពលករខ្មែរចំនួន ២ នាក់ស្លាប់ និងរបួសធ្ងន់-ស្រាលចំនួន ១២ នាក់ ខណៈរថយន្តដឹកពលករខ្មែរ ជួបគ្រោះថ្នាក់ចរាចរណ៍នៅខេត្តស្រះកែវ កាលពីថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០២២៕

## រដ្ឋមន្ត្រីក្រសួងការងារ ស្នើឱ្យជប៉ុន ទទួលកម្មសិក្សាការី ក៏ដូចជាពលករជំនាញរបស់កម្ពុជា ទៅធ្វើការនៅប្រទេសជប៉ុនឱ្យកាន់តែច្រើន

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២២ វិទ្យុជាតិកម្ពុជា៖ បូណា

ភ្នំពេញ÷រដ្ឋមន្ត្រីក្រសួងការងារ ស្នើឱ្យជប៉ុនទទួលកម្មសិក្សាការី ក៏ដូចជាពលករជំនាញរបស់កម្ពុជា ទៅធ្វើការនៅប្រទេសជប៉ុនឱ្យកាន់តែច្រើន ដើម្បីលើកកម្ពស់ជីវភាព និងមានជំនាញបំពេញការងារជូនអ្នកវិនិយោគជប៉ុននៅកម្ពុជា។ ក្នុងជំនួបសំដែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Fumiaki Takahashi ប្រធានសមាគមជប៉ុនកម្ពុជា( JC A) និងជាអតីតឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា (២០០៣-២០០៧) និងលោក KATO Kazunori ជានាយកប្រតិបត្តិសមាគម បានដឹកនាំប្រតិភូដែលជាអ្នកវិនិយោគមកពីប្រទេសជប៉ុននៅកម្ពុជា ដើម្បីសិក្សាស្វែងយល់ពីឱកាសវិនិយោគ ក៏ដូចជាកម្មសិក្សាការីដែលបានចេញទៅធ្វើការនៅប្រទេសជប៉ុន នៅទីស្តីការក្រសួងការងារ នាព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជំរុញឱ្យខាងភាគីជប៉ុន ទទួលកម្មសិក្សាការី ក៏ដូចជាពលករជំនាញរបស់កម្ពុជា បានទៅធ្វើការនៅប្រទេសជប៉ុនឱ្យកាន់តែច្រើន ពីព្រោះ នៅពេលដែលពួកគេវិលត្រឡប់មកកាន់មាតុភូមិកំណើតវិញ ទទួលបានចំណេះជំនាញ សម្រាប់បង្កើតអាជីវកម្មផ្ទាល់ខ្លួន រឺក៏ក្លាយជាអ្នកគ្រប់គ្រងនៅក្នុងក្រុមហ៊ុន សហគ្រាសរបស់ជប៉ុនដែលមានវត្តមាននៅកម្ពុជា។

លើវិស័យការងារ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង អះអាងថា កម្ពុជាមានកិច្ចសហប្រតិបត្តិសម្រាប់កម្មសិក្សាការី និងពលករជំនាញ ចេញទៅធ្វើ ការនៅជប៉ុន និងដោយសារទីផ្សារនៅជប៉ុន ផ្តល់នូវប្រាក់កម្លាំងពលកម្មខ្ពស់ ដែលអាចទាក់ទាញពលករពីក្រៅប្រទេសនានា។ ម្យ៉ាងទៀត ពលករដែលបានបម្រើការនៅទីនោះ ទទួលបាននូវការអាណិតស្រឡាញ់រាប់អាន ពីអ្នករួមការងារ និងថៅកែរបស់ពួកគេផងដែរ។ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង សំដែងការរីករាយដែលបានជួបជាមួយខាងសមាគមជប៉ុនកម្ពុជា(JC A) ដែលជាឱកាសមួយក្នុងការបន្តកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយគ្នា រវាងប្រទេសយើងទាំងពីរ កម្ពុជា-ជប៉ុន ឯកឧត្តមសង្ឃឹមថាទស្សនកិច្ចរបស់គណៈប្រតិភូ ដែលជាអ្នកវិនិយោគជប៉ុននៅលើទឹកដីកម្ពុជា ពិតជានាំមកនូវការពូនជ្រំសាមគ្គីភាព រវាងប្រជាជន និងប្រជាជនរបស់យើងកាន់តែរីកចម្រើនបន្តទៀត។

លោក Fumiaki Takahashi បានជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីថា នៅក្នុងឆ្នាំ២០១៩ ខាងសមាគមរបស់លោកក៏ធ្លាប់បានដឹកនាំអ្នកវិនិយោគជប៉ុន មកសិក្សាស្វែងយល់ពីបរិយាកាសវិនិយោគនៅកម្ពុជាម្តងហើយដែរ ប៉ុន្តែដោយសារតែមានបញ្ហាកូវីដ-១៩ ធ្វើឱ្យរំខាននូវដំណើរការចង្វាក់ផលិតកម្ម និងវិនិយោគ ទើបខាងសមាគមខកខានមិនបានមកកាន់កម្ពុជា។ លោកមើលឃើញថា ក្នុងចំណោមប្រទេសក្នុងតំបន់ ប្រទេសកម្ពុជា បានទប់ស្កាត់ការឆ្លងរាលដាលនូវជំងឺកូវីដ-១៩ បានយ៉ាងល្អប្រសើរ។ លោកក៏រីករាយដែលបានជួបជាមួយឯកឧត្តមរដ្ឋមន្ត្រី ក៏ដូចជាថ្នាក់ដឹកនាំរបស់ក្រសួង ដើម្បីទទួលបាននូវព័ត៌មានមួយចំនួនពាក់ព័ន្ធទៅនឹងវិស័យការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាឱកាសវិនិយោគនៅកម្ពុជាផងដែរ។ ឯកឧត្តមរដ្ឋមន្ត្រី កត់សម្គាល់ឃើញថា អ្នកវិនិយោគជប៉ុនមកកម្ពុជាមានការកើនឡើង មានច្រើនផ្នែក ដូចជាកសិកម្ម ឧស្សាហកម្ម ធនាគារ សេវាកម្ម សំណង់ អចលនទ្រព្យ ផ្សារទំនើបជាដើម។

ការវិនិយោគរបស់ជប៉ុន បានរួមចំណែកដល់សេដ្ឋកិច្ចរបស់កម្ពុជា មានប្រព័ន្ធបច្ចេកវិទ្យាទំនើប ទាន់សម័យ។ មកដល់បច្ចុប្បន្ន បរិយាកាស និងឱកាសវិនិយោគនៅកម្ពុជាមានភាពល្អប្រសើរ ដោយសារកម្ពុជាមានសមត្ថភាពអាចគ្រប់គ្រងបាននូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ឯកឧត្តមរដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលជប៉ុនដែលបានជួយមកកម្ពុជា ក្នុងវិស័យសុខាភិបាល ដោយផ្តល់នូវជំនួយវ៉ាក់សាំងមកដល់ពលរដ្ឋកម្ពុជា ព្រមទាំងវិស័យជាច្រើនទៀតដែលរាជរដ្ឋាភិបាលជប៉ុនបានជួយដល់កម្ពុជានាពេលកន្លងមក។ ជាមួយគ្នានេះដែរ ឯកឧត្តមរដ្ឋមន្ត្រី បានជម្រាបទៅកាន់អ្នកវិនិយោគជប៉ុនថា កម្ពុជាបានរៀបចំនូវច្បាប់វិនិយោគថ្មី ដើម្បីជួយសម្រួលដល់បរិយាយកាសវិនិយោគនៅកម្ពុជាផងដែរ៕

## នៅព្រឹកថ្ងៃអង្គារ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ចំនួន២លើក

https://gdlf-kh.com/ 2022/04/26/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅ

លួនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងឃោជាវរសេនាតូច៩៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២លើក សរុបចំនួន២២នាក់ ស្រី៩នាក់ ក្មេង២នាក់ ក្មេងស្រី២នាក់។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមាន និងមានប័ណ្ណចាក់វ៉ាក់សាំងស្តែនចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## សមត្ថកិច្ចថៃឃាត់ខ្លួនពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់សរុប៦២នាក់នៅខេត្តស្រះកែវ

http://nokorwatnews.com/ 26/04/2022

ប្រទេសថៃ ៖ សេចក្តីរាយការណ៍ពីបន្ទាត់ព្រំដែនកម្ពុជា-ថៃថា សមត្ថកិច្ចថៃបានឃាត់ខ្លួនពលរដ្ឋខ្មែរសរុបចំនួន៦២នាក់ នៅថ្ងៃទី២៦ មេសា ២០២២ ដែលពួកគាត់បានប្រមូលផ្តុំគ្នាលាក់ខ្លួនក្នុងព្រៃក្រោយភូមិនើន សំបូរណ៍ ឃុំ/ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ។ ប្រភពបន្តថា: កម្លាំងចុះល្បាត និងឃ្លាំមើលក្នុងភូមិសាស្ត្រទទួលខុសត្រូវបានប្រទះឃើញក្រុមមនុស្សលាក់ខ្លួនក្នុងព្រៃ ទើបចូលទៅត្រួតពិនិត្យ និងចាប់ឃុំពលរដ្ឋខ្មែរបាន១៦នាក់ ក្នុងនោះប្រុស១១ និងស្រី៥នាក់ ក្រោយសមត្ថកិច្ចថៃសួរនាំពួកគេប្រាប់ថា ត្រូវការធ្វើដំណើរទៅធ្វើការតាមបណ្តាខេត្ត ក្នុងប្រទេសថៃ និងមិនទាន់បានចំណាយលុយឲ្យមេខ្យល់នៅឡើយទេ។បន្ទាប់មក កម្លាំងទាហានប្រាណកងរយទី១២០៤ បានប្រទះឃើញមនុស្សមួយក្រុមទៀតគួរឲ្យសង្ស័យ ដើរមកតាមច្រករបៀងសំដៅចូលមកប្រទេសថៃចំនួន២៩នាក់ ក្នុងនោះប្រុស១៨ ស្រី១០ និងក្មេងប្រុសម្នាក់ នៅបរិវេណភូមិណង យ៉ាកែវ ឃុំ/ស្រុកគោកឃ្សូង ខេត្តស្រះកែវ ទើបសមត្ថកិច្ចថៃចូលទៅត្រួតពិនិត្យនិងឃុំខ្លួនបញ្ជូនឲ្យជំនាញ ដើម្បីចាត់ការតាមច្បាប់។ សមត្ថកិច្ចបន្តថា:ក្រោយពីសួរនាំក៏បន្តចាប់ខ្លួនពលរដ្ឋខ្មែរ៤គោលដៅផ្សេងទៀតបានចំនួន១៧នាក់បន្ថែមទៀត សរុបទាំងអស់៦២នាក់៕

គួររំលឹកថា: ក្រោយពីរដូវចូលឆ្នាំបានកន្លងផុតទៅជាងមួយសប្តាហ៍ គេសង្កេតឃើញកម្លាំងជួរមុខកម្ពុជា និងថៃបានឃាត់ខ្លួនពលរដ្ឋខ្មែរយើងឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើជាច្រើនអ្នក ទាំងដោយសារតែពួកគាត់នៅតែបន្តចាញ់បោកមេខ្យល់ ដែលបង្កឲ្យមានវិបត្តដល់គ្រួសារពេលពួកគាត់ជួបបញ្ហាគ្រោះថ្នាក់ដោយប្រការណាមួយមិនខាន ៕

# ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២

## ពលករ៧៤នាក់ត្រូវកម្លាំងនគរបាលឃាត់ខ្លួនមកសួរនាំ

http://nokorwatnews.com/ 26/04/2022

ខេត្តបន្ទាយមានជ័យ ៖ នគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ ទប់ស្កាត់ពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់០២ករណីសរុបចំនួន៧៤នាក់ ។

លោកវរសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានឲ្យដឹងថា៖ ជានិច្ចកាល លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ តែងដាក់ចេញបទបញ្ជាដល់វរសេនាតូចនគរបាលការពារព្រំដែន យកចិត្តទុកដាក់ទប់ស្កាត់បង្ក្រាបបទល្មើសតាមព្រំដែន និងការលួចឆ្លងដែនខុសច្បាប់របស់ពលរដ្ឋខ្មែរ ក្នុងបរិបទយុទ្ធការប្រយុទ្ធប្រឆាំងការដាលរាលជម្ងឺកូវីដ-១៩។ នៅវេលាម៉ោង០៦

ល្ងាចថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ កម្លាំងប៉ុស្តិ៍ការពារព្រំដែនអូរសោយ នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨០៧ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរបម្រុងលួចឆ្លងដែនទៅប្រទេសថៃចំនួន៦៥នាក់ នៅចំណុច ភូមិសាមគ្គី ឃុំគោករមៀត ស្រុកថ្មពួក និងនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង០១ និង៣០នាទី រំលងអធ្រាត្រកម្លាំងនគរបាលប៉ុស្តិ៍អូរសោយ ទប់ស្កាត់បានចំនួន០៩នាក់ បន្ថែមទៀត សរុបចំនួន៧៤នាក់ ស្រី៣០នាក់។ លោកវរសេនីយ៍ឯក ឡុង សំណាង បានបញ្ជាក់ថា៖ក្រោយពីឃាត់ខ្លួនកម្លាំងនគរបាលយើងបានធ្វើការស្រាវជ្រាវរកមុខសញ្ញាមេខ្យល់នាំផ្លូវ តែពុំទទួលបានលទ្ធផលនោះទេពួកគាត់ពុំមានមេខ្យល់នាំផ្លូវនោះឡើយ ។ក្រោយពីធ្វើការសួរនាំរួច នៅវេលាម៉ោង០៨និង៤៥នាទីព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ បានបញ្ជូនពួកគាត់ទៅឲ្យនគរបាលជំនាញនៃអធិការដ្ឋាននគរបាលស្រុកថ្មពួក ដើម្បីមានវិធានការបន្ត ៕

## សមត្ថកិច្ចថៃឃាត់ខ្លួនពលករខ្មែរ១២៥នាក់ចាញ់បោកមេខ្យល់ឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 26/04/2022

ប្រទេសថៃ ៖ សមត្ថកិច្ចនៅបន្ទាត់ព្រំដែន បានរាយការណ៍ថា មួយរយៈចុងក្រោយបន្ទាប់ពីរដូវចូលឆ្នាំប្រពៃណីខ្មែរបានកន្លងផុតទៅពលករខ្មែរ ហាក់បីដូចជាមានកំណើនក្នុងការឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅក្រៅប្រទេសជាក់ស្តែងកាលពីវេលាម៉ោង១១ និង៣០នាទី ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ថា កម្លាំងនគរបាលអន្តោប្រវេសន៍ខេត្តស្រះកែវ សហការជាមួយកម្លាំងទាហានកងរយ១២៤,ទាហានកងកម្លាំងបូរផា បានចាត់ក្រុមល្បាត ឃ្លាំមើលរហូត២៤ម៉ោង បរិវេណព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តស្រះកែវ ជាប់ជាមួយខេត្តបន្ទាយមានជ័យ របស់កម្ពុជា ដើម្បីទប់ស្កាត់ការលបលួចឆ្លងដែនចូលប្រទេសដោយខុសច្បាប់ ក្នុងភូមិសាស្រ្តទទួលខុសត្រូវ រហូតឈានទៅចាប់ឃុំខ្លួនពលករខ្មែរបានសរុប១២៥នាក់ នៅបរិវេណព្រៃល្បាស់ ចម្ងាយពីទូរប៉េមនគបាលប្រមាណ១០០ម៉ែត្រតែប៉ុណ្ណោះ ក្នុងឃុំផានសឹក ស្រុកអារញ្ញ ខេត្តស្រះកែវ។

ក្រោយពីសមត្ថកិច្ចថៃសួរនាំពលករខ្មែរទាំងអស់ខាងលើបានសារភាពថា ពួកគាត់លួចឆ្លងដែនចូលមកដើម្បីទៅធ្វើការក្នុងប្រទេសថៃ ក្រោយពីសាកសួរនិងធ្វើកំណត់ហេតុចាប់ឃុំរួចរាល់ សមត្ថកិច្ចបាននាំខ្លួនបញ្ជូនទៅឲ្យជំនាញ ខ្លងណាំសៃ ស្រុកអារញ្ញ ដើម្បីចាត់ការតាមច្បាប់បន្ត។ ខណៈដូចគ្នានេះដែរ បរិវេណប្រឈមជាមួយព្រំដែនប្រទេសថៃ ចំណុចត្រួតពិនិត្យក្បាលស្ពាន បាននាំកម្លាំងទប់ស្កាត់និងចាប់ឃុំខ្លួនពលករខ្មែរចំនួន១៥នាក់ ក្នុងនោះប្រុស៧ និងស្រី៨នាក់ ខណៈព្យាយាមលួចឆ្លងដែនទៅធ្វើការប្រទេសថៃ បរិវេណច្រករបៀងភូមិក្បាលស្ពានឃុំស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ប្រឈមជាមួយភូមិចាប់ព្រិក ស្រុកអារញ្ញ ខេត្តស្រះកែវរបស់ថៃ ខាងសមត្ថកិច្ចកម្ពុជា បាននាំពលករទាំងអស់ បញ្ជូនទៅអនុវត្តទោសនៅអធិការដ្ឋាននគបាលស្រុកម៉ាឡៃ បន្ត៕

## នគរបាលវរសេនាតូចការពារព្រំដែនគោក<br>លេខ៨០៧ ទប់ស្កាត់ពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់០២ករណីសរុបចំនួន៧៤នាក់

https://gdlf-kh.com/ 2022/04/26/ Noun Vanny បន្ទាយមានជ័យ

បន្ទាយមានជ័យ ៖ លោកវរសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានឲ្យដឹងថា ៖ ជានិច្ចកាល លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យតែងដាក់ចេញបទបញ្ជាដល់វរសេនាតូចនគរបាលការពារព្រំដែន យកចិត្តទុកដាក់ទប់ស្កាត់បង្ក្រាបបទល្មើសតាមព្រំដែននិងការលួចឆ្លងដែនខុសច្បាប់របស់ពលរដ្ឋខ្មែរក្នុងបរិបទយុទ្ធនាការប្រយុទ្ធប្រឆាំងការរាលដាលជម្ងឺកូវីដ-១៩។ នៅវេលាម៉ោង០៦យប់ថ្ងៃចន្ទ ៩ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែមេសា

ឆ្នាំ២០២២ កម្លាំងប៉ុស្តិ៍ការពារព្រំដែនអូរសោយ នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨០៧ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរបម្រុងលួចឆ្លងដែនទៅប្រទេសថៃចំនួន៦៥នាក់ នៅចំណុច ភូមិសាមគ្គី ឃុំគោករមៀត ស្រុកថ្មពួក និងនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង០១និង៣០នាទីរំលងអាធ្រាតកម្លាំងនគរបាលប៉ុស្តិ៍អូរសោយទប់ស្កាត់បានចំនួន០៩នាក់បន្ថែមទៀត សរុបចំនួន៧៤នាក់ ស្រី៣០នាក់។

លោកវរសេនីយ៍ឯក ឡុង សំណាង បានបញ្ជាក់ថា ៖ ក្រោយពីឃាត់ខ្លួនកម្លាំងនគរបាលយើងបានធ្វើការស្រាវជ្រាវរកមុខសញ្ញាមេខ្យល់នាំផ្លូវ តែពុំទទួលបានលទ្ធផលនោះទេពួកគាត់ពុំមានមេខ្យល់នាំផ្លូវនោះឡើយ ។ ក្រោយពីធ្វើការសួរនាំរួច នៅវេលាម៉ោង០៨និង៤៥នាទីព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ បានបញ្ជូនពួកគាត់ទៅឲ្យនគរបាលជំនាញនៃអធិការដ្ឋាននគរបាលស្រុកថ្មពួក ដើម្បីមានវិធានការបន្ត ៕

## រយៈពេល០២ថ្ងៃនគរបាលវរ សេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយយោធាកងពលតូចលេខ៥១ បានទប់ស្កាត់ប្រជាពលរដ្ឋខ្មែរបម្រុងលួចឆ្លងដែនខុសច្បាប់ ចំនួន២១នាក់/ស្រី១០នាក់

https://gdlf-kh.com/ 2022/04/26/ Noun Vanny បន្ទាយមានជ័យ

បន្ទាយមានជ័យ ៖ កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាកងពលតូចថ្មើរជើងលេខ៥១បានទប់ស្កាត់ប្រជាពលរដ្ឋខ្មែរបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃរយៈពេល០២ថ្ងៃជាបន្តបន្ទាប់ចំនួន២១នាក់ ក្នុងនោះស្រី១០នាក់ ក្នុងភូមិសាស្ត្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា ៖ អនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ក្នុងការទប់ស្កាត់ការលួចឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសជិតខាង។ក្នុងរយៈពេល០២ថ្ងៃគឺថ្ងៃចន្ទ-អង្គារ ៩-១០ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី២៥-២៦ ខែមេសា ឆ្នាំ២០២២ នគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាកងពលតូចថ្មើរជើងលេខ៥១ បានទប់ស្កាត់ប្រជាពលរដ្ឋខ្មែរបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ រយៈពេល០២ថ្ងៃជាបន្តបន្ទាប់ចំនួន២១នាក់ ក្នុងនោះស្រី១០នាក់ ក្នុងភូមិសាស្ត្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ លោកមេបញ្ជាការបានបន្តថា ៖ ក្រោយពីធ្វើការឃាត់ខ្លួន ប្រជាពលរដ្ឋទាំងអស់នោះត្រូវបានធ្វើការអប់រំណែនាំពួកគាត់កុំឲ្យមានការលួចឆ្លងដែនទៅប្រទេសគេដោយខុសច្បាប់នាំឲ្យមានគ្រោះថ្នាក់។ មួយវិញទៀតប្រទេសយើងទាំង០២កំពុងតែបិទព្រំដែនដើម្បីទប់ស្កាត់ការឆ្លងរាលដាលជម្ងឺកូវីដ-១៩ ហើយសុំឲ្យពួកគាត់វិលត្រឡប់ទៅរកការងារធ្វើនៅក្នុងប្រទេសរបស់យើងវិញ។ បន្ទាប់មកយើងបានឲ្យពួកគាត់ធ្វើកិច្ចសន្យានិងបានប្រគល់ពួកគាត់ឲ្យកម្លាំងនគរបាលជំនាញ នៃអធិការដ្ឋាននគរបាលដើម្បីមានវិធានការបន្ត ៕

## បើទោះបីខាងកម្ពុជា ប្រឹងទប់ស្កាត់យ៉ាងណាក៏នៅមានពលរដ្ឋខ្មែរលួចឆ្លងដែនបានត្រូវសមត្ថកិច្ចថៃឃាត់ខ្លួន

https://gdlf-kh.com/ 2022/04/26/ Noun Vanny បន្ទាយមានជ័យ

បន្ទាយមានជ័យ ៖ លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា ៖ នៅវេលាម៉ោង ០៤៖០០នាទីទៀបភ្លឺ ថ្ងៃអង្គារ ១០ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័កពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ យើងបានទទួលព័ត៌មានថាមានប្រជាពលរដ្ឋខ្មែរលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ កម្លាំងប៉ុស្តិ៍ក្បាលទំនប់ចំនួន ០៤នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី រឿម ប៊ុនរិ

ទូ នាយប៉ុស្តិ៍ ចុះពិនិត្យដល់អូរព្រំដែននៅកន្លែងដែលប្រជាពលរដ្ឋទាំងនោះលួចឆ្លងដែន រួចបានធ្វើការទំនាក់ទំនងផ្តល់ព័ត៌មានទៅទាហានព្រាន(ឈុតខ្មៅថៃ) កងអនុសេនាធំលេខ១៣-០៥ ដែលឈរជើងទល់មុខភូមិសាស្ត្រប៉ុស្តិ៍ក្បាលទំនប់សហការជួយទប់ស្កាត់។ លុះដល់វេលាម៉ោង០៥និង២០នាទីទាបភ្លឺ ទាហានឈុតខ្មៅថៃទប់ស្កាត់បានប្រជាពលរដ្ឋខ្មែរចំនួន ៣៧នាក់ (ស្រី១៨នាក់) នៅចំណុចភូមិគុតហ៊ីន (មូស៊ី) ឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ទល់មុខភូមិក្បាលទំនប់ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ លោកមេបញ្ជាការបានបញ្ជាក់ថា ៖ ពលរដ្ឋខ្មែរទាំង៣៧នាក់នោះ បន្ទាប់ពីឃាត់ខ្លួនធ្វើការសាកសួរ និងធ្វើតេស្តរកមេរោគកូវីដ-១៩ រួច ទាហានឈុតខ្មៅថៃបានបញ្ជូនឲ្យនគរបាលក្លងណាំសៃ ដើម្បីចាត់វិធានការបន្តតាមនីតិវិធី ៕

## ឃាត់ខ្លួនពលករខ្មែរ១៣៤នាក់ បម្រុងលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៧ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ០៩:២៥

បន្ទាយមានជ័យ ៖ កម្លាំងនគរបាលការពារព្រំដែនគោក២ អង្គភាព ឃាត់ខ្លួនពលករខ្មែរ ចំនួន១៣៤នាក់ ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ កាលពីថ្ងៃទី២៥ ខែមេសានេះ ក្នុងភូមិសាស្ត្រ ស្រុកម៉ាឡៃ និងស្រុកថ្មពួក ។ កម្លាំងនគរបាលការពារព្រំដែនគោក២ អង្គភាពបានឃាត់ពលករខ្មែរចំនួន១៣៤នាក់ និងស្រីចំនួន៥៣នាក់ ដែលបម្រុងលួចចូលទៅប្រទេសថៃ ដើម្បីទៅរកការងារធ្វើដោយខុសច្បាប់ ។

លោកវរៈសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨០៧ បានប្រាប់ថា ៖ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ នៅចំណុចព្រំដែនភូមិសាមគ្គី ឃុំគោករមៀត ស្រុកថ្មពួក កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧ បានសហការជាមួយកម្លាំងយោធាបានឃាត់ពលករខ្មែរ ចំនួន៧៤នាក់ ស្រី៣០នាក់ ដែលបម្រុងលួចឆ្លងទៅប្រទេសថៃ ដើម្បីទៅរកការងារធ្វើដោយខុសច្បាប់ ។

លោកវរៈសេនីយ៍ឯក សួង សៅ មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានប្រាប់ថា ៖ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ នៅចំណុចតាមបន្ទាត់ព្រំដែន ភូមិក្បាលស្ពាន ឃុំ.ស្រុកម៉ាឡៃ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ បានសហការជាមួយកម្លាំងយោធាបានឃាត់ពលករខ្មែរ ចំនួន១២០នាក់ ស្រី២៣នាក់ ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃ ដើម្បីទៅរកការងារធ្វើដោយខុសច្បាប់ ។

លោកវរៈសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាក្រុមការងារទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជា នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ តាមច្រកអូរបីជាន់ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ដែលក្រុមការងារទទួលមាន ចំនួន១១៨នាក់ ស្រី៥២នាក់ កុមារ១៨នាក់ ក្នុងនោះមានអ្នកដែលចាក់វ៉ាក់សាំងការពារកូវីដ.១៩ ដូសទី២ និងដូសទី៣ មានចំនួន១០៨នាក់ ស្រី៤៦នាក់ ៕

## នគរបាលព្រំដែនគោក ឃាំងពលករខ្មែរបម្រុងលួចឆ្លងដែន១៣នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៧ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១០:២៧

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ បានឃាត់ខ្លួនពលករខ្មែរដែលបម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ ចំនួន១៣នាក់ នៅ២គោលដៅផ្សេងគ្នា កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២កន្លងទៅ នៅស្រុកម៉ាឡៃ ។

វរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ថ្លែងថា តាមការណែនាំរបស់ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្ត កម្លាំងនគរបាលការពារព្រំដែនគោក សហការជាមួយកម្លាំងយោធា ចេញល្បាតប្រទះឃើញពលករខ្មែរបម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយ

ខុសច្បាប់ទាំង២គោលដៅក្នុងស្រុកម៉ាឡៃ ចំនួន១៣នាក់ ក៏បានឃាត់ខ្លួន ។ លោកមេបញ្ជាការបន្តថា នៅគោលដៅទី១ វេលាម៉ោង៥ភ្លឺថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២នៅចំណុចអូរព្រំដែន ស្ថិតក្នុងភូមិក្បាលស្ពាន ឃុំម៉ាឡៃ កម្លាំងចម្រុះបានឃាត់ខ្លួនពលករខ្មែរចំនួន៧នាក់(ស្រី៣នាក់) ។ ក្នុងថ្ងៃជាមួយគ្នានោះដែរ នៅគោលដៅទី២ ត្រង់ចំណុចអូរព្រំដែនភូមិក្បាលទំនប់ ឃុំអូរសំព័រ បានឃាត់ខ្លួនចំនួន៦នាក់(ស្រី២នាក់)។ លោក សួង សៅ បញ្ជាក់ថា តាមការសាកសួរព័ត៌មាន គឺពួកគាត់បម្រុងលួចឆ្លងដែនតាមរយៈមេខ្យល់ដោយយកក្នុងម្នាក់៦.០០០បាត និងសន្យាជូនទៅរកការងារធ្វើនៅប្រទេសថៃ។ ប៉ុន្តែ នៅពេលជូនដល់កន្លែងរង់ចាំរថយន្តដែលមេខ្យល់ថៃមកទទួល ក៏ត្រូវបានកម្លាំងសមត្ថកិច្ចឃាត់ខ្លួនតែម្តង ៕

## ទទួលព័ត៌មានភ្លាមៗ សហការរវាងព្រំដែនកម្ពុជានិងថៃ ឃាត់ខ្លួនពលរដ្ឋជិត៤០នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ២៧ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១០:៣៨

ខេត្តបន្ទាយមានជ័យ ៖ លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូច នគរបាលការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា ៖ នៅវេលាម៉ោង០៤នាទីទៀបភ្លឺ នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ យើងបានទទួលព័ត៌មានថា មានប្រជាពលរដ្ឋខ្មែរលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ បន្ទាប់មកកម្លាំងប៉ុស្តិ៍ក្បាលទំនប់ចំនួន០៤នាក់ ដឹកដោយលោកវរសេនីយ៍ត្រី រឿម ប៊ុនរិទ្ធ នាយប៉ុស្តិ៍ ចុះពិនិត្យដល់អូរព្រំដែននៅកន្លែងដែលប្រជាពលរដ្ឋទាំងនោះលួចឆ្លងដែន រួចក៏បានធ្វើការទំនាក់ទំនងផ្តល់ព័ត៌មានទៅទាហានព្រាន (ឈុតខ្មៅថៃ) កងអនុសេនាធំលេខ១៣-០៥ ដែលឈរជើងទល់មុខភូមិសាស្រ្តប៉ុស្តិ៍ក្បាលទំនប់ ដើម្បីសហការជួយទប់ស្កាត់។ លុះដល់វេលាម៉ោង០៥និង២០នាទីទបភ្លឺ ទាហានឈុតខ្មៅថៃ ក៏ទប់ស្កាត់បានប្រជាពលរដ្ឋខ្មែរចំនួន៣៧នាក់ (ក្នុងនោះស្រី១៨នាក់) នៅចំណុចភូមិគុតហ៊ីន (មូស៊ី) ឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ទល់មុខភូមិក្បាលទំនប់ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ លោកមេបញ្ជាការបានបញ្ជាក់ថា ពលរដ្ឋខ្មែរទាំង៣៧នាក់នោះ បន្ទាប់ឃាត់ខ្លួនធ្វើការសាកសួរ និងធ្វើតេស្តរកមេរោគកូវីដ-១៩ រួច ទាហានឈុតខ្មៅថៃក៏បានបញ្ជូនននគរបាលក្លងណាំសៃវិញ ដើម្បីចាត់វិធានការបន្តនីតិវិធី៕

## កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ៦ ក្នុងការងារទេសន្តរប្រវេសន៍

https://www.kampucheathmey.com/ ថ្ងៃពុធ ២៧ មេសា ២០២២ដោយ Dy Bunnara

លោកស្រីវេជ្ជបណ្ឌិត Nenette Motus នាយិកាប្រចាំថ្នាក់តំបន់ របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក បានចូលរួមអបអរសាទរដល់ប្រទេសកម្ពុជាដែលជាប់ចំណាត់ថ្នាក់លេខ៦ ក្នុងការងារទេសន្តរប្រវេសន៍។ លោកស្រី វេជ្ជបណ្ឌិត Nenette Motus បានលើកឡើងបែបនេះកាលពីរសៀលថ្ងៃទី២៦មេសា ខណៈដែលលោកស្រីបានដឹកនាំសហការីចូលជួបសំដែងការគួរសមជាមួយ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

សម្តេចក្រឡាហោម ស ខេង មានប្រសាសន៍ថា ក្នុងរយៈពេលនៃការឆ្លងរីករាយដាលជំងឺកូវីដ១៩ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ធ្វើកិច្ចការងារជាច្រើនពាក់ព័ន្ធនិងការងារទេសន្តរប្រវេសន៍ ជាពិសេសពលរដ្ឋកម្ពុជាដែលធ្វើចំណាកស្រុកឆ្លងដែនតាមព្រំដែនកម្ពុជា-ថៃ ហើយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ក៏បានចូលរួមចំណែកយ៉ាងសកម្ម ទៅលើការងារដោះស្រាយចំពោះមុខ ដោយបានសាងសង់មណ្ឌលសំចតសម្រាប់ពលករដែលឆ្លងដែនមកកម្ពុជាវិញ។

ជាការឆ្លើយតបលោកស្រី វេជ្ជបណ្ឌិត Nenette Motus បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការនានារបស់ក្រសួងមហាផ្ទៃកម្ពុជា លើការងារជួយគាំទ្រដល់ការងារទេសន្តរប្រវេសន៍ចាប់តាំងពីឆ្នាំ១៩៩៣មក។ លោកស្រីនាយិកា បន្ថែមទៀតថា អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) មិនត្រឹមតែធ្វើការងារទៅលើទេសន្តរប្រវេសន៍ប៉ុណ្ណោះទេ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ក៏បានយកចិត្តទុកដាក់ទៅលើការងារប្រឈមពាក់ព័ន្ធនិងការបម្រែបម្រួលអាកាសធាតុ ដោយសារតែបញ្ហានេះក៏ជាកត្តាដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការបំលាស់ទីរបស់ប្រជាពលរដ្ឋ ដែលនាំឱ្យមានការធ្វើទេសន្តរប្រវេសន៍នេះផងដែរ៕ អត្ថបទ៖ សំអឿន

## ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២

## រកឃើញពលករខ្មែរក្នុងចំណោមជនចំណាកស្រុកខុសច្បាប់៧៥នាក់នៅអយុធ្យា

https://www.khmertimeskh.com/ ខ្មែរថាមស៍ April 27, 2022

ពលរដ្ឋខ្មែរ ត្រូវបានរកឃើញក្នុងចំណោមជនចំណាកស្រុកខុសច្បាប់ចំនួន ៧៥នាក់ នៅជំរុំកម្មករ ក្នុងតំបន់ឧស្សាហ៍កម្មមួយក្នុងស្រុក Uthai កាលពីថ្ងៃអង្គារ។ មន្ត្រីមូលដ្ឋាន អ្នកស្ម័គ្រចិត្តការពារដែនទឹក និងក្រុមប្រតិបត្តិការពិសេស បានបើកការចុះត្រួតពិនិត្យនៅតំបន់ឧស្សាហកម្មនោះ ក្នុងឃុំណងណាំសោម នៅម៉ោង ៦ និង ៣០នាទីព្រឹក។ ក្រោយពីពិនិត្យរួច ក្រុមមន្ត្រីបានរកឃើញជនចំណាកស្រុក៨៦នាក់នៅក្នុងជំរំកម្មករនេះ ដែលមកពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា និង ឡាវ។ មានតែ ១១ នាក់ប៉ុណ្ណោះដែលចូលមកប្រទេសថៃដោយស្របច្បាប់ និងមានប័ណ្ណការងារ ខណៈ ៧៥ នាក់ផ្សេងទៀតមិនមានប័ណ្ណការងារ និង ឯកសារធ្វើដំណើរនោះទេ។
ក្រោយមក ពួកគេត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងរង់ចាំចំណាត់ការតាមផ្លូវច្បាប់ចំពោះការចូលដោយខុសច្បាប់ និងបទចោទប្រកាន់ផ្សេងៗទៀត៕ *បាងកកប៉ុស្តិ៍*

## កម្លាំងនគរបាលខ្មែរនិងយោធាថៃ

## ជួបគ្នាបង្កើតសហប្រតិបត្តិការទប់ស្កាត់បទល្មើសនៅតាមព្រំដែន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៨ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ០៩:៣៤

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ បានជួបជាមួយកម្លាំងយោធាឈុតខ្មៅថៃដើម្បីបង្កើតការទំនាក់ទំនងសហប្រតិបត្តិការគ្នាល្អទប់ស្កាត់បទល្មើសតាមបន្ទាត់ព្រំដែន ធ្វើឡើងនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ ស្ថិតនៅចំណុចព្រំដែនក្នុងភូមិសាស្រ្តភូមិគុតហ៊ីន ឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវប្រទេសថៃ ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការរងសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥បានប្រាប់ថា កម្លាំងនគរបាលការពារព្រំដែនគោកលេខ ៨១៥ មានចំនួន០៧រូប ដែលដឹកនាំដោយលោកវរសេនីយ៍ត្រី រឿម ប៊ុនរិទ្ធ នាយប៉ុស្តិ៍បានជួបពិភាក្សាជាមួយកម្លាំងឈុនខ្មៅថៃចំនួន១៥រូបនៅចំណុចអូរព្រំដែនភូមិសាស្រ្តភូមិគុតហ៊ីន ឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ដែលឈមភូមិបន្ទាយទី២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ លោកបានបញ្ជាក់ថា ការជួបពិភាក្សារវាងកម្លាំងនគរបាលការពារព្រំដែនគោលេខ៨១៥ ជាមួយកម្លាំងយោធាឈុតខ្មៅថៃ នៅអូរជាប់ព្រំដែនថៃ-កម្ពុជានេះ ក្នុងគោលបំណងបង្កើនការទំនាក់តំនង និងសហប្រតិបត្តិការ និងរឹតចំណងសាមគ្គីភាព មិត្តភាព ដើម្បីរួមគ្នាទប់ស្កាត់រាល់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ត្រូវអនុវត្តអោយបាននិងមានប្រសិទ្ធភាព ។ លោកវរសេនីយ៍ឯក សួង សៅ បានបញ្ជាក់ថា ការជួបពិភាក្សារវាងកម្លាំង

នគរបាលការពារព្រំដែនគោកលេខ៨១៥ និងទាហានឈុតខ្មៅថៃ ត្រូវធ្វើរាល់ពេលមានការដោះដូរកម្លាំងថ្មី ត្រូវមានការទំនាក់ទំនងល្អរវាងគ្នានិងរួមគ្នាទប់ស្កាត់អោយបានរាល់បទល្មើសដែលកើតឡើងតាមបន្ទាត់ព្រំដែន៕

## កម្ពុជាមានពលករចំណាកស្រុកជាង១,៣លាននាក់ ទៅធ្វើការនៅក្រៅប្រទេសដោយបានផ្ញើរប្រាក់ជាង៣ពាន់លានដុល្លារក្នុងឆ្នាំ២០២១

https://www.khmertimeskh.com/ ខ្មែរថាមស៍ April 28, 2022

បច្ចុប្បន្នកម្ពុជាមានពលករសរុបចំនួន ១,៣០១,៦០៩ នាក់ក្នុងប្រទេសចំនួន ៧។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងបែបនេះ ក្នុងសារអេបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា ខាងមុខ។
យោងតាមសារនេះ ពលករខ្មែរដែលធ្វើការក្នុងប្រទេសទាំង៧ រួមមាន៖

- ប្រទេសថៃ មានចំនួន ១,២២០,១៩៧ នាក់
- ប្រទេសកូរ៉េ មានចំនួន ៤៥,៨៦៦ នាក់
- ម៉ាឡេស៊ី មានចំនួន ២៣,០២៧ នាក់
- ប្រទេសជប៉ុន មានចំនួន ១១,៤៥៣ នាក់
- សិង្ហបុរី មានចំនួន ៨២១ នាក់
- ហុងកុង មានចំនួន ២០២ នាក់
- អារ៉ាប៊ីសាអូឌីត មានចំនួន ៤៣ នាក់

គេប៉ាន់ប្រមាណថា ការផ្ញើរប្រាក់ដែលកម្មករផ្ញើទៅគ្រួសាររបស់ពួកគេមានចំនួនរាប់ពាន់លានដុល្លារក្នុងមួយឆ្នាំ ដែលរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងសុខុមាលភាពរបស់គ្រួសារអ្នកធ្វើការ។ រាជរដ្ឋាភិបាលកម្ពុជា ក៏កំពុងបន្តជំរុញការអនុវត្តគោលនយោបាយស្តីពីការធ្វើចំណាកស្រុកសម្រាប់កម្ពុជាឆ្នាំ ២០១៩-២០២៣ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ដើម្បីការពារ និងលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍។

កាលពីឆ្នាំមុន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប៉ាន់ប្រមាណថា ការផ្ញើប្រាក់របស់ពលករទៅគ្រួសារមានប្រមាណ ៣ពាន់លានដុល្លារក្នុងមួយឆ្នាំ។ យោងតាមរបាយការណ៍សង្ខេបរបស់ក្រសួងការងារ ប្រាក់ចំណូលរបស់ពលករកម្ពុជាទាំងនេះបានរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ និងកម្រិតជីវភាពរបស់គ្រួសារពលករ។ បន្ថែមលើនេះ របាយការណ៍ដដែលបានបន្តថា លំហូរនៃមូលនិធិបន្តជំរុញការអនុវត្តគោលនយោបាយស្តីពីការធ្វើចំណាកស្រុកការងាររបស់កម្ពុជាឆ្នាំ ២០១៩-២០២៣ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីការពារ និងលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍របស់កម្មករ រួមទាំងការគាំពារសង្គមក្នុងពេលកំពុងធ្វើការ និងត្រឡប់មកផ្ទះវិញ៕

## ចាប់រថយន្តដឹកស្ពៃ ធ្វើបន្ទប់សម្ងាត់លួចដាក់ពលករខុសច្បាប់ចូលក្នុងប្រទេសថៃ

https://kbn.news/ April 28, 2022

**ប្រទេសថៃ៖** ករណីដ៏គួរឱ្យភ្ញាក់ផ្អើលមួយបានកើតឡើងទាំងយប់ បន្ទាប់ពីប៉ូលីសបានឃាត់រថយន្តដឹកស្ពៃមួយគ្រឿង និងមានការសង្ស័យ ក៏បានធ្វើការឆែកឆេរស្រាប់តែបានរកឃើញពលករខុសច្បាប់ជាច្រើននាក់សំងំក្នុងបន្ទាប់សម្ងាត់ដែលបានច្នៃធ្វើជាបន្ទប់លាក់ពលករក្នុងគំនរបន្លែទាំងនោះ។ នេះបើយោងតាមការចុះផ្សាយរបស់សារព័ត៌មាន Khaosod។ ករណីនៃការបង្ក្រាបជាមួយនឹងរថយន្តដឹកបន្លែ លួចលាក់បញ្ជូនពលករខុសច្បាប់ខាងលើនេះ បានកើតឡើងនៅវេលាម៉ោង ២ និង ០០នាទីទៀបភ្លឺថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ នៅចំណុចផ្លូវ មេសុត – អុំផាង ភូមិ ៩ ឃុំ ចុងឃ្វា ស្រុក ភោគប្រា ខេត្តតាក ក្នុងប្រទេសថៃ។ ដោយនៅក្នុងប្រតិបត្តិការណ៍នោះលោក វរ

សេនីយ៍ទោ អ៊ូប៉ាស គង់មឿង ស្នងការរងនគរបាលខេត្ត តាកផ្ទាល់រួមជាមួយនឹងកងកំលាំងជាច្រើនទៀតចុះត្រួតពិនិត្យរថយន្តធ្វើដំណើរនៅតាមដងផ្លូវ ដើម្បីស្ទាក់ចាប់ និង រកមើលពលករចំណាក ស្រុកខុសច្បាប់។ ដំបូងឡើយក្រុមប៉ូលីសបានឃើញរថយន្តដឹកបន្លែពីរគ្រឿងធ្វើដំណើរក្នុងល្បឿនលឿន ហើយក៏ឃាត់សាកសួរ លុះម្ចាស់បើកបរដែលជាតៃកុងឡាននោះមានសភាពភ័យ ញ័រក្នុងពេលសាកសួរ សមត្ថកិច្ចមានការសង្ស័យបានទៅឆែកឆេរ ក្នុងរថយន្តបន្លែទាំងពីរគ្រឿងនោះ ស្រាប់តែបានឃើញនូវពលករចំណាកស្រុកខុសច្បាប់សំងំនៅក្នុងបន្ទប់សម្ងាត់មួយក្នុងគំនរបន្លែនោះជាច្រើននាក់ ដែលមានលក្ខណៈចង្អៀតហប់ស្ទើរតែគ្មានខ្យល់ដកដង្ហើម ហើយក៏នាំចេញយកមកសាកសួរទើបដឹងថា ពលករទាំងនោះមានចំនួន១៤នាក់ ពួកគេធ្វើចំណាកស្រុកពីប្រទេសមីយ៉ាន់ម៉ា ដើម្បីមករកការងារធ្វើក្នុងប្រទេសថៃ ក្នុងនោះពួកគេត្រូវបង់កម្រៃជើងសារដល់អ្នកដឹកជញ្ជូនក្នុងម្នាក់ ៣០,០០០ បាត។ យ៉ាងណាមិញបន្ទាប់ពីមានការចុះបង្ក្រាបនូវជនចំណាកស្រុកចូលក្នុងប្រទេសថៃខុសច្បាប់រួចមកសមត្ថកិច្ចក៏នឹងរៀបចំនូវឯកសារដើម្បីបញ្ជូនអ្នកទាំង១៦នាក់នោះទៅកាន់ផ្លូវច្បាប់បន្តទៅទៀត៕ ប្រភព៖ Khaosod

## ថៃចាប់ឃុំពលករខ្មែរ ៥នាក់<br>ដែលចូលនេសាទនៅសមុទ្រខេត្តឈុនបុរី ស្ថានទូតកម្ពុជាកំពុងជួយរកដំណោះស្រាយ

https://kohsantepheapdaily.com.k ២៨ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ១៦:៣៨

ទីក្រុងបាងកក ៖ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ បានអោយដឹងនៅថ្ងៃទី២៨ មេសា ២០២២នេះថា អនុព័ន្ធការងារតំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះទៅស្រុកសាត់តះហ៊ីប ខេត្តឈុនបុរី ដើម្បីជួបសួរសុខទុក្ខសាច់ញាតិពលករនេសាទខ្មែរចំនួន ៥នាក់ ដែលត្រូវអាជ្ញាធរថៃចាប់ខ្លួនដោយសារចូលធ្វើការនេសាទនៅក្នុងតំបន់ហាមឃាត់ ក្នុងសមុទ្រនៅខេត្តឈុនបុរី ។ អនុព័ន្ធការងារ ក៏បាននាំយកអំណោយទៅចែកជូនកាលពីថ្ងៃទី២៦ មេសា កន្លងទៅនេះ រួមមាន ៖ អង្ករ ត្រីខ មី ប្រេងឆា ទឹកដោះគោ និងម៉ាស់ ដល់គ្រួសារអ្នកជាប់ឃុំឃាំង ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ ។ ជាមួយគ្នានោះដែរ តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានធ្វើការសាកសួរព័ត៌មាន លម្អិតបន្ថែមទៀត ក្នុងបំណងបន្តធ្វើការជាមួយអាជ្ញាធរពាក់ព័ន្ធថៃ និយោជក ដើម្បីរកដំណោះស្រាយជួយដល់អ្នកជាប់ឃុំឃាំង ៕

## ទាហានឈុតខ្មៅនិងទាហានខ្មែរ<br>ពិភាក្សាគ្នា រឹតចំណងសាមគ្គីភាព មិត្តភាព និងរួមគ្នាទប់ស្កាត់រាល់បទល្មើសឆ្លងដែន

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៨ មេសា ២០២២ដោយ Kang Tola

បន្ទាយមានជ័យ ៖ ល្ងាច ថ្ងៃទី២៨ ខែ មេសា ឆ្នាំ ២០២២នេះ មានទាហានឈុតខ្មៅ១ក្រុម និងទាហានខ្មែរ១ក្រុម បានជួបពិភាក្សា ដើម្បីរឹតចំណងសាមគ្គីភាព មិត្តភាព និងរួមគ្នាទប់ស្កាត់រាល់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ពិសេសមនុស្សឆ្លងដែនទៅមករកការងារធ្វើ។ កិច្ចពិភាក្សាគ្នានេះនៅចំណុចមាត់អូរព្រំដែនដីថៃ ស្ថិតក្នុងភូមិគុតហ៊ីន ឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ចំណែកភាគីខ្មែរទល់មុខភូមិបន្ទាយទី២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ត្រី សូវ៉ាត់ យាន់បួ បានមានប្រសាសន៍ថា កិច្ចពិភាក្សាគ្នានោះផ្តោតទៅលើការទប់ស្កាត់ការលួចឆ្លងដែនតាមច្រករបៀងរបស់ពលករខ្មែរ និងប្រជាជនថៃឆ្លងដែនមកធ្វើការនៅក្រុងប៉ោយប៉ែត។ ព្រោះ ប្រទេសថៃនៅតែធ្វើការទប់ស្កាត់ជម្ងឺ កូវីត .១៩នៅឡើយ រោងចក្រត្រូវបិត ហូតមកដល់សព្វថ្ងៃនេះប្រទេសថៃមិនទាន់

ដំណើរការដូចមុននោះឡើយព្រោះសំអាងថា ជំងឺកូវីដ-១៩ មិនទាន់បានធូរស្បើយនៅឡើយ។ ប្រជាជនថៃនៅតែមានការប្រុងប្រយ័ត្នទាំងអស់គ្នាជានិច្ចអ្វីៗមិនទាន់ដំណើរការនៅឡើយ ដូច្នេះពលករខ្មែរទាំងអស់ចង់មកធ្វើការនៅថៃប្រយ័ត្នចាញ់បោកមេខ្យល់។ លោកវរសេនីយ៍ត្រី សូរ៉ាត់ យ៉ាន់បួ បានមានប្រសាសន៍បន្តទៀតថា សព្វថ្ងៃនេះសមត្ថកិច្ចថៃធ្វើការទប់ស្កាត់ពលករខ្មែរ ដែលលបលួចចូលឆ្លងដែនទៅធ្វើការក្នុងប្រទេសថៃខុសច្បាប់ខ្លាំងសំបើមណាស់ ដើម្បីការពារទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ.១៩។

លោកវរសេនីយ៍ត្រី រឿម ប៊ុនរិទ្ធ មេប៉ុស្តិ៍ក្បាលទំនប់បានមានប្រសាសន៍ថា ប្រជាពលរដ្ឋខ្មែរជាច្រើនពាន់គ្រួសារក្រោយពីចេញពីប្រទេសថៃមកលេងបុណ្យចូលឆ្នាំខ្មែរកន្លងមកនេះរួចរាល់ហើយ បានបុកសម្រុកទៅរកការងារធ្វើនៅប្រទេសថៃ មួយថ្ងៃរាប់រយនាក់តាមរយៈមេខ្យល់ឆ្លងដែនខុសច្បាប់ ភាគច្រើនមិនជោគជ័យតាមបំណងទេត្រូវ ប្រឈម នឹង គេ ចាប់បញ្ជូន ត្រឡប់មកវិញ ក៏នៅតែ ប្រថុយ អស់ទាំងប្រាក់ ខាតទាំងពេលវេលា ត្រូវសមត្ថកិច្ចថៃចាប់ដាក់គុកបន្ថែមទៀតផង៕ *ដោយ ៖ វ៉ាន់ ណាង*

## លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការនគរបាលការពារព្រំដែនគោក លេខ៨១៥ អំពាវនាវដល់ពលរដ្ឋខ្មែរកុំឲ្យបន្តចាញ់បោកមេខ្យល់នាំឆ្លងទៅប្រទេសថៃ

https://gdlf-kh.com/ 2022/04/28/ Noun Vanny បន្ទាយមានជ័យ

បន្ទាយមានជ័យ ៖ បើទោះបីជាមានការរឹតបន្តឹងតាមបន្ទាត់ព្រំដែនយ៉ាងណា ក៏នៅមានប្រជាពលរដ្ឋខ្មែរលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃហើយត្រូវបានកម្លាំងសមត្ថកិច្ចថៃចាប់ឃាត់ខ្លួនបញ្ជូនមកកម្ពុជាវិញជាបន្តបន្ទាប់។ ជាក់ស្តែងនៅវេលាម៉ោង០៣ និង១៥នាទីរសៀលថ្ងៃអង្គារ ១០ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ តម្រួតព្រំដែនថៃកងអនុសេនាធំលេខ១២៤ (តធដ.១២៤) បានឃាត់ពលរដ្ឋខ្មែរចំនួន១២៧នាក់ ត្រង់ចំណុចភូមិណងព្រី ឃុំផាន់សឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ទល់មុខភូមិដំបូកវិល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា ៖ ពលរដ្ឋខ្មែរត្រូវបានថៃឃាត់ខ្លួនចំនួន ១២៧នាក់ (ស្រី៣៩នាក់ កុមារ០៧នាក់) តាមការឲ្យដឹងពីសមត្ថកិច្ចថៃ ដែលបានសួរនាំពួកគាត់បានប្រាប់ថា មកពីខេត្តបន្ទាយមានជ័យ,បាត់ដំបង,តាកែវ,ព្រៃវែង,សៀមរាប។ បន្ទាប់ពីធ្វើការសួរនាំ និងធ្វើតេស្តរកមេរោគកូវីដ-១៩ រួច តម្រួតព្រំដែនថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរទាំង១២៧នាក់ ទៅឲ្យតម្រួតអន្តោប្រវេសន៍ថៃប្រចាំស្រុកអារញ្ញ ដើម្បីចាត់វិធានការបន្ត ។

ទាក់ទិននឹងករណីឆ្លងដែនខុសច្បាប់នេះ លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការ នគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានអំពាវនាវដល់ពលរដ្ឋខ្មែរ ឈប់ចាញ់បោកមេខ្យល់ទៀត បើទោះបីជាបងប្អូនឆ្លងដែនផុតពីកម្ពុជាមែន ប៉ុន្តែពេលថៃចាប់បានក៏បញ្ជូនមកខ្មែរវិញ ដែលនាំឲ្យបងប្អូនខាតបង់ប្រាក់កាស ដោយកត្តាចាញ់បោកមេខ្យល់និងខាតពេលវេលាទៀតផង ។ លោកសុំឲ្យប្រជាពលរដ្ឋរកការងារធ្វើនៅក្នុងស្រុកជាការល្អ ឬក៏ដាំដំណាំ ចិញ្ចឹមសត្វដើម្បីរកចំណូលទ្រទ្រង់ជីវភាព ព្រោះខណៈពេលនេះប្រទេសទាំង០២ កំពុងរួមគ្នាទប់ស្កាត់ ការឆ្លងរាលដមីកូវីដ-១៩។ លោកមេបញ្ជាការវរសេនាតូចការពារព្រំដែនគោលេខ៨១៥ បានបញ្ជាក់ទៀតថា៖ ដើម្បីរឹតចំណងមិត្តភាពសាមគ្គីភាព រវាងសមត្ថកិច្ចការពារព្រំដែននៃប្រទេសទាំង០២ នៅវេលាម៉ោង០៩ដល់ម៉ោង១០និង៥០នាទីព្រឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ កម្លាំងប៉ុស្តិ៍ក្បាលទំនប់ចំនួន ០៧នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី រឿម ប៊ុនរិទ្ធ នាយប៉ុស្តិ៍ និងទាហាន(ព្រាន) ឈុនខ្មៅថៃកងអនុសេនាធំលេខ ១៣.០៥ ចំនួន១៥នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី សូរ៉ាត់ យ៉ាន់បួបាន មេបញ្ជាការ កងអនុសេនាធំ បានជួបពិភាក្សាគ្នានៅចំណុចមាត់អូរព្រំដែនខាងទឹកដីថៃ ស្ថិតក្នុងភូមិគុតហ៊ីន ឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ទល់មុខភូមិបន្ទាយទី២

ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ការជួបពិភាក្សានេះក្នុងគោលបំណងបង្កើនទំនាក់ទំនងកិច្ចសហប្រតិបត្តិការ រឹតចំណងសាមគ្គីភាព មិត្តភាព និងរួមគ្នាទប់ស្កាត់រាល់បទល្មើសឆ្លងដែនគ្រប់ប្រភេទ និងផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមក រាល់បទល្មើសកើតមានតាមបន្ទាត់ព្រំដែន ៕

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ៖ ការកេងប្រវ័ញ្ច ផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ កំពុងរីករាលដាល និងកំពុងក្លាយជាក្តីបារម្ភ

https://cen.com.kh/ Posted ByPen Srey Neat April 29, 2022

ភ្នំពេញ៖ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានគូសបញ្ជាក់ថា ក្នុងបរិការណ៍ នៃការរីកចម្រើនខាងផ្នែកបច្ចេកវិទ្យា និងអ៊ីនធឺណិត, ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ កំពុងរីករាលដាល និងកំពុងក្លាយជាក្តីបារម្ភសម្រាប់ពិភពលោកទាំងមូល និងកម្ពុជា។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ នេះ, ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ដែលត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាងក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ព្រមទាំងដៃគូដែលមានការពាក់ព័ន្ធផ្សេងទៀត។

ក្នុងវគ្គបណ្តុះបណ្តាលនេះ ក៏មានការអញ្ជើញចូលរួមផងដែរពីលោកជំទាវ ខៀវ បូរី រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ឯកឧត្តម កេង សុម៉ារិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌, លោកស្រី គ្រីននេត វ៉ង នាយកប្រចាំប្រទេសនៃអង្គការភ្លែនអន្តរជាតិកម្ពុជា និងឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធមួយចំនួនទៀត។ វគ្គបណ្តុះបណ្តាលនេះ ជាវគ្គបណ្តុះបណ្តាលលើកទី២ ដែលរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងរបស់ចៅក្រម ព្រះរាជអាជ្ញានៃសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្តទូទាំងប្រទេស អំពីបទល្មើសដែលកើតមាននៅក្នុងបណ្តាញសង្គមដែលមានហានិភ័យចំពោះកុមារ និងបទប្បញ្ញត្តិគតិយុត្តជាធរមានសម្រាប់ចំណាត់ការលើបទល្មើសទាំងនេះ សំដៅធានាបាននូវសង្គតិភាពនិងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត។

ថ្លែងក្នុងពិធីនេះ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានលើកឡើងថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យកការងារការពារសិទ្ធិកុមារ និងការគាំពារកុមារពីការរំលោភបំពានផ្សេងៗតាមគ្រប់រូបភាព គឺជាការងារអាទិភាព ដោយហេតុថា កុមារគឺជាទំពាំងស្នងឫស្សី និងជាសសរទ្រូងរបស់ប្រទេសជាតិ ហើយការអភិវឌ្ឍកុមារ គឺជាកូនសោគន្លឹះដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងរយៈពេលវែង។ ទន្ទឹមនេះ, កន្លងមកកម្ពុជាបានរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តយ៉ាងច្រើនដែលបង្កើតបានជាក្របខណ្ឌគតិយុត្តរឹងមាំ ដើម្បីផ្តល់នូវការគាំពារផ្លូវច្បាប់ដល់កុមារប្រឆាំងរាល់ទម្រង់នៃការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

ឯកឧត្តមរដ្ឋមន្ត្រីបានគូសបញ្ជាក់បន្ថែមថា ក្នុងបរិការណ៍នៃការរីកចម្រើនខាងផ្នែកបច្ចេកវិទ្យា និងអ៊ីនធឺណិត, ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ កំពុងរីករាលដាល និងកំពុងក្លាយជាក្តីបារម្ភសម្រាប់ពិភពលោកទាំងមូល និយាយជារួម និងសម្រាប់កម្ពុជា និយាយដោយឡែក ដែលទាមទារនូវការយកចិត្តទុកដាក់ និងកិច្ចសហប្រតិបត្តិការល្អបន្ថែមទៀតពីគ្រប់តួអង្គពាក់ព័ន្ធ ទាំងលើការលើកកម្ពស់ការអប់រំ និងផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងដ៏ត្រឹមត្រូវអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ទាំងលើការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការច្បាប់ចំពោះបទល្មើស។ ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តការងារប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនេះ ក៏ទាមទារជាចាំបាច់ផងដែរឱ្យមន្ត្រីអនុវត្តច្បាប់ ត្រូវយល់ដឹងឱ្យបានស៊ីជម្រៅអំពីទម្រង់ផ្សេងៗនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ, ពីចរិកលក្ខណៈ

និងកលល្បិចរបស់ជនល្មើស, ឧត្តម្មានុវត្តក្នុងការស៊ើបអង្កេត និងកិច្ចការពារជនរងគ្រោះ ក៏ដូចជា បញ្ហាប្រឈមផ្សេងៗក្នុងការស៊ើបអង្កេតបទល្មើស បន្ថែមលើចំណេះដឹងស៊ីជម្រៅផ្នែកបច្ចេកទេសច្បាប់ និងនីតិវិធី៕ សុទ្ធ លី

## ឯកឧត្តម ប្រាក់ សុខុនៈ
## កម្ពុជាបានបញ្ជូនពលករជាងពីរពាន់នាក់ក្នុងមួយឆ្នាំៗ ទៅកាន់ប្រទេសម៉ាឡេស៊ី

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២

(ភ្នំពេញ)៖ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលគណៈប្រតិភូ សហគ្រាសធុនតូច និងមធ្យម មកពីប្រទេសម៉ាឡេស៊ី ចំនួន ៥៣រូប កាលពីម្សិលមិញ ដែលមានចំណាប់អារម្មណ៍ក្នុងការស្វែងរកកាលានុវត្តភាពថ្មីៗ សម្រាប់អាជីវកម្ម និងការវិនិយោគនៅកម្ពុជា។ ឯកឧត្តមបានឲ្យដឹងថា ម៉ាឡេស៊ីគឺនៅក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចធំមួយនៅអាស៊ីអាគ្នេយ៍ ហើយក៏ជាប្រទេសដែលជាប់ចំណាត់ថ្នាក់លេខបី ក្នុងចំណោមប្រទេសអាស៊ាន បើគិតពីតម្លៃវិនិយោគទុននៅកម្ពុជា។

ទន្ទឹមនេះដែរ ប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានបញ្ជូនពលករជាងពីរពាន់នាក់ក្នុងមួយឆ្នាំៗ ទៅកាន់ប្រទេសម៉ាឡេស៊ី។ ជាក់ស្តែង ទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរនឹងបន្តពង្រឹងបន្ថែមទៀត បើទោះបីជាយើងបាននឹងកំពុងជួបវិបត្តិនៃជំងឺរាតត្បាតក៏ដោយ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ក៏វាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី និងភាគីពាក់ព័ន្ធដែលបានផ្តួចផ្តើមព្រឹត្តិការណ៍នេះឡើង៕

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ៖ ដើម្បីអនុវត្តការងារប្រឆាំងការកេងប្រវ័ញ្ច
## ផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ មន្ត្រីអនុវត្តច្បាប់ ត្រូវយល់ដឹងអំពីបទល្មើសនេះ

https://www.gntimes.com/ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២

ភ្នំពេញ ៖ លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានលើកឡើងថា ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តការងារប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនេះ ក៏ទាមទារជាចាំបាច់ផងដែរឱ្យមន្ត្រីអនុវត្តច្បាប់ ត្រូវយល់ដឹងឱ្យបានស៊ីជម្រៅអំពីទម្រង់ផ្សេងៗ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ពីចរិកលក្ខណៈ និងកលល្បិចរបស់ជនល្មើស, ឧត្តម្មានុវត្តក្នុងការស៊ើបអង្កេត និងកិច្ចការពារជនរងគ្រោះ ក៏ដូចជា បញ្ហាប្រឈមផ្សេងៗក្នុងការស៊ើបអង្កេតបទល្មើស បន្ថែមលើចំណេះដឹងស៊ីជម្រៅផ្នែកបច្ចេកទេសច្បាប់ និងនីតិវិធី។ លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានថ្លែងបែបនេះ នៅក្នុងឱកាសដែលលោកបានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២២ ដែលត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាងក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ព្រមទាំងដៃគូដែលមានការពាក់ព័ន្ធផ្សេងទៀត។

លោក កើត រិទ្ធបានថ្លែងបន្តទៀតថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យកការងារការពារសិទ្ធិកុមារ និងការគាំពារកុមារពីការរំលោភបំពានផ្សេងៗតាមគ្រប់រូបភាព គឺជាការងារអាទិភាព ដោយហេតុថា កុមារគឺជាទំពាំងស្នងឫស្សី និងជាសសរទ្រូងរបស់ប្រទេសជាតិ ហើយការអភិវឌ្ឍកុមារ គឺជាកូនសោគន្លឹះដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងរយៈពេលវែង។ ទន្ទឹមនេះកន្លងមកកម្ពុជាបានរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តយ៉ាងច្រើន ដែលបង្កើតបានជាក្របខណ្ឌគតិយុត្តរឹងមាំដើម្បីផ្តល់នូវការគាំពារផ្លូវច្បាប់ដល់កុមារប្រឆាំងរាល់ទម្រង់នៃការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

លោកបានគូសបញ្ជាក់បន្ថែមថា ក្នុងបរិការណ៍នៃការរីកចម្រើនខាងផ្នែកបច្ចេកវិទ្យា និងអ៊ីនធឺណិត, ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ កំពុងរីករាលដាល និងកំពុងក្លាយជាក្តីបារម្ភសម្រាប់ពិភពលោកទាំងមូល និយាយជារួម និងសម្រាប់កម្ពុជា និយាយដោយឡែក ដែលទាមទារនូវការយកចិត្តទុកដាក់ និងកិច្ចសហប្រតិបត្តិការល្អបន្ថែមទៀតពីគ្រប់តួអង្គពាក់ព័ន្ធ ទាំងលើការលើកកម្ពស់ការអប់រំ និងផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងដ៏ត្រឹមត្រូវអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ទាំងលើការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការច្បាប់ចំពោះបទល្មើស។